# ទឹកដីសុវណ្ណភូមិ

## Agricultural Land





# ដំណាំសណ្តែកដី
# (Peanuts)

## I-សេចក្តីផ្តើម

សណ្តែកដីស្ថិតនៅក្នុងពួកលេហ្គុមីណ ដែលមានផ្កានៅលើដើម មែក ហើយបន្ទាប់ពីកកើតទងផ្លែ និងចាក់ចូលទៅក្នុងដីជាមួយអូរ៉ុល កកើតជាគ្រាប់រីកធំរហូតដល់ទុំ។ ដំណាំសណ្តែកដីមានគេធ្វើការដាំដុះនៅក្នុងតំបន់ត្រូពិច និងស៊ុបត្រូពិច ដែលមានផលិតផលបានជាប្រេងសំរាប់សេចក្តីត្រូវការរបស់មនុស្ស។

ដំណាំសណ្តែកដីមានសារៈសំខាន់ បន្ទាប់ពីធ្វើការកិនកៀបយកប្រេង ហើយកាកសំណល់ត្រូវបានគេប្រើប្រាស់សំរាប់ជាចំណីសត្វ។ សណ្តែកដីត្រូវការដីធូរ មានជីជាតិ ដែលជាលក្ខណៈងាយស្រួលដល់ការចុះផ្លែទៅក្នុងដី និងរីកធំបានងាយព្រមទាំងមានការងាយស្រួលដល់ការប្រមូលផល(ដកដោយដៃផ្ទាល់។ ការដាំដុះអាចធ្វើទាំងសំបក ឬក៏ដាំគ្រាប់ បន្ទាប់ពីបានបកសំបកចេញដោយយោលទៅតាមការនិយម។ បន្ទាប់ពីការដាំរួចការជួសរណ្តៅដែលដាច់(មិនដុះ) ឬ បាត់រណ្តៅ រួមទាំងការសំអាតស្មៅ និងជ្រុំជ្រួយដីឱ្យបានល្អជាការងារសំខាន់បំផុតក្នុងការថែទាំដំណាំនេះ ហើយក៏ជាកត្តាកំណត់ក្នុងការប្រមូលផលបានល្អប្រសើរ។

## II-គោលបំណង

១-បង្កើនការយល់ដឹងឱ្យកាន់តែខ្ពស់ពីការដាំដុះដំណាំសណ្តែកដីតាមបច្ចេកទេស។
២-បង្កើនសមត្ថភាពក្នុងការអនុវត្តន៏បច្ចេកទេសឱ្យបានល្អ។
៣-បង្កើនប្រាក់ចំណូលឱ្យកាន់តែប្រសើរក្នុងការអនុវត្តន៏បច្ចេកទេសដោយកាត់បន្ថយការចំណាយ។

## III-ការអនុវត្តន៏ការដាំដុះរបស់កសិករកន្លងមក

- ការជ្រើសរើសពូជមិនទាន់បានល្អដែលអាចឆ្លើយតបនឹងតំរូវការទីផ្សារ(ពូជខ្វះគុណភាព)។
- អនុវត្តការដាំដុះនៅមិនទាន់សមស្របទៅនឹងបច្ចេកទេស(ការរៀបចំដី, ការថែទាំ, ការប្រើប្រាស់ជី...)។
- មិនទាន់យកចិត្តទុកដាក់ក្នុងការប្រើប្រាស់សំណល់ពីការប្រមូលផល ដើម្បីរក្សានិងបង្កើនគុណភាពដីដាំដុះ។

## IV- បច្ចេកទេសនៃការដាំដំណាំសណ្តែកដី

សណ្តែកដីជាដំណាំដែលត្រូវការដីធូរ មានជីជាតិនិងស្រស់ទឹកល្អ(ដីច្រាំងទន្លេ ឬដីល្បាប់ក្រោយច្រាំង និងដីខ្ពង់រាប)។ ម្យ៉ាងទៀត សណ្តែកដីត្រូវការការថែទាំមានការសំអាតស្មៅចង្រៃ និងការជ្រុំជ្រួយដីឱ្យបានសមស្របតាមពេលវេលា។ ដូចនេះការរៀបចំដីបានល្អធ្វើឱ្យដីផុសមានខ្យល់ចេញចូលស្រួល ជាគន្លឹះធ្វើឱ្យដំណាំរីកលូតលាស់បានឆាប់ ពិសេសផ្នែកប្រព័ន្ធឫស។

## ១_ការជ្រើសរើសពូជ



ការជ្រើសរើសពូជជាកត្តាកំណត់នូវទិន្នផលបានខ្ពស់ និងឆ្លើយតបតំរូវការទីផ្សារ :

- ពូជធន់ជំងឺ និងសត្វល្អិត ។
- ពូជដែលផ្តល់ទិន្នផលខ្ពស់និងតំរូវការទីផ្សារ ។
- ពូជមានរយៈពេលខ្លី ។
- ពូជដែលរក្សាទុកទាំងសំបកមានគុណភាពដំណុះគ្រាប់ចាប់ពី៩០%ឡើងទៅ ។

## ២_ការរៀបចំដីសំរាប់ដាំដុះ

សណ្តែកដីស្ថិតក្នុងពពួកលេហ្គុមីណើ មិនសូវត្រូវការដីច្រើនប៉ុន្មានទេ ប៉ុន្តែដើម្បីបង្កើនទិន្នផលខ្ពស់ក្នុងផលិតកម្មនោះ ការរៀបចំដីក៏ជាកត្តាកំណត់មួយមានសារៈសំខាន់ក្នុងការអនុវត្តន៏បច្ចេកទេសដាំដុះផងដែរ ។

### ការភ្ជួររាស់ដី:

- ត្រូវធ្វើការភ្ជួររាស់ដីឱ្យបាន ២-៣ ដងក្នុងជំរៅ ១៥សម - ២០សម ។
- ការភ្ជួរត្រូវធ្វើឱ្យបានហ្មត់ចត់ (កុំឱ្យឆកល្វែងដី, ភ្ជួរកាត់ទទឹងលើកទី១ និងភ្ជួរកាត់ទទឹងលើកទី២) ។
- ភ្ជួរទី១ (ភ្ជួរដាស់ដី) ត្រូវទុកហាលដីឱ្យបាន១០-១៥ថ្ងៃ មុននឹងចាប់ភ្ជួរលើកទី២ ។
- ភ្ជួរលើកទី២ រួមការរាស់ដីសំអាតកំទេចកំទីនិងស្មៅឱ្យបានស្អាត ។
- ភ្ជួរលើកទី៣ រួមការរាស់សំរេច ឱ្យដីហ្មត់ផង់ល្អ និងមានភាពរាបស្មើសំរាប់ធ្វើការដាំដុះ ។

## ៣_ការដាក់ជីទ្រាប់បាត

ដំណាំសណ្តែកដីមិនសូវល្មោភជីប៉ុន្មានទេ ប៉ុន្តែការអនុវត្តន៏នៃការដាក់ជីទ្រាប់បាត ជាការចាំបាច់បំផុតក្នុងការដាំដុះដំណាំគ្រប់ប្រភេទដើម្បីធានាទូវសារធាតុបំរុងសំរាប់តំរូវការរបស់ដំណាំ និងការពារការបាត់បង់ជីជាតិក្នុងដី និងរក្សាបាននូវគុណភាពដីកសិកម្មឱ្យមាននិរន្តរភាព ។នៅលើដីដែលខ្សត់ជីជាតិគេត្រូវអនុវត្តការដាក់ជីទ្រាប់បាតសំរាប់ដំណាំសណ្តែកដី ដូចជា :

- ជីកំប៉ុស្ត ឬជីលាមកសត្វពុករលួយល្អចំនួន១០-១៥តោនក្នុង ១ ហិកតារ ។
- ជីគីមី ១៥.១៥.១៥ ចំនួន ១៥គក្រ - ២០គក្រក្នុង១ហិកតារ ។

ជីទាំងពីរមុខនេះ ត្រូវបាចរោយសព្វល្អលើដីរួចភ្ជួររាស់(ភ្ជួររាស់លើកទី៣) ច្របល់ឱ្យបានចូលគ្នាទៅក្នុដី ។

## ៤_ការរៀបចំគ្រាប់ពូជ

ពូជសណ្តែកដីមាន ៣ ប្រភេទដែលគេនិយមធ្វើការដាំដុះ :

- ពូជគ្រាប់ធំ ។
- ពូជសំបកឆ្នូត ។
- ពូជសំបករលីង ។

- ត្រូវយកផ្លែសណ្ដែកដីទាំងសំបកមកបកយកគ្រាប់ឱ្យបានពី ៧-១០ ថ្ងៃមុនពេលដាំ។
- ត្រូវរើសយកគ្រាប់ស្អៀត,គ្រាប់តូច,គ្រាប់ស្អុយនិងគ្រាប់ដែលមានរោគចេញឱ្យអស់ (ទុកតែគ្រាប់ល្អពេញលក្ខណៈ)។
- ត្រូវយកគ្រាប់ពូជដែលបានសំរាំងរួច មកប្រឡាក់ថ្នាំបិនឡាតក្នុងអត្រា ២%(ពីរភាគពាន់) ក្នុងពូជ ១គក្រមុនពេលយកទៅដាំ ការពារសត្វស្រមោចស៊ីពូជក្នុងរណ្ដៅ។

## ៥_ពេលវេលា និងរបៀបដាំ

### គេអាចធ្វើការដាំដុះបាន៖



- នៅដើមរដូវភ្លៀង (ខែ មេសា, ខែ ឧសភា)។
- នៅក្នុងរដូវភ្លៀង (ខែ មិថុនា, ខែ កក្កដា)។
- នៅចុងរដូវភ្លៀង (ខែ តុលា)។

### របៀបដាំមាន ២ យ៉ាងតាមការនិយម៖

- ការដាំដោយលើករង: ការដាំរបៀបនេះគេច្រើនអនុវត្តនៅក្នុងរដូវវស្សា ដោយការលើករងក្រោយពីការរៀបចំដីដាំដុះរួច (ក្នុងតំបន់វាលរាបមិនលិចទឹក)។
- ការដាំលាត : គេអនុវត្តនៅរដូវប្រាំង និងរដូវវស្សាផងដែរ(តំបន់ខ្ពង់រាប,វាលរាប,ក្រោយច្រាំងទន្លេ,...) ការដាំនៅដើមរដូវភ្លៀង និងចុងរដូវភ្លៀង ត្រូវឧស្សាហ៍ត្រួតពិនិត្យ និងគ្រប់គ្រងសំណើមដីឱ្យបានល្អសំរាប់ការលូតលាស់ និងផ្កាផ្លែបានពេញលេញ (៦០-៨០%)។

- ដំណាំសណ្ដែកដីត្រូវការចន្លោះរង ៥០ សម និងចន្លោះជួរ ២០-២៥ សម ដើម្បីលូតលាស់ល្អ។ រណ្ដៅមានជំរៅ ២-៤ សម។
- តំរូវការពូជបកស្រេចចំនួន ៨០ គក្រក្នុង ១ ហិកតារ ឬ ពូជទាំងសំបកចំនួន ១៥០ គក្រក្នុង ១ ហិកតារ។ ក្នុង ១ រណ្ដៅដាក់ ១-២ គ្រាប់។

## ៦_ការថែទាំ

### ការជំរះស្មៅ និងពូនគល់

ការជំរះស្មៅ ឬ ការសំអាតស្មៅចង្រៃជាសកម្មភាពមួយសំខាន់ណាស់ នៅក្នុងផលិតកម្មដំណាំសណ្ដែកដី ដើម្បីធ្វើឱ្យដំណើរីកលូតលាស់លឿនទៅតាមសក្ដានុពលរបស់វា។ ដូចនេះ ការសំអាតស្មៅចង្រៃត្រូវអនុវត្តឱ្យបាន២ដង និងទាន់ពេលវេលា ធ្វើយ៉ាងណាកុំឱ្យស្មៅដុះប្រជែងជាមួយដំណាំឱ្យសោះ ព្រោះការងារនេះបើយើងធ្វេសប្រហែសនឹងនាំឱ្យដំណាំបន្ថយការលូតលាស់ ហើយទិន្នផលក៏នឹងថយចុះទៅតាមនោះដែរ (មិនអាចកែបានឡើយ)។

លើកទី១: ពី ១៥-២០ ថ្ងៃក្រោយពេលដាំ។ ពេលនេះសំខាន់គឺបំបាត់ស្មៅចង្រៃ និងរក្សាសំណើមដីឱ្យបានល្អតាមរយៈការជ្រុំជ្រួយដីជាមួយ។



លើកទី២: ពី ៣០-៤០ ថ្ងៃក្រោយពេលដាំ ពេលនេះការសំអាតស្មៅចង្រៃរួមទាំងការពូនគល់តិចៗផង ។

បញ្ជាក់ : បើហួសពី ៦០ ថ្ងៃឡើងទៅហាមមិនឱ្យពូនគល់ឡើយ ។

### ការស្រោចស្រព

ដំណាំសណ្តែកដី ត្រូវការសំណើមដីល្មមពី ៦៥-៧៥% ដើម្បីធ្វើការលូតលាស់បានល្អ ។ ក្នុងមួយវដ្តលូតលាស់របស់វា ត្រូវការទឹកពី ១០០០-១៥០០ម$^{៣}$ ប៉ុណ្ណោះ ។ ដូចនេះ ត្រូវពិនិត្យឱ្យបានជាប្រចាំនូវសំណើមដី បើមានការរាំងស្ងួតត្រូវធ្វើការបូមទឹកស្រោចស្រពជាបន្ទាន់ ។

## ៧_សត្វល្អិត និងជំងឺ

ដំណាំសណ្តែកដីមិនសូវមានជួបប្រទះការបំផ្លាញពីសត្វល្អិត និងជំងឺធ្ងន់ធ្ងរទេ ។ ប្រការដែលត្រូវប្រុងប្រយ័ត្នគឺនៅពេលមុនដាំត្រូវការពារសត្វល្អិតបំផ្លាញគ្រាប់ពូជនៅក្នុងរណ្តៅ ធ្វើឱ្យបាត់រណ្តៅដោយប្រើថ្នាំហ៊្វុយរ៉ាដាន(ធុរាដាន) ក្នុងអត្រា ១ ក្រាម ក្នុង ១ ម$^{២}$ ឬ ១០ គក្រក្នុង ១ ហិកតារ (រោយព្រោចឱ្យបានសព្វដីមុនដាំ) ។

ការប្រើថ្នាំនេះក៏អាចការពារការបំផ្លាញពីសត្វល្អិតដល់សណ្តែកដី ដែលកំពុងរីកលូតលាស់នៅក្នុងដី ដោយដង្កូវឈ្មោះអាក្រូទីសអ៊ីបស៊ីឡុង(Agrotis hypsilon) ។ មានដង្កូវរមូរស្លឹកសណ្តែកដី ធ្វើឱ្យដំណាំបន្ថយការលូតលាស់ ។ វិធីកំចាត់ ប្រើថ្នាំ អាហ្សូឌ្រីន (Azodrin) ក្នុងអត្រា ២-៣% ក្នុង ១ លីត្រទឹក ។



### ជំងឺអុតស្លឹកពណ៌ខ្មៅ

វិធីការពារមាន :

- កុំដាំញឹកពេកនៅរដូវវស្សា ។
- ប្រើពូជធន់នឹងជំងឺនេះ ។
- ត្រូវដកដើមដែលមានជំងឺនេះបំផ្លាញចោល ។

### ជំងឺរលួយគល់

វិធីការពារមាន :

- ត្រូវរក្សាសំណើមដីឱ្យបានល្អ ។
- ត្រូវផ្លាស់ប្តូរមុខដំណាំ (សណ្តែកដី សណ្តែកបាយ ពោត) ។ល ។



## ៨_ការប្រមូលផល

គេចាប់ប្រមូលផលដំណាំសណ្តែកដីក្នុងកំឡុង ៣ ខែទៅ ៣ ខែកន្លះក្រោយពីការដុះចេញ គិតទៅតាមពូជដែលបានធ្វើការដាំដុះ ។ ប៉ុន្តែការកំណត់ពេលប្រមូលផលនៅដំណាក់កាលដែលដំណាំសណ្តែកដីមានស្លឹកលឿងទុំច្រើន (៦០-៧០%) ។

គេដកដើមសណ្តែកដីដោយទាំងផ្លែពីក្នុងដីរួចគេធ្វើការហាលក្នុងរយ:ពេល ២-៣ ថ្ងៃរួចគេធ្វើការប្រលេះ និងបកយកគ្រាប់ជាបន្តបន្ទាប់ ។

### ប្រការដែលគួរជៀសវាង

- កុំទុកឱ្យស្ងួតដោយកំដៅខ្លាំងពេក ។
- កុំដកដើមផ្លែស្រស់គរជាគំនរ ។
- កុំហាលថ្ងៃយូរពេកក្រោយពេលដកប្រមូលផល ។

## V- វិភាគសេដ្ឋកិច្ចក្នុងផលិតកម្មដំណាំសណ្តែកដី(ក្នុង ១ ហិកតារ)

| បរិយាយ | ឯកតា | តាមប្រពៃណី | | | តាមបច្ចេកទេស | | |
|---|---|---|---|---|---|---|---|
| | | ចំនួន | តំលៃរាយ $ | តំលៃសរុប $ | ចំនួន | តំលៃឯកតា $ | តំលៃសរុប $ |
| ការរៀបចំដីសរុប | ហត | 1 | 20.00 | 20.00 | 1 | 40.00 | 40.00 |
| គ្រាប់ពូជ | គក្រ | 80 | 0.80 | 64.00 | 80 | 0.80 | 6400 |
| ដាំដុះ | ថ្ងៃ ,នាក់ | 7 | 1.70 | 11.90 | 7 | 1.70 | 11.90 |
| ថែទាំសរុប | ថ្ងៃ ,នាក់ | 20 | 1.70 | 34.00 | 30 | 1.70 | 51.00 |
| ជី១៥.១៥.១៥ | គក្រ | 100 | 0.45 | 45.00 | 150 | 0.45 | 67.00 |
| ជីកំប៉ុស្តលាមកសត្វ | តោន | - | - | - | 10 | 5.00 | 50.00 |
| ថ្នាំ Furadan | គក្រ | - | - | - | 10 | 1.20 | 12.00 |
| ថ្នាំ Azodrin | លីត្រ | - | - | - | 2 | 5.00 | 10.00 |
| ប្រមូលផលសរុប | $ | 225.90 | | | 357.40 | | |
| ទិន្នផល | គក្រ | 2,000 | | | 3,500 | | |
| ចំណូលក្នុងផលិតកម្ម | 4 | 0.25 x 2,000 = 500.00 | | | 0.25 x 3,500= 875.00 | | |
| ចំណេញសរុប | 4 | 274.10 | | | 517.60 | | |



# ដំណាំម្នាស់
# (Pineapple)

## I- សេចក្ដីផ្ដើម

ដំណាំម្នាសគឺជាដំណាំទាមទារប្រភេទដីមានជីជាតិ ដីកណ្ដេង ដីជើងភ្នំ ដីមាត់ទន្លេ ដីល្បាប់មាត់ទន្លេ សមុទ្រ។ គេតែងប្រទះឃើញដំណាំនេះដែរ ច្រើនដាំនៅលើផ្ទៃដីតូចតាមគ្រួសារ តែមិនអនុវត្តតាមបច្ចេកទេសដាំដុះទេ។

អាកាសធាតុសមស្របនឹងដំណាំម្នាស់គឺ ២៥-៣០ អង្សាសេ។ តាមលក្ខណៈចាំបាច់របស់ដំណាំនេះគេអាចដាំលើដីដែលមាន PH ចន្លោះ ៥.៩ និង ៦.៥។ ផ្លែម្នាស់ជាចំណីទទួលទានស្រស់ រឺចូលរោងចក្រជាកំប៉ុង។

ចំពោះការដាំដុះវិញវាទាមទារនូវបច្ចេកទេសកសិកម្មដូចជា ការភ្ជួររាស់ ដាក់ជី កិច្ចការពារសត្វល្អិតបំផ្លាញ ការពារជំងឺ និងការថែទាំជាប្រចាំ មានការបំប៉នជី បញ្ចូលទឹក ការពារផ្លែអោយល្អ ជៀសវាងជំងឺ ធាតុអាកាសក្ដៅខ្លាំង។ សត្វល្អិតតូចឆ្មារនៅក្នុងដីពណ៌ក្រហម បំផ្លាញឫសដំណាំបណ្ដាលអោយម្នាស់ស្រពោនងាប ក្រៅពីនេះក៏មានចៃម្សៅបំផ្លាញផ្លែដែរ ។

## II- គោលបំណង

១- ចង់អោយកសិករដាំម្នាស់ យល់ដឹងនូវបច្ចេកទេសដាំដុះ។

២- ចេះជ្រើសរើសពូជល្អ ៗ ទទួលទិន្នផលខ្ពស់។

៣- ចេះការពារសត្វល្អិតបំផ្លាញដំណាំ និងចេះការពារ ព្យាបាលជំងឺ។

៤- ចេះប្រើថ្នាំកំចាត់សត្វបំផ្លាញលើដំណាំ។

## III- ទំលាប់កសិករដាំម្នាស់ដោយគ្មានបច្ចេកទេស

- ជ្រើសរើសដីដាំដុះពុំបានសមស្រប ( មានទឹកលិច ដីមិនស្មើ ដីគ្មានជីវជាតិ) ។
- ភ្ជួររាស់មិនបានស្អាត បើដីនៅជំរាលជើងភ្នំវិញពុំបានភ្ជួរកាត់ទទឹងតាមជំរាលដីទេ ពោលគឺភ្ជួរបណ្ដោយតាមជំរាលដីនោះ អោយទឹកហូរច្រោះដី បាត់បង់ជីជាតិមួយចំនួន។
- លើករងដាំមិនបានត្រង់ជួរ លាមកសត្វជាជីជាតិចាំបាច់ដល់ការលូតលាស់ដំណាំម្នាស់ ប្រើបានតិចតួច ដាំមិនបានតាមបច្ចេកទេសកប់គល់រាក់ពេកចន្លោះជួររង និងចន្លោះគុម្ពញឹកពេក លំបាកក្នុងការថែទាំ( ដាក់ជីបំប៉នដើរពិនិត្យតាមរង ជំងឺច្រើន និងងាយស្រួលដល់ជំរកសត្វល្អិតបំផ្លាញដំណាំ ) ។
- ការលូតលាស់ពុំបានល្អ ទិន្នផលថយចុះ។



រៀបចំដោយលោក ជិត សុវណ្ណ និងស្រី ស្រស់ធីតា

## IV- ការអនុវត្តន៍ដំណាំម្នាស់តាមបច្ចេកទេសដាំដុះ

ដំណាំម្នាស់ចាប់ផ្តើមដាំនៅដើមរដូវវស្សា ឬ ដាំនៅដើមរដូវប្រាំង បើមានប្រភពទឹកគ្រប់គ្រាន់។ រយៈពេលលូតលាស់មាន ១២ ដល់ ១៦ ខែ។ ប្រភេទខ្នែងដែលត្រូវយកទៅដាំគឺ ខ្នែងក្រោមផ្លែ (Slip) និងខ្នែងដើមដែលអោយផលច្រើន ។

### ១_ការរៀបចំដីសំរាប់ដំណាំម្នាស់

- ដីមិនលិចទឹក ឬ ដីទួល ដីមានជីជាតិល្អ ដីសមស្របនឹងដំណាំមាន PH ចន្លោះ ៥.៩ និង ៦.៥ ។
- ការធ្វើដី ការភ្ជួររាស់ អោយបានម៉ដ្ឋល្អ ដីធូរ ( ភ្ជួរ ៣ដង )ហើយរាស់សំអាតស្មៅ ។

### ២_ការជ្រើសរើសពូជ



- ពូជធន់នឹងជំងឺ និងធននឹងសត្វល្អិតបំផ្លាញ។
- ពូជមានទិន្នផលខ្ពស់ (ម្នាស់ទឹកឃ្មុំ) ផលរបស់វាមួយផ្លែអាច ១.៥ គីឡូក្រាមដល់ ៧ គីឡូក្រាម ។
- ពូជដែលទីផ្សារគេនិយម។

### ៣_ការលើករង

ក-រងទោល (រង ១ ជួរ) ដែលមានកំពស់ ៣ តឹក។

ខ-រង ២ ជួរដែលលមានទទឹងរង ៦-៨ តឹក(៦០-៨០ សម)។

គ-ដាំចន្លោះគុម្ព ៣ តឹក។

ឃ-ចន្លោះពីរងមួយ ទៅរងមួយ : ៩០ សម-១ ម។ បើដីទួលមិនលិចទឹកគេអាចដាំម្នាស់មិនបាច់លើករង។

### ៤_ការដាក់ជីទ្រាប់បាត(ជីធម្មជាតិ និងជីគីមី ១៥_១៥_១៥)

គេប្រើជីធម្មជាតិដាក់លើដំណាំម្នាស់ចំនួន ២០-៣០ តោនក្នុង ១ ហិកតារ គេប្រើជីគីមី ១៥-១៥-១៥ ចំនួន ៣០០ គក្រក្នុង ១ ហិកតារ។

### ៥_ការជ្រើសរើសខ្នែងម្នាស់មុនពេលដាំ



- ខ្នែងមានទំងន់ ២៥០-៤០០ ក្រាម។
- ខ្នែងដែលគ្មានជំងឺ។
- ខ្នែងថ្លោស ស្លឹកធំ។

### ៦_ការបកស្លឹកចាស់នៅគល់ខ្នែង

ខ្នែងម្នាសមុនពេលយកទៅដាំត្រូវបកស្លឹកចាស់ៗជុំវិញគល់ខ្នែងអោយអស់ ដើម្បីសំរួលដល់ការលូតលាសរបស់ខ្នែង គឺឆាប់ដុះឬស ។

## ៧_ការជ្រលក់ថ្នាំការពារឈ្មោះ Alliette(Phosophy)

ដើម្បីការពារពពួកជំងឺ ជាថ្នាំការពារជំងឺផ្សិតអោយកូនម្នាស់លូតលាស់បានល្អ ចេញស្លឹក និងឫសថ្មី ។

របៀបលាយ: ថ្នាំអាលីយ៉េត(Aliette) ១០ ក្រាមលាយនឹងទឹក ២០ លីត្រ ដោយយកខ្នែងម្នាស់ ជ្រលក់ ត្រាំទឹករយៈពេល ៣ នាទី ។

## ៨_ការដាំម្នាស់

### ការដាំមានពីរយ៉ាង:

- ដាំបញ្ឈរត្រង់សំរាប់រដូវប្រាំង ហើយកប់គល់ខ្នែងអោយលើសពី ១០-១៥ ស.ម ។
- ដាំទ្រេតខ្នែងប្រហែល ៤៥ ដឺក្រេ នៅរដូវវស្សា ។

## ៩_ការថែទាំ

ក. ការដាក់ជីបំប៉នចែកជាពីរដំណាក់កាល (ក្រោយពីធ្វើស្មៅរួច) :

- ដំណាក់កាលទី១ : ម្នាស់មានអាយុ ២-៣ ខែ គេប្រើជី ១៥-១៥-១៥ ។

  រូបមន្តប្រើជី : ១០ ក្រាម រឺ កន្លះស្លាបព្រាបាយក្នុង ១ ដើម ដោយរោយជុំវិញគល់ហើយលុបដីពីលើ ។
- ដំណាក់កាលទី២ : ម្នាស់មានអាយុ ៦ ខែ គេប្រើជី ១៥-១៥-១៥ ចំនួន ១០ ក្រាម រឺ កន្លះស្លាបព្រាបាយ ។

ខ-ការធ្វើស្មៅ :

ស្មៅចង្រៃអាចដណ្តើមជីពីដំណាំម្នាស់ជាជំរកសត្វល្អិតចង្រៃ ។ ចាំបាច់ត្រូវសំអាតស្មៅ ៣ ដង ក្នុងពេលលូតលាស់របស់ដំណាំម្នាស់

- លើកទី១ : ពី ១-២ ខែ ក្រោយពេលដាំ ។
- លើកទី២ : ពី ៣-៤ ខែ ក្រោយពេលដាំ ។
- លើកទី៣ : ពី ៦-៧ ខែ ក្រោយពេលដាំ ។

គ-ការគ្របគល់ម្នាស់ (កំទេចស្មៅ ចំបើង ស្លឹកឈើ មែកឈើ)

គុណសម្បត្តិរបស់វាមាន ៤ យ៉ាង:

- ការពារសំណើមក្នុងដី. ។
- ការពារការហូរច្រោះរងដោយទឹកភ្លៀង ។
- បង្អាក់ការលូតលាស់របស់ស្មៅ ។
- ជាជីជាតិសំរាប់ដំណាំនៅពេលវាពុករលួយ ។





រៀបចំដោយលោក ជិត សុវណ្ណ និងស្រី ស្រស់ធីតា



## ឃ-វិធីការពារ ព្យាបាលជំងឺ និង សត្វល្អិតចង្រៃ

ជំងឺដែលធ្លាប់ប្រទះញឹកញាប់គឺៈ

### ១-ជំងឺរលួយបណ្តូល

ជំងឺនេះច្រើនកើតឡើងនៅរដូវភ្លៀង បណ្តាលមកពីផ្សិត ( Fungal diseases group)

**រោគសញ្ញា :**

ស្លឹកចាស់ប្រែពណ៌ទៅជាលឿងស្លេកហើយបាក់ពាក់កណ្តាល។ កញ្ចុំបណ្តូល (Crown) ធ្លាក់ចុះបើយើងចាប់ទាញវា វានឹងសណ្តកមកយ៉ាងស្រួល ព្រោះគល់បណ្តូលត្រូវរលួយទាំងអស់។

**ការការពារ :** ( Preventive measures)

មុនពេលយកកូនម្នាស់ទៅដាំ ត្រូវយកវាទៅជ្រលក់ក្នុងថ្នាំ អាលីយ៉េត ( Alliette)

### ២-ជំងឺរលួយឫស ( Rot roots)

**រោគសញ្ញា :**

ធ្វើអោយម្នាស់ក្រិនមិនលូតលាស់ មិនចេញផ្លែ បើយើងគាស់ដើមមើល យើងនឹងឃើញឫសរលួយធុំក្លិនស្អុយ។

**ការការពារ :**

- ជៀសវាងដាំម្នាស់នៅរដូវវស្សា។
- យកកូនម្នាស់ដែលត្រូវដាំទៅជ្រលក់ទឹកថ្នាំ អាលីយ៉េត (Aliette) ។



### ៣-ជំងឺស្អុយផ្លែ ( ចំណុចពណ៌លឿង Yellow spot)

ជំងឺនេះច្រើនកើតនៅលើស្លឹកនៃដើមម្នាស់នៅខ្ចី, ភាគច្រើននៅលើផ្លែ។

**រោគសញ្ញា :**

- លើដើមខ្ចី : មានស្នាមអុចរាងមូលពណ៌លឿងទំហំពី ២-១៥ មម នៅលើស្លឹកផ្នែកខាងលើ ហើយរហូតដល់គល់ស្លឹក វាឆ្លងស្លឹកខ្ចីផ្សេងៗទៀតរួចឆ្លងទៅដល់បណ្តូល បណ្តាលអោយដើមម្នាស់ងាប់ក្នុងរយៈពេល ២-៣ សប្តាហ៍។
- លើផ្លែ : ជំងឺនេះឆ្លងចេញពីស្លឹកកំប៉ោយផ្លែ (Crown) ដែលមានរោគ។ គេឃើញមានស្នាមជាំខ្មៅនៅផ្នែកខាងលើនៃផ្លែ បន្ទាប់មកក៏ចាប់រលួយបណ្តាលអោយកំប៉ោយផ្លែស្វិត ងាប់ ឆ្លងទៅភ្នែកម្នាស់ ហើយភ្នែកនោះក៏កកើតជាដំបៅ ។

**កិច្ចការពារៈ**

ត្រូវយកដើមម្នាស់មានជំងឺនេះ ដុត ឬ កប់ ហើយហាមយកកូនម្នាស់កើតជំងឺទៅដាំ ។

### ៤-សត្វល្អិតចង្រៃ ( ណេម៉ាតូត Nematode)

សត្វនេះរស់នៅក្នុងដី ទំហំតូចឆ្មារពណ៌ក្រហមសឹងតែមើលពុំឃើញ វាបំផ្លាញប្រពន្ធ័ឫស។ ដើមម្នាស់មិនអាចលូតលាស់បានល្អ ខូចប្រពន្ធ័ឫស ចេញជាដុំតូចៗរឹង (Lumpy) ។

**កិច្ចការពារ និង ការព្យាបាលៈ**

ដើម្បីសម្លាប់ណេម៉ាតូត ឬ ការពារវាគេប្រើថ្នាំឈ្មោះ ហ្វុយរ៉ាដាន (Furadan ) ដោយរោយគ្រាប់ថ្នាំនេះនៅលើផ្ទៃរងដាំដុះអោយបានស្មើចំនួន ២-៣ ស្លាបព្រាបាយ( ៤០-៨០ ក្រាម) ហើយកាប់បង្កប់ទៅក្នុងដីរង រួចស្រោចទឹក



ពីលើ ទើបយកកូនម្នាស់ទៅដាំ ។ បើដាំហើយ ត្រូវយកថ្នាំនេះរោយតាមគល់បង្កប់ទៅក្នុងដីហើយស្រោចទឹកដើម្បីសម្លាប់វា ។

### ៥-សត្វល្អិតចង្រៃចៃម្សៅជាចៃពណិស

វារស់នៅជាក្រុម ជាកញ្ចុំពណិសខ្លួនទន់ នៅតាមគល់ស្លឹក និងផ្លែម្នាស់ ។ វាជញ្ជក់យកសារជាតិផ្សេងៗដែលចិញ្ចឹមដើមម្នាស់ សំរាប់លូតលាស់ ។

**រោគសញ្ញា ៖**

- ដើមម្នាស់ស្វិតស្រពោន មិនអាចលូតលាស់បាន

**វិធីកំចាត់ ៖**

បាញ់ថ្នាំកំចាត់ចៃម្សៅ ដោយថ្នាំបុរាណផ្សំពីរុក្ខជាតិ ឬ ជាឱយ៉ាស៊ីណុង ឬ សេវិន ក្នុងកំរិត ៣ ស្លាព្រាបាយទឹក ២០ លីត្រ ។

## V- ការប្រៀបធៀបទិន្នផលម្នាស់ និងវិភាគសេដ្ឋកិច្ច

| បរិយាយ | ការប្រមូលផលម្នាស់គ្មានបច្ចេកទេសដាំដុះ | | ប្រមូលផលម្នាស់តាមបច្ចេកទេសដាំដុះ | |
|---|---|---|---|---|
| | កំរិតបាត់បង់ជា % | ក្នុង ១០០% នៅសល់ | កំរិតបាត់បង់ជា % | ក្នុង ១០០% នៅសល់ |
| ពូជ | ២% | - | ១% | - |
| ការដាំដុះ | ១០% | - | ៣% | - |
| ជំងឺ | ៥% | - | ១% | - |
| សត្វល្អិតបំផ្លាញ | ៥% | - | ១% | - |
| សរុប | ២២% | ៧៨% | ៦% | ៩៤% |







# ដំណាំបន្លែក្នុងរដូវវស្សា
# (Rain season vegetable Production)

## I-សេចក្តីផ្តើម

ដំណាំបន្លែត្រូវចែកជា ៣ ប្រភេទគឺ បន្លែយកស្លឹក បន្លែយកផ្លែ និងបន្លែយកមើម ។ ដំណាំបន្លែមានទំនាក់ទំនងជាមួយការរស់នៅរបស់មនុស្សយើង ទាំងផ្នែកម្ហូបអាហារក៏ដូចជាផ្នែកសេដ្ឋកិច្ច ។ បន្លែមានលក្ខណៈពិសេសសំរាប់សុខភាពមនុស្ស បន្លែសម្បូរទៅដោយប្រូតេអ៊ីន និងគ្លុយស៊ីត ជាតិប្រេង ជាពិសេសរូបធាតុ ព្រមទាំងជីវជាតិ អា.បេ.សេ ផងដែរ ។

ក្រោយពីការដាំដុះសំរាប់ផ្គត់ផ្គង់គ្រួសារ កសិករបានយកបន្លែទៅលក់នៅទីផ្សារ ដែលជាប្រភពនៃការរកចំណូលជាប្រាក់តិច ឬ ច្រើនទៅតាមសកម្មភាព ទំហំដី និងផលិតផលដែលទទួលបាន ។ កត្តាសំខាន់ដែលទាក់ទងទៅនឹងការដាំដុះគឺ អាកាសធាតុ ទឹក ដី ជី សំភី ពូជ និងម្យ៉ាងទៀតវាមានទំនាក់ទំនងផ្ទាល់ទៅនឹងចំណេះដឹង ចំណេះធ្វើខាងបច្ចេកទេសថែមទៀត ។

អនុវត្តដាំដុះដំណាំបន្លែនៅក្នុងរដូវវស្សា គេសង្កេតឃើញមិនសូវមានការដាំដុះច្រើនទេ ព្រោះវាមានការលំបាកច្រើន ដែល បណ្តាលពីទឹកភ្លៀងធ្លាក់ច្រើនធ្វើអោយរលួយ ឬ បណ្តាលពីការបំផ្លាញពីសត្វល្អិត និងជំងឺដែលជាកត្តាធ្វើអោយផលិតផលបន្លែមានការខ្វះខាត តម្រូវការចំបាច់របស់ទីផ្សារ ទាំងបរិមាណ និងគុណភាពព្រមទាំងភាពប្រក្រតីឱ្យបានទៀងទាត់ នាំមកនូវការនាំចូលពីខាងក្រៅយ៉ាងច្រើនទៀតផង ។

## II-គោលបំណង

១-បង្កើនចំណេះដឹង និងចំណេះធ្វើដល់ផលិតករដំណាំបន្លែឱ្យបានកាន់តែខ្ពស់ ក្នុងការអនុវត្តន៍បច្ចេកទេសដាំដុះ ។

២-ធ្វើអោយផលិតផលបន្លែមានជាប្រចាំទាំងបរិមាណ និងគុណភាព តម្រូវតាមសេក្តីត្រូវការទីផ្សារ ។

៣-បង្កើនប្រាក់ចំណូលឱ្យកាន់តែខ្ពស់ដល់កសិករ ក្នុងការផលិតដំណាំបន្លែនៅរដូវវស្សា ។

## III-ការអនុវត្តន៍ការដាំដុះរបស់កសិករកន្លងមក

- អនុវត្តតាមគ្នាដោយខ្វះខាតនូវបច្ចេកទេស ។
- ប្រភេទបន្លែដាំដុះដូចៗគ្នាតាមរដូវកាល ធ្វើអោយផលិតផលបន្លែជុញ និងមានតំលៃថោក បាត់ចំណូល ។
- មិនបានប្រើជីធម្មជាតិឱ្យបានសមស្របតាមបច្ចេកទេស (ជីមិនទាន់ពុកផុយល្អ ដាក់តិចតួច ច្រើនប្រើតែលាមកសត្វស្រស់ហើយមិនបានភ្ជួរ ឬ កាប់បំផុសច្របល់ឱ្យបានសព្វល្អ) ។



រៀបចំដោយលោក ជិត សុវណ្ណ និងស្រី ស្រស់ធីតា



- ប្រើប្រាស់ជីគីមី និងថ្នាំពុលកសិកម្មគ្មានកំរិតច្បាស់លាស់ នាំឱ្យខូចដំណាំ និងប៉ះពាល់បរិស្ថាន ។
- ការដាំដុះមិនរើសពេលវេលា ។

## IV- ការអនុវត្តន៍បច្ចេកទេសដាំបន្លែក្នុងរដូវវស្សា

ការដាំដុះដំណាំបន្លែក្នុងរដូវវស្សា ត្រូវយកចិត្តទុកដាក់ឱ្យបានខ្ជាប់ខ្ជួនលើការងារមួយចំនួនដូចជា:

- ការជ្រើសរើសទីតាំងសំរាប់ធ្វើការដាំដុះ ។
- ការរៀបចំដីដាំដុះ ។
- ការដាក់ជី ជីធម្មជាតិ និងជីគីមី ។
- ការសាប និងការស្ទូងកូនដំណាំ ( ថ្នាលខ្ពស់ពីដី ឬ ថ្នាលផ្ទាល់ដី ) ។
- ការថែទាំដំណាំ ។
- ការដាក់ជីបំប៉ន ។
- ការប្រមូលផលដំណាំ ។



### ១_ការជ្រើសរើសទីតាំងសំរាប់ធ្វើការដាំដុះ

- ដីខ្ពស់ មិនលិចទឹក ឬ ស្រស់ទឹកល្អ មិនដាំទឹក ។
- ដីមានជីជាតិ ។
- ដីនៅក្បែរផ្លូវចេញចូល ឬ នៅក្បែរលំនៅដ្ឋាន សំរួលដល់ការថែទាំ និងដឹកជញ្ជូន ។

### ២_ការរៀបចំដីដាំដុះ

- ភ្ជួររាស់ ឬ កាប់គាស់ឱ្យបាន ២-៣ ដង ក្នុងជំរៅ ២០-២៥ សម និងដើម្បីធ្វើដីឱ្យបានម៉ដ្ឋល្អ ។
- លើកជារងកំពស់ ២០-៣០ សម ដោយមានទទឹងរង ១០០ សម ( បណ្តោយរងតាមតម្រូវការ ) ។
- ដាក់ជីទ្រាប់បាត :
  - ជីកំប៉ុស្ត ឬ ជីលាមកសត្វពុករលួយល្អ: ៣០០ គក្រ / ១០០ម$^{២}$ ។
  - ជី DAP (១៨-៤៦-០): ១ គក្រ / ១០០ម២ ។
  - ជី $K_2O$ (០-០-៦០ ): ១ គក្រ / ១០០ម២ ។
  - រោយផេះអង្កាម: ៥០ គក្រ / ១០០ម២ ។
- ដាក់ជីឱ្យបានស្មើល្អ រួចភ្ជួររាស់ ឬ កាប់គាស់ច្របល់ឱ្យបានសព្វនៅក្នុងដី( នៅពេលភ្ជួររាស់ ឬ កាប់គាស់លើកទី៣ ) ។

### ៣_ការសាបគ្រាប់ពូជ និងការស្ទូងកូនបន្លែ

#### ៣.១ ការសាបគ្រាប់ពូជ(ថ្នាលខ្ពស់ ពីដីថ្នាលផ្ទាល់ដី)

- ធ្វើឱ្យម៉ដ្ឋ ហាលឱ្យស្ងួត ហើយស្រោចទឹកក្តៅ ( ១០ លីត្រ / ម២ ) ។
- លាយដី ៤០% ជីកំប៉ុស្ត ៤០% និងផេះអង្កាម ២០% ។



- ដីដែលបានលាយច្របល់ហើយត្រូវហាលថ្ងៃ ៣-៤ ថ្ងៃមុនសាប ។
- ធ្វើដីថ្នាលឱ្យបានស្អាត ស្មើល្អ និងរើសកំទេចកំទីចោល ។
- ឆូតជាចង្អូរកាត់ទទឹងរងចម្ងាយពីចង្អូរមួយទៅចង្អូរមួយ ១០ សម ។
- រោយគ្រាប់ពូជក្នុងចង្អូរឱ្យបានស្មើ ១-២ សម ក្នុងជំរៅ ១-១,៥០ សម ។
- លុបគ្រាប់ពូជក្នុងចង្អូរដោយដីដែលបានលាយហើយ រួចយកដៃទះថ្នមៗដើម្បីឱ្យគ្រាប់ពូជ និងដីរឹបជាប់គ្នា ។
- ប្រើថ្នាំម៉ង់កូហ្សែបលើថ្នាល ដើម្បីការពារជម្ងឺផ្សិត ។
- រោយកំទេចចំបើងស្ងួត ស្អាត ដើម្បីរក្សាសំណើម និងការពារកំហាប់ដីដោយការស្រោចទឹក ។
- ស្រោចទឹកឱ្យបានជោក និងរក្សាសំណើមឱ្យបានល្អ ។
- ធ្វើដំបូលការពារកំដៅថ្ងៃខ្លាំង  និងការពារទឹកភ្លៀង ។

## ៣.២ ការស្ទូងកូនបន្លែក្នុងថង់ប្លាស្ទិក ឬ កន្ទោងស្លឹកចេក

- ១០-១២ ថ្ងៃក្រោយដុះ គេអាចគាស់កូនបន្លែយកមកស្ទូងបាន ។
- ការរៀបចំដីក្នុងកន្ទោង ឬ ថង់ ក៏ដូចរៀបចំដីសំរាប់ថ្នាលដែរ ។
- បំពេញថង់ ឬ កន្ទោងស្លឹកចេកឱ្យហាប់ល្មម ។
- ប្រើឈើសំរាប់ធ្វើរន្ធ ដាំកូនបន្លែនៅក្នុងថង់ ឬ កន្ទោង ។
- យកកូនបន្លែទៅស្ទូងក្នុងថង់ ឬ កន្ទោងដោយការប្រុងប្រយ័ត្ន ។
- អាយុបាន ១៥-២០ ថ្ងៃ អាចយកទៅដាំបាន ។



## ៣.៣ ការស្ទូងកូនបន្លែលើរងបន្លែ

- ធ្វើរណ្ដៅនៅលើរងបន្លែ តម្រូវតាមខ្នាតថង់ប្លាស្ទិក ឬ កន្ទោង ។
- ដកថង់ប្លាស្ទិក ឬ កន្ទោងចេញ ។
- ដាក់កូនបន្លែទៅក្នុងរណ្ដៅ ។
- លុបបំពេញដីទៅក្នុងរណ្ដៅ ។
- ស្រោចទឹកឱ្យបានជោកល្អ ។







## តារាងបង្ហាញពីរបៀបដាំផុះតាមមុខដំណាំមួយចំនួន

| ប្រភេទដំណាំ | ចន្លោះជួរ | ចន្លោះដើម |
|---|---|---|
| - សាលាដ | ២៥ - ៣០ សម | ២០ - ២៥ សម |
| - ខាត់ណាកាត់ | ២៥ - ៣០ សម | ២០ - ២៥ សម |
| - ស្ពៃក្រញាញ់ | ៣០ - ៣៥ សម | ២៥ - ៣០ សម |
| - ម្ទេសហាវ៉ៃ | ៤០ - ៥០ សម | ៣០ - ៤០ សម |
| - ប៉េងប៉ោះ | ៥០ - ៦០ សម | ៤០ - ៥០ សម |
| - ត្រប់វែង | ៥០ - ៦០ សម | ៤០ - ៥០ សម |
| - ឆៃថាវ | ១០ - ១៥ សម | ០,៥ - ១០ សម |
| - ការ៉ុត | ១០ - ១៥ សម | ០,៥ - ១០ សម |

## ៤_ការថែទាំបន្លែ និងការស្រោចទឹក

- គ្របគល់ដោយប្រើចំបើងស្ងួត ដើម្បីការពារការហាប់ដី និងរក្សាសំណើមបានល្អ។
- ស្រោចទឹកដំណាំឱ្យបានគ្រប់គ្រាន់ ដើម្បីដំណាំលូតលាស់ល្អ។
- ឧស្សាហ៍ជ្រុំជ្រួយគល់ដំណាំ និងកំចាត់ស្មៅចង្រៃ ដើម្បីបង្កើនការលូតលាស់ផ្នែកប្រព័ន្ធ ឫស និងកុំឱ្យស្មៅប្រជែងជាមួយដំណាំ។
- រេះ ឬ កាត់ស្លឹកចាស់ចោលចេញខ្លះ ចៀសវាងការរលួយស្លឹក ។
- បេះ ឬ កាត់ស្លឹកដែលសត្វល្អិតបំផ្លាញ ឬ ស្លឹកមានជម្ងឺ ។
- បេះ ឬ កាត់ផ្លែស្អុយ ឬ មានរោគចោលចេញ។
- រើសផ្លែដែលស្អុយជ្រុះទៅដីយកទៅកប់ចោលឱ្យឆ្ងាយ ដើម្បីការពារ កុំឱ្យឆ្លងរោគ។
- ធ្វើរបាំងការពារកំដៅថ្ងៃខ្លាំង និងភ្លៀងធ្លាក់ខ្លាំងដោយអនុវត្តប្រក់ស្លឹកដូង ឬ ប្រក់សំណាញ់ស៊ីរ៉ែន។
- រយៈពេល ១០-១៥ ថ្ងៃ ក្រោយស្ទូងលើរង ឬ ដាំគ្រាប់ ត្រូវធ្វើការជ្រុំជ្រួយគល់ដំណាំដាក់ជីបំប៉នលើកទី ១

## តារាងបង្ហាញពី ការដាក់ជីបំប៉នដំណាំបន្លែ

| ប្រភេទជីបំប៉ន | បរិមាណប្រើប្រាស់ | ពេលវេលាត្រូវប្រើប្រាស់ |
|---|---|---|
| ជីអ៊ុយរ៉េ | ១ គក្រ សំរាប់ផ្ទៃដី ១០០ម$^2$ ( សំរាប់ដាក់ម្តង ៗ) | ១០ - ១៥ថ្ងៃក្រោយពីដាំ ឬស្ទូង<br>១៥ - ៣០ថ្ងៃក្រោយលើកទី ១<br>(ដំណាំខ្លះ អាចដាក់លើកទី ៣) |
| ជីអាចម៍ប្រចៀវ | ៥-១០ គក្រសំរាប់ដី ១០០ម$^2$ ( សំរាប់ដាក់ម្តង ៗ) | ១០ - ១៥ថ្ងៃក្រោយដាំ ឬស្ទូង<br>១៥ - ៣០ថ្ងៃក្រោយលើកទី ១<br>(ដំណាំខ្លះ អាចដាក់លើកទី ៣) |
| ជីកំប៉ុស្តទឹក | ១០០ លីត្រ សំរាប់ផ្ទៃដី ១០០ម២ | ២ អាទិត្យក្រោយការដាំ ឬស្ទូង<br>(រៀងរាល់ ៧ថ្ងៃ បន្ទាប់ពីលើកទី ១) |



## ៥_ការពារ និងកំចាត់សត្វល្អិត,ជម្ងឺ



- ត្រូវឧស្សាហ៍ត្រួតពិនិត្យនូវការវិវត្តន៍របស់សត្វល្អិត ពីព្រោះវិធានការការពារ និងកំចាត់ធ្វើបានជោគជ័យ នៅក្នុងដំណាក់កាលពង និងកូនដង្កូវប៉ុណ្ណោះ។ បើហួសពីដំណាក់កាលនេះយើងពិបាកនឹងទប់ទល់ ហើយធ្វើឱ្យពពួកសត្វល្អិតមានការស៊ាំនឹងថ្នាំ។ ម្យ៉ាងទៀតការប្រើប្រាស់ថ្នាំត្រូវជ្រើសថ្នាំ៣មុខ(ឬប្រភេទ)សំរាប់ធ្វើការបាញ់ឆ្លាស់គ្នា(ម្តងប្រើថ្នាំនេះ ម្តងទៀតប្រើថ្នាំនោះ និងជាបន្តបន្ទាប់)។

| មុខសញ្ញាបំផ្លាញ | សត្វល្អិត | ថ្នាំកំចាត់សត្វល្អិត |
|---|---|---|
| ស្លឹក | - ចៃ<br>- ដង្កូវ | - កុងហ្វ៊ីដរ<br>- អាបាម៉ិចតាំង<br>(បាញ់ឆ្លាស់គ្នា) |
| ផ្លែ | ដង្កូវចោះផ្លែ | |

- ចំពោះជំងឺផ្សិតក្រោយពីស្ទូង ២ ថ្ងៃ ធ្វើការបាញ់ថ្នាំ ម៉ង់កូហ្សែប ( Mancozeb ) ឬ ម៉ានីក្រូ (Manicro) ក្នុងកំរិត ៣០-៥០ ក្រាម លាយទឹក ២០ លីត្រ សំរាប់ផ្ទៃដី ១០០ ម$^{២}$ (អនុវត្តការបាញ់ថ្នាំឆ្លាស់គ្នា) ។

## V- ការប្រមូលផលបន្លែ និងការវិភាគលើមុខដំណាំ(រដូវវស្សា)

តាមការពិសោធន៍ ការទទួលផលមានដូចតទៅ :

- ដំណាំប៉េងប៉ោះ ទទួលបានទិន្នផល.....................................៧ គក្រ ក្នុង ១ម$^{២}$
- ដំណាំស្ពៃក្តោប ទទួលទិន្នផល.........................................៥ គក្រ ក្នុង ១ម$^{២}$
- ដំណាំសណ្តែកទ្រើង ទទួលបានទិន្នផល..............................៣ គក្រ ក្នុង ១ម$^{២}$
- ដំណាំការ៉ុត ទទួលបានទិន្នផល.........................................៣ គក្រ ក្នុង ១ម$^{២}$
- ត្រសក់ ទទួលបានទិន្នផល...............................................៤,៥០គក្រ ក្នុង ១ម$^{២}$
- ម្ទេសហាវ៉ៃ ទទួលបានទិន្នផល.........................................៤ គក្រ ក្នុង ១ម$^{២}$
- ខ្ទឹមស្លឹក ទទួលបានទិន្នផល............................................៣ គក្រ ក្នុង ១ម$^{២}$
- សាឡាដ ទទួលបានទិន្នផល..............................................៣ គក្រ ក្នុង ១ម$^{២}$
- ខាត់ណាកាត់ ទទួលបានទិន្នផល.......................................៣ គក្រ ក្នុង ១ម២
- ដំណាំស្ពៃក្រញាញ់ ទទួលបានទិន្នផល................................៣ គក្រ ក្នុង ១ម$^{២}$ ។





# ផែនការដាំដុះដំណាំបន្លែ
# (Vegetable Farm Management)

## I-សេចក្ដីផ្ដើម

ម្ហូបអាហារទាក់ទងទៅនឹងដំណាំជាច្រើនដូចជា ស្រូវ ពោត បន្លែគ្រប់មុខ បន្លែស្ថិតក្នុងចំណោមអាហារយ៉ាងសំខាន់ ដែលធ្វើការដាំដុះក្នុងក្របខ័ណ្ឌវិទ្យាសាស្ត្របច្ចេកទេសយ៉ាងខ្ពស់។ បច្ចេកទេសដ៏ទំនើបនេះ ត្រូវបានយកមកប្រើក្នុងន័យបង្កើនទិន្នផល និងបង្កើនគុណភាពផលិតផលសំរាប់ម្ហូបអាហារប្រចាំគ្រួសារ និងរកចំណូលច្រើនតាមរដូវកាលខុសៗគ្នាដែរ។ ការដាំបន្លែតាមអាកាសធាតុ ឬប្រើប្រាស់តាមបច្ចេកទេសទំនើប ត្រូវយោងទៅលើពេលវេលា តំបន់ តំលៃ ឬតំរូវការ ។

ការកំណត់អោយយល់ដឹងពីផែនការដាំដុះបន្លែគឺសំខាន់ណាស់ ហើយចែកចេញជាពីររដូវគឺ រដូវប្រាំង និងរដូវវស្សា។ ដំណាំបន្លែចែកចេញជាបីប្រភេទដែរគឺ បន្លែយកស្លឹក បន្លែយកផ្លែ និងបន្លែយកមើម។
ក្នុងមួយឆ្នាំៗ រដូវប្រាំងចាប់ពីចុងខែ តុលា ដល់ ដើមខែ ឧសភា ឯរដូវវស្សាវិញចាប់ពីចុងខែ ឧសភា ដល់ដើមខែតុលា។

## II-គោលបំណង

១-អោយកសិករដាំបន្លែ យល់ដឹងពីផែនការដាំដុះក្នុងមួយឆ្នាំ។
២-ផ្តល់បច្ចេកទេសដាំដុះបន្លែទទួលបានទិន្នផលខ្ពស់ រកចំណូលបានច្រើន ប្រៀបធៀបតាមរដូវកាល។
៣-ចេះត្រិះរិះថ្លឹងថ្លែង ស្វែងយល់ពីបច្ចេកទេសដាំដុះបន្ថែមទៀត ដោយជំនះរាល់ឧបសគ្គទាំងឡាយ។
៤-ខិតខំដាំបន្លែដែលគេដាំមិនបាន (រដូវវស្សា)ហើយដាំអោយបានដើម្បីទទួលផលល្អ រកកំរៃបានច្រើន (លក់ផលិតផលបានតំលៃខ្ពស់) ។
៥-ចេះការពារសត្វល្អិតដោយប្រើថ្នាំពុលបុរាណជៀសវាងគ្រោះថ្នាក់ និងចេះដាំដំណាំឆ្លាស់គ្នា ផ្លាស់ប្តូរមុខដំណាំដើម្បីបង្វែងដានសត្វល្អិតដែលធ្លាប់មកស៊ីបំផ្លាញដំណាំបានងាយស្រួល។
៦-ចេះពិនិត្យ, សង្កេត និងវិនិច្ឆ័យប្រភេទជំងឺ ចេះរៀបរបៀបការពារជំងឺ និងព្យាបាលជំងឺលើដំណាំបន្លែ។

## III- ទំលាប់ដាំដុះដំណាំបន្លែរបស់កសិករ

- តាមការសង្កេត កសិករដាំបន្លែតាមការចេះដឹងតៗគ្នាពីរដូវកាលដាំដុះបន្លែ ហើយនាំគ្នាដាំប្រភេទបន្លែភាគច្រើនដូចៗគ្នា ដូចជាដាំបន្លែ ស្ពៃ សាលាដ ជាដើម ដោយប្រើប្រាស់បច្ចេកទេសដាំដុះបន្តិចបន្តួច ដូចជាលាមកគោក្របី ជីគីមី ហើយមានកំរិតទាប។ ការដាក់ជីលើដំណាំបន្លែ មិនបានគ្រប់គ្រាន់ ហើយមិនបានសមស្របតាមតំរូវការនូវប្រភេទបន្លែនីមួយៗ (បន្លែស្លឹក បន្លែផ្លែ បន្លែមើម) ។


រៀបចំដោយលោក ជិត សុវណ្ណ និងស្រី ស្រស់ធីតា



• ការថែទាំមិនបានគ្រប់គ្រាន់ (ជំរះស្មៅ ស្រោចទឹកមិនបានសព្វ ដោយខ្វះប្រភពទឹក) ។

• ជ្រុំជ្រួយដីមិនបានទៀងទាត់ គ្មានវិធីការពារ និងសំលាប់សត្វល្អិតដែលស៊ីបំផ្លាញដំណាំបន្លែ(ទិន្នផលចុះទាប) ។ ដូច្នេះ ដំណាំមិនល្អផលបានតិច តំលៃទាបនៅទីផ្សារ ។

## IV- ផែនការបច្ចេកទេសដាំដុះបន្លែតាមរដូវកាល និងតាមប្រភេទដំណាំ

ដំណាំបន្លែយកស្លឹក( រដូវប្រាំង, រដូវវស្សា)

| មករា | កុម្ភះ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | |

បញ្ជាក់: រយៈពេលលូតលាស់របស់ដំណាំបន្លែយកស្លឹក រហូតដល់ប្រមូលផលមាន: ២៥ ដល់ ៣៥ ថ្ងៃ (ខ្ទឹមស្លឹក, សាលាដ,ស្ពៃចង្កឹះ.....)

កំណត់សំគាល់:

: ដាំនៅរដូវប្រាំង, លូតលាស់ល្អណាស់, ដាំច្រើន, លក់នៅផ្សារតំលៃថោក ។

: រដូវប្រាំង លូតលាស់មិនល្អ, ដាំបានតិច, ខូចខាតច្រើន, លក់នៅទីផ្សារតំលៃថោក ដោយផលិតផលសត្វស៊ី មិនល្អ ។

: ដាំនៅរដូវវស្សា, បានតិច ព្រោះភ្លៀងច្រើនជោកជាំ ធ្វើអោយដំណាំខូចខាត បាត់បង់ទិន្នផលច្រើន បណ្តាលមកពីជំងឺរលួយដើម, រលួយគល់, អុចៗក្រហមស្លឹក, ទិន្នផលថយចុះយ៉ាងច្រើន ។ លក់ផលនៅទីផ្សារ បាន តំលៃថោក ។ ផ្ទុយមកវិញ បើចង់ទទួលបានផលច្រើននៅទីផ្សារ តំលៃបានថ្លៃ ត្រូវធ្វើតាមបច្ចេកទេស ។

### ១-បច្ចេកទេសដាំដុះបន្លែស្លឹកនៅរដូវវស្សា

ដើម្បីជំនះគ្រប់ឧបសគ្គសំរាប់ដំណាំបន្លែយកស្លឹក នៅរដូវវស្សាទទួលបានផលច្រើន ខូចខាតបាត់បង់តិចតួច ហើយ តំលៃបានខ្ពស់នៅទីផ្សារ ត្រូវធ្វើ:

- ដំបូល ឬគំរបរងការពារទឹកភ្លៀង ។
- រងត្រូវលើកខ្ពស់(២០ ស.ម) ។
- ធ្វើដីអោយធូរ ដាក់ជីកំប៉ុស្តចំនួន ៥ បង្គី ឬ ៥០ គ.ក្រ លើផ្ទៃដី ១០ ម២ ។
- ថែទាំបានល្អ (ជំរះស្មៅ,ពូនគល់, ជីបំប៉ន,ការពារសត្វល្អិត ។
- ប្រើជីកំប៉ុស្តទឹក ១ ភាគ ៤ ឬជីអ៊ុយរ៉េ ចំនួន ២ ស្លាបព្រាបាយ លាយទឹក ១០ លីត្រ ស្រោចលើដំណាំ ។



ដំណាំបន្លែយកផ្លែ( រដូវប្រាំង, រដូវវស្សា)

| មករា | កុម្ភះ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | |

បញ្ជាក់: រយៈពេលលូតលាស់របស់ដំណាំបន្លែយកផ្លែ រហូតដល់ប្រមូលផលមាន : ៥០ ដល់ ៩០ថ្ងៃ ដូចជា ( សណ្តែកកួរ ត្រសក់ ប៉េងប៉ោះ ត្រប់ ជាដើម.....) ។

កំណត់សំគាល់:

: ដាំនៅរដូវប្រាំង, លូតលាស់ល្អណាស់, ដាំច្រើន, ផលិតផលបានច្រើន, លក់នៅផ្សារតំលៃថោក ។

: រដូវប្រាំង លូតលាស់មិនល្អ, ដាំបានតិច, ខូចខាតច្រើន, ផលបានតិច, ផលលក់នៅទីផ្សារតំលៃថោក ដោយសត្វស៊ី ខ្វះទឹក ។

: ដាំនៅរដូវវស្សា, ដាំបានតិច ព្រោះភ្លៀងច្រើនជោកជាំ ដំណាំខូចខាតច្រើនដោយជាំទឹក, រលួយដើម ជំងឺនៅផ្លែ, រលួយស្លឹក ទិន្នផលថយចុះ, ផលលក់នៅទីផ្សារតំលៃថោក មូលហេតុផ្លែតូច, ផ្លែមានជំងឺ, សម្បុរមិនល្អ។ ផ្ទុយទៅវិញ ដើម្បីដាំដំណាំនៅរដូវវស្សាអោយទទួលផលបានច្រើន ហើយជៀសវាងការខូចខាតបាត់បង់ផល ត្រូវធ្វើតាមបច្ចេកទេស ។

## ២_បច្ចេកទេសដាំដុះបន្លែយកផ្លែនៅរដូវវស្សា

- ត្រូវមានដំបូល ឬគំរបរងបន្លែការពារទឹកភ្លៀង ។
- ធ្វើដីអោយម៉ដ្ឋល្អ, ធូរ មានខ្យល់ចេញចូល, ដាក់ជីទ្រាប់បាតចំនួន ៥ បង្គី ឬ ៥០ គក្រ លើផ្ទៃដី ១០ ម២ ។
- លើករងអោយខ្ពស់ ២០ ស.ម កុំអោយដក់ទឹក ។
- ថែទាំដំណាំ( ធ្វើស្មៅ,ដាក់ជីបំប៉ន,ការពារសត្វល្អិត) ។



រៀបចំដោយលោក ជិត សុវណ្ណ និងស្រី ស្រស់ធីតា



## ដំណាំបន្លែយកមើម

ដំណាំបន្លែយកមើម គេអាចដាំនៅរដូវប្រាំងច្រើនជាងរដូវវស្សា

| មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | |
| | | | | | | | | | | | |

បញ្ជាក់: រយៈពេលលូតលាស់របស់ដំណាំបន្លែយកមើម រហូតដល់ប្រមូលផលមានៈ ៣០ ដល់ ៩០ថ្ងៃ ដូចជា (ដំណាំរ៉ាឌី ការ៉ុត ឆៃថាវ ជាដើម.....)

កំណត់សំគាល់ :

: ដាំនៅរដូវប្រាំង, លូតលាស់ល្អ, ដាំបានច្រើនៈ ផ្ទៃដីដាំធំធេង, ផលិតផលច្រើន,ផលលក់នៅផ្សារតំលៃថោក ។

: ពិបាកដាំ, ថែទាំ, ប៉ុន្តែតំលៃខ្ពស់ ។

តាមការសង្កេត ដំណាំបន្លែយកមើម គេអាចដាំបានទាំងរដូវប្រាំង ទាំងរដូវវស្សា។ ក្នុងរដូវប្រាំង ផលិតផលសំបូរនៅទីផ្សារ ឯតំលៃក៏ថោក ករណីនេះយើងត្រូវសង្កេតមើលនៅទីផ្សារ បើផលិតផលដំណាំបន្លែយកមើមច្រើនហូរហៀរ គេអាចពន្យាពេលចដកយកផលពី ២ ដល់ ៧ ថ្ងៃ ដើម្បីទទួលចំណូលបានច្រើន លក់បានថ្លៃ ។



# អត្តសញ្ញាណដីសំរាប់ដំណាំស្រូវ
# (Rice Soil Identification)

## I-សេចក្តីផ្តើម

កសិកម្មកម្ពុជា កំពុងចាប់ផ្តើមដំណាក់កាលអភិវឌ្ឍនដ៏ឆាប់រហ័សមួយ ហើយរចនាសម្ពន័ស្រាវជ្រាវកំពុងត្រូវបានស្តារឡើងវិញយ៉ាងផុលផុស ។ ការស្រាវជ្រាវដ៏មានសារៈសំខាន់ត្រូវបានចាប់ផ្តើម ហើយគំរោងជាច្រើនក៏កំពុងស្ថិតនៅក្នុងការរៀបចំដែរ ។ ការអភិវឌ្ឍន៏ទាំងនេះ ទាមទារព័ត៌មានអំពីដីអោយកាន់តែសុក្រឹតឡើងដើម្បីជំរុញអោយមានផែនការល្អ ការបកស្រាយទិន្នន័យអោយបានច្បាស់លាស់ ហើយនឹងធ្វើការផ្សព្វផ្សាយលទ្ធផលទាំងនេះអោយបានទូលំទូលាយ ដល់តំបន់ផលិតស្រូវផ្សេងៗនៅក្នុងប្រទេស ។

អ្នកកសិកម្មជាច្រើននាពេលបច្ចុប្បន្ន ទទួលបានព័ត៌មានដ៏តិចតួចណាស់ដើម្បីជាមូលដ្ឋានក្នុងការសិក្សា ។ ឯកសារបោះពុម្ពផ្សាយរបស់ Crocker នៅឆ្នាំ ១៩៦២ ស្តីអំពីការស្រាវជ្រាវអំពីដីនៅកម្ពុជា (Exploratory survey of the soil of Cambodia) ហើយមានការលំបាកនឹងយកទៅអនុវត្តអោយបានល្អពីសំណាក់អ្នកបច្ចេកទេសនានាផងដែរ ។ ឆ្នាំ ១៩៩៥ ឯកសារមួយរបស់បណ្ឌិត ភីធើរវ៉ាយ នៃវិទ្យាស្ថានស្រាវជ្រាវនឹងអភិវឌ្ឍន៏កសិកម្មកម្ពុជា ស្តីអំពីឯកសារចងក្រងសំរាប់ការធ្វើអត្តសញ្ញាណ និងការគ្រប់គ្រងដី ដែលបានបង្ហាញពីការសិក្សាស្រាវជ្រាវនៅលើក្រុមដីចំនួន ១១ កន្លែងនៅក្នុងប្រទេស និងការកំណត់នូវការប្រើប្រាស់ដីសំរាប់ដំណាំស្រូវ និងការគ្រប់គ្រងដី ដើម្បីធ្វើអោយមានការងាយស្រួលដល់អ្នកបច្ចេកទេសតាមមូលដ្ឋាន មានលទ្ធភាពក្នុងការអនុវត្តកំណត់អត្តសញ្ញាណដីសំរាប់ដំណាំស្រូវ ។

## II-គោលបំណង

១-ជាដំបូងផ្តល់ដល់អ្នកគ្មានឯកទេស អាចធ្វើចំណាត់ថ្នាក់ដីបានដោយមិនបាច់មានជំនួយពីមន្ទីរពិសោធន៏ ក្នុងការកំណត់ និងជ្រើសរើសដីធ្វើផលិតកម្មដំណាំស្រូវនៅតាមមូលដ្ឋាន ។

២-ធ្វើអោយមានការយល់ដឹងការបែងចែកប្រភេទដី និងការគ្រប់គ្រងកែលំអដីនៅតាមតំបន់ សំរាប់ផលិតកម្មដំណាំស្រូវ ។

៣-ធ្វើអោយមានការយល់ដឹងពីការគ្រប់គ្រង កែលំអដីតាមរយៈការប្រើប្រាស់ជី( ជីសរីរាង្គ នឹង ជីអសរីរាង្គ) ទៅលើប្រភេទដីក្នុងផលិតកម្មដំណាំស្រូវតាមតំបន់ ដែលរក្សាបាននូវបរិស្ថាន និងនិរន្តរភាព ។



រៀបចំដោយលោក ជិត សុវណ្ណ និងស្រី ស្រស់ធីតា



## III-ការអនុវត្តន៍កន្លងមករបស់កសិករ ក្នុងការជ្រើសរើសដីសំរាប់ធ្វើស្រែ

១-កសិករខ្មែរដែលជាផលិតករក្នុងផលិតកម្មស្រូវជាលក្ខណៈគ្រួសារ បានអនុវត្តតៗគ្នាជាច្រើនតំណដំយូរលង់ណាស់មកហើយ ដោយគ្មានឯកសារច្បាស់លាស់។

២-ការធ្វើស្រែជាលក្ខណៈប្រពៃណីនៅលើដីដូនតា ឬ គ្រួសារបានចែកតៗគ្នា មិនបានស្គាល់ច្បាស់ពីប្រភេទដី ដោយគ្រាន់តែដឹងថានេះជាប្រភេទដីខ្សាច់ ឬ ដីល្បាយ ឬ ជាដីឥដ្ឋប៉ុណ្ណោះ ហើយគ្រាន់តែធ្វើឧបករណ៍កសិកម្ម ( នង្គ័ល រនាស់.....) តម្រូវទៅតាមប្រភេទដីសំរាប់ជាមធ្យោបាយងាយស្រួលក្នុងការភ្ជួររាស់ដោយកំលាំងអូសទាញ។

៣-សកម្មភាពបង្កបង្កើនផលនេះ ធ្វើអោយប៉ះពាល់ដល់ការរិចរិលដីជាបន្តបន្ទាប់ ឈានដល់ការបោះបង់ទៅរកទីកន្លែងថ្មី ( ដីថ្មី) ដើម្បីបន្តសកម្មភាពក្នុងការធ្វើស្រែចំការ។

៤-ការផ្សព្វផ្សាយពីអត្តសញ្ញាណដី ដើម្បីគ្រប់គ្រងកែលំអ ដល់កសិករនៅមានកំរិត។

## IV-ទិន្នន័យដើម្បីកំណត់អត្តសញ្ញាណដី សំរាប់ផលិតកម្មដំណាំស្រូវ

### ក. ភូមិសណ្ឋានវិទ្យា និងដីសំរាប់ដំណាំស្រូវនៅកម្ពុជា

តាមលក្ខណៈរូបសាស្ត្រគេអាចចែកតំបន់ដាំដុះស្រូវជាបីតំបន់:

១-ដីដែលវិវត្តនៅលើវាលទំនាបនៃល្បាប់ចាស់ (Old alluvial) និងល្បាប់ (Colluvial)។

២-ដីដែលវិវត្តទាំងស្រុងពីថ្មមេនៅខាងក្រោម (Parent material) ។

៣-ដីដែលវិវត្តននៅលើវាលទំនាបលិចទឹកទន្លេ ឬ បឹងដែលទទួលកំណជីល្បាប់ (Alluvial) ជារៀងរាល់ឆ្នាំ។

### ខ. ដីដែលមានប្រភពពីដីល្បាប់ចាស់(Old Alluvial) និងទំនាបល្បាប់(Colluvial)

- ប្រភេទដីនេះជាដីដែលកើតមាននៅគ្រប់បណ្តាខេត្តផលិតស្រូវនៅក្នុងប្រទេសកម្ពុជា។ តំបន់នេះកាលពីដើមវាជាស្ទឹង និងបឹង ឬ វាលទំនាបលិចទឹក ហើយឥឡូវនេះវាស្ថិតនៅខ្ពស់ជាងនីវ៉ូទឹកជំនន់ធម្មតា ដែលទទួលការលិចលង់ដោយសារទឹកជំនន់ប្លែកពីធម្មតាក្នុងរយៈពេលមួយខ្លី។ ដីចាស់ៗខ្ពស់ បង្កអោយកើតជាខ្ពង់រាបធំៗ។ សណ្ឋានដីរបៀបនេះ កើតឡើងនៅក្នុងបណ្តាខេត្តជាច្រើននៅក្នុងប្រទេសកម្ពុជា ។
- នៅក្នុងប្រទេសកម្ពុជា ការកើតទីទំនាបល្បាប់ (Colluvial) មានសារៈសំខាន់នៅក្នុងតំបន់ដាំដុះដំណាំស្រូវណាស់ជាពិសេស នៅក្នុងខេត្តបាត់ដំបង, បន្ទាយមានជ័យ, សៀមរាប និងផ្នែកខ្លះនៃខេត្តពោធិសាត់, កំពង់ធំ, កំពង់ចាម និងស្វាយរៀង។ នៅក្នុងតំបន់មួយចំនួនដែលពីដើមជាភ្នំ ឬ កូនភ្នំត្រូវបានសឹករិចរិលអស់ទៅហើយ ហើយបង្កើតបានជាខ្ពង់រាបដែលមានសណ្ឋានខ្ពស់ទាបៗដូចទឹករលក ។

### គ. ដីដែលបានវិវត្តទាំងស្រុងពីសិលាមេខាងក្រោម(Parent material)

#### ១_ទីវាលទំនាបលិចទឹកបត់ស៊ែន

កើតឡើងនៅតាមបណ្តោយទឹកទន្លេ ដៃទន្លេ តំបន់ក្រោយច្រាំងទន្លេ និងអាងទឹក។ ដីទំនាបនេះត្រូវលិចទឹកនៅរដូវវស្សាពេលទឹកជំនន់តាមទន្លេ, ព្រែក។ គេប្រើប្រាស់វាលទំនាបនេះ ( តំបន់ច្រាំង និងក្រោយច្រាំងទន្លេ) សំរាប់



ធ្វើដំណាំបន្លែ, ដំណាំសំខាន់ៗសំរាប់សេដ្ឋកិច្ច ឬ ក៏សំរាប់ផលិតកម្មដំណាំស្រូវផងដែរ ដោយគេមានសំណង់ធារាសាស្ត្រ សំរាប់ធ្វើការស្រោចស្រព។ សណ្ឋានដីនេះ ត្រូវបានគេប្រទះឃើញមានជាច្រើនកន្លែង នៅតាមបណ្តោយដងទន្លេមេគង្គ និងតាមផ្នែកជាច្រើននៃដងទន្លេបាសាក់ ព្រមទាំងបណ្តោយផ្លូវទឹកជាច្រើនទៀត នៅក្នុងប្រទេស។ សណ្ឋានដីលាតសន្ធឹងជួបជាមួយនឹងវាលទំនាបលិចទឹកធំៗ នៅពាក់កណ្តាលនៃភាគខាងត្បូងនៃខេត្តតាកែវ, កណ្តាល និង ព្រៃវែង ហើយជួបនឹងវាលទំនាបលិចទឹកនៃបឹងទន្លេសាប។

### ២_វាលទំនាបលិចទឹកធំ

ជាសណ្ឋានដីសំខាន់មួយនៅក្នុងប្រទេសកម្ពុជា ដែលត្រូវញែកអោយដាច់ពីវាលទំនាបលិចទឹកបត់បែន។ វាលទំនាបនេះអាចលាតសន្ធឹងពី ១៥ គម ទៅ ២០ គម ពីដៃទន្លេក្នុងតំបន់ខ្លះនៃខេត្តតាកែវ។ ក្នុងមួយឆ្នាំៗ វាលទំនាបត្រូវជន់លិចក្នុងជំរៅ ២ ម អស់រយៈពេលវែង។ ផ្ទៃដីទាំងនេះមានប្រហែលពាក់កណ្តាលភាគខាងត្បូងនៃខេត្តកណ្តាល និងព្រៃវែង។

### ៣_វាលទំនាបលិចទឹកដែលនៅជុំវិញបឹងទន្លេសាប

គឺជាវាលទំនាបមានការវិវត្តន៍យ៉ាងល្អ។ ជាទូទៅ មានផ្ទៃដីរាបស្មើហើយដីមានលក្ខណៈម៉ដ្ឋល្អផង។ ជាវាលទំនាបលិចទឹកឡាគូសស្ទ្រីន (Lacustrine Floodplain) ដែលមានលក្ខណៈរួមជាច្រើនដូចគ្នានឹងវាលទំនាបធំៗដែរ (Expansive Floodplains)។ កំណកំណើតលក្ខណៈដីនេះ អាស្រ័យទៅលើសិលាវិទ្យានៃតំបន់ជុំវិញ និងរបបទឹកដែលហូរចូល និងចេញនៃបឹងទន្លេសាបជារៀងរាល់ឆ្នាំ ដោយនាំកករដីចូលទៅក្នុងបឹង។ ក្រៅពីនេះនៅមានផ្លូវទឹកតូចៗ និងមធ្យមច្រើនទៀតដែលបានហូរចូលថែមទៀតទៅក្នុងបឹងនោះ។ ការហូរត្រឡប់របស់ទឹកទន្លេ កករដីដែលមានលក្ខណៈជាខ្សាច់ម៉ដ្ឋ ឬ ល្បាយម៉ដ្ឋ បង្កើតបានជាស្រទាប់ដីផ្សេងៗគ្នា។

## V-ដំណើរការសំរាប់ធ្វើចំណាត់ថ្នាក់ដី

ខាងក្រោមនេះ បង្ហាញពីទស្សនៈទូទៅអំពីក្រុមការពិពណ៌នា អំពីអនុក្រុមដី ការប៉ាន់ស្មាននៃផ្ទៃដីដាំស្រូវក្នុងប្រទេសកម្ពុជា:

| ទស្សនៈអំពីក្រុមដី និងការពិពណ៌នាអំពីអនុក្រុម | ភាគរយនៃផ្ទៃដីដាំស្រូវ |
|---|---|
| ក្រុម ០ ដីព្រៃខ្មែរ :<br>ដីកើតមានឡើងនៅលើល្បាប់ចាស់(Alluvial) ឬ ដីទំនាប (alluvial/colluvial) ដែលមានលក្ខណៈជាទ្រាប់ខ្សាច់ជំរៅជ្រៅជាង ៥០ ស.ម។<br>អនុក្រុមខ្សាច់ម៉ដ្ឋ: ដីខ្សាច់ច្រើនតែជាប្រភេទខ្សាច់ម៉ដ្ឋ( គ្រាប់ខ្សាច់មានអង្កត់ផ្ចិតតូចជាង ០.៥ ម.ម)។<br>អនុក្រុមខ្សាច់គ្រើម: ដីខ្សាច់ច្រើនតែជាប្រភេទខ្សាច់គ្រើម( គ្រាប់ខ្សាច់មានអង្កត់ផ្ចិតធំជាង ០.៥ ម.ម)។ | ១០-១២ %<br>ជីនឹងត្រូវបានអោយប្រើប្រាស់តាមកំរិតក្នុង ១ ហ.តៈ<br>- N អាសូត : ២៨-៥២ គ.ក្រ<br>- $P_2O_5$ ផូស្វាត : ១២-១៥ គ.ក្រ<br>- $K_2O$ ប៉ូតាស្យូម : ១០-២០ គ.ក្រ<br>- S ស្ពាន់ធ័រ : ០-២០ គ.ក្រ |



| | |
|---|---|
| **ក្រុម ១ ដីប្រទះឡាង**<br>ដីដែលកើតឡើងនៅលើដីល្បាប់(ដីល្បាប់ចាស់(Alluvial) ឬវាលទំនាប (Alluvial/colluvial) ដែលមានស្រទាប់ខាងលើជាខ្សាច់កំរាស់តិចជាង ៤០ ស.ម នៅពីលើដីស្រទាប់ក្រោមដែលមានលក្ខណៈជាដីល្បាយឥដ្ឋ ។<br>អនុក្រុមរាក់: ជំរៅដីនៅស្រទាប់លើគឺ ២០ ស.ម ឬ រាក់ជាងហើយលក្ខណៈនៃដីស្រទាប់ក្រោមគឺដីឥដ្ឋ ឬ មានស្រទាប់រឹងមួយកើតឡើងក្នុងជំរៅ ២០ ស.ម ពីផ្ទៃខាងលើ ។<br>អនុក្រុមដីល្បាយស្រទាប់ក្រោម: ដីស្រទាប់ក្រោមមានល្បាយ និងពុំមានវត្តមាននៃស្រទាប់រឹងមួយនៅជំរៅ ២០ ស.ម ពីផ្ទៃខាងលើឡើយ ។<br>អនុក្រុមដីឥដ្ឋស្រទាប់ក្រោម: ដីស្រទាប់លើមានជំរៅ ២០ ស.ម ឬជ្រៅជាង និងពុំមានវត្តមាននៃស្រទាប់រឹងក្នុងជំរៅ ២០ ស.ម ឡើយហើយដីស្រទាប់ក្រោមមានលក្ខណៈជាដីឥដ្ឋ ។ | ២៣-៣០%<br>ជីធម្មជាតិ និងជីគីមី គួរដាក់នៅស្រែសន្ទូងតាមកំរិតដូចតទៅក្នុង ១ ហ.តៈ<br>- N អាសូត : ៤០-៦០ គ.ក្រ<br>- $P_2O_5$ ផូស្វាត : ២៣-២៩ គ.ក្រ<br>- $K_2O$ ប៉ូតាស្យូម : ២០-៣០ គ.ក្រ<br>- S ស្ពាន់ធ័រ : 0-១០ គ.ក្រ |
| **ក្រុមដី ២ ឡាបានសៀក**<br>ជាដីដែលកើតឡើងនៅលើចង្កេះកូនភ្នំ ឬ ភ្នំដែលមានពណ៌ពីក្រហមទៅត្នោតក្រហម ។ ដីផ្ទៃខាងលើជាដីឥដ្ឋដែលមានរចនាសម្ព័ន្ធជាគ្រាប់ល្អិតៗហើយជាដីឥដ្ឋស្រទាប់ក្រោម ។<br>អនុក្រុមផេត្រូហ្វេរិចៈ ស្រទាប់ថ្មដែករឹងផ្គុំគ្នាមានកំរាស់ជាច្រើនសង់ទីម៉ែត្រមានវត្តមាននៅក្នុងដីស្រទាប់លើជំរៅ ៥០ ស.ម ។<br>អនុក្រុមមិនមែនផេត្រូហ្វេរិចៈ ស្រទាប់ថ្មដែករឹង ពុំមានវត្តមាននៅក្នុងដីស្រទាប់លើកំរាស់ ៥០ ស.ម ទេ ។ | ១%<br>ជីគួរដាក់តាមកំរិត ដូចខាងក្រោមក្នុង ១ ហ.តៈ<br>- N អាសូត : ៤៨-៩៤ គ.ក្រ<br>- $P_2O_5$ ផូស្វាត : ៤៦-៦៣ គ.ក្រ<br>- $K_2O$ ប៉ូតាស្យូម : 0-២២ គ.ក្រ<br>- កំរិតទាបត្រូវប្រើចំពោះស្រូវប្រពៃណី កំរិតខ្ពស់សំរាប់ពូជទំនើប ។ |
| **ក្រុម ៣ ដីអូរវ៉ូង**<br>ជាដីដែលកើតនៅលើតំបន់ល្បាប់ចាស់ (Old alluvial) ដែលស្រទាប់លើមានប្រភេទពីល្បាប់ទៅដីឥដ្ឋកំរាស់តិចជាង៤០ស.មស្ថិតនៅខាងលើដីស្រទាប់ខាងក្រោមជាដីខ្សាច់ក្រាស់ជាង ១០ ស.ម ។<br>អនុក្រុមអូរវ៉ូង: អនុក្រុមផ្សេងៗមិនទាន់បានកណត់នៅឡើយ ។ | ១-២%<br>ជីធម្មជាតិ និងជីគីមីគួរប្រើប្រាស់ក្នុងស្រែសន្ទូងតាមកំរិតក្នុង១ ហ.តៈ<br>- N អាសូត : ៣៦-៧០ គ.ក្រ<br>- $P_2O_5$ ផូស្វាត : ២៣-៤០ គ.ក្រ<br>- $K_2O$ ប៉ូតាស្យូម : 0-៣០ គ.ក្រ<br>- S ស្ពាន់ធ័រ : 0-១៥ គ.ក្រ |







| | |
|---|---|
| ក្រុម ៤ ដីក្រគរ<br>ជាដីដែលមានលក្ខណៈជាដីល្បាយ ឬ ដីឥដ្ឋពណ៌ប្រផេះទៅត្នោត ប៉ុន្តែមិនមែនពណ៌ប្រផេះក្រម៉ៅ ឬ ខ្មៅទេ ដីស្រទាប់លើមានប្រភេទជាដីឥដ្ឋ ឬ ល្បាយ នៅពីលើដីស្រទាប់ក្រោមដែលមានលក្ខណៈជាដីឥដ្ឋដែលកើតឡើងនៅលើវាលទំនាបលិចទឹកសកម្ម។ វត្ថុមានខ្សាច់អាចកើតឡើងផងដែរនៅក្នុងដីស្រទាប់ក្រោម។<br>អនុក្រុមបែកក្រហែងៈ ស្នាមប្រេះក្រហែងពីមធ្យមទៅធំ កើតឡើងនៅក្នុងផ្ទៃខាងលើ នៅពេលវាស្ងួត។ ស្នាមប្រេះក្រហែងចាក់ជ្រៅជាង ៥ ស.ម ទៅក្នុងដីនៅពេលស្ងួត ។<br>អនុក្រុមមិនបែកក្រហែងៈ ស្នាមប្រេះក្រហែងមិនត្រូវបានកើតឡើងនៅក្នុងផ្ទៃដីខាងលើទេ ពេលវាស្ងួត ឬ កើតមានតែស្នាមប្រេះក្រហែងដែលមិនជ្រៅជាង ៥ ស.ម ទៅក្នុងដីតែប៉ុណ្ណោះ។ | ១៥%<br>ជីដែលត្រូវដាក់តាមកំរិតក្នុង ១ ហ.តៈ<br>- N អាសូត : ៦៦-១២០ គ.ក្រ<br>- $P_2O_5$ ផូស្វាត : ២៣ - ៣៤ គ.ក្រ |
| ក្រុម ៥ ដីបាកាន<br>ជាដីដែលកើតឡើងនៅលើវាលទំនាប(Alluvial/colluvial) ឬនៅលើដីល្បាប់ (Alluvial)ចាស់ ដែលមានស្រទាប់លើជាដីឥដ្ឋ ឬ ល្បាយ តែមិនប្រេះក្រហែង ឬ មានតែស្នាមប្រេះនៅផ្ទៃខាងលើរាក់ៗតែប៉ុណ្ណោះ ដែលកើតមានឡើងនៅលើដីស្រទាប់ក្រោម ដែលមានលក្ខណៈជាដីឥដ្ឋ ឬ ល្បាយពណ៌ចំរុះ។<br>អនុក្រុមបាកានៈ អនុក្រុមដោយឡែកៗមិនទាន់ត្រូវបានកំណត់ទេ។ | ១០ - ១៥%<br>ជីធម្មជាតិនិងជីសរីរាង្គត្រូវបានដាក់ក្នុងស្រែសន្ទូងតាមកំរិត ១ ហ.តៈ<br>- N អាសូត : ៣០-៧០ គ.ក្រ<br>- $P_2O_5$ ផូស្វាត : ២០-៣០ គ.ក្រ<br>- $K_2O$ ប៉ូតាស្យូម : ០-១៥ គ.ក្រ<br>- S ស្ពាន់ធ័រ : ០-១៥ គ.ក្រ |
| ក្រុម ៦ ដីក្បាលពោធិ៍<br>ជាដីមានស្រទាប់លើ ជាដីឥដ្ឋពណ៌ប្រផេះចាស់ទៅពណ៌ខ្មៅ ដែលកើតមានស្នាមប្រេះក្រហែងធំៗហើយជ្រៅ ស្ថិតនៅពីលើស្រទាប់ដីក្រោមជាដីឥដ្ឋដែលកើតឡើងនៅលើវាលទំនាបលិចទឹកសកម្ម។ វត្ថុមានខ្សាច់នៅក្នុងដីស្រទាប់ក្រោម អាចកើតមានឡើង។<br>អនុក្រុមស្សូនិចៈ តំលៃ ផះ របស់ដីទាបជាង ៤.០<br>អនុក្រុមមិនស្សូនិចៈ តំលៃ ផះ របស់ដីខ្ពស់ជាង ៤.០ | ១៣%<br>ត្រូវដាក់ជីតាមកំរិត ១ ហ.តៈ<br>- N អាសូត : ៦៦-១២០ គ.ក្រ<br>- $P_2O_5$ ផូស្វាត : ២៣-៣៤ គ.ក្រ |
| ក្រុម ៧ ដីកៀនស្វាយ<br>ជាដីឥដ្ឋ ឬ ល្បាយពណ៌ត្នោត( ទាំងស្រទាប់លើនិងស្រទាប់ក្រោម) ជាមួយនឹងប្រូហ្វីលដីដែលវិវត្តខ្សោយ ជាដីដែលបានកើតឡើងនៅលើតំបន់ច្រាំងទន្លេ និងនៅលើដីជំរាលច្រាំងទន្លេ។<br>អនុក្រុមកៀនស្វាយៈ អនុក្រុមដោយឡែកៗមិនត្រូវបានកំណត់ទេ។ | ២%<br>ត្រូវដាក់ជីទៅតាមកំរិត១ ហ.តៈ<br>- N អាសូត : ៦២-១២០ គ.ក្រ<br>- $P_2O_5$ ផូស្វាត : ០-៣៤ គ.ក្រ |

<table>
<tr>
<td>

**ក្រុម ៨ ដីទួលសំរោង**<br>ជាដីដែលកើតឡើងនៅលើដីល្បាប់ចាស់ (Alluvial) ឬ នៅលើវាលទំនាប (Alluvial/colluvial) ដែលមានដីស្រទាប់លើជាដីឥដ ឬ ល្បាយ ដែលកើតមានស្នាមប្រេះធំៗចាក់ចូលទៅក្នុងដីជ្រៅជាង ៥ ស.ម ស្ថិតនៅលើដីស្រទាប់ក្រោមដែលជាដីឥដ្ឋ ឬ ល្បាយ ។ ពណ៌នៃដីស្រទាប់លើគឺប្រផេះ ឬ ត្នោត ប៉ុន្តែមិនមែនប្រផេះដិត ឬ ខ្មៅឡើយ ។<br>អនុក្រុមពណ៌ត្នោតៈ ពណ៌នៃផ្ទៃដីខាងលេនៅពេលសើមគឺ ពណ៌ត្នោត ឬ ពណ៌ត្នោតភ្លឺ ។<br>អនុក្រុមពណ៌ប្រផេះ: ពណ៌នៃផ្ទៃដីខាងលើនៅពេលសើមគឺ ពណ៌ប្រផេះ ឬ ប្រផេះភ្លឺ ។

</td>
<td>

៧-១០%<br>ដាក់ជីគីមីនៅក្នុងស្រែសន្ទូង ១ ហ.តៈ<br>- N អាសូត : ៦២ - ១០០ គ.ក្រ<br>- $P_2O_5$ ផូស្វាត : ៤០ - ៥២ គ.ក្រ<br>គីរីតទាបប្រើសំរាប់ពូជប្រពៃណីឬកន្លែងដែលពុំមានលទ្ធភាពទឹក។ គីរីតខ្ពស់ជាងប្រើសំរាប់ស្រូវនាំចូល ឬ កន្លែងដែលមានលទ្ធភាពទឹក ។

</td>
</tr>
<tr>
<td>

**ក្រុម ៩ ដីគោកត្រប់**<br>ជាដីដែលកើតឡើងនៅលើដីល្បាប់ចាស់ ដែលមានស្រទាប់ដីខាងលើពណ៌ប្រផេះក្រម៉ៅខ្លាំងទៅពណ៌ខ្មៅ ហើយមានលក្ខណៈជាដីឥដ្ឋ ឬ ល្បាយស្ថិតនៅលើស្រទាប់ដីខាងក្រោមពណ៌ប្រផេះស្រាល ឬ ពណ៌ត្នោត ដែលមានលក្ខណៈជាដីឥដ្ឋ ឬ ល្បាយ ។<br>អនុក្រុមខ្សត់ជីជាតិៈ ទិន្នផលដែលមិនដាក់ជីនៅលើវាលស្រែរបស់កសិករទាបជាង ១២០០ គ.ក្រ ក្នុង ១ ហ.ត ជាទូទៅប្រហែល ៥០០ ទៅ ៨០០ គ.ក្រ ក្នុង ១ ហ.ត ។ ស្លឹកស្រូវដែលគេដាំនៅលើដីនេះជាញឹកញាប់កើតមានពណ៌ច្រែះស្រាល ទៅពណ៌ច្រែះចាស់ ។<br>អនុក្រុមមានជីជាតិៈ ទិន្នផលស្រូវដែលមិនដាក់ជីនៅលើស្រែរបស់កសិករលើសពី ១២០០ គ.ក្រ ក្នុង ១ ហ.ត ជាទូទៅច្រើនជាង ១៥០០ គ.ក្រ ក្នុង ១ ហ.ត ហើយមិនកើតមានពណ៌ដូចខាងលើនៅលើដំណាំស្រូវទេ ។

</td>
<td>

៥%<br>ដាក់ជីក្នុងស្រែសន្ទូងតាមរូបមន្តក្នុង១ ហ.តៈ<br>- អនុក្រុមដីខ្សត់ជីជាតិៈ<br>- N អាសូត : ៤២-៩៤ គ.ក្រ<br>- $P_2O_5$ ផូស្វាត : ៣៥-៦៣ គ.ក្រ<br>- $K_2O$ ប៉ូតាស្យូម : ១៥-២២ គ.ក្រ<br>- អនុក្រុមដីខ្សត់ជីជាតិ :<br>- N អាសូត : ៦២-១០០ គ.ក្រ<br>- $P_2O_5$ ផូស្វាត : ២៣-៣៤ គ.ក្រ

</td>
</tr>
<tr>
<td>

**ក្រុម ១០ ដីកំពង់សៀម**<br>ជាដីដែលកើតឡើងនៅក្នុងផ្នែកទំនាបនៃតំបន់ សណ្ឋានដីខ្ពង់រាបប្រែប្រួល ដែលស្រទាប់លើមានលក្ខណៈជាដីឥដ្ឋពណ៌ខ្មៅ ឬ ប្រផេះដិត ហើយបង្កើតអោយមានស្នាមប្រេះក្រហែងដ៏ធំ ហើយជ្រៅស្ថិតនៅពីលើដីស្រទាប់ក្រោមដែលមានប្រភេទជាដីឥដ្ឋ ។<br>អនុក្រុមមានគ្រួស (Gravelly)ៈ មានវត្តមានគ្រួសតូចៗពណ៌ខ្មៅ និងពណ៌ត្នោត កើតមានឡើងនៅក្នុងប្រូហ្វិលដីទាំងមូល ។<br>អនុក្រុមគ្មានគ្រួសៈ ពុំមានវត្តមាននៃគ្រួសនៅក្នុងស្រទាប់ដីឡើយ ។ គ្រួសតូចៗអាចមានតែនៅស្រទាប់ក្រោមខ្លះៗប៉ុណ្ណោះ ។ ពុំមានវត្តមាននៅផ្ទៃលើនៃដីឡើយ ។

</td>
<td>

១-២%<br>ជីត្រូវដាក់តាមកំណត់ ១ ហ.តៈ<br>- N អាសូត : ៦៦-១១០ គ.ក្រ<br>- $P_2O_5$ ផូស្វាត : ២៣-៤០ គ.ក្រ<br>គីរីតទាបប្រើសំរាប់ពូជប្រពៃណី ឬ កន្លែងដែលពុំមានលទ្ធភាពទឹក។ គីរីតខ្ពស់ជាងប្រើសំរាប់ស្រូវនាំចូល ឬ កន្លែងដែលមានលទ្ធភាពទឹក ។

</td>
</tr>
</table>



# ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ តាមគោលការណ៍ធម្មជាតិ
# (Rice Soil Identification)

## I- សេចក្តីផ្តើម

ប្រព័ន្ធប្រពលវប្បកម្មដំ ណាំស្រូវតាមគោលការណ៍ធម្មជាតិ បានធ្វើការអភិវឌ្ឍន៍ដំបូងនៅក្នុងប្រទេស ម៉ាដាហ្គាស្កា នាទសវត្សឆ្នាំ៨០ដោយលោក ហង់រី ដឺឡូឡានី (HENRI DELAULANI) តាមរយៈការប្រមូលបទពិសោធពីកសិករ និងដោយមានការជួយជ្រោមជ្រែងពី CIIFAD (Cornel International Institute For Food and Agriculture Development) ជាពិសេសលោកសាស្ត្រាចារ្យ NORMAN UPHOFF ហើយត្រូវបានផ្សព្វផ្សាយដល់ប្រទេសផ្សេងទៀត នៅក្នុងឆ្នាំ ១៩៩៩ ។ រហូតមកទល់បច្ចុប្បន្នមានប្រទេសចំនួន ២២ ហើយ ដែលបាននឹងកំពុងអនុវត្តនូវបច្ចេកវិទ្យានេះ ។

នៅកម្ពុជាក៏បានចាប់ផ្តើមធ្វើការណែនាំពីប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវនេះតាមរយៈមជ្ឈមណ្ឌលសិក្សា និង អភិវឌ្ឍកសិកម្មកម្ពុជា (CEDAC) នៅក្នុងឆ្នាំ ១៩៩៩ នៅលើស្រែកសិករចំនួន ២៨ គ្រួសារ ព្រមទាំងទទួលបាន លទ្ធផលជាវិជ្ជមាន ដោយមានការចំណាយទុនតិច និងទទួលបានទិន្នផលខ្ពស់ ។ រហូតមកទល់ឆ្នាំ ២០០៥ មាន កសិករចំនួនច្រើបានយល់ដឹង និងអនុវត្តតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ តាមគោលការណ៍ធម្មជាតិនេះ នៅក្នុង ២០ ខេត្ត-ក្រុង (មានកសិករប្រមាណ ៤ ម៉ឺនគ្រួសារ នៅក្នុងភូមិប្រមាណ ២០០០ ភូមិ) ។

ការអនុវត្តនូវប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ មានលក្ខណៈសមស្របណាស់ទៅនឹង កសិករដែលមានដីស្រែតូចៗប្រមាណពី ០,៥០ ហិកតារ ទៅ ១,៥០ ហិកតារ ដែលពីមុនគាត់បានធ្វើស្រែមានលក្ខណៈ ប្រពៃណីតែម្តងក្នុង ១ ឆ្នាំហើយទទួលបានទិន្នផលទាប ។ ការងារនេះមានសារៈសំខាន់ទៅលើផលិតកម្មដំណាំស្រូវ ជាលក្ខណៈគ្រួសារ ដែលមានការចំណាយទុនតិច និងទទួលបានទិន្នផលខ្ពស់ ហើយម្យ៉ាងទៀតកសិករមានលទ្ធភាព បង្កើនផ្ទៃដីដាំដុះបាន ២ ដង ក្នុង ១ ឆ្នាំ លើផ្ទៃដីដដែលព្រមទាំងរក្សាបាននូវបរិស្ថានល្អថែមទៀត ។

## II- គោលបំណង

១-បង្កើនសមត្ថភាពដល់កសិករដាំដំណាំស្រូឱ្យបានកាន់តែប្រសើរ លើការអនុវត្តន៏បច្ចេកទេសក្នុងផលិតកម្មរបស់ គាត់បានសមស្រប ដែលរក្សាបានល្អនូវបរិស្ថាន ។

២-បង្កើនប្រាក់ចំណូលឱ្យបានកាន់តែខ្ពស់ ដោយកាត់បន្ថយការចំណាយទៅលើការប្រើប្រាស់ជីគីមី ដែលមានតំលៃខ្ពស់ និងដោយការលក់ផលិតផលស្រូវដែលមានគុណភាពល្អ ។

៣-បង្កើនចំណេះដឹងក្នុងការធ្វើផែនការដាំដុះស្រូវ តាមគោលការណ៏ធម្មជាតឱ្យទទួលផលកាន់តែខ្ពស់ ហើយនឹង ធ្វើស្រែបាន ២ ដងក្នុង ១ ឆ្នាំ ។



រៀបចំដោយលោក ជិត សុវណ្ណ និងស្រី ស្រស់ធីតា

## III-ការអនុវត្តន៍ដាំដុះស្រូវរបស់កសិករកន្លងមក

១-ជាទូទៅការធ្វើស្រែមានលក្ខណៈជាប្រពៃណី ហើយធ្វើតែម្តងក្នុង ១ ឆ្នាំ ទទួលបានទិន្នផលទាប ។

២-ការប្រើប្រាស់ពូជមិនសូវមានគុណភាព ។

៣-ការប្រើប្រាស់ជីគីមីមិនទាន់បានសមស្រប( មិនស្គាល់ជីច្បាស់,ដាក់ជីជួនច្រើន ឬ តិចពេក,ដាក់ជីមិនចំពេលដំណាំត្រូវការ.) ។

៤-ភ្លេច ឬ មិនយកចិត្តទុកដាក់ក្នុងការប្រមូលសារធាតុសរីរាង្គ ដែលមានសារៈសំខាន់សំរាប់ធ្វើជីកំប៉ុស្ត ក្នុងការបង្កើនផលស្រូវ និងកែលំអដីបានល្អ និងមាននិរន្តរភាព ។

៥-ការគ្រប់គ្រងទឹកសំរាប់ដំណាំស្រូវនៅមានការខ្វះខាតច្រើន (ពឹងតែលើទឹកភ្លៀង និងខ្វះបច្ចេកទេស) ។

៦-អនុវត្តការសាបព្រោះ ដកស្ទូងមិនទាន់បានត្រឹមត្រូវតាមបច្ចេកទេស(ពូជច្រើន,សំណាបចាស់ជ្រុល,ស្ទូងដោយចាប់ធំៗ,ដកសំណាបបោកធ្វើឱ្យបាក់ដើមសំណាប និងដាច់ឫស, ចងតឹង និងផ្អាប់កណ្តាប់ទុកយូរ, ស្ទូងដោតជ្រៅពេក ។ល ។

៧-ការប្រមូលផលច្រូតកាត់ បោកបែន និងទុកដាក់ផលស្រូវនៅមិនទាន់បានសមស្រប ធ្វើឱ្យបាត់បង់ផលស្រូវ និងខូចគុណភាព ។

## IV-បច្ចេកទេសនៃការអនុវត្តន៍ប្រព័ន្ធប្រពលវប្បកម្ម ដំណាំស្រូវតាមគោលការណ៍ធម្មជាតិ

### ១-ការយល់ដឹងពីដំណាក់កាលលូតលាស់របស់ដំណាំស្រូវ

ការយល់ដឹងពីដំណាក់កាលលូតលាស់របស់ដំណាំស្រូវមានសារៈសំខាន់ណាស់ ដើម្បីគ្រប់គ្រងឱ្យបានត្រឹមត្រូវតាមបច្ចេកទេស និងជៀសវាងបាននូវការចំណាយច្រើនឥតប្រយោជន៍ ព្រមទាំងធ្វើឱ្យបាត់បង់នូវទិន្នផលស្រូវដោយកត្តាផ្សេងៗ ។

ការលូតលាស់របស់ដំណាំស្រូវ ត្រូវចែកជា ៣ វគ្គសំខាន់:

ក-វគ្គលូតលាស់: វគ្គលូតលាស់នេះមានរយៈពេលខុសៗគ្នា អាស្រ័យតាមប្រភេទស្រូវ( ស្រូវប្រកាន់រដូវ ឬ មិនប្រកាន់រដូវ) និងអាយុកាលនៃពូជស្រូវនីមួយៗ ហើយចែកចេញជា ៤ ដំណាក់កាលគឺ:

- ដំណាក់កាលដុះពន្លក (ចាប់ពីគ្រាប់ស្រូវដល់ស្រូវដុះពន្លកស្លឹកទី ១) ។
- ដំណាក់កាលសំណាប (ចាប់ពីស្រូវដុះស្លឹកទី ១ ដល់ស្រូវចាប់បែកគុម្ព) ។
- ដំណាក់កាលបែកគុម្ព (ចាប់ពីស្រូវបែកគុម្ពដំបូង ដល់ស្រូវបែកគុម្ពពេញទំហឹង) ។
- ដំណាក់កាលពន្លូតដើម (ចាប់ពីស្រូវបែកគុម្ពពេញទំហឹង ដល់ស្រូវចាប់ផ្តើមពន្លកកកួរ) ។

ខ-វគ្គបង្កបង្កើតផល: វគ្គបង្កបង្កើតផលមានរយៈពេល ៣៥ ថ្ងៃ និងចែកចេញជា ៣ ដំណាក់កាលគឺ:

- ដំណាក់កាលពន្លកកកួរ (ចាប់ពីពន្លកកកួរ ដល់ស្រូវផើម) ។
- ដំណាក់កាលចេញកួរ (ចាប់ពីស្រូវផើម ដល់ស្រូវចេញកួរផុតពីស្លឹកទង់ជ័យ) ។
- ដំណាក់កាលចេញផ្កា (ចាប់ពីស្រូវចេញកួរផុត ដល់ស្រូវរោយលំអង) ។

គ-វគ្គទុំៈ វគ្គទុំមានរយៈពេល ៣ ថ្ងៃ និងចែកចេញជា ៣ ដំណាក់កាលគឺៈ

- ដំណាក់កាលដាក់ទឹកដោះ ។
- ដំណាក់កាលដាក់ម្សៅ ។
- ដំណាក់កាលទុំពេញលេញ ។

## ២_ការជ្រើសរើសទីកន្លែងដាំដុះស្រូវ

- ស្រែត្រូវមានប្រភពទឹកសំរាប់ធ្វើការស្រោចស្រពទាំងរដូវប្រាំង និងរដូវវស្សា ។
- ដីស្រែត្រូវមានជីជាតិល្អ ។
- យកល្អ ស្រែត្រូវនៅក្បែរផ្លូវ សំរួលដល់ការថែទាំ និងដឹកជញ្ជូន ។
- ស្រែត្រូវមានផ្ទៃដីរាបស្មើល្អ ។

## ៣_ការជ្រើសរើសពូជ

ការជ្រើសរើសពូជមានសារៈសំខាន់ណាស់ ហើយក៏ជាកត្តាកំណត់ក្នុងការប្រមូលផលស្រូវផង ។ ដូចនេះពូជស្រូវត្រូវមានលក្ខណៈ

- ពូជស្រូវធន់នឹងជំងឺ និងសត្វល្អិត ។
- ពូជស្រូវផ្តល់ទិន្នផលខ្ពស់ ។
- ពូជស្រូវសុទ្ធនិងមានដំណុះគ្រាប់ពី ៨៥% ឡើងទៅ ។
- ពូជស្រូវមានគុណភាពអង្ករល្អ ( មានរសជាតិ និងតំរូវការទីផ្សារ) ។
- ពូជស្រូវស្រាល ឬ ស្រូវកណ្តាល ។



## ៤_ថ្នាលសំណាប

- អនុវត្តធ្វើថ្នាលសំណាបគោក និងជិតប្រភពទឹក ។
- ថ្នាលសំណាបត្រូវមានជីជាតិល្អ និងរាបស្មើ ។
- ត្រូវភ្ជួររាស់ឱ្យបានច្រើនសារក្នុងជំរៅ ១៥ ស.ម ។
- ត្រូវធ្វើជារង ១,៥០ម- ២ ,០០ម ដោយមានចង្អូរបណ្តោយរងមិនកំណត់ ( តាមលទ្ធភាព) ។
- ត្រូវដាក់ជីកំប៉ុស្តិពី ២-៣ គក្រ ក្នុង ១ម២ ។
- ត្រូវធ្វើថ្នាលសំណាបពី ២០០-២៥០ម២ សំរាប់ស្ទូងលើផ្ទៃដី ១ ហិកតារ
- ថ្នាលសំណាបត្រូវនៅឆ្ងាយពីម្លប់ ។

សេចក្តីបញ្ជាក់ៈ

ការភ្ជួររាស់ត្រូវធ្វើឱ្យបានច្រើនសា ដើម្បីច្របល់ដីឱ្យបានសព្វល្អ ធ្វើឱ្យដីធូរសំរួលដល់ការរីកលូតលាស់ផ្នែកប្រព័ន្ធឫស និងមានខ្យល់ចេញចូលបានល្អ ព្រមទាំងធ្វើឱ្យផ្ទៃរងរាបស្មើ ។



រៀបចំដោយលោក ជិត សុវណ្ណ និងស្រី ស្រស់ធីតា

## ៥_ការរៀបចំពូជស្រូវសំរាប់សាប,ការដកសំណាប

- ជាដំបូង ត្រូវធ្វើការសំអាតគ្រាប់ពូជស្រូវដោយត្រូវញែកគ្រាប់ពូជមិនគ្រប់លក្ខណៈចេញ ដាក់ពងមាន់ ឬ ពងទាទៅក្នុងទឹក រួចដាក់អំបិលមួយចំនួនទៅក្នុងទឹកជាមួយគ្នានោះដែរ ។ កូរឱ្យអំបិលរលាយអស់ រង់ចាំស៊ុតអណ្តែតឡើង( បើមិនទាន់អណ្តែត ត្រូវថែមអំបិល) ។ បន្ទាប់មកត្រូវចាក់ស្រូវទៅក្នុងធុងទឹក ព្រមទាំងកូរឱ្យបានច្រើនដង ។ រង់ចាំ និងស្រង់គ្រាប់ស្រូវដែលអណ្តែតចោល ហើយស្រង់គ្រាប់ស្រូវដែលលិចនៅក្នុងធុងទុកមួយកន្លែង ត្រូវធ្វើរបៀបនេះឱ្យបាន ២ ឬ ៣ ដង រួចហើយត្រូវលាងគ្រាប់ស្រូវនឹងទឹកធម្មតាឱ្យស្អាត( ឱ្យអស់ជាតិអំបិល និងធូលីដី) ។
- បន្ទាប់មក យកគ្រាប់ស្រូវដាក់ក្នុងបាវស្អាតចងមាត់ រួចត្រាំក្នុងទឹកធម្មតារយៈពេល ២៤ ម៉ោង ។ ត្រូវលាងគ្រាប់ពូជត្រាំនេះឱ្យស្អាត រួចយកទៅផ្អាប់រយៈពេល ២៤ ម៉ោងនៅក្រោមម្លប់ ដោយពង្រាបបាវស្រូវនេះក្នុងកំពស់ ១០-១៥ ស.ម និងយកចំបើងគ្របពីលើបាវស្រូវ ដើម្បីបង្កើនកំដៅឱ្យគ្រាប់ពូជដុះបានល្អ ។ ត្រូវធ្វើការត្រឡប់បាវស្រូវផង ដើម្បីសំរួលកំដៅក្នុងរយៈពេល ១២ ម៉ោង ហើយត្រូវស្រោចទឹករក្សាសំណើមឱ្យស្រូវឆាប់ចេញពន្លក ។
- ផ្អាប់ពូជរួចហើយស្រូវចាប់ផ្តើមបែកពន្លក ត្រូវយកគ្រាប់ពូជទៅសាបលើថ្នាលក្នុងអត្រា ១០០-១៥០ ក្រាមក្នុង ១ ម$^{២}$ ដោយធ្វើការរាយគ្រាប់ឱ្យបានស្មើល្អ ( ស្មានប្រហែលមួយទូកដៃ) ។ ធ្វើរបៀបនេះ ជៀសវាងសំណាបក្រាស់ពេក មានលក្ខណៈដើមតូចរៀវខ្វះគុណភាព ។

ការសាបស្រូវ ត្រូវអនុវត្តនៅពេលល្ងាច ជៀសវាងការថយចុះកំលាំងគ្រាប់ពូជដោយសារកំដៅថ្ងៃ និងម្យ៉ាងទៀតបើមេឃបំរុងនឹងភ្លៀងគួរផ្អាកការសាប ជៀសវាងធ្វើឱ្យរមូរគ្រាប់ពូជ ឬ ហូរគ្រាប់ចូលក្នុងចង្អូរថ្នាលសំណាប ។
- ត្រូវថែទាំសំណាបឱ្យបានល្អ, កុំឱ្យមានសត្វបំផ្លាញ, កំចាត់ស្មៅចង្រៃចេញ, ថែរក្សាទឹកឱ្យសើមជានិច្ចនៅក្នុងថ្នាល យកល្អដាក់ទឹកក្នុងចង្អូរថ្នាលជាប្រចាំ ។
- សំណាបអាចដកយកទៅស្ទូងបានក្នុងរយៈពេល ១៥ ថ្ងៃ ឬ លើសបន្តិចបន្តួច ( ជាគោលការណ៍សំណាបត្រូវធ្វើការដកទៅស្ទូងនៅក្រោមអាយុ ២០ថ្ងៃ) ដោយអនុវត្តៈ
  + ដកថ្នមៗកុំឱ្យបាក់ដើមសំណាប និងដាច់ឫស ។
  + ដករួចដាក់ក្នុងបង្គីឬសំភារៈផ្សេងៗដែលអាចធានាបាននូវភាពល្អនៃដើមសំណាប រួចហើយត្រូវយកទៅស្ទូងជាបន្ទាន់( ក្នុងថ្ងៃតែមួយ) ។




ប្រការត្រូវជៀសវាង !
+ មិនត្រូវដកសំណាបបោកឡើយ ។
+ មិនត្រូវចងជាកណ្តាប់ទេ ។
+ មិនត្រូវផ្អាប់ទុកឆ្លងថ្ងៃឡើយ ។

## ៦_ការរៀបចំដីសំរាប់ស្ទូង

ការរៀបចំដីសំរាប់ស្ទូង ជាផ្នែកមួយមានឥទ្ធិពល និងសារៈសំខាន់បំផុតដល់ការអនុវត្តបព័ន្ធប្រពលវប្បកម្មដំណាំស្រូវ តាមគោលការណ៍ធម្មជាតិដែលធ្វើឱ្យដំណាំស្រូវមានការរីកលូតលាស់ និងផ្លែផ្កាបានល្អ និងដើម្បីពង្រីកនូវសក្តានុពលរបស់ពូជស្រូវ ក្នុងការផ្តល់ទិន្នផលបានខ្ពស់ ។ ទន្ទឹមនេះ ការថែទាំភ្លឺស្រែក៏ត្រូវតែអនុវត្តឱ្យបានម៉ឺងម៉ាត់ ( ភ្លឺតូចល្មមនឹងមាំ) ជៀសវាងជាជំរកសត្វកណ្តុរ ព្រមទាំងការពង្រាបដីស្រែឱ្យបានល្អផង ។



## ៦.១_ការភ្ជួរដី

អនុវត្តការភ្ជួរដីឱ្យបានត្រឹមត្រូវ តើត្រូវភ្ជួរផ្ទុំ ឬក៏ ឱ្យបកទៅខាងណាក្នុងជំរៅ ១៥ សម និងកុំឱ្យល្វែងដី។ អាចមិនបំណាស់ ត្រូវគ្របជាស្រទាប់ៗដើម្បីត្រឡប់ដី និងគ្របលុបស្មៅកប់សារធាតុសរីរាង្គដែលមានក្នុងស្រែបានល្អ។ ការភ្ជួរលើកទី ១ នេះ ត្រូវទុករយៈពេល ១០-១៥ ថ្ងៃ ដើម្បីហាលដីឱ្យដីធ្វើអុកស៊ីដកម្ម និងឱ្យសារធាតុសរីរាង្គ (ឬជីស្រស់) បានពុករលួយល្អ។ គេអាចភ្ជួរលើកទី ២ ដោយកាត់ទទឹងលើកទី ១ និងភ្ជួរលើកទី ៣ ដោយកាត់ទទឹងលើកទី ២។ ការភ្ជួរលើកទី ២ ឬទី ៣ មានសារៈសំខាន់ក្នុងការលុបច្របល់នូវគ្រប់សារធាតុ ដែលបានដាក់ជាជីទ្រាប់បាត ឱ្យបានសព្វល្អបំរុងទុកសេចក្តីត្រូវការរបស់ដំណាំស្រូវ។

## ៦.២_ការរាស់

- អនុវត្តការរាស់ដីឱ្យបានសព្វល្អ និងមានភាពស្មើក្នុងផ្ទៃស្រែ។
- ត្រូវអនុវត្តការរាស់ដីស្រែឱ្យបាន ៣ ដង ជាការល្អដោយធ្វើការរាស់កាត់ទទឹង។ ទន្ទឹមនេះ ត្រូវមានវិធីសាស្ត្ររាស់កៀរដីឱ្យបានស្មើ។ ការរាស់ដីត្រូវធ្វើនៅលើដីដែលមានទឹករត់គន្លងនង្គ័លដើម្បីៈ
  + សំរួលដល់ការបំបែកដីជាដុំតូចៗ
  + សំរួលដល់ការរាស់កៀរដីឱ្យបានស្មើល្អ។
  + សំរួលដល់ការស្ទូងសំណាប ដោយគ្រាន់តែផ្តិតឫសទៅនឹងដីជាការល្អបំផុត ។

## ៧_ការប្រើជីលើដំណាំស្រូវ

ក្នុងការអនុវតនីនូវ ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ ជីធម្មជាតិមានឥទ្ធិពលខ្ពស់បំផុតដើម្បីធ្វើឱ្យដំណាំស្រូវមានការលូតលាស់បានល្អ និងឆាប់រហ័សទៅតាមសក្តានុពលរបស់ស្រូវ។ ជីធម្មជាតិឬជីសរីរាង្គរួមមានជីកំប៉ុស្តគោក, កំប៉ុស្តទឹក និងជីស្រស់ ឬ ជីបៃតង។ ប្រភេទជីធម្មជាតិនេះ បានមកពីជីជាតិសារធាតុសរីរាង្គមានកំទេចកំទីរុក្ខជាតិ និងសត្វដោយមានការជំរុញថែមពីធម្មជាតិមានកំដៅថ្ងៃ និងសំណើម។

ការដាក់ជីៈ

- ដាក់ជីកំប៉ុស្ត ឬជីលាមកសត្វដែលពុករលួយល្អពី ១០-១៥ តោនក្នុង ១ ហិកតារ ក្នុងពេលរៀបចំដីសំរាប់ស្ទូង (ពេលភ្ជួររាស់ចុងក្រោយ )។
- ប្រើប្រាស់ជីស្រស់ ត្រូវធ្វើការដាំដុះជាមុនសិន(អនុវត្តការព្រោះគ្រាប់)ដូចជាសណ្តែកបាយ ឬ ស្មៅ អាចភ្ជួរលុបបញ្ចូលទឹកអស់រយៈពេលយ៉ាងតិច ១០-១៥ ថ្ងៃ ដើម្បីឱ្យសារធាតុសរីរាង្គពុករលួយល្អ(ប្រហែល ១៥ តោន ជីស្រស់នៅក្នុងដីក្នុង ១ ហិកតារ)។

សេចក្តីបញ្ជាក់ៈ បើប្រើជីស្រស់ហើយ មិនបាច់ប្រើកំប៉ុស្ត ឬ ជីលាមកសត្វ ឬ ជីគីមីឡើយ ។

## ៨_ការស្ទូងស្រូវ

ការស្ទូងស្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមបច្ចេកទេសដូចជាៈ

- ស្ទូងជាជួរតាមឈើក្រិត ឬ ខ្សែក្រិតក្នុងចន្លោះ ២៥ សម x ២៥ សម ចំពោះស្រូវក្នុងស្រុ និង ២០ សម x ២០សម ចំពោះស្រូវស្រាលនាំចូលមិនប្រកាន់រដូវ ដើម្បីសំរួលដល់ការថែទាំ បោចស្មៅ និងការរីកលូតលាស់របស់ដំណាំស្រូវ។

- ត្រូវស្ទូងរាក់ៗធ្វើឱ្យស្រូវឆាប់លូតលាស់ល្អ ។
- ត្រូវស្ទូងកុំឱ្យមានបត់ដើមសំណាប ។

## ៩_ការថែទាំសន្ទូង និងការគ្រប់គ្រងទឹក

- ត្រូវពិនិត្យ និងធ្វើការជួសសន្ទូងជាបន្ទាន់ បើមានបាត់ដំណោត ។
- ត្រូវឧស្សាហ៍បោចស្មៅ កុំឱ្យស្មៅដុះប្រជែងដំណាំស្រូវ ។
- ត្រូវឧស្សាហ៍ត្រួតពិនិត្យភ្លឺស្រែក្រែងមានធ្លុះធ្លាយ ដោយសត្វក្តាម ឬ កណ្តុរធ្វើរន្ធ និងត្រូវធ្វើការគ្រប់គ្រងទឹកក្នុងស្រែឱ្យបានល្អ ។ ស្រូវត្រូវការទឹកក្នុងវគ្គបង្កបង្កើតផល និងវគ្គទុំ (២-៣ សម ជាការប្រសើរ) ។ ក្នុងវគ្គលូតលាស់ស្រូវត្រូវការទឹកធម្មតា (ចាប់ពីស្ទូងរហូតដល់វគ្គបង្កបង្កើតផល) ។

## ១០_ការដាក់ជីបំប៉ន

ជាការសំខាន់ ការដាក់ជីបំប៉នស្រូវ ត្រូវធ្វើឱ្យចំពេលដែលដំណាំស្រូវត្រូវការ ។ បើពុំដូចនោះទេនឹងនាំឱ្យមានការខាតបង់ថវិកា និងទិន្នផលថយចុះ ។

- ពេលវេលាសមស្រប ត្រូវធ្វើនៅពេលស្រូវចាប់ផ្តើមបែកគុម្ព ក្នុងគោលបំណងឱ្យស្រូវបែកគុម្ពជាអតិបរមា គ្មានដើមស្ទៀតដែលមិនផ្លែផ្កា ។ ការងារនេះត្រូវធ្វើម្តងទៀតនៅពេលស្រូវចាប់ផ្តើមកំណកំណើតពន្លកកកួរ ។
- គេអាចប្រើជីកំប៉ុស្តទឹក ឬ ដើមទន្រ្ទានខែត ដែលកាប់ចិញ្ច្រាំឱ្យខ្ទីហើយឱ្យស្អួតល្អ ។ យកជីនេះទៅចាក់ ឬ បាចតាមចន្លោះជួរ សន្ទូងជាការស្រេច ។ កំទេចកំទីទន្រ្ទានខែតដែលបានដាក់នឹងចាប់រលួយ ក្នុងរយៈពេលខ្លី(មួយសប្តាហ៍) ។
  + កំប៉ុស្តទឹកចំនួន ៤០០ លីត្រ ក្នុង ១ ហិកតារ ។
  + ទន្រ្ទានខែតចំនួន ៥ បាវ មួយលើកក្នុង ១ ហិកតារ (១០ បាវ ពីរលើក) ។

សេចក្តីបញ្ជាក់: ការប្រើប្រាស់ជីធម្មជាតិលើដំណាំស្រូវតាមបច្ចេកទេស ដែលបានរៀបរាប់នេះនឹងកាត់បន្ថយជាអតិបរិមាការបំផ្លាញពីសត្វល្អិតផ្សេងៗ ព្រោះប្រភេទជីធម្មជាតិមានក្លិនម្យ៉ាង ដែលធ្វើឱ្យពពួកសត្វល្អិតទាំងឡាយមិនហ៊ានមកក្បែរ ។

## ១១_ការប្រមូលផលស្រូវ និងទុកដាក់ផលស្រូវ

### ក-ការប្រមូលផលស្រូវ :

ដើម្បីប្រមូលផលស្រូវ តម្រូវឱ្យមានការត្រួតពិនិត្យ និងពិចារណាលើភាពទុំរបស់ស្រូវឱ្យបានត្រឹមត្រូវ ។ ពេលវេលាច្រូតកាត់ដែលសមស្របនោះគឺ នៅពេលដែលគ្រាប់ស្រូវ ៨០-៨៥% ផ្នែកចុងកួរមានពណ៌លឿងដូចចំបើង ហើយគ្រាប់ស្រូវនៅគល់កួរស្ថិតនៅក្នុងដំណាក់កាលដាក់ម្សៅខ្ពស់ ។

ការច្រូតកាត់បានទាន់ពេលវេលានេះមានសារៈសំខាន់:

- គុណភាពអង្ករល្អ និងតំរូវការទីផ្សារ ។
- មិនមានបាត់បង់ទិន្នផល ដែលបណ្តាលពីការដួលដើមស្រូវ និងបាក់កកួរស្រូវជ្រុះគ្រាប់ស្រូវ និងម្យ៉ាងទៀតធ្វើឱ្យគ្រាប់ស្រូវមិនពេញលេញ (ស្ទៀត) បើសិនជាយើងច្រូតមុនពេលទុំ ។

ខ-ការទុកដាក់ផលស្រូវ៖

គ្រាប់ស្រូវដែលទើបនឹងបោកបែនហើយ អាចមានសំណើមគ្រាប់រហូតដល់ ២៥% ។ គេមិនអាចយកគ្រាប់ស្រូវដែលមានសំណើមខ្ពស់នេះទៅស្តុកទុកបានទេ ព្រោះគ្រាប់ស្រូវនោះនឹងត្រូវពុកផុយដោយជំងឺផ្សិត និងពពួកសត្វល្អិតចង្រៃបំផ្លាញថែមទៀត ។ ដូចនេះ ត្រូវហាលស្រូវឱ្យបានស្ងួតល្អ ដែលកំណត់សំណើមត្រឹម ១៤% ។ គេអាចធ្វើតេស្តដោយខាំគ្រាប់ស្រូវ ហើយពិនិតមើលផ្ទៃគ្រាប់អង្ករមានពណ៌ថ្លា នោះគ្រាប់ស្រូវស្ងួតល្មមហើយ ។ បើសិននៅស្រអាប់មិនទាន់ថ្លានោះទេ គ្រាប់ស្រូវមិនទាន់ស្ងួតឡើយ ។

ម្យ៉ាងទៀត ចូរកុំហាលស្រូវឱ្យស្ងួតហួសពេក វានឹងនាំឱ្យគុណភាពអង្ករបាក់ខ្ទេច,មានកញ្ចុំងច្រើន ។ គេអាចទុកដាក់ស្រូវក្នុងជង្រុកដែលមានខ្យល់ចេញចូលបានល្អ ព្រមទាំងការពារបានពីសំណាក់សត្វកណ្តុរ និងចាបផង ។ បាវក៏ជាឧបករណ៍ម្យ៉ាងសំរាប់ស្តុកស្រូវបានល្អដែរ ។ ស្រូវត្រូវទុកដោយឡែកពីគ្នា បើសិនជាមានពូជច្រើន ត្រូវសរសេរផ្លាកដាក់តាមពូជនោះផង ។

## V-ការប្រៀបធៀបជីគីមី និងជីធម្មជាតិ

| ជីគីមី | ជីធម្មជាតិ |
|---|---|
| មានសារធាតុចិញ្ចឹមខ្ពស់ | មានសារធាតុចិញ្ចឹមតិចតែច្រើនមុខ |
| មានតំលៃខ្ពស់ | មានតំលៃថោក ឬ ក៏គ្មានចំណាយ |
| ប្រសិទ្ធភាពឆាប់ | ប្រសិទ្ធភាពយឺតតែបានយូរ |
| ប្រើយូរទៅធ្វើឱ្យខូចគុណភាពដី | ធ្វើឱ្យដីកាន់តែល្អឡើង |
| ប្រើខុសបច្ចេកទេសនាំឱ្យខូចដំណាំ ( ប្រើច្រើនហួស) | ប្រើកាន់តែច្រើន កាន់តែប្រសើរ |
| ផលិតចេញពីរោងចក្រ | ការសន្សំសារធាតុសរីរាង្គធ្វើជី |
| ធ្វើឱ្យដីរឹងក្តាំង | ជាចំណីរបស់អតិសុខុមប្រាណ ( ដីរស់) |
| ប្រើប្រាស់មានកំរិត ( ស្រួលដឹកជញ្ជូន ) | ប្រើច្រើន ( ពិបាកដឹកជញ្ជូន) |
| ប៉ះពាល់ដល់បរិស្ថាន | ជួយកែលំអដី និងជួយដល់បរិស្ថានធម្មជាតិ( ដីរិះចំរុះ) |



# ស្រូវចំការ
# (Upand Rice Growing)

## I-សេចក្តីផ្តើម

ប្រទេសកម្ពុជា មានវិសាលភាពធំធេងលើវិស័យកសិកម្ម ដែលប្រជាជនជាង ៨០% ជាកសិករស់នៅតាមជានបទ ជាពិសេស លើការងារបង្កើនផលស្រូវ ។ ដំណាំស្រូវជាដំណាំមួយមានប្រពៃណីជាយូរលង់ណាស់មកហើយ សំរាប់ប្រជាជនកម្ពុជា ដែលគេអនុវត្តកន្លងមកហើយ ក៏ជាសេដ្ឋកិច្ចចម្បងរបស់ប្រទេសផងដែរ ។

គេអនុវត្តធ្វើដំណាំស្រូវជាលក្ខណៈគ្រួសារ សំរាប់ផ្គត់ផ្គង់ជីវភាព និងលក់នូវកសិកផលដែលសល់ពីការហូបចុក ដើម្បីបានប្រាក់សំរាប់គ្រួសារ ។

ការដាំដំណាំស្រូវមកទល់បច្ចុប្បន្នមានៈ

- ស្រូវប្រពៃណីដែលមានពូជស្រូវប្រកាន់រដូវ ស្រូវឡើងទឹក, ស្រូវជ្រះ ដែលគេអនុវត្តនៅក្នុងតំបន់វាលរាប និងតំបន់លិចទឹកនៅជុំវិញបឹងទន្លេសាប ។
- ស្រូវចំការដែលធ្វើការដាំដុះ ក្នុងបរិមាណតិចតួចដោយកសិករជាជនភាគតិច នៅតំបន់ខ្ពង់រាប(តំបន់ភ្នំ) អនុវត្តជាប្រពៃណី ដោយប្រើពូជពិសេសរបស់គេ ធន់នឹងការរាំងស្ងួតក្នុងរដូវវស្សា ហើយមានរយៈពេលមធ្យម (ស្រូវកណ្តាល) ។
- ស្រូវពូជថ្មី នាំចូលមានរយៈពេលខ្លី ទិន្នផលខ្ពស់ ដែលគេអនុវត្តនៅតំបន់វាលរាបជាស្រូវប្រាំង,ស្រូវប្រដេញទឹកឬជាស្រូវបង្កើនរដូវ បច្ចុប្បន្នកសិករយើងមានធ្វើការដាំដុះពូជស្រូវប្រភេទនេះ នៅតំបន់ខ្ពង់រាប មានទិន្នផលខ្ពស់ ធន់នឹងជំងឺផងដែរ ។

## II-គោលបំណង

១-បង្កើនការយល់ដឹងឱ្យបានកាន់តែខ្ពស់ លើការងារអនុវត្តផលិតកម្មស្រូវចំការ ។

២-លើកកំពស់សមត្ថភាពកសិករនៅតំបន់ខ្ពង់រាប ក្នុងការអនុវត្តន៏ដាំដុះស្រូវចំការតាមរយៈបច្ចេកទេស និងទទួលបានទិន្នផលខ្ពស់ ។

៣-បង្កើនប្រាក់ចំណូលដល់ផលិតករឱ្យបានកាន់តែខ្ពស់ ពីការធ្វើផែនការបានត្រឹមត្រូវ និងពីការលក់ដូរផលិតផលស្រូវ ដោយបង្កើនផ្ទៃដីដាំដុះ(ពង្រីកផ្ទៃដីដាំដុះ) ។

## III-ការអនុវត្តន៍របស់កសិករកន្លងមក

- ការដាំដុះជាលក្ខណៈប្រពៃណី ( Culture de rail ) ដោយកាប់ឆ្ការព្រៃដាំជាផ្ទៃដីតូចៗ ( ១០០០- ១៦០០ ម២ ) ក្នុងព្រៃឈើ ។
- ការដាំដុះមិនបានជ្រើសរើសពូជឱ្យបានត្រឹមត្រូវ និងទុកដាក់ពូជឱ្យបានល្អឡើយ ( ខ្ចីបុលគេ..... ) ។
- ការដាំដុះមិនបានអនុវត្តការដាក់ជីសំរាប់កែលំអដី និងសំរាប់បង្កើនផលស្រូវឡើយ ។
- ការអនុវត្តន៍ដាំដុះមានលក្ខណៈជាដំណាំ យថាផល ។
- មួយចំនួនបានអនុវត្តការភ្ជួររាស់ និងដាំដុះដែរ តែមិនបានអនុវត្តឱ្យបានត្រឹមត្រូវតាមបច្ចេកទេសឡើយ ។

## IV- ការអនុវត្តន៍បច្ចេកទេសដាំដុះស្រូវចំការ

### ការយល់ដឹងពីដំណាក់កាលលូតលាស់របស់ដំណាំស្រូវ

ការយល់ដឹងពីដំណាក់កាលលូតលាស់របស់ដំណាំស្រូវ មានសារៈសំខាន់ណាស់ដើម្បីគ្រប់គ្រងឱ្យបានត្រឹមត្រូវតាមបច្ចេកទេស និងជៀសវាងបាននូវការចំណាយច្រើនឥតប្រយោជន៍ ព្រមទាំងធ្វើឱ្យបាត់បង់នូវទិន្នផលស្រូវដោយកត្តាផ្សេងៗ ។

ការលូតលាស់របស់ដំណាំស្រូវ ត្រូវចែកជា ៣ វគ្គសំខាន់:

ក-វគ្គលូតលាស់: វគ្គលូតលាស់នេះមានរយៈពេលខុសៗគ្នា អាស្រ័យតាមប្រភេទស្រូវ ( ស្រូវប្រកាន់រដូវ ឬ មិនប្រកាន់រដូវ ) និងអាយុកាលនៃពូជស្រូវនីមួយៗ ហើយចែកចេញជា ៤ ដំណាក់កាលគឺ:

- ដំណាក់កាលដុះពន្លក ( ចាប់ពីគ្រាប់ស្រូវដល់ស្រូវដុះពន្លកស្លឹកទី ១) ។
- ដំណាក់កាលសំណាប ( ចាប់ពីស្រូវដុះស្លឹកទី ១ ដល់ស្រូវចាប់បែកគុម្ព) ។
- ដំណាក់កាលបែកគុម្ព ( ចាប់ពីស្រូវបែកគុម្ពដំបូង ដល់ស្រូវបែកគុម្ពពេញទំហឹង) ។
- ដំណាក់កាលពន្លូតដើម ( ចាប់ពីស្រូវបែកគុម្ពពេញទំហឹង ដល់ស្រូវចាប់ផ្ដើមពន្លកកកួរ) ។

ខ-វគ្គបង្កបង្កើតផល: វគ្គបង្កបង្កើតផលមានរយៈពេល ៣៥ ថ្ងៃ និងចែកចេញជា ៣ ដំណាក់កាលគឺ:

- ដំណាក់កាលពន្លកកកួរ ( ចាប់ពីពន្លកកកួរ ដល់ស្រូវផើម) ។
- ដំណាក់កាលចេញកួរ ( ចាប់ពីស្រូវផើម ដល់ស្រូវចេញកួរផុតពីស្លឹកទង់ជ័យ) ។
- ដំណាក់កាលចេញផ្កា ( ចាប់ពីស្រូវចេញកួរផុត ដល់ស្រូវរោយលំអង) ។



គ-វគ្គទុំ: វគ្គទុំមានរយៈពេល ៣០ថ្ងៃ និងចែកចេញជា ៣ ដំណាក់កាលគឺ:

- ដំណាក់កាលដាក់ទឹកដោះ ។
- ដំណាក់កាលដាក់ម្សៅ ។
- ដំណាក់កាលទុំពេញលេញ ។

## ១-ការរៀបចំដីសំរាប់ដាំដុះស្រូវចំការ

### ក- ដីនៅតាមជំរាលជើងភ្នំ

ដើម្បីកាត់បន្ថយនូវការហូរច្រោះដីនៅពេលមានភ្លៀង ត្រូវមើលស្ថានភាពដី ដោយធ្វើភ្លឺខ័ណ្ឌជាបន្ទាត់កោង ដូចតទៅនេះ:

- ដីមានចំណោតខ្លាំង ត្រូវធ្វើភ្លឺតាមបន្ទាត់កោង ចម្ងាយពីស្រែមួយទៅស្រែមួយ ៥ ម៉ែត្រ ជាបន្តបន្ទាប់ ។
- ដីមានចំណោតមធ្យម ត្រូវរៀបចំស្រែតាមបន្ទាត់កោង ចំម្ងាយពីស្រែមួយទៅស្រែមួយ ១០ ម៉ែត្រ និង ជាបន្តបន្ទាប់ ។
- ដីមានជំណោតខ្សោយ ត្រូវរៀបស្រែជាធម្មតាតាមបន្ទាត់កោង ពីស្រែមួយទៅស្រែមួយ ២០ ម៉ែត្រ ឬ លើសពីនេះទៅតាមសណ្ឋានដី និងជាបន្តបន្ទាប់ ។

### ខ-ការភ្ជួររាស់

សំរាប់ដំាណាំស្រូវ ការភ្ជួររាស់ជាវិធីមួយចាំបាច់បំផុតក្នុងការធ្វើអោយ:

- ដីធូរ, ភ្ជួររាស់បង្កប់នូវសារធាតុសរីរាង្គ ឬ ជីទ្រាប់បាតដែលបានដាក់ ។
- បំបាត់ស្មៅចង្រៃដោយ ភ្ជួររាស់លុប, ភ្ជួររាស់ពង្រាបដីឱ្យមានភាពស្មើល្អ ។
  - \+ ភ្ជួររាស់ត្រូវធ្វើឱ្យបានច្រើនសា ពី ២-៣ ដង ជាការប្រសើរ ។
  - \+ ភ្ជួររាស់លើកទី ១ ត្រូវទុកហាលដី ពី ៧-១០ ថ្ងៃ ដើម្បីបំបាត់នូវមេរោគ និងសត្វល្អិត និងធ្វើឱ្យដីធ្វើអុកសីដកម្មបានល្អ ។
  - \+ ការភ្ជួរដីត្រូវអនុវត្តឱ្យបានល្អ ដោយធ្វើឱ្យអាចមិ៍បំណាស់គ្របជាស្រទាប់ៗ ដែលអាចបកទៅរកផ្ទៃកទាបនៃដីស្រែដែលបានគ្រោងទុកពីមុន ។

## ២-ការជ្រើសរើសពូជ



- ពូជស្រូវត្រូវមានរយ:ពេលខ្លី ( ស្រូវកណ្តាល ឬ ស្រូវ អ៊ីអែរ (IR) នាំចូល) ។
- ពូជស្រូវធន់នឹងជំងឺ និងសត្វល្អិត ។
- ពូជស្រូវមានទិន្នផលខ្ពស់ ។
- ពូជស្រូវត្រូវមានកំលាំងដុះ និងមានដំណុះពី ៨៥% ឡើងទៅ ។
- ពូជស្រូវត្រូវមានគុណភាពអង្ករល្អ ឆ្លើយតាមតំរូវការទីផ្សារ ។

## ៣-ពេលវេលា និងរបៀបដាំដុះស្រូវចំការ

ពេលវេលាសមស្របក្នុងការដាំដុះស្រូវចំការគឺ ចាប់ពីពាក់កណ្តាលខែ ឧសភា ដល់ ថ្ងៃទី ១០ ខែមិថុនា ។ ពេលវេលានេះល្អសំរាប់:

- ការអនុវត្តន៏ការរៀបចំដីដាំដុះបានល្អ ( មិនសូវមានភ្លៀង ) ។
- ធានាបានក្នុងការប្រមូលផល ដោយមិនបារម្ភស្រូវស្អកដោយខ្វះទឹកភ្លៀងចុងរដូវ ។
- មានភាពងាយស្រួលក្នុងការថែទាំ ( ធ្វើស្មៅបានល្អនៅពេលស្រូវកំពុងលូតលាស់ ដោយពុំសូវមានភ្លៀងជោកជាំ) ។

របៀបដាំដុះអាចធ្វើបានពីរយ៉ាងៈ

វិធីដាំដុះស្រូវចំការគេអាចធ្វើបានពីរយ៉ាងគឺ ការអនុវត្តន៏ដោយការព្រោះគ្រាប់ស្រូវ(ឬហៅថាស្រូវពង្រោះ) ប៉ុន្តែការធ្វើរបៀបនេះគេមិនសូវជួបប្រទះឡើយ ដោយពិបាកក្នុងការកំចាត់ស្មៅចង្រៃ និងការថែទាំដូចជាដាក់ជីបំប៉ន និងប្រើពូជច្រើនពី ៧០-១០០ គក្រ សំរាប់ដី ១ ហិកតារ។

ម្យ៉ាងទៀត គឺការដាំដុះដោយអនុវត្តការបុកដាំ ឬ បច្ចេកទេសទី ២ នេះគេអនុវត្តច្រើន ព្រោះមានការងាយស្រួលក្នុងការថែទាំគ្រប់បែបយ៉ាងដូចជា ការសំអាតស្មៅចង្រៃ ការដាក់ជីបំប៉ន ការបាញ់ថ្នាំ កំចាត់សត្វល្អិត ហើយការលូតលាស់របស់ដំណាំស្រូវបានល្អ និងឆាប់របហ័ស និងប្រើអស់ពូជតិច។

អំពីការដាំដុះដោយបុកដាំៈ

- ការអនុវត្តន៏ដោយបុកដាំជាវិធីមួយងាយស្រួល និងដាំជាជួរតាមខ្សែក្រិត ២៥ សម x ២៥ សម ហើយប្រើគ្រាប់ពូជតិចពី ៣០ ទៅ ៣៥ គក្រ ប៉ុណ្ណោះក្នុងដីដាំដុះ ១ ហិកតារ។
- ការដាំដុះលើដីស្ងួត គេប្រើគ្រាប់ស្ងួត។
- ការដាំដុះលើដីសើម គេប្រើគ្រាប់ពូជដែលបានត្រាំមុន។

## ៤-ការប្រើប្រាស់ជីលើដំណាំស្រូវចំការ

ការប្រើប្រាស់ជីលើដំណាំស្រូវចំកាមិនខុសពីស្រូវវស្សាឡើយ ដើម្បីកំណត់បាននូវទិន្នផលបានខ្ពស់ និងរក្សាបាននូវនិរន្តរភាពដីកសិកម្មសំរាប់ផលិតកម្មដំណាំ នាពេលអនាគត។

របៀបដាក់ជីគឺ ជីទ្រាប់បាត និង ដាក់ជីបំប៉ន :

### ជីទ្រាប់បាត

- ជីកំប៉ុស្ត ឬ ជីលាមកសត្វពុកផុយល្អពី ៥-១០ តោន ក្នុង ១ ហិកតារ។
- ជី ដេ-អា-ប៉េ (១៨-៤៦-០) ១០០ គក្រ ក្នុង ១ ហិកតារ។
- ជីប៉ូតាស្យូម (០-០-៦០) ៥០ គក្រ។

ការអនុវត្តជីទ្រាប់បាតគឺ ត្រូវធ្វើនៅមុនភ្ជួរចុងក្រោយ ដោយភ្ជួរច្របល់លុបឱ្យបានសព្វល្អ រួចរាស់លុបឱ្យបានស្មើមុនធ្វើការដាំដុះ។

### ជីបំប៉ន

ជីបំប៉នត្រូវប្រើជី អ៊ុយរ៉េ ជាពីរលើកចំនួន ១០០ គក្រ ក្នុង ១ ហិកតារៈ

- លើកទី១: ប្រើជីអ៊ុយរ៉េ ៥០ គក្រ បាច ឬ រោយទៅតាមចន្លោះជួរស្រូវ មុនធ្វើការជំរះស្មៅលើកទី ១ ពី ១៥-២០ថ្ងៃ ឬ នៅពេលស្រូវចាប់បែកគុម្ព រួចចាំង ឬ ចូកស្មៅ ជ្រុំជ្រួយ លុបជីតែម្តង។
- លើកទី២: ប្រើជីអ៊ុយរ៉េ ៥០ គក្រ នៅពេលស្រូវចាប់កំណកួរ។ ធ្វើនៅពេលមុនជំរះស្មៅលើកទី ២ ឬ លើកទី៣ ដោយបាច ឬ រោយនៅតាមចន្លោះជួរស្រូវ រួចចាំង ឬ ចូកស្មៅ ជ្រុំជ្រួយដី លុបជីតែម្តង។

## ៥- ការថែទាំ

- កូនស្រែដែលបានរៀបចំរួច ត្រូវឧស្សាហ៍មើលថែទាំភ្លឺដែលធ្វើរួចហើយ ដើម្បីរក្សាសំណើមដីឱ្យបានល្អ ព្រោះស្រូវត្រូវការទឹកចាំបាច់ណាស់ក្នុងដំណាក់កាលនីមួយៗ រហូតដល់ស្រូវទុំ។

- ការសំអាតស្មៅចង្រៃក៏ជាការងារចាំបាច់ណាស់ ដើម្បីឱ្យដំណាំស្រូវលូតលាស់បានល្អ និងឆាប់រហ័ស។ ស្មៅចង្រៃជាប្រភពស្រូបយកជីជាតិ និងជាជំរកសត្វល្អិត និងដុះប្រជែងដំណាំស្រូវ បើធ្វេសប្រហែសមិនបានកំចាត់ឱ្យទាន់ពេលវេលានោះ។

- ឧស្សាហ៍ពិនិត្យមើលសត្វល្អិតចង្រៃចូលយាយីដំណាំស្រូវ។ ប៉ុន្តែដំណាំស្រូវចំការគេមិនសូវជួបនឹងការបំផ្លាញខ្លាំងពីសត្វល្អិតចង្រៃឡើយ។ ចាំបាច់នឹងបញ្ហានេះ គេអាចប្រើថ្នាំពុលកសិកម្មដើម្បីកំចាត់ឱ្យទាន់ពេល។

## ៦-ការប្រមូលផល និងទុកដាក់ផលស្រូវ

### ១-ការប្រមូលផលស្រូវ:

ដើម្បីប្រមូលផលស្រូវ តម្រូវឱ្យមានការត្រួតពិនិត្យ និងពិចារណាលើភាពទុំរបស់ស្រូវឱ្យបានត្រឹមត្រូវ។ ពេលវេលាច្រូតកាត់ដែលសមស្របនោះគឺ នៅពេលដែលគ្រាប់ស្រូវ ៨០-៨៥% ផ្នែកចុងកួរមានពណ៌លឿងដូចចំបើង ហើយគ្រាប់ស្រូវនៅគល់កួរស្ថិតនៅក្នុងដំណាក់កាលដាក់ម្សៅខ្ចស់។

ការច្រូតកាត់បានទាន់ពេលវេលានេះមានសារៈសំខាន់ :

- គុណភាពអង្ករល្អ តំរូវការទីផ្សារ។
- មិនមានបាត់បង់ទិន្នផលដែលបណ្តាលពីការដួលដើមស្រូវ និងបាក់កកួរស្រូវ ជ្រុះគ្រាប់ស្រូវ និងម្យ៉ាងទៀតធ្វើឱ្យគ្រាប់ស្រូវមិនពេញលេញ (ស្កៀត) បើសិនជាយើងច្រូតមុនពេលទុំ។

### ២-ការទុកដាក់ផលស្រូវ:

គ្រាប់ស្រូវដែលទើបនឹងបោកបែនហើយ អាចមានសំណើមគ្រាប់រហូតដល់ ២៥%។ គេមិនអាចយកគ្រាប់ស្រូវដែលមានសំណើមខ្ពស់នេះទៅស្តុកទុកបានទេ គ្រាប់ស្រូវនោះនឹងត្រូវពុកផុយដោយជំងឺផ្សិត និងពពួកសត្វល្អិតចង្រៃបំផ្លាញថែមទៀត។ ដូចនេះ ត្រូវហាលស្រូវឱ្យបានស្ងួតល្អ ដែលកំណត់សំណើមត្រឹម ១៤%។

គេអាចធ្វើតេស្តដោយខាំគ្រាប់ស្រូវ ហើយពិនិត្យមើលផ្នែកគ្រាប់អង្ករមានពណ៌ថ្លានោះគឺ គ្រាប់ស្រូវស្ងួតល្មមហើយ។ បើសិននៅស្រអាប់ មិនទាន់ថ្លានោះទេ គ្រាប់ស្រូវមិនទាន់ស្ងួតឡើយ។ ម្យ៉ាងទៀត ចូរកុំហាលស្រូវឱ្យស្ងួតហួសពេក នឹងនាំឱ្យគុណភាពអង្ករបាក់ខ្ទេច មានកញ្ចុងច្រើន។ គេអាចទុកដាក់ស្រូវក្នុងជង្រុក ដែលមានខ្យល់ចេញចូលបានល្អ ព្រមទាំងការពារបានពីសំណាក់សត្វកណ្តុរ និងចាបផង។ បាវក៏ជាឧបករណ៍ម្យ៉ាងសំរាប់ស្តុកស្រូវបានល្អដែរ។ ស្រូវត្រូវទុកដោយឡែកពីគ្នា បើសិនជាមានពូជច្រើនត្រូវសរសេរផ្លាកដាក់តាមពូជនោះផង។



## V- វិភាគសេដ្ឋកិច្ចលើផលិតកម្មស្រូវចំការ(ផ្ទៃដី ១ ហត)

| បរិយាយ | ឯកតា | តាមប្រពៃណី | | | តាមបច្ចេសទេស | | |
|---|---|---|---|---|---|---|---|
| | | ចំនួន | តំលៃឯកតា $ | តំលៃសរុប $ | ចំនួន | តំលៃឯកតា $ | តំលៃសរុប $ |
| ការរៀបចំដីសរុប | ហត | ១ | ៣០ | ៣០.០០ | ១ | ៤០.០០ | ៤០.០០ |
| គ្រាប់ពូជ | គក្រ | ៣៥ | ០.២៥ | ០.៧៥ | ៣៥ | ០.២៥ | ៨.៧៥ |
| ការដាំដុះ | ថ្ងៃ/នាក់ | ១០ | ១.៧៥ | ១៧.៥០ | ១០ | ១.៧៥ | ១៧.៥០ |
| ជីគីមី ( DAP - $K_2O$ ) | គក្រ | - | - | - | ១៥០ | ០.៤៥ | ៦៧.៥០ |
| ជីអ៊ុយរ៉េ | គក្រ | - | - | - | ១០០ | ០.៣៥ | ៣៥.០០ |
| ជីកុំប៉ុស្ត ឬ លាមកសត្វ | តោន | - | - | - | ១០ | ៥.០០ | ៥០.០០ |
| ថ្នាំសម្លាប់សត្វល្អិត | លីត្រ | - | - | - | - | - | - |
| ថ្នាំកំចាត់ស្មៅ | លីត្រ | - | - | - | - | - | - |
| ការច្រូតកាត់ | ថ្ងៃ/នាក់ | ២៥ | ១.៧៥ | ៤៣.៧៥ | ២៥ | ១.៧៥ | ៤៣.៧៥ |
| ដឹកជញ្ជូន បោកបែនសរុប | ថ្ងៃ/នាក់ | ៣០ | ១.៧៥ | ៥២.៥០ | ២៥ | ១.៧៥ | ៥២.៥០ |
| ការទុកដាក់ស្រូវ | បាវ | ៥០ | ០.២៥ | ១២.៥០ | ៩០ | ០.២៥ | ២២.៥០ |
| ចំណាយសរុប | $ ១៦៥.០០ | | | | $ ៣៣៧.៥០ | | |
| ចំណូលសរុប | $ ០.១៣ x ២ ៥០០R = $ ៣២៥.០០ | | | | $ ០.១៣ x ៤ ៥០០R = $ ៥៨៥.០០ | | |
| ចំណេញ | $១៦០.០០ | | | | $២៤៧.៥០ | | |

តាមប្រពៃណី : ទិន្នផល : ២៥០០ គក្រ/ហត

តាមបច្ចេសទេស : ទិន្នផល : ៤៥០០ គក្រ /ហត

តំលៃលក់ស្រូវ : $០.១៣/គក្រ



# ការបន្សុទ្ធគ្រាប់ពូជស្រូវ
# (Farmer seed production)

## I-សេចក្តីផ្តើម

នៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រជាជនយើងប្រកបមុខរបរកសិកម្មប្រមាណ ៨០ ទៅ ៨៥ ភាគរយជាពិសេសលើដំណាំស្រូវ។ ការធ្វើផលិតកម្មលើដំណាំស្រូវដែលមានរយៈពេលខ្លី ផ្តល់ទិន្នផលខ្ពស់ដោយគ្រាប់ពូជសុទ្ធ គ្មានលាយជាមួយពូជស្រូវដទៃ បានសេចក្តីថាគ្រាប់ពូជមានទំហំប៉ុនគ្នាគុណភាពល្អ ក្លិនប្រហើរ កំពស់ដើមស្មើគ្នា ក្នុងគោលបំណងបំពេញតំរូវការនៅក្នុងប្រទេស និងចំណាប់អារម្មណ៍ ទៅលើគុណភាពស្រូវស្រុកខ្មែរ នាំចេញទៅក្រៅប្រទេស។ ការប្រើប្រាស់ពូជសុទ្ធល្អ គឺជាគ្រឹះនៃការផលិតពូជស្រូវអោយមានគុណភាពខ្ពស់។ គ្រាប់ពូជដែលមានគុណភាពខ្ពស់ក៏អាចមានតម្លៃខ្ពស់ដែរ។ ដូច្នេះ ដើម្បីអោយផលស្រូវរបស់កសិករទទួលបានជោគជ័យ យើងត្រូវដឹងអំពីរបៀបផលិត និងថែទាំពូជសុទ្ធ។



## II-គោលបំណង

១-សំរិតសំរាំងពូជស្រូវ ដើម្បីទទួលនូវពូជសុទ្ធល្អ។
២-ចំណង់ចំណូលចិត្តពីអ្នកទិញ ដើម្បីទុកធ្វើពូជ និងតំរូវការទីផ្សារ។
៣-ងាយស្រួលក្នុងការច្រូតកាត់តាមកាលកំណត់។

## III-ទំលាប់ធ្វើរបស់កសិករ

- កសិករច្រូតកាត់មិនបានគិតគូរស្រូវលាយ ឬ សុទ្ធដែលបានច្រូតជាមួ
- ដាក់ស្រូវក្នុងលានបែនច្របូកច្របល់។
- បញ្ជាន់ស្រូវក្នុងលានមានលាយខ្លះជាមួយពូជដទៃ។
- ទុកដាក់គ្រាប់ពូជស្រូវពុំបានញែកដាច់ចេញពីគ្នា (ដាក់ចំរុះគ្នាជាមួយស្រូវទុកចំណាយ និងស្រូវទុកពូជ)។

## IV-បច្ចេកទេសដាំដុះ និងសំរិតសំរាំងពូជស្រូវ

ពាក្យថាសំរិតសំរាំង គឺការដកចេញរុក្ខជាតិមិនធម្មតា ឬ ខុសគេ។ ការធ្វើរបៀបនេះ ជាទង្វើតាមរបៀបបុរាណរបស់កសិករ ដើម្បីអោយពូជសុទ្ធនៅក្នុងស្រែរបស់ខ្លួន។ ពេលល្អដែលត្រូវធ្វើការសំរិតសំរាំង គឺដំណាក់កាលនៃការចេញក្តួរ ហើយវាក៏ជាពេលដែលរុក្ខជាតិមានកំពស់ជាអតិបរមា។ ថ្ងៃខែចេញក្តួរអាចអោយយើងកំណត់បានអាយុកាលខ្លី ឬ អាយុកាលវែង។ ការសំរិតសំរាំងពូជអាចធ្វើបានគ្រប់ពេល នៅពេលណាដែលយើងពិនិត្យទៅឃើញថា ដំណាំនោះដុះមានសភាពខុសគ្នា។

## ក_ការជ្រើសរើសទីកន្លែងដាំដុះ

កន្លែងដែលត្រូវជ្រើសរើសសំរាប់ដាំដុះគឺៈ

- មានប្រភពទឹកគ្រប់គ្រាន់ ។
- ទីកន្លែងស្រឡះគ្មានម្លប់ឈើ ។
- កន្លែងងាយស្រួលក្នុងការបញ្ចេញ បញ្ចូលទឹក ។
- ដីមានផ្ទៃក្រឡាតូចចំនួន ២ មានទំហំ ៦ម x ៥ម = ៣០ ម៉ែត្រក្រឡា ។
- មានភ្លឺព័ទ្ធជុំវិញ ។
- ដីស្រែមានជីជាតិ ។



## ខ_ការពិនិត្យពូជស្រូវដុះលាយ

ស្រូវមានច្រើនប្រភេទណាស់នៅក្នុងប្រទេសកម្ពុជាយើង ។ ដូច្នេះ ត្រូវជ្រើសរើសដោយប្រុងប្រយ័ត្ន នូវពូជសរិតសំរាំង (ពូជស្រូវបែកគុម្ពច្រើន, ធន់នឹងជម្ងឺ, ធន់នឹងសត្វល្អិត, ធន់នឹងការដួលរលំ) ។

គេអាចចែកស្រូវជា ៣ យ៉ាងគឺ ស្រូវស្រាលមានអាយុពី ១០៥ ទៅ ១១០ ថ្ងៃ, ស្រូវកណ្តាលមានអាយុពី ១២០ ទៅ ១៤០ ថ្ងៃ, និងស្រូវធ្ងន់មានអាយុពី ១៦០ ទៅ ១៨០ ថ្ងៃ ។

នៅពេលចាប់ផ្តើមស្ទូងដំបូង ពូជលាយចំរុះគ្នាមានការបែកគុម្ពដូចគ្នា ។ ប៉ុន្តែ នៅពេលចេញកួរយើងត្រូវពិនិត្យមើលសភាពខុសគ្នារវាងៈ

- កំពស់ៈ ពូជខ្លះទាប, ពូជខ្លះខ្ពស់ ។ ពូជទាប ច្រើនតែមានលើពូជស្រូវស្រាល ដែលចាប់ផ្តើមបែកគុម្ពពេញទំហឹងមុនគេ ។ រីឯពូជកណ្តាល និងធ្ងន់ ការបែកគុម្ពមិនដូចគ្នា ។ ដូច្នេះដើម្បីកុំអោយច្រឡំពូជ យើងត្រូវសង្កេតមើលបើមានដើមណាដុះខ្ពស់ខុសគេ មិនស្មើ ឬ បែកគុម្ពពេញទំហឹងខុសគេ ត្រូវដកដើមដុះលាយចេញអោយឆ្ងាយដើម្បីការពារកុំអោយពូជមិនសុទ្ធនេះនៅក្នុងស្រែ ។
- ពេលវេលានៃការចេញកួរៈ ការចេញកួរមិនដូចគ្នាទេ ទៅតាមអាយុរបស់ស្រូវ ឬ ទៅតាមប្រភេទស្រូវ( ស្រាល ,កណ្តាល, ធ្ងន់) ។ ដូច្នេះ បើស្រូវណាចេញកួរមុនគេហើយស្រូវដទៃទៀតមិនទាន់ចេញកួរ យើងត្រូវដកស្រូវចេញកួរមុនគេនោះចោល ។
- ស្លឹក-ដើមៈ ស្រូវខ្លះមានស្លឹកចុងស្រួច ខ្លះទៀតមានស្លឹករាងទ្រវែង ដើមខ្លះខុសគេ ។ យើងពិនិត្យមើលបើមានលក្ខណៈខុសគេត្រូវដកចោល ។
- ពណ៌គ្រាប់ស្រូវៈ ប្រភេទពូជស្រូវនៅពេលមានផ្កា ផ្លែ ទុំ មានពណ៌មិនដូចគ្នាទេ ។ ដូច្នេះ យើងត្រូវសង្កេតមើល បើឃើញមានភាពប្លែកពីគេចាប់ពី ២ ទៅ ៣ ភាគរយ យើងត្រូវដកចោល ដើម្បីកុំអោយមានលាយគ្នា ។
- មុំស្លឹក-ប្រភេទដំណេកកួរៈ ក្នុងវគ្គផលិត ស្រូវចាប់ផ្តើមចេញកួរ ។ ដូច្នេះ មុំស្លឹកស្រូវទូលាយ ឬ ញីក ឬ ដំណេកកួរស្រូវរង្វើល ឬ ញីក ហើយស្រូវទាំងនោះមានលក្ខណៈប្លែកពីគេក្នុងចំណោមស្រូវទាំងអស់ក្នុងស្រែ ត្រូវដកចោលកុំទុកអោយមាន ។
- ប្រភេទកួរស្រូវៈ យើងពិនិត្យមើលក្នុងស្រែ បើមានប្រភេទកួរខុសគេ យើងត្រូវដកចោល ។



- មុំស្លឹកអមកួរៈ ស្លឹកអមកួរស្រូវខ្លះ មានមុំចង្អៀត ខ្លះមានមុំទូលាយទៅតាមប្រភេទពូជ។ នៅក្នុងដំណាក់កាលផលិត យើងត្រូវសង្កេតមើលដើម, កំពស់, ស្លឹក, ពេលវេលាចេញកួរ និងមុំស្លឹកអមកួរ ដើម្បីកុំអោយមានពូជលាយគ្នា។
- ទំហំគ្រាប់ៈ គ្រាប់ស្រូវទាំងអស់មានទំហំមិនដូចគ្នាទេ។ គ្រាប់ស្រូវខ្លះមានទំហំធំ, ខ្លះតូច, ខ្លះរាងទ្រវែងទៅតាមប្រភេទពូជ។មុននឹងច្រូតកាត់ គួរពិនិត្យមើល បើមានគ្រាប់ស្រូវប្លែក ត្រូវច្រូតសរិតសំរាំង ហើយយកគ្រាប់ស្រូវខុសគេចេញ។
- វត្តមាន ឬ អវត្តមាននៃការដុះគ្រាប់កន្ទុយវែងៈ ដើមណាដែលមិនបង្ហាញអំពីលក្ខណៈធម្មតានៃពូជទេនោះគឺជាដើមលាយ។

## គ_ការច្រូតកាត់ និងជ្រើសរើសគ្រាប់ពូជ

នៅពេលដែលស្រូវជិតទុំ គេត្រូវបង្ហូរទឹកចេញពីស្រែអោយអស់ ដើម្បីអោយស្រូវឆាប់ទុំស្រុះ និងឆាប់ស្ងួតដីក្នុងស្រែ។ យកពូជស្រូវសុទ្ធទាំងនោះសំរាប់ធ្វើជាពូជនៅឆ្នាំក្រោយ។ ពូជសុទ្ធងាយស្រួលក្នុងការច្រូតកាត់ ព្រោះវាទុំស្មើគ្នា ស្រុះគ្នា និងមិនទុំបណ្តាក់។

ច្រូតកាត់រួចត្រូវចងជាកណ្តាប់ រួចដាក់ដោយឡែកចេញពីកណ្តាប់ស្រូវពីស្រែដទៃទៀត។ បន្ទាប់មកត្រូវយកពូជក្នុងកណ្តាប់មកពិនិត្យ រើសយកពូជសុទ្ធសំរាប់ធ្វើពូជឆ្នាំក្រោយ។ រួចហើយបោកបែនរោយហាលក្រោមពន្លឺថ្ងៃលើកន្ទេលស្អាត ឬ លើលានចាក់ស៊ីម៉ង់។

ត្រូវហាលរហូតដល់សំណើមក្នុងគ្រាប់មានប្រមាណ ១៤ ភាគរយ។ កិច្ចការនេះអាចប្រព្រឹត្តទៅពី ៣ ទៅ ៥ ថ្ងៃ។ បន្ទាប់មកត្រូវរក្សាទុកក្នុងថង់ ឬ បាវថ្មី ដោយចងផ្លាកលើពូជ (ឈ្មោះពូជ, ថ្ងៃ-ខែ-ឆ្នាំ នៅក្នុងបាវ ឬ នៅក្រៅបាវ)។

## ឃ_ការថែរក្សាពូជសុទ្ធ

ត្រូវថែរក្សាគ្រាប់ពូជសុទ្ធក្នុងទីកន្លែងណាដែលមានខ្យល់ចេញចូលបានល្អ ហើយគួរលាយជាមួយថ្នាំកំចាត់សត្វល្អិតដែលបំផ្លាញគ្រាប់ពូជ។

បញ្ជាក់ :

ក-គុណសម្បត្តិរបស់ពូជស្រូវសុទ្ធ

ឈ្មួញហ៊ានទិញដោយអោយតម្លៃខ្ពស់ៈ ដើមដុះស្មើគ្នា, ចេញកួរស្រុះគ្នា, ទុំស្មើគ្នា,ស្រួលច្រូត, ផលខ្ពស់, គ្រាប់ស្រូវសុទ្ធល្អ, អង្ករមិនបាក់ គុណភាពអង្ករល្អ ឆ្លើយតបទៅទីផ្សារ។

ខ-គុណវិបត្តិរបស់ពូជស្រូវមិនសុទ្ធ

ស្រូវមិនសុទ្ធនាំអោយចេញកួរមិនស្រុះគ្នា, កំពស់ដើមមិនស្មើគ្នា, ទុំមិនស្មើគ្នានាំអោយពិបាកច្រូតកាត់, អង្ករលាយពូជដទៃច្រើន, គ្រាប់អង្ករបាក់ជាច្រើនកំណាត់, គុណភាពស្រូវមិនល្អ, តម្លៃនៅទីផ្សារថោក (បាត់ប្រាក់ចំណូល)។ស្រូវសុទ្ធល្អមានទំហំគ្រាប់ស្មើគ្នាងាយស្រួលក្នុងការកិនជាអង្ករ មិនបាក់ព្រោះគេអាចតម្រូវលេខម៉ាស៊ីនកិនជាអង្ករតែមួយលេខ។ ចំណែកស្រូវមិនសុទ្ធ គេពិបាកតម្រូវលេខម៉ាស៊ីន ព្រោះគ្រាប់ស្រូវមានទំហំមិនស្មើគ្នា។



## V-តារាងប្រៀបធៀបក្នុងការវិភាគសេដ្ឋកិច្ច លើការងារបន្សុទ្ធគ្រាប់ពូជស្រូវ

| បរិយាយ | ផលស្រូវតាមទំលាប់របស់កសិករ | | ផលស្រូវតាមការអនុវត្តបច្ចេកទេសកសិកម្ម | |
|---|---|---|---|---|
| | កំរិតបាត់បង់គិត % | ទទួលបានគិតជា % | កំរិតបាត់បង់គិតជា % | ទទួលបានគិតជា % |
| ផលស្រូវក្រោយពីច្រូតកាត់ | ៧ | - | ២ | - |
| បរិមាណអង្ករក្រោយពីកិន នៅរោងចក្រ | ៣ | - | ១ | - |
| តំលៃអង្ករនៅទីផ្សារ | ៤ | - | ២ | - |
| សរុប | ១៤% | ៨៦% | ៥% | ៩៥% |



រៀបចំដោយលោក ជិត សុវណ្ណ និងស្រី ស្រស់ធីតា



# ដំណាំឈើហូបផ្លែខ្នាតតូចជាលក្ខណៈគ្រួសារ
# (Small-scale Fruit Orchards)

## I-សេចក្តីផ្តើម

ឈើហូបផ្លែជាប្រភេទដំណាំ ដែលផ្តល់នូវសារៈសំខាន់សំរាប់ទ្រទ្រង់រាងកាយរបស់មនុស្ស ឬក៏សត្វបានល្អក្នុងការផ្តល់ជីវជាតិនិងវីតាមីនសំរាប់សុខុមាលភាពនៃការរស់នៅ។ ម្យ៉ាងទៀតឈើហូបផ្លែជាប្រភពរុក្ខជាតិដែលផ្តល់ឱ្យបរិយាកាសមានភាពល្អប្រសើរ ព្រមទាំងការពារបាននូវកំដៅ, ខ្យល់ខ្លាំង និងរាំងខ្ទប់ ឬកាត់បន្ថយនូវការហូរច្រោះបង្កដោយសារទឹកភ្លៀង។

មិនតែប៉ុណ្ណោះ ផ្លែឈើផ្តល់នូវភាពពេញនិយមចំពោះមនុស្សក្នុងការហូបចុក ដែលធ្វើឱ្យអ្នកផលិតរកចំណូលបានយ៉ាងប្រសើរចំពោះគ្រួសារ និងជួយទ្រទ្រង់ដល់សេដ្ឋកិច្ចរបស់ប្រទេសថែមទៀត។
ជាដំណាំដែលធ្វើការដាំដុះម្តងទទួលផលបានយូរឆ្នាំ។ នៅពេលដែលដំណាំចាស់ថមថយទិន្នផល គេកាត់ដើមនោះរួចធ្វើការដាំដុះសាជាថ្មី មានសារៈប្រយោជន៍ក្នុងការផ្តល់នូវអនុផលជាឱសដុត ឬក៏អាចធ្វើជាឈើសំណង់តូចតាចសំរាប់សេចក្តីត្រូវការរបស់គ្រួសារបានថែមទៀតផង។

បច្ចុប្បន្ន ឈើហូបផ្លែមួយចំនួន ត្រូវបានទទួលការរាតត្បាតយ៉ាងធ្ងន់ធ្ងរពីសត្វល្អិត និងជំងឺដែលធ្វើឱ្យមានការខូចខាតជាច្រើន ជាពិសេសដំណាំក្រូចពោសាត់នៅក្នុងខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តពោធិសាត់.... នោះបណ្តាលមកពីការសាកមែកបន្តនៅលើដើមដែលមានរោគពីមុនមក។

ដូច្នេះ អ្នកដាំដំណាំឈើហូបផ្លែ ត្រូវតែមានផែនការច្បាស់លាស់ក្នុងការដាំដំណាំឈើហូបផ្លែ ដែលអាចផ្តល់សារៈប្រយោជន៍ខាងសេដ្ឋកិច្ចគ្រួសារបានល្អប្រសើរទៅថ្ងៃមុខ។

## II-គោលបំណង

១-បង្កើនការយល់ដឹងឱ្យកាន់តែខ្ពស់ ក្នុងការដាំដុះដំណាំឈើហូបផ្លែជាកលក្ខណៈគ្រួសារមានការរីកចំរើន។
២-បង្កើនសមត្ថភាពអនុវត្តបច្ចេកទេសដាំដុះដំណាំឈើហូបផែ ដើម្បីទទួលផលបានខ្ពស់ទាំងបរិមាណ និងគុណភាពតំរូវតាមសេចក្តីត្រូវការទីផ្សារ។
៣-បង្កើនប្រាក់ចំណូល បានពីការដាំដុះដំណាំឈើហូបផ្លែជាលក្ខណៈគ្រួសារ ឱ្យបានកាន់តែប្រសើរឡើង និងរក្សាបាននូវធនធានធម្មជាតិ និងបរិស្ថានល្អប្រកបដោយនិរន្តរភាពក្នុងផលិតកម្ម។



រៀបចំដោយលោក ជិត សុវណ្ណ និងស្រី ស្រស់ធីតា



## III-ការអនុវត្តន៍ដាំដុះដំណាំឈើហូបផ្លែរបស់កសិករកន្លងមក

- ជាអ្នកអភិរក្សនិយម ទុកដីភូមិឱ្យនៅទំនេរក្រោមម្លប់ឈើ (ស្វាយ ចាន់ លុត......) ដែលមានដើមធំៗ មិនហ៊ាន កាប់ដាំដំណាំថ្មី ។
- ការដាំដុះដំណាំឈើហូបផ្លែ ដោយមិនបានជ្រើសរើសពូជល្អ ។
- ការដាំដុះមិនបានអនុវត្តនូវបច្ចេកទេសដំណាំឈើហូបផ្លែ (ការធ្វើរណ្តៅ ការប្រើប្រាស់ជី ការកាត់តែងមែក.....) ។
- ដំណាំដែលបានដាំហើយមានលក្ខណៈប្រពៃណី និងជាដំណាំយថាផល ។
- ផលិតផលឈើហូបផ្លែ ខ្វះគុណភាព ។

## IV- បច្ចេកទេសក្នុងការដាំដុះដំណាំឈើហូបផ្លែ ជាលក្ខណៈគ្រួសារ

### ១_ការជ្រើសរើសពូជ សំរាប់ដាំដុះ

ការជ្រើសរើសពូជ ជាការងារមួយសំខាន់ណាស់ក្នុងការដាំដុះដំណាំឈើហូបផ្លែឱ្យបានល្អ ។ ពូជដំណាំមានច្រើនប្រភេទៈ

- ពូជបណ្តុះដោយគ្រាប់ ឬ ផ្លែ (ដូង ស្វាយ ខ្នុរ ស្វាយចន្ទី ត្របែក ម្កាក់ ។ល ។ មានតំលៃថោក ។
- ពូជដែលគេមិនប្រើគ្រាប់ដោយអនុវត្ត :

+ ការសាកមែក, ការតមែក, ការតត្រួយ, ការភ្ជាប់ភ្នែក ។ ដែលបច្ចុប្បន្នគេនិយមធ្វើ និងដាំដុះតែពូជដែលបានពីការភ្ជាប់ភ្នែក និងតមែកពីព្រោះ:

- ផ្តល់ផលមិនក្លាយ (ពូជសុទ្ធ ផ្លែល្អ), ឆាប់ផ្តល់ផលក្នុងរយៈពេល ៣ ឆ្នាំ ដូចជា ក្រូច ស្វាយ ជាដើម,......
- ពូជគ្មានជំងឺ, ពូជដែលផ្តល់ទិន្នផលខ្ពស់ ។

ក្នុងការជ្រើសរើសពូជដាំដុះជាលក្ខណៈគ្រួសារ កសិករអាចទិញដាំតែម្តង ។

### ២_ការជ្រើសទីតាំង និងការរៀបចំដីដាំដុះ

#### ២.១. អំពីទីតាំង

ដំណាំឈើហូបផ្លែ អាចដាំបានលើដីដែលមានស្ថានភាពជា ខ្ពង់រាប វាលរាប ជើងភ្នំ និងចំរាក់ភ្នំ ។

- ដីខ្ពង់រាបៈ មានលក្ខណៈរាបស្មើល្អ យើងមិនបាច់លើកជារងសំរាប់ដាំទេ ។ កន្លែងរបៀបនេះមិនសូវចំណាយច្រើន ក្នុងការដាំឈើហូបផ្លែឡើយ ។
- ដីវាលរាបៈ ជាដីរាបដែលធ្លាប់លិចទឹកជំនន់ក្នុងពេលខ្លះ ។ ដីប្រភេទនេះ ភាគច្រើនជាដីឥដ្ឋ ហើយជាំទឹកផង ។ ដូចនេះ បើធ្វើការដាំដុះឈើហូបផ្លែ គប្បីលើករងឱ្យបានខ្ពស់ផុតទឹកជំនន់ និងធ្វើភ្លឺខ្ពស់ព័ទ្ធជុំវិញការពារទឹកជំនន់ នៅឆ្នាំខ្លះ ។
- ដីចំរាក់ភ្នំៈ ជាដីខ្ពស់ហើយចោត មានជំរាលច្រើនជាង ១០% ។ កន្លែងរបៀបនេះ គប្បីធ្វើដីឱ្យស្មើជាថ្នាក់ៗ ទើបដាំដំណាំហូបឈើហូបផ្លែបានល្អ ។



## ២.២. ការរៀបចំដីដាំដុះ

- អំពីប្រភេទដីៈ ជាទូទៅ ដំណាំឈើហូបផ្លែត្រូវការដីស្រស់ទឹកល្អ ដីធូរ និងសំបូរជីជាតិ ដោយមិនប្រកាន់ថាដីនោះជាដីខ្សាច់ ល្បាយខ្សាច់ ដីឥដ្ឋ ឬ ល្បាយឥដ្ឋឡើយ ។
- ការភ្ជួររាស់ៈ ក្នុងការដាំដុះជាលក្ខណៈគ្រួសារ ការភ្ជួររាស់ដីជាការងារសំខាន់ បន្ទាប់ពីជ្រើស និងរៀបដីរួចហើយនោះ ។ ត្រូវភ្ជួររាស់ឱ្យបានជ្រៅ និងច្រើនដង ។ ចំពោះចំការលើករងថ្មីនៅវាលរាប មិនបាច់ភ្ជួររាស់ឡើយ ។
- ការរៀបចំរណ្តៅ ៈ ក្រោយពីការរៀបចំដីរួច ត្រូវធ្វើការវាស់វែងចន្លោះរណ្តៅតាមប្រភេទដី ។
  + ខ្នាតរណ្តៅធំ ១ម x ១ម x ១ម
  + ខ្នាតរណ្តៅមធ្យម ០,៧៥ម x ០,៧៥ម x ០,៧៥ម
  + ខ្នាតរណ្តៅតូច ០,៥០ម x ០,៥០ម x ០,៥០ម
  + ការជីករណ្តៅ ត្រូវយកដីស្រទាប់លើដាក់ដោយឡែក ពីដីស្រទាប់ក្រោម ។
  + រណ្តៅជីករួច ត្រូវទុកហាលថ្ងៃឱ្យបានយ៉ាងតិច ១៥ ថ្ងៃ មុនធ្វើការដាក់ជី និងលុបរណ្តៅ ។
  + បន្ទាប់មកត្រូវយកស្មៅ ឬចំបើងដាក់បាតរណ្តៅជាស្រទាប់ៗជាមួយដីស្រទាប់លើ ដែលលាយច្របល់ដោយជីផូស្វាត ឬ ជី ដេ-អា-ប៉េ ចំនួន ៥០០ ក្រាម បូករួមជីកំប៉ុស្ត ឬជីលាមកសត្វ ពុកផុយល្អ ចំនួន ២០-៣០ គក្រ ។

បញ្ជាក់ៈ បើសិនជាលុបរណ្តៅមិនទាន់ពេញ ត្រូវផ្សំដីស្រទាប់ក្រោម(លាយដូចដីស្រទាប់លើ) ហើយលុបបន្ថែមឱ្យកំពុងរណ្តៅប្រមាណ ២០- ៣០សម ពីមាត់រណ្តៅ ត្រៀមការស្រុតចុះនៅពេលខាងមុខ ។ រណ្តៅដែលបានរៀបចំនេះ គប្បីទុករយៈពេល ១ ខែ ទើបធ្វើការដាំដុះ ។

## ៣_ការដាំដុះកូនឈើហូបផ្លែ

ដើម្បីធានាភាពសមស្របទៅនឹងបច្ចេកទេស នឹងទទួលបានផលគាប់ប្រសើរជាទីពេញចិត្តនោះ ការដាំដុះដើមឈើហូបផ្លែ គប្បីយកចិត្តទុកដាក់លើសារៈសំខាន់ ៥ យ៉ាងគឺៈ



### ៣.១. ពេលវេលាដាំដុះ

- ដាំដុះនៅពេលល្ងាច ឬពេលដែលមានអាកាសធាតុត្រជាក់ជាការល្អ ។
- ដាំនៅដើមរដូវភ្លៀងក្នុងខែ មិថុនា និងកក្កដា ។
- ដាំនៅចុងរដូវភ្លៀងក្នុងខែ តុលា និងវិច្ឆិកា ។

### ៣.២. ការរៀបចំកូនឈើ

ការរៀបចំកូនឈើមានលក្ខណៈចាំបាច់ ដែលយើងត្រូវអនុវត្តឱ្យបានល្អ និងត្រឹមត្រូវ ព្រោះថាកូនឈើទាំងនេះ បានមកពីការភ្ជាប់ភ្នែក ។ យើងត្រូវដឹកជញ្ជូនកូនឈើទាំងនេះទៅដាក់តាមរណ្តៅ ដែលបានត្រៀមសំរាប់ដាំឱ្យបានរួចជាស្រេច ។



### ៣.៣. ការរៀបចំសំភារៈសំរាប់ដាំ

មុននឹងដាំកូនឈើ យើងគប្បីមានសំភារៈដូចជា ចបកាប់ កាំបិតធំ, តូច ពូថៅ បង្គោលឬស្សី ខ្សែសំរាប់ចង របាំង ធាងដូង ចំបើង...។

### ៣.៤. របៀបដាំកូនឈើ

យកចបកាប់កាយចំកណ្តាលរណ្តៅ ដែលបានរៀបចំទុកពីមុនក្នុងជំរៅ ១០-១៥ សម ឬលើសនេះទៅតាមទំហំថង់កូនឈើ។ ពេលដាំត្រូវយកកូនកាំបិតមកវះថង់ប្លាស្ទិក ហើយយកកូនឈើចេញ រួចដាក់កូនឈើថ្នមៗទៅក្នុងរណ្តៅ ដោយដៃម្ខាងទប់កូនឈើឱ្យត្រង់ល្អ ដៃម្ខាងទៀតកាយដីលុបរណ្តៅជុំវិញកូនឈើនោះឱ្យណែនល្មម រួចយកបង្គោលឬស្សីមកបោះឱ្យជាប់រឿងទេបន្តិច រួចហើយយកខ្សែចងផ្ទោបជាមួយកូនឈើឱ្យជាប់ការពារខ្យល់។ ក្រោយមក ត្រូវយកចំបើងស្ងួតមកគ្របជុំវិញគល់ដំណាំ និងដោតរបាំងស្លឹកដូងពីខាងលិច និងពីខាងកើត ដើម្បីការពារកំដៅ រួចហើយស្រោចទឹកឱ្យជោកជាការស្រេច។

## ៤_ការថែទាំដំណាំឈើហូបផ្លែ

### ៤.១. ការសំអាតស្មៅចង្រៃ

ការងារនេះត្រូវធ្វើឱ្យបានល្អ ព្រមទាំងធ្វើការជ្រុំជ្រួយដីជុំវិញគល់ដំណាំឱ្យបានជាប្រចាំ ដើម្បីឱ្យដំណាំបានលូតលាស់ឆាប់រហ័ស។

### ៤.២. ការស្រោចស្រព

បន្តការស្រោចស្រពដំណាំបន្ទាប់ពីការដាំរួច ដើម្បីរក្សាសំណើមឱ្យបានល្អ តាមតារាងខាងក្រោម (សំរាប់រដូវប្រាំង)។

| អាយុកាលដំណាំ | បរិមាណទឹកក្នុង១ដើម/លីត្រ | រយៈពេលស្រោចស្រព | សេចក្តីផ្សេងៗ |
|---|---|---|---|
| ៣ ខែ | ៦-១០ | ៣ ថ្ងៃម្តង | ក្នុងពេលដំបូង/ចាប់ផ្តើមលូតលាស់ |
| ១ ឆ្នាំ | ១០-១២ | ៧ ថ្ងៃម្តង | ពេលកំពុងលូតលាស់ |
| ២ ឆ្នាំ | ២០ | ៧ ថ្ងៃម្តង | ពេលកំពុងលូតលាស់ |
| ៣ ឆ្នាំ | ២៥-៣០ | ៧ ថ្ងៃម្តង | ចាប់ផ្តើមផ្លែផ្កា |
| ៤ ឆ្នាំ | ៣០-៣៥ | ៧ ថ្ងៃម្តង | លូតលាស់ផ្លែផ្កា |
| ៥ ឆ្នាំ | ៣៥-៤០ | ៧ ថ្ងៃម្តង | លូតលាស់ផ្លែផ្កា |



+ ការស្រោចស្រពមានទំនាក់ទំនងទៅនឹងរដូវកាល (រដូវភ្លៀង, រដូវប្រាំង) ប៉ុន្តែតាមបច្ចេកទេសគឺត្រូវរក្សាសំណើមឱ្យបានល្អ។

+ ចំពោះដំណាំស្វាយ ការស្រោចទឹកមិនត្រូវអនុវត្តទេនៅពេលស្វាយមុនចេញផ្កា។ បើយើងធ្វើការស្រោចទឹកវានឹងមិនចេញផ្កានៅរដូវដែលចេញផ្កាឡើយ ព្រោះថានៅក្នុងរយៈពេលស្វាយសំរាក ឬផ្អាកការលូតលាស់ គឺធ្វើសំយោគអាហារជំពូកម្សៅ និងស្ករ ដើម្បីត្រៀមទំ លុះទងផ្កាចេញមក។ ដូចនេះហើយ ទើបមានពេលមួយដែលយើងផ្តាច់ទឹកស្វាយរយៈពេលមួយខែ។ មានខ្លះគេដុតភ្លើងដើម្បីឱ្យកំដៅ បន្ថយជាតិសើមក្នុងដី គឺត្រូវការភាពស្ងួតល្មមនៅក្នុងដី។ ប៉ុន្តែពេលចេញផ្កាស្រុះហើយ ការឱ្យទឹកត្រូវចាប់ផ្តើមដោយស្រោចម្តងបន្តិចៗ ឱ្យសើមតែដីខាងលើប៉ុណ្ណោះ។ ការឱ្យទឹករបៀបនេះ ទឹកអាចលាងទងផ្កា ហើយផ្លែក៏បានចាប់ផ្តើមរីកធំឡើង។

## ៤.៣. ការដាក់ជីបំប៉នដំណាំ

ការដាក់ជីបំប៉នត្រូវធ្វើជា ៣ ដំណាក់កាលក្នុង ១ ឆ្នាំ។ ដូចនេះ បរិមាណជីដែលត្រូវដាក់មួយឆ្នាំ ត្រូវបែងចែកឱ្យស្មើៗគ្នា:

ដាក់លើកទី ១ ខែ មេសា, ដាក់លើកទី ២ ខែ សីហា, ដាក់លើកទី ៣ ខែ វិច្ឆិកា។

+ ការដាក់ជីនៅក្នុងចំការនៅពេលដែលដើមឈើនៅក្មេង

| តាមអាយុកាលដំណាំ | N.P.K 15-15-15 | ជីកំប៉ុស្ត |
|---|---|---|
| ឆ្នាំទី ១ | ៥០០ ក្រាម (០,៥០គក្រ) | ៤០- ៥០ គក្រ |
| ឆ្នាំទី២ | ១០០០ ក្រាម (១ គក្រ) | ៤០-៥០ គក្រ |
| ឆ្នាំទី៣ | ១៥០០ ក្រាម (១,៥០ គក្រ) | ៤០-៥០ គក្រ |

+ ការដាក់ជីនៅពេលឈើហូបផ្លែចាប់ផ្តើមផ្លែ

| តាមអាយុកាលដំណាំ | N.P.K 15-15-15 | ជីកំប៉ុស្ត |
|---|---|---|
| ឆ្នាំទី ៤ | ២០០០ ក្រាម (២ គក្រ) | ៦០-១០០ គក្រ |
| ឆ្នាំទី៥ | ២៥០០ ក្រាម (២,៥០ គក្រ) | ៦០-១០០ គក្រ |
| ឆ្នាំទី៦ | ៣០០០ ក្រាម (៣ គក្រ) | ៦០-១០០ គក្រ |
| ឆ្នាំទី៧ | ៣៥០០ ក្រាម (៣,៥០ គក្រ) | ៦០-១០០ គក្រ |
| ឆ្នាំទី៨ | ៤០០០ ក្រាម (៤ គក្រ) | ៦០-១០០ គក្រ |
| ឆ្នាំទី៩ | ៤៥០០ ក្រាម (៤,៥០ គក្រ) | ៦០-១០០ គក្រ |
| ឆ្នាំទី១០ | ៥០០០ ក្រាម (៥ គក្រ) | ៦០-១០០ គក្រ |

## ៤.៤. ការតាក់តែងមែកឈើហូបផ្លែ

តាក់តែងមែកឈើ មានគោលបំណងឱ្យដំណាំលូតលាស់ល្អ គ្មានជំងឺ និងបានផ្កាផ្លែល្អ ទាំងគុណភាព និងបរិមាណ ។ ដូចនេះ ត្រូវអនុវត្តៈ



- កាត់មែកងាប់ចោល
- កាត់មែកមានជំងឺចោល
- កាត់មែកបាក់បែកចោល
- កាត់មែកមានបញ្ញើរក្អែកចោល
- កាត់មែកលំពង់ចោល ( មែកស៊ីជីខ្លាំង និងគ្មានផែ )
- កាត់មែកជិតគ្នាពេក ឬមែកកកិតគ្នាចោល
- កាត់មែកដែលមិនអាចទទួលពន្លឺបានចោល
- កាត់មែកដែលមានមុំ ៩០ ចោល

វិធីសាស្ត្រកាត់តែងមែកមានច្រើន ប៉ុន្តែសំខាន់មានពីរៈ

ក-ការតាក់តែងមែកដើម្បីបានទ្រង់ទ្រាយដើមៈ

ត្រូវចាប់ផ្តើមតាំងពីដើមនៅតូចក្នុងឆ្នាំដំបូង ។ ត្រូវកាត់មែកខ្នែង ដែលបែកចេញមកតាមដើមឱ្យអស់ ( ពីលើដីប្រមាណ ៣០-៤៥ សម) ដើម្បីឱ្យគល់ស្រឡះ ពិសេសចំពោះកូនដំណាំឈើហូបផ្លែដែលតមែក ។ បន្ទាប់ពីកាត់ពន្លក ឬមែកក្រោមអស់ហើយ ចាំបាច់ត្រូវកាត់តែងមែកដែលបានគ្រោងរាងឱ្យដើមឈើសមរម្យ និងជ្រើសរើសទុកមែករឹងមាំ និងមុំទូលាយ ២-៤ មែក ។

ខ-ការកាត់តែងមែកដើម្បីត្រៀមឱ្យដើមឈើចេញផ្កាផ្លែបានទៀងទាត់ៈ

ធម្មតាដើមឈើដែលដុះលូតលាស់មានស្លឹកច្រើនពេកនោះ វានាំកើតមានការមិនសមស្របសារធាតុចិញ្ចឹម ។ បើវាទទួលសារធាតុ N ច្រើនហួសរហូតពេញមួយឆ្នាំ ដើមឈើនោះក៏មិនអាចចេញផ្កា ព្រោះដើមឈើមុនពេលចេញផ្កា ត្រូវមានអាហារពួក ប៉ូតាស្យូម $K_2O$ គ្រប់គ្រាន់ជាមុនសិន ។ ដូចនេះ ចាំបាច់ត្រូវកាត់តែងមែកចេញខ្លះ ដើម្បីបង្គ្រប់សារធាតុចិញ្ចឹមក្នុងកំឡុងមុនពេលចេញផ្កា ។

គ-ពេលវេលាកាត់តែងមែកៈ

ការកាត់តែងមែក គេនិយមអនុវត្តនៅពេលក្រោយការប្រមូលផលរួច និងមួយពេលទៀត គឺដើមរដូវរងា ( ក្រោយរដូវភ្លៀង) ។

- ការកាត់តែងមែកក្រោយពេលប្រមូលផល :

វាជារដូវក្តៅ ដើមឈើត្រូវការអាហារមកចិញ្ចឹមដើម,មែកច្រើន ដូចនេះការកាត់តែងមែកព្រមជាមួយគ្នាការដាក់ជីបំប៉ន និងស្រោចទឹកមានសារៈសំខាន់ណាស់ សំរាប់បន្តការលូតលាស់ និងផ្កាផ្លែលើកក្រោយទៀត ។

- ការកាត់តែងមែកក្រោយរដូវភ្លៀង :

ក្នុងកំឡុងរដូវភ្លៀង ដើមឈើបានទទួលអាសូតច្រើន ហើយការលូតលាស់មែកខ្នែងស្លឹក ច្រើនហួសពីសេចក្តីត្រូវការ ។ ករណីនេះ បណ្តាលឱ្យកើតជំងឺផ្សិត និងសំបូរសត្វល្អិតចូលបំផ្លាញ ។ ដូចនេះការកាត់តែងមែកពេលនេះ ធ្វើឱ្យដើមឈើមានលទ្ធភាពប្រមូលពួកម្សៅ និងស្ករមកចិញ្ចឹមសរីរាង្គបានច្រើនជាងអាសូត ( N ) វិញ ។



## ៥_ការប្រមូលផលដំណាំឈើហូបផ្លែ

### ៥.១. ពេលវេលាប្រមូលផល

ការប្រមូលផលនេះគឺជាលទ្ធផលចុងក្រោយរបស់ដំណាំ។ ពេលវេលាប្រមូលផល វាអាស្រ័យទៅតាមប្រភេទដំណាំនីមួយៗ និងលក្ខណៈរបស់ពូជ និងធាតុអាកាសតាមតំបន់ដាំដុះ។ ម្យ៉ាងទៀត ការប្រមូលផលត្រូវពិនិត្យសង្កេតមួយទៀត លើទ្រង់ទ្រាយរបស់ផ្លែឈើ ពណ៌សំបុរ និងធ្វើការបេះផ្លែយកមកពិនិត្យមើលតែម្តង។

ចំពោះដំណាំខ្លះ ការប្រមូលផលចាប់ផ្តើមតាំងពីផ្លែនៅខ្ចី ផ្លែចាស់ ផ្លែទុំ ជាប្រភេទផ្លែដែលគេបរិភោគ ឬ តាមសេចក្តីត្រូវការផ្សេងៗទៅតាមដំណាក់កាលរបស់ផ្លែឈើនោះ។

### ៥.២. តម្រូវការទីផ្សារ

ទីផ្សារតំរូវឱ្យអ្នកដាំគិតគូរឱ្យបានខ្ពស់ យើងត្រូវប្រមូលផលឱ្យបានទាន់ពេលវេលា ហើយត្រូវកំណត់គុណភាពផលិតផល ដែលមានដាក់ដោយឡែកៗពីគ្នា (លេខ១ និងលេខ២) ទៅតាមតំរូវការអ្នកទិញ។

### ៥.៣. សំភារៈ និងឧបករណ៍ប្រមូលផល

សំភារៈ និងឧបករណ៍ប្រមូលផល ត្រូវរៀបចំឡើងឱ្យបានងាយស្រួលដល់ការបេះផ្លែឈើ និងធានាគុណភាពល្អដល់ផ្លែឈើ។

សំភារៈឧបករណ៍នេះមានៈ កាំបិតតូច-កាំបិតធំ-កន្ត្រៃ-កន្ត្រៃងដងខ្លី ឬ វែង-ទំពក់ (ឈើ ឬ ឫស្សី) -កញ្ជ្រែ ឬ កេះ។



# V-វិភាគសេដ្ឋកិច្ចលើការដាំដុះឈើហូបផ្លែជាលក្ខណៈគ្រួសារ

## ផ្ទៃដី ១០០០ ម៉ែត្រការ៉េ ក្នុងរយៈពេល ៥ ឆ្នាំ នៃការផលិត

| បរិយាយ | ឯកតា | តាមប្រពៃណី | | | ទាមបច្ចេកទេស | | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | ចំនួន | តំលៃ ឯកតា (រ) | តំលៃសរុប (រៀល) | ចំនួន | តំលៃ ឯកតា (រ) | តំលៃសរុប (រៀល) | |
| ការចំណាយ | | | | | | | | |
| ការរៀបចំដី | ម ២ | - | - | - | ១០០០ | ១០០០ | ១០០០០០០ | ជីកស្រះចាក់ដីបំពេញ |
| ដើមស្វាយដាំយូរឆ្នាំ | ដើម | - | - | - | - | - | - | ដើមស្វាយពីដូនតា ១០០០ម ២ អាយុ ៤០ ឆ្នាំ |
| ចំនួនស្វាយពូជ | ដើម | - | - | - | ៨០ | ៥០០០ | ៤០០០០០ | ដាំ (៣,៥០ម x៣,៥០) |
| ដំណាំម្នាស់ | ដើម | - | - | - | ២០០០ | ២០០ | ៤០០០០០ | ដាំតាមចន្លោះជួរស្វាយ ឆ្នាំទី១-ទី២ |
| ការថែទាំ | ឆ្នាំ | - | - | - | ៥ | ២០០០០ | ១០០០០០០ | ជី និងពលកម្ម |
| សរុប | | | | | | | ២៨០០០០០ | |
| ចំណូល | | | | | | | | |
| ដំណាំម្នាស់ឆ្នាំទី១-ទី២ | ផ្លែ | - | - | - | ១៨០០ | ៥០០ | ៩០០០០០ | ខូច២០០ដើម |
| កូនម្នាស់ | ដើម | - | - | - | ៥x១៨០០ | ២០០ | ១៨០០០០០ | ១ដើមមានកូន៥ |
| ស្វាយដើមធំដាំយូរឆ្នាំ | ផ្លែ | ២០០០ | ២០០ | ៤០០០០០ | - | - | - | |
| ដាំស្វាយពូជឆ្នាំទី៣ | ផ្លែ | - | - | - | ១០ x ៨០ | ៥០០ | ៤០០០០០ | ផ្លែដំបូង១០ផ្លែ/ដើម (ឆ្នាំទី៣) |
| ដាំស្វាយពូជឆ្នាំទី៤ | ផ្លែ | - | - | - | ៣០ x ៨០ | ៥០០ | ១២០០០០០ | ផ្លែឆ្នាំទី៤-៣០ផ្លែ/ដើម |
| ដំណាំស្វាយពូជឆ្នាំទី៥ | ផ្លែ | - | - | - | ៤០ x ៨០ | ៥០០ | ១៦០០០០០ | ផ្លែឆ្នាំទី៥-៤០ផ្លែ/ដើម |
| សរុបចំណូល៥ឆ្នាំ | ២ ៤០០ ០០០៛០០ | | | | ៥ ៩០០ ០០០៛០០ | | | |
| ចំណេញ | ២ ៤០០ ០០០រ០០ | | | | ៣ ១០០ ០០០រ០០ | | | ស្វាយពូជដាំអាចប្រមូលផល៥ឆ្នាំទៀតទើបកាប់ដាំជាថ្មី។ |

# សត្វកណ្ដុរ និងវិធានការកំចាត់
# (Rodent Control)

## I-ទស្សនៈទូទៅ

សត្វកណ្ដុរជាសត្វម្យ៉ាងដែលធ្វើការបំផ្លិចបំផ្លាញយ៉ាងសំខាន់ និងធ្វើឱ្យខាតបង់ដល់កសិករជាងពាក់កណ្ដាលនៃពិភពលោក ដែលប្រកបមុខរបរកសិកម្មគ្រប់ប្រភេទបានជួបប្រទះ ពិសេសគឺដំណាំស្រូវ។ តាមរយៈការកើនឡើងយ៉ាងលឿននៃចំនួនសត្វចង្រៃនេះ កម្មវិធីកំចាត់សត្វកណ្ដុរត្រូវធ្វើដោយខានមិនបាន ព្រោះកណ្ដុរវាធ្វើឱ្យខូចខាត និងធ្លាក់ចុះទិន្នផល ៥%-១០% នៃដំណាំស្រូវ ឬអាចលើសពីនេះ។

នៅតាមបណ្ដាប្រទេសជឿនលឿន គេប្រើប្រាស់បច្ចេកទេសផ្សេងៗក្នុងគោលបំណងកំចាត់សត្វដ៏ចង្រៃនេះ ដើម្បីបង្កើនផលិតផលដំណាំស្រូវ និងគុណភាពស្រូវសំរាប់បំរើសេចក្ដីត្រូវការរបស់មនុស្ស ក៏ដូចធ្វើឱ្យសេដ្ឋកិច្ចជាតិរីកចំរើន ។

នៅក្នុងប្រទេសកម្ពុជា សត្វចង្រៃនេះមានតួលេខខ្ពស់ ហើយការកំចាត់ពួកវារៀងរាល់ឆ្នាំនៅមានកំរិតទាបមិនទាន់សមស្របទៅតាមការកើនឡើងនៃចំនួនកណ្ដុរ ដោយកសិករដែលដាំដំណាំស្រូវខ្វះបច្ចេកទេស ក៏ដូចជាមធ្យោបាយផ្សេងៗក្នុងការកំចាត់។ ដូចនេះ កសិកររងការខូចខាតច្រើនដោយសារបញ្ហានេះ។ ដោយរងការខូចខាតនេះហើយ ទើបគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចក្រសួងកសិកម្មមានវិធានការ ដើម្បីធានាឱ្យបាននូវការកាត់បន្ថយជាអតិបរមានៃការបំផ្លាញដោយសត្វកណ្ដុរចង្រៃនេះតាមរយៈការផ្ដល់ចំណេះដឹង និងបច្ចេកទេសសំរាប់អនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

## II-គោលបំណង

១-បង្កើនការយល់ដឹងអំពីការវិវត្តន៍ និងការបំផ្លាញរបស់សត្វកណ្ដុរ។

២-បង្កើនការយល់ដឹងពីវិធានការ ការកំចាត់សត្វកណ្ដុរ។

៣-បង្កើនការយល់ដឹងពីការគ្រប់គ្រងផលិតកម្មកសិកម្មឱ្យមានប្រសិទ្ធភាព។

## III-ការអនុវត្តន៍របស់កសិករកន្លងមក

- មិនស្គាល់លក្ខណៈរូបសាស្ត្រនៃសត្វកណ្ដុរ។ កសិករភាគច្រើនស្គាល់សត្វកណ្ដុរ តែមិនបានស៊ីជំរៅដល់លក្ខណៈរូបរបស់វាទេ។
- ខ្វះការយល់ដឹងពីការបន្តពូជរបស់សត្វកណ្ដុរ គឺគាត់គ្រាន់តែដឹងពីសត្វនេះបន្តពូជដូចសត្វផ្សេងទៀត តែមិនទាន់បានដឹងថាតើកណ្ដុរបង្កើតកូនបានប៉ុន្មានក្នុង ១ ឆ្នាំប៉ុន្មានដង រយៈពេលផ្ដើម, អំឡុងពេលដែលពេញវ័យ, ចំនួនញីឈ្មោលកូនកណ្ដុរនៅពេលកើត។



រៀបចំដោយលោក ជិត សុវណ្ណ និងស្រី ស្រស់ធីតា

- កសិករយល់ដឹងពីកណ្តុររវារស់នៅក្នុងសំបុកហើយនិងរន្ធ តែគាត់មិនបានយល់ថា រន្ធ និងសំបុក តើមានសារៈសំខាន់អ្វី ។ រីឯ ចលនាពីកន្លែងមួយទៅកន្លែងមួយ មិនដឹងផងដែរថាមានគោលដៅដែរ ឬ អត់?
- កសិករយល់ច្បាស់ពីការបំផ្លាញរបស់សត្វកណ្តុរ (ពួកគាត់កំពុងតែដឹងថាសត្វចង្រៃនេះអ្វីក៏វាស៊ីដែរ បើវាមិនស៊ីទេក៏វាកកេរចោល) ។
- វិធានការកំចាត់សត្វកណ្តុរ របស់កសិករនៅមានកំរិត (ភាគច្រើន ទំលាប់តាមប្រពៃណី ដូចជាការដាក់អន្ទាក់, ដាក់អង្គប់, ជីករន្ធ, តាមរយៈសត្វរំពា និងធ្វើតែឯកឯង) ។

## IV- វិធានការកំចាត់សត្វកណ្តុរ

### ១_ការស្វែងយល់ពីសត្វកណ្តុរ

សត្វកណ្តុរជាសត្វចង្រៃដែលបំផ្លាញដំណាំរបស់កសិករ ពិសេសគឺស្រូវ ។ បើគ្មានវិធានការទប់ស្កាត់ទេ វានឹងបំផ្លាញយើងឱ្យខូចខាតខ្លាំង ។ កម្មវិធីកំចាត់សត្វកណ្តុរធ្វើរួមគ្នា ២ លើកយ៉ាងតិចក្នុង ១ ឆ្នាំ (នៅពេលសាបព្រោះ និងពេលទឹកឡើងក្នុងខែ កញ្ញា និង ខែ តុលា) ។



#### ១.១ លក្ខណៈរូបនៃសត្វកណ្តុរ

- ភ្នែកមិនពូកែ ។
- វាងវៃ, ការស្រងក្លិន, ស្ទាប និង ស្តាប់ ។
- ពុកមាត់ និងរោមវែងសំរាប់នាំផ្លូវពេលវាផ្លាស់ប្តូរទីកន្លែង ។
- ធ្មេញមុខដូចពន្លាក ថ្គាមដូចកន្ត្រៃ ។
- ពូកែហែលទឹក ។
- ពូកែវារឡើង ។

#### ១.២ ការបន្តពូជរបស់សត្វកណ្តុរ

- កណ្តុរមានអាយុរយៈ ១ ឆ្នាំ ឬអាចលើសពីនេះបន្តិចបន្តួច ។
- អាចបន្តពូជបាន ៤ ដងក្នុង ១ ឆ្នាំ ។
- ចំនួនកូនគិតជាមធ្យមក្នុង ១ លើកៗ ចាប់ពី ៦ ទៅ ៨ ក្បាល ។
- រយៈពេលផើម ២១-២៣ ថ្ងៃ ។
- ពេញវ័យរយៈពេល ៣ ខែ ។
- ចំនួនកូនមួយលើកៗចំនួនញី និងឈ្មោលស្មើគ្នា ។
- តាមការប៉ាន់ស្មាន កណ្តុរញីឈ្មោលអាចបង្កើតបាន ២៤ កណ្តុរក្នុង ១ ឆ្នាំ ។ តាមការវិវត្តកំណើតតៗគ្នា កណ្តុរញីមួយ ឈ្មោលមួយ អាចបង្កើតបានជាង ៥០០ ក្បាល ក្នុង ១ ឆ្នាំ ។

### ១.៣ ចលនា និងទីជំរករបស់សត្វកណ្ដុរ

- កណ្ដុរភាគច្រើនរស់នៅជាក្រុម ហើយដើរកស៊ីចំងាយពីរូង ២០ម-៨០ម ជួនកាលអាចដល់ទៅ ១០០ម។ ការផ្លាស់ជំរកផ្ទាល់ខ្លួន ជាទូទៅគ្មានទិសដៅ ។

### ១.៣ ចំណីអាហារដែលចូលចិត្ត និងទំលាប់ស៊ីរបស់សត្វកណ្ដុរ

- ចំណីទី ១: ដើមស្រូវ, គ្រាប់ស្រូវ និងគ្រាប់ពោតខ្ចី។
- ចំណីទី ២: ដំឡូងឈើ, ដូងអំពៅ, ពោត។
- ចំណីផ្សេងៗ: សត្វល្អិត, ខ្យង, ត្រីងៀត, សត្វងាប់។
- កណ្ដុរ ១ ក្បាលស៊ីស្រូវពី ១០-២០ ក្រាមក្នុង ១ ថ្ងៃ។

### ១.៥ ជំរកដែលចូលចិត្តរបស់សត្វកណ្ដុរ

- កន្លែងសមរម្យអាចការពារនឹងការយាយីរបស់សត្វរំពា ហើយជាទីមានអាហារដែលវាចូលចិត្ត និងស្រួលធ្វើចលនា ។

### ១.៦ ទំលាប់កាយរូងរបស់សត្វកណ្ដុរ

- កណ្ដុរធ្វើរូង គឺសំរាប់បន្តពូជ។ រូងកណ្ដុរមានច្រកចំមួយ និងរូងចេញមួយ ឬច្រើនមានប្រវែង ៣០-១៥០សម បត់បែនក្រោមដី ជំរៅប្រហែល ៦០ សម ហើយមានផ្នែកស្តុកចំណីអាហារ និងកូន។

### ១.៧ លក្ខណៈនៃការបំផ្លាញរបស់សត្វកណ្ដុរ

- ការបំផ្លាញរបស់សត្វកណ្ដុរ មាននៅគ្រប់ដំណាក់កាលនៃដំណាំស្រូវ។ វាបំផ្លាញមានកំរិតខ្ពស់នៅដំណាក់កាលស្រូវផើម ឬទុំ។ រយៈពេលនៃការបំផ្លាញគឺ នៅក្នុងរដូវវស្សាច្រើនជាងរដូវប្រាំង ព្រោះនៅរដូវវស្សាសំបូរចំណីទឹក និងជំរកដែលផ្តល់ឱ្យមានភាពងាយស្រួលក្នុងការបង្កបង្កើតកូនចៅ។ អត្រាបំផ្លាញខ្ពស់គឺ បណ្តាលមកពីការកើនឡើងរបស់សត្វកណ្ដុរ ស្ថានភាពភូមិសាស្ត្រអំណោយផល គ្របដណ្តប់ទៅដោយស្រូវ ស្មៅ នៅលើដី ជាទូទៅការបំផ្លាញខ្លាំងច្រើននៅចំកណ្តាលស្រែ។

ដំណាក់កាលដែលសត្វកណ្ដុរបំផ្លាញដំណាំស្រូវ:

+ ការបំផ្លាញក្នុងថ្នាលសំណាប ដោយស៊ីគ្រាប់ពូជស្រូវ ឬដកពន្លកគ្រាប់ពូជស្រូវស៊ី។
+ ដកសន្ទូងទើបស្ទូងរួច ធ្វើឱ្យបាត់ដើម ឬគុម្ពស្រូវនៅដំណាក់កាលស្រូវផើម។
+ កាត់ដើមស្រូវនៅពេលស្រូវកំពុងដាក់គ្រាប់។
+ កាត់ដើមស្រូវនៅពេលស្រូវទុំ ដើម្បីស៊ីគ្រាប់ស្រូវ។

## ២_វិធី ៤ យ៉ាងក្នុងការកំចាត់សត្វកណ្តុរ

### ២.១. ដោយវិធីដាំដុះ

បន្ថយចំណីអាហារ និងជំរកដោយកាប់ព្រៃជុំវិញស្រែ ហើយប្រមូលដុតឱ្យអស់ពីស្រែ ។ ដាំស្រូវឱ្យដំណាលគ្នា ឬជៀសវាងទុំមុន និងក្រោយ, បន្ថយទំហំភ្លឺស្រែ ទាំងនេះអាចបន្ថយជំរករន្ធ និងបន្ថយទីដុះស្មៅ ។

### ២.២. ដោយវិធីបែបមេកានិក

នៅក្នុងវិធីនេះ យើងលើកយកវិធីសាស្ត្រមេកានិកមួយចំនួនដូចជា:
- ការដាក់អន្ទាក់ ដើម្បីទាក់កណ្តុរដែលបំផ្លាញស្រូវទាំងដុំៗនៅក្នុងស្រែ ។
- ការធ្វើឱ្យឡប់ ដោយមានការចូលរួមក្រុមមនុស្សច្រើន ហ៊ុមព័ទ្ធ នាំគ្នាដេញបង្អើលពីខាងៗឱ្យរត់មកផ្តុំគ្នានៅកណ្តាលហើយវាយសំលាប់ដោយដំបង ។
- ការជីករន្ធ: វិធីនេះប្រើដោយចបកាប់ ឬចបជីក បំផ្លាញរន្ធឱ្យចេញមកក្រៅ យើងអាចបំផ្លាញបាន ។
- ការដុតបំផ្លាញ: គឺជាការដុតបំផ្លាញដោយគ្រឿងឆេះ ។
- ការប្រើបំពង់: យើងយកឫស្សី ៤-៥ ម ដោយបុកទំលុះថ្នាំងឱ្យអស់ ។ បើបំពង់ជ័រ ឬដែក ចងបិទរន្ធម្ខាងដោយក្រណាត់កៅស៊ូ ទុកប្រហោងតែមួយចំហៀង រួចយកទៅដាក់តាមបណ្តោយភ្លឺស្រែ យកស្មៅ ឬចំបើងគ្របពីលើ ។ ១ ថ្ងៃ លើកបំពង់នេះ ២ ដង: ព្រឹកម្តង, ល្ងាចម្តង ដើម្បីចាប់សំលាប់សត្វកណ្តុរ ។




### ២.៣. ដោយវិធីប្រើថ្នាំគីមី

ប្រភេទថ្នាំចែកជា ២ ក្រុម និងឧស្ម័ន ១ ក្រុម:
- ក្រុមថ្នាំបំពុលអាចស្លាប់ជាបន្ទាន់ ក្រោយពេលស៊ីនុយចូលដល់ក្នុងពោះ ។
- ក្រុមថ្នាំពុលធ្វើឱ្យមានជំងឺរ៉ាំរ៉ៃ ឱ្យកណ្តុរស៊ីនុយ ២-៣ ដង ទើបងាប់ ។
- ប្រភេទឧស្ម័នមានជាតិ កាល់ស្យូម ស្យានីដ (Calcium Cyanide) ។ ឧស្ម័ននេះត្រូវថ្ងៃ និងខ្យល់ វាប្រែទៅជាឧស្ម័នអ៊ីដ្រូហ្សែន ស្យានីដ (Hydrogen Cyanide) គឺជាឧស្ម័នពុលធ្វើឱ្យកណ្តុរស្លាប់បាន ។

### ២.៤. ដោយវិធីតាមបែបជីវសាស្ត្រ

- ចិញ្ចឹមសត្វរំពា ដូចជា ឆ្កែ, ឆ្មារ ។ល។ ឱ្យស៊ីកណ្តុរ ។
- ឈីម៉ូស្ទីរីឡង់ (Chemosterilants Cyanide) ជាថ្នាំធ្វើឱ្យកណ្តុរពុំអាចបង្កបង្កើតកូនបាន ។

ថ្នាំនេះ ជាវិធានការដ៏ល្អតែមួយគត់ ដែលអាចលុបបំបាត់ពូជកណ្តុរបានបន្ទាប់ពីប្រើថ្នាំគីមី ។

## ៣_របៀបដាក់ថ្នាំ និងដាក់នុយ

### ៣.១. របៀបប្រើថ្នាំ

- មុនដំបូងត្រូវមើលបានច្បាស់នូវផ្លាកសញ្ញា, របៀបប្រើនៅលើធុង ឬនៅលើសំបកកញ្ចប់ ដាក់ថ្នាំមុនយកទៅលាយ បន្ទាប់មកត្រូវយកកន្ទក់ ឬកញ្ចុំងអង្ករ និងសំភារៈដែលកណ្ដុរចូលចិត្ត ដូចជាបំពង់ឬស្សី សំបកធុងជ័រ សំបកដូង ដើម្បីដាក់នុយ ។

### ៣.២. ការដាក់នុយ

- យើងដាក់នុយមាន ៥ កន្លែងក្នុង ១ ហិកតារ ចន្លោះពីកន្លែងមួយទៅកន្លែងមួយ ត្រូវឃ្លាតគ្នាយ៉ាងតិច ៥០ ម។ កន្លែងល្អ ១ ម ពីភ្លឺស្រែ ត្រូវដាក់នុយចំនួន ២ ស្លាបព្រាបាយ ក្នុងប្រដាប់ដាក់នុយនីមួយៗ ហើយកន្លែងដាក់នុយនោះ ត្រូវដាក់ប្រដាប់ដាក់នុយឱ្យបានចាប់ពី ២ ឡើងទៅ ហើយឃ្លាតគ្នាប្រវែង ១ ម។

## V-ការវិភាគកំណើនសត្វកណ្ដុរ និងការបាត់បង់ស្រូវ

តារាងនៃការវិវត្តន៍ និងការបំផ្លាញរបស់សត្វកណ្ដុរ (ចាប់ផ្ដើមពីមេ ១ ឈ្មោល ១)

| | | | | |
|---|---|---|---|---|
| ៩០ ថ្ងៃ | សប្ដាហ៍ទី ០ | កណ្ដុរញី ១ ក្បាល | កណ្ដុរឈ្មោល ១ ក្បាល | កណ្ដុរ ២ ក្បាល |
| | កំរិតបំផ្លាញ | ១.៣៥ គក្រ | ១.៣៥ គក្រ | ២.៧ គក្រ |
| ៩០ ថ្ងៃ | សប្ដាហ៍ទី ១ | កណ្ដុរ ៣ ក្បាល | កណ្ដុរ ៣ ក្បាល | កណ្ដុរ ៦ ក្បាល |
| | កំរិតបំផ្លាញ | ៤.០៥ គក្រ | ៤.០៥ គក្រ | ៨.១ គក្រ |
| ៩០ ថ្ងៃ | សប្ដាហ៍ទី ៤ | កណ្ដុរ ១២ ក្បាល | កណ្ដុរ ១២ ក្បាល | កណ្ដុរ ២៤ ក្បាល |
| | កំរិតបំផ្លាញ | ១៦.២ គក្រ | ១៦.២ គក្រ | ៣២.៤ គក្រ |
| ៩០ ថ្ងៃ | សប្ដាហ៍ទី ៧ | កណ្ដុរ ៤៨ ក្បាល | កណ្ដុរ ៤៨ ក្បាល | កណ្ដុរ ៩៦ ក្បាល |
| | កំរិតបំផ្លាញ | ៦៤.៨ គក្រ | ៦៤.៨ គក្រ | ១២៩.៦ គក្រ |
| ៩០ ថ្ងៃ | សប្ដាហ៍ទី ១០ | កណ្ដុរ ១៩២ ក្បាល | កណ្ដុរ ១៩២ ក្បាល | កណ្ដុរ ៣៨៤ ក្បាល |
| | កំរិតបំផ្លាញ | ២៥៩.២ គក្រ | ២៥៩.២ គក្រ | ៥១៨.៤ គក្រ |
| ៩០ ថ្ងៃ | សប្ដាហ៍ទី ១៣ | កណ្ដុរ ៧៦៨ ក្បាល | កណ្ដុរ ៧៦៨ ក្បាល | កណ្ដុរ ១៥៣៦ ក្បាល |
| | កំរិតបំផ្លាញ | ១០៣៦.៨ គក្រ | ១០៣៦.៨ គក្រ | ២០៧៣ គក្រ |
| ៩០ ថ្ងៃ | សរុបកណ្ដុរ | កណ្ដុរ ១០២៤ ក្បាល | កណ្ដុរ ១០២៤ ក្បាល | កណ្ដុរ ២០៤៨ ក្បាល |
| | សរុបកំរិតបំផ្លាញ | ១៣៨២.៤ គក្រ | ១៣៨២.៤ គក្រ | ២៧៦៤.៨ គក្រ |

# ដំណាំដំឡូងឈើ
# (Cassava)

## I-សេចក្ដីផ្ដើម

ជាទូទៅ នៅប្រទេសកម្ពុជាយើងភាគច្រើនប្រជាកសិករដាំដំឡូងឈើនេះនៅតាមជួរជើងភ្នំ តាមតំបន់ខ្ពង់រាប ឬ នៅវាលរាបនានា និងតាមរដូវកាល។ ដំឡូងឈើនេះមានពីរប្រភេទគឺៈ

- ប្រភេទទី១ៈ ដើម, មើមនិងធាងរបស់វាពណ៌សកសិករហៅថាដំឡូងមី។
- ប្រភេទទី២ៈ ដើម, មើមនិងធាងរបស់វាពណ៌ក្រហមកសិករភាគច្រើនហៅថាដំឡូងគ។ មើមដំឡូងឈើទាំង ២ ប្រភេទគេអាចហូបបានដូចគ្នាតាមការស្ងោរចំអិនទាំងមូល។



ក្រោយបកសំបករួចគេឈូសស្ដើងៗវេចខ្ចប់ជា នំបត់ អន្សម ឬ ធ្វើបង្អែមផ្សេងៗ កិនជាម្សៅកែច្នៃជាចំណីអាហារបានច្រើនបែបច្រើនយ៉ាងសំរាប់មនុស្ស និងសត្វ។ ចំណែកឯស្លឹកត្រួយរបស់វាយើងអាចយកទៅស្ងោរ ឬ ស្លតាមការនិយមទៅតាមតំបន់នីមួយៗដែលគេចូលចិត្ត។

ដំឡូងឈើពូជថ្មីមួយទៀត ដែលទទួលបានទិន្នផលរហូតជាង៨0តោនក្នុង ១ ហិកតារ ហើយមើមមានគុណភាពខ្ពស់សំរាប់ផ្សំធ្វើជាចំណីសត្វ វាគឺពូជមកពីប្រទេសឥណ្ឌូនេស៊ីមានធាងពណ៌បៃតង។ ដំឡូងឈើទាំង ៣ ប្រភេទក្រៅពីមើមវាគេយកស្លឹក និងដើមទៅប្រើប្រាស់ជាៈ

- ស្លឹកផ្សំជាមួយវត្ថុផ្សេងទៀតធ្វើចំណីសត្វ មាន់ ជ្រូក។
- ដើមកិនបំបែកធ្វើជាវត្ថុផ្សំសំរាប់បណ្ដុះ ផ្សិតអំបោះ។

## II-គោលបំណង

១-ផ្ដល់បច្ចេកទេសដាំដុះដំឡូងឈើដល់ប្រជាកសិករ។

២-បង្កើនសមត្ថភាពក្នុងការផលិតដំណាំដំឡូងឈើដើម្បីផ្ដល់ដល់រោងចក្រ ឬ សិប្បកម្មផ្សេងៗ។

៣-បង្កើនប្រាក់ចំណូលដល់កសិករ។

## III-ទំលាប់ធ្វើរបស់កសិករ

- ការដាំដុះមិនតាមក្បួនខ្នាត, ការដាំជាលក្ខណៈប្រពៃណី។
- ការថែទាំមិនបានដិតដល់នាំឱ្យការលូតលាស់មានការថយចុះ។

- ការដាំដុះមិនរើសពេលវេលា ។
- ការរៀបចំដីមិនទាន់បានសមស្របតាមលក្ខណៈបច្ចេកទេស ។
- ការជ្រើសពូជមិនទាន់បានសមស្របល្អ ។

## IV-បច្ចេកទេសនៃការដាំដំឡូងឈើ

### ១_ការជ្រើសរើសទីតាំងសំរាប់ដាំដំឡូងឈើ និងការរៀបចំដី

- ទីតាំងដែលសមស្របបំផុតសំរាប់ផលិតកម្មដំណាំដំឡូងឈើ ជាលក្ខណៈឧស្សាហកម្មក៏ដូចជាលក្ខណៈគ្រួសារ តំបន់ខ្ពង់រាបនិងតំបន់វាលរាបមិនលិចទឹកដែលមានដីជាតិល្អ ។
- នៅតំបន់ខ្ពង់រាបត្រូវកាប់គាស់ឱ្យអស់នូវប្រភេទឈើធំៗពីទីតាំង ឬ កាប់ គាស់ដីទួលនិងដំបូកដែលមិនរៀបស្មើនៅចំកណ្តាលចំការ ។ របៀបភ្ជួររាស់មានការខុសគ្នារវាងដីនៅតំបន់ខ្ពង់រាប និងវាលទំនាប ។ តាមក្បួនបច្ចេកទេសនៅតំបន់ខ្ពង់រាប គេមិនចាំបាច់លើករងដាំទេព្រោះស្ថានភាព ដីខ្ពស់ស្រាប់ង ការភ្ជួររាស់វិញយើងច្រើនធ្វើតែ ១-២ ដងប៉ុណ្ណោះ ។ យើងត្រូវភ្ជួរឱ្យបានជំរៅពី 0.២0 ម៉ែត្រ ទៅ 0.២៥ ម៉ែត្រអាស្រ័យលើស្ថានភាពដីជួរភ្នំ ឬ ខ្ពង់រាបឬ ទំនាប ។



#### ការភ្ជួររាស់នៅតំបន់វាលរាប

ការដាំដុះដំឡូងឈើនៅតំបន់វាលរាបត្រូវអនុវត្តឱ្យសមស្របដូចជាការជ្រើសពូជ,បច្ចេកទេសដាំ,ការថែទាំ,ការដាក់ជីកំប៉ុស្ត,ដាក់ជីបំប៉ន,ដើម្បីទទួលបានទិន្នផលខ្ពស់ ។

### ២_ការប្រើប្រាស់ជីទ្រាប់បាត

- ជីកំប៉ុស្ត គឺជាជីដែលគេផលិតដោយវត្ថុធាតុពីធម្មជាតិ ដែលអ្នកបច្ចេកទេសបានបង្កើតឡើងរួមផ្សំជាមួយលាមកគោក្របី មាន់ ទា និងស្លឹករុក្ខជាតិផ្សេងៗ ។ ក្នុង ១ ហិកតារ ត្រូវប្រើជីកំប៉ុស្តពី ៣0 ទៅ ៥0 តោន ។
- ជីឌីអេភី អិន-ប៉េ-កា គេប្រើរួមផ្សំជាមួយជីផ្សេងៗទៀត ប្រើសំរាប់ជំនួយស្លឹក, ជំនួយមើម, ជំនួយឫស, ជំនួយផ្លែផ្កា ។

#### អត្រានៃការប្រើជីមាន

- ជីកំប៉ុស្ត...................................៣0-៥0 តោន ក្នុង ១ ហិកតារ ។
- ជីឌីអេភី (DAP) ...........................៧0-១00 គ.ក្រ ក្នុង ១ ហិកតារ ។
- ជីប៉ូតាស្យូម............................៥0-១00 គ.ក្រ ក្នុង ១ហិកតារ ។

## ៣_របៀបជ្រើសរើសពូជសំរាប់ដាំដុះ

- ជ្រើសរើសពូជណាដែលគ្មានជំងឺ និងមានគុណភាពល្អ ។
- ដើមពូជដំឡូងត្រូវតែស្រស់ស្អាត ហើយមានថ្នាំងញឹកល្អ ។
- ដើមដែលមានមើមច្រើន, ធំវែង, ថ្លោស ហើយខ្ពស់ ។
- ពូជដែលទីផ្សារត្រូវការហើយមើមវាអាចយកទៅធ្វើចំណីសត្វបានទៀតផង ។

## ៤_ប្រការដែលគួរជៀសវាង

- ជៀសវាងការយកចុងដែលមានពណ៌លឿង ឬ ចុងស្វិតពេកព្រោះវាអាចធ្វើឱ្យភ្នែកដំឡូងដុះអន់ និងមានជំងឺ ។
- គួរជៀសវាងកាត់យកដើមពូជដំឡូងជិតគល់នៅជាប់នឹងដីពេក ។ កាលណាយកផ្នែកនៃដើមជិតគល់ពេក ឬចាស់ពេក ការដុះលូតលាស់ក៏ខ្សោយដែរ ហើយដើមក៏មិនសូវធំធាត់ដែរ ។
- ចោលពីផ្នែកគល់ ០.២០ម-០.៣០ ម និងចោលពីចុង ០.៣០ម-០.៥០ ម ។

## ៥_ការរៀបចំលំពង់ឬពូជដំឡូង

- របៀបកាប់លំពង់ ឬ ពូជដំឡូងសំរាប់ដាំគឺយើងកាត់ប្រវែងចាប់ពី ០.២០ ទៅ ០.២៥ ម ងាយស្រួលក្នុងការដាំដុះ ( បើខ្លីពេក បណ្តាលឱ្យខូច ឬវែងពេកបណ្តាលឱ្យខាតពូជ) ។
- ការកាប់លំពង់ ឬ ដើមដំឡូងលៃយ៉ាងណាកុំឱ្យលំពង់បែក ឬ ឱ្យភ្នែកលំពង់ខូចបើមិនដូចនេះទេការដាំដុះរបស់យើងមានការខូចអសារបង់ជាមិនខានឡើយ ។

## ៦_ការកំណត់ពេលវេលាដែលត្រូវដាំដុះ

- ពេលដាំដុះសមស្រប គឺនៅក្នុងខែ មិនា ឬ ខែតុលា ។ កាលណាកសិករដាំខុសពីខែនេះអាចនឹងជួបផលវិបាក (ជួនកាលភ្លៀងខ្លាំងពេក-ជួនការរាំងពេក) ។

## ៧_របៀបដាំដុះ

- ការរៀបចំរណ្តៅត្រូវអនុវត្តឱ្យបានចាប់ពី ០.១០ម ទៅ ០.១៥ម កុំធ្វើជ្រៅពេក ឬ រាក់ពេក ។
- ត្រូវកប់ដើម ឬ លំពង់ដំឡូងបញ្ឆិតក្នុងករិត ៤៥ អង្សា ។
- កប់លំពង់ ២ ភាគ ៣ ចូលទៅក្នុងដី( រក្សាទុកនៅលើដី ១ ភាគ ៣) ។
- ក្នុងរណ្តៅនីមួយៗដាក់មួយកំណាត់ ឬ មួយលំពង់រួចលុបដី ។
- យកស្មៅស្ងួត ឬ ចំបើងដាក់គ្របពីលើរណ្តៅ( ការពារមិនឱ្យត្រូវកំដៅខ្លាំងធ្វើឱ្យស្ងួតចុងលំពង់ ) ។
- គួរគ្របរងទាំងមូលដែលអាចធ្វើឱ្យមានសំណើមល្អ និងមិនខូចលំពង់ ឬចុងដំឡូងរបស់យើង និងអាចជួយបង្កើនសារធាតុសរីរាង្គដល់ផ្ទៃដីផងដែរ ។
- ចន្លោះរងចន្លោះដើម ១.០០ម ខ ០.៨០ម ។

## ៨_របៀបផ្ទេទាំពន្លកបស់លំពង់

- ត្រូវមើលលំពង់ណាដែលមិនដុះ ត្រូវជួសដាក់លំពង់ថ្មី ( កុំឱ្យបាត់រណ្ដៅ ឬ ដើម) ។



- ក្រោយពេលដាំ ១០ ថ្ងៃទៅ ១៥ ថ្ងៃ ត្រូវជំរះ ឬ បោចស្មៅ។
- កុំឱ្យស្មៅដុះប្រជែងនឹងដំឡូងក្នុងចំការដំឡូងរបស់យើង ( ស្មៅវាជាអ្នកដណ្ដើមជីជាតិ) ។
- យើងអាចដាក់ជី អាហ្សូត បន្ថែមចំនួន ៨ ទៅ ១០ ក្រាម ឬ ១ ស្លាបព្រាបាយរាយជុំវិញរណ្ដៅក៏បាន។
- ពេលដាក់ជីបំប៉នត្រូវដាក់ក្រោយភ្លៀងមួយថ្ងៃទើបល្អ ឬ ក៏មុនពេលភ្លៀង។

## ៩_ការប្រមូលផលដំឡូងឈើ

- ចាប់ពីដាំរួចរហូតបាន ១០ ទៅ ១៣ ខែយើងអាចប្រមូលផលបានយ៉ាងល្អប្រសើរលក់ដូរតាមបំណងរបស់យើង។
- យើងអាចទុកដើមរបស់មើមដំឡូងបានរហូតដល់ ២០ ទៅ ២២ ខែក៏មិនខូចមើមដំឡូងរបស់យើងបានទេ។
- បើសិនហួសចាប់ពី២៣ខែឡើងទៅមើមដំឡូងពិតជាខូចរលួយស្អុយ ឬ មួយមើមក្លាយទៅជាសរសៃឈើធ្វើអ្វីមិនបាន ( យើងអាចទុកដើមសំរាប់ដាំឆ្នាំមុខ ) ។







## V-វិភាគសេដ្ឋកិច្ចផលិតកម្មដំណាំដំឡូងមី(ផ្ទៃដី១ហត)

| បរិយាយ | ឯកតា | តាមប្រពៃណី | | | តាមបច្ចេកទេស | | |
|---|---|---|---|---|---|---|---|
| | | ចំនួន | តំលៃរាយ $ | តំលៃសរុប $ | ចំនួន | តំលៃឯកតា $ | តំលៃសរុប $ |
| ការរៀបចំដីសរុប | ហត | 1 | - | 40.00 | 1 | - | 40.00 |
| ជីគីមី( DAP - K2O ) | គក្រ | - | - | - | 200 | 0.45 | 90.00 |
| ជីកំប៉ុស្ត និងលាមកសត្វ | តោន | - | - | - | 5 | 20.00 | 100.00 |
| ដើមពូជ | ដើម | 2300 | 0.075 | 172.5 | 2300 | 0.075 | 172.50 |
| ការដាំដុះសរុប | ថ្ងៃ/នាក់ | 15 | 1.75 | 26.25 | 15 | 1.75 | 26.25 |
| ការថែទាំសរុប | ថ្ងៃ/នាក់ | 40 | 1.75 | 70.00 | 50 | 1.75 | 87.50 |
| ជីបំប៉ន ( UREE ) | គក្រ | - | - | - | 100 | 0.35 | 35.00 |
| ការប្រមូលផល | ថ្ងៃ/នាក់ | 70 | 1.75 | 122.5 | 80 | 1.75 | 140.00 |
| ដឹកជញ្ជូន | ត្រាក់ទ័រ | 6 | 10.00 | 60.00 | 10 | 10.00 | 100.00 |
| ចំណាយសរុប | $491.25 | | | | $791.25 | | |
| ចំណូលសរុប | $ 0.05 x 4.000R = $ 20,000.00 | | | | $ 0.05 x 7000R = $ 35,000.00 | | |
| ចំណេញ | $1,508.75 | | | | $2,708.75 | | |

**តាមប្រពៃណី**

ទិន្នផល : ៤០ តោន /ហត

**តាមបច្ចេកទេស**

ទិន្នផល : ៧០ តោន /ហត

តំលៃលក់ស្រស់ : 40.0៥ /កគ្រ

# ការធ្វើជីកំប៉ុស្តទ្រុងរយៈពេលខ្លី
# (Compost Preparation)

## I- សេចក្តីផ្តើម

ជីកំប៉ុស្តជា ជីសរីរាង្គដែលកើតឡើងដោយកំទេចកំទីរុក្ខជាតិនិងសត្វ ដោយជំរុញពីកំដៅថ្ងៃ និងសំណើម។ ជីកំប៉ុស្តមានសារៈសំខាន់លើការងារដាំដុះផ្សេងៗក្នុងការធ្វើអោយដំណាំលូតលាស់បានលឿននិងផ្លែផ្កាបានល្អ។ ការអនុវត្តមានច្រើនប្រភេទដូចជាកំប៉ុស្តរណ្តៅកំប៉ុស្តគំនរកំប៉ុស្តទឹក ហើយនិងការអនុវត្តកំប៉ុស្តទ្រុង។ ការអនុវត្តជីកំប៉ុស្តខាងលើនេះគឺប្រើពេលវេលាខុសៗគ្នាទាំងអស់។ ការអនុវត្តន៏ជីកំប៉ុស្តទ្រុងរយៈពេលខ្លីនេះមានសារៈសំខាន់ដល់កសិករក្នុងការអនុវត្តន៏ជាលក្ខណៈគ្រួសារ ដែលមានផ្ទៃដីតូចក្នុងផលិតកម្មកសិកម្ម ព្រោះកំប៉ុស្តទ្រុងដែលមានរយៈពេលខ្លីយើងត្រូវការសារធាតុសរីរាង្គ ដែមាននៅជុំវិញផ្ទះដោយមិនចាំបាច់ចំណាយថវិកាច្រើនក្នុងការផលិត។ ម្យ៉ាងវិញទៀតជីកំប៉ុស្តទ្រុងរយៈពេលខ្លីមានលក្ខណៈពិសេសគឺជីនេះមិនមានក្លិន និងងាយស្រួលក្នុងការទុកដាក់ដោយការវេចខ្ចប់និងមានការងាយស្រួលដល់ការប្រើប្រាស់ទៅលើដំណាំ។




## II- គោលបំណង

១-អោយកសិករយល់ដឹងអំពីបច្ចេកទេស ធ្វើជីកំប៉ុស្តទ្រុងរយៈពេលខ្លី។

២-អោយកសិករយល់ដឹងអំពីតួនាទី និងសារៈសំខាន់របស់ជីកំប៉ុស្ត។

៣-កាត់បន្ថយការចំណាយខ្ពស់ទៅលើការប្រើប្រាស់ជីកំប៉ុស្ត។

## III- ការងារដែលកសិករអនុវត្តកន្លងមក

ជាទូទៅកសិករបានអនុវត្តមិនទាន់បានសមស្របលើការប្រើប្រាស់ជីលាមកសត្វ ឬកាកសំណល់ដូចជាៈ

- និយមដុតកាកសំណល់ផ្សេងៗឬលាមកសត្វរួចហើយយកទៅប្រើប្រាស់លើដំណាំផ្សេងៗ។
- ប្រើប្រាស់ជីលាមកសត្វដែលគរចោលដោយមិនទាន់បានកែច្នៃ។
- យកជីលាមកសត្វទៅដាក់ចោលជាគំនរតូចៗនៅក្នុងស្រែរយៈពេលយូរ។
- គ្មានការសន្សំសារធាតុសរីរាង្គផ្សេងៗសំរាប់ធ្វើជីកំប៉ុស្ត។



រៀបចំដោយលោក ជិត សុវណ្ណ និងស្រី ស្រស់ធីតា

- ប្រើប្រាស់ជីលាមកសត្វមិនត្រឹមត្រូវតាមបច្ចេកទេស ។

# IV-បច្ចេកទេសធ្វើជីកំប៉ុស្តរយៈពេលខ្លី

## ១_របៀបធ្វើជីកំប៉ុស្តទ្រុងរយៈពេលខ្លី

ការធ្វើជីកំប៉ុស្តទ្រុងដែលមានរយៈពេលខ្លី យើងត្រូវធ្វើការបែងចែកដំណាក់កាលរបស់វាជា ៨ ដំណាក់កាល យ៉ាងច្បាស់ដូចខាងក្រោមនេះគឺ

- របៀបធ្វើទ្រុងជីកំប៉ុស្ត
- ការជ្រើសរើសទីកន្លែង
- ការដំឡើងទ្រុងជីកំប៉ុស្ត
- ការប្រមូលវត្ថុធាតុដើមដែលអាចធ្វើជីកំប៉ុស្តបាន
- ដំណើរកាលធ្វើជីកំប៉ុស្ត
- ការជួយត្រឡប់ជីកំប៉ុស្ត
- ដំណាក់កាលនៃការសំរេចរបស់ជីកំប៉ុស្ត និងការទុកដាក់ និងប្រើប្រាស់ជីកំប៉ុស្ត ។

## ២_សំភារៈនិងឧបករណ៍សំរាប់ធ្វើជីកំប៉ុស្ត

- ទ្រុងជីកំប៉ុស្តដែលមានទំហំ (១ម x ១ម x ១ម) ។
- បង្គោលឈើមួយដើមមានទំហំ ៨ សម ទៅ ១០ សម ។
- បន្ទះឬស្សីដែកគោល ។
- កាំបិត ពូថៅ ចបកាប់ ប៉ែល ធុងស្រោច ។
- វត្ថុធាតុស្រស់មានស្លឹកឈើ ចក កំប្លោក ដើមពោត កាកសំណល់ផ្ទះបាយ និងដើមទន្រ្ទានខែត្រ ។ ល ។
- លាមកសត្វ មាន់ ទា ជ្រូក គោ ក្របី ។
- កំបោរ ស ឬ ផេះ ។

## ៣_ដំណើរកាលនៃការធ្វើជីកំប៉ុស្ត

### ៣.១. របៀបធ្វើទ្រុងជីកំប៉ុស្ត

ត្រូវកាត់បន្ទះនីវ ឬ ឬស្សីជាកំណាត់ៗប្រវែង ១ម អោយស្មើគ្នាល្អ។ រៀបបន្ទះឬស្សី ឬ នីវជាបួនជ្រុង ១ម x ១ម x ១ម រួចវាយបន្ទះឬស្សី ឬ នីវលើមេទទឹងដោយទុកចន្លោះឃ្លាតពីគ្នា ២ សម ។ យើងត្រូវធ្វើរនាបនេះអោយបាន ៤ ផ្ទាំងស្មើៗគ្នា ។

### ៣.២. ការជ្រើសរើសទីកន្លែងធ្វើជីកំប៉ុស្ត

- គប្បីធ្វើទ្រុងជីកំប៉ុស្តក្នុងចំការឈើហូបផ្លែ ឬច្បារដំណាំក្បែរទ្រុងជ្រូក ឬរោងគោ។
- គប្បីធ្វើក្បែរប្រភពទឹក។



### ៣.៣. ការដំឡើងទ្រុងជីកំប៉ុស្ត

- ក្រោយពេលធ្វើការជ្រើសរើសទីកន្លែងរួចហើយយើងត្រូវកាប់គាស់ដីនោះបំផុសអោយបានល្អដែលមានប្រវែង ១ម x ១ម ឬមួយម៉ែត្របួនជ្រុង ។
- បន្ទាប់មកយើងត្រូវជីករណ្តៅអោយចំកណ្តាល រួចដាំបង្គោលមូលដែលមានទំហំពី ៨ សម ទៅ ១០ សម។ បន្ទាប់មកយើងយកផ្ទាំងដែលបានធ្វើចំនួនបួនផ្ទាំង មកផ្គុំចូលគ្នារួចយកខ្សែ ឬលួសមកចងតាមជ្រុងនីមួយៗ។

### ៣.៤. ការរៀបចំវត្ថុធាតុដើមធ្វើជីកំប៉ុស្ត

ចំពោះវត្ថុធាតុដើមដែលយើងប្រមូលបានរួចហើយនោះ ទាំងចំបើងស្ងួត កំប្លោកស្រស់ចាំបាច់ត្រូវធ្វើការកាប់ចិញ្ច្រាំអោយបានខ្លីៗជាស្រេច រួចប្រមូលលាមកសត្វផេះ ឬ កំបោរមកទុកក្បែរកន្លែងដែលយើងត្រូវធ្វើ។ យើងធ្វើរបៀបនេះងាយស្រួលក្នុងដំណើរការធ្វើជីកំប៉ុស្ត។

### ៣.៥. ដំណើរការធ្វើជីកំប៉ុស្ត

- ដំបូងយើងត្រូវរៀបវត្ថុធាតុស្ងួត ដែលយើងចិញ្ច្រាំហើយអោយបានកំរាស់ ២៥ សម ដាក់ទៅក្នុងទ្រុងរួចត្រូវស្រោចទឹកអោយជោកអោយហើយ។
- យើងយកវត្ថុធាតុស្រស់ដែលចិញ្ច្រាំរួចនោះ មករៀបបន្តពីលើអោយបានកំរាស់ ១០ ទៅ ១៥ សម ដោយចាក់ទឹកពីលើបន្ថែមទៀតអោយសើមល្មម។



- យកលាមកសត្វដាក់ពីលើវត្ថុធាតុស្រស់អោយបាន ៥ សម ទើបយើងរោយកំបោរ ឬផេះអោយបានកំរាស់ ៥ សម ឬ ១០ សម។ យើងត្រូវរៀបវាជាជាន់ៗតាមលំដាប់លំដោយដូចដែលបានអនុវត្តខាងលើរហូតពេញទ្រុងកំប៉ុស្ត។
- ក្រោយពេលយើងរៀបពេញល្អហើយ យើងត្រូវរង្វៀកបង្គោលកណ្តាលអោយរលុងហើយទើបដកយកបង្គោលនោះចេញដើម្បីអោយមានខ្យល់ចេញចូល។

### ៣.៦. ការជ្រួយត្រឡប់ជីកំប៉ុស្ត

ក្រោយរយៈពេល ៧ ថ្ងៃបន្ទាប់ពីបានរៀបចំវត្ថុធាតុទៅក្នុងទ្រុង ហើយគំនរកំប៉ុស្តនឹងឡើងកំដៅដល់ ៧០ អង្សាសេ យើងត្រូវជ្រួយជាលើកទី ១ ដោយជ្រួយត្រឡប់ទៅតាមស្រទាប់នីមួយៗ។ មុននឹងធ្វើការជ្រួយត្រឡប់កំប៉ុស្តយើងត្រូវកាប់ដីបំផុស ១ ម៉ែត្របួនជ្រុងនៅកន្លែងផ្សេង រួចដាំបង្គោលឈើចំកណ្តាលដូចដំណាក់កាលទី ៣.៣ ដែរ។

**បញ្ជាក់៖**

- នៅពេលធ្វើការត្រឡប់ជីកំប៉ុស្ត ត្រូវអនុវត្តដោយយកស្រទាប់លើទៅដាក់ផ្នែកខាងក្រោមស្រទាប់ក្រោមដាក់ផ្នែកខាងលើ។ ផ្នែកកៀន ឬក្រៅត្រូវដាក់ផ្នែកខាងក្នុង ។
- បន្ទាប់ពីត្រឡប់លើកទី ១ បានរយៈពេល ៣ ថ្ងៃទៅ ៤ ថ្ងៃយើងត្រូវត្រឡប់វាម្តងទៀត។ ដូច្នេះរយៈពេល ៣ ទៅ ៤ ថ្ងៃយើងត្រឡប់ម្តងរហូតជីកំប៉ុស្តរបស់យើងប្រើការបាន។

**បញ្ជាក់៖**

ពេលជីកំប៉ុស្តរយៈពេលខ្លីអាចប្រើការបាន ជីកំប៉ុស្តនៅពេលដែលវាសំរេច ឬ អាចប្រើប្រាស់បានហើយនោះ យើងសង្កេតឃើញមានលក្ខណៈដូចខាងក្រោម

- សម្បុរពណ៌ត្នោតចាស់។
- កំដៅថយចុះជាធម្មតា។
- គ្មានក្លិន។
- គ្រាប់រុក្ខជាតិអាចដុះចេញពីកំប៉ុស្តបាន។
- ការទុកដាក់ និងការប្រើប្រាស់ជីកំប៉ុស្ត។
- ជីកំប៉ុស្តអាចសំរេចបានក្នុងរយៈពេលពី ៣០ ទៅ ៤០ ថ្ងៃ។ ដូច្នេះយើងត្រូវធ្វើការទុកដាក់អោយបានល្អ ក្នុងម្លប់ ឬ ក្រោមផ្ទះកុំអោយត្រូវថ្ងៃ ឬ ភ្លៀង។ គប្បីធ្វើការរែងយកកំទេចជីកំប៉ុស្តច្រកការ៉ុង ឬ បាវអោយបានត្រឹមត្រូវល្អ ឬ ក៏អាចយកទៅប្រើប្រាស់តែម្តង។ ចំពោះកាកសំណល់ក្នុងកញ្ច្រែងដែលយើងរែងយើងអាចដាក់ចូលក្នុងទ្រុងធ្វើសារជាថ្មីវិញក៏បានដែរ។ ដូច្នេះ ក្នុងការប្រើយើងអាចយកទៅប្រើលើដំណាំផ្សេងៗក្នុងអត្រា ២ គក្រ ទៅ ៣ គក្រ ក្នុង ១ ម៉ែត្រការ៉េ។

## បញ្ហា និងដំណោះស្រាយលើជីកំប៉ុស្ត

| បញ្ហា | មូលហេតុ | ដំណោះស្រាយ |
|---|---|---|
| ជីកំប៉ុស្តធំក្លិនឧស្ម័នអាម៉ូនីញ៉ាក់ឆេះ | - សំបូរជាតិអាសូតជ្រុលពេក<br>- ខ្យល់អុកស៊ីហ្សែន | - បន្ថែមវត្ថុស្ងួត<br>- កាយត្រឡប់ឱ្យបានច្រើនដង ដើម្បីអោយ អុកស៊ីហ្សែនរត់កាត់ចេញចូលបាន |
| កំប៉ុស្តមិនឡើងកំដៅ | - ខ្វះជាតិអាសូត<br>- សើមជ្រុល<br>- ខ្យល់អុកស៊ីហ្សែន<br>- ជាតិអាស៊ីដច្រើនជ្រុល | - បន្ថែមលាមកសត្វដែលសម្បូរជាតអាសូត<br>- បន្ថែមវត្ថុស្ងួតនៅពេលត្រឡប់<br>- កាយត្រឡប់អោយបានញឹកញាប |

## ការប្រៀបធៀបជីកំប៉ុស្ត និងជីគីមី

| ការប្រៀបធៀបជីកំប៉ុស្ត និងជីគីមី | |
|---|---|
| -មានសារធាតុចិញ្ចឹមច្រើនមុខតែតិចតួច<br>-កែរចនាសម្ព័ន្ធដីល្អ<br>-ជាចំណីរបស់អតិសុខុមប្រាណ<br>-មិនចំណាយប្រាក់ច្រើន<br>-កាត់បន្ថយការហូរច្រោះដី<br>-រក្សាសំណើមបានល្អ<br>-ជាប់ទឹកបានល្អ<br>-បរិមាណប្រើច្រើន<br>-ការិតនៃការស្រូបរបស់រុក្ខជាតិយឺត | -មានសារធាតុចិញ្ចឹមច្រើនតែមួយមុខ<br>-គ្មាន ហើយធ្វើអោយដីឆាប់ហិល<br>-គ្មាន<br>-ចំណាយប្រាក់ច្រើន<br>-គ្មាន<br>-គ្មាន<br>-គ្មាន<br>-បរិមាណប្រើតិច<br>-ការិតនៃការស្រូបរុក្ខជាតិលឿន |

# ដំណាំបន្លែនៅរដូវប្រាំង
# (Dry season Vegetable Production)

## I-សេចក្តីផ្តើម

ដំណាំបន្លែចែកជាបីប្រភេទ គឺបន្លែយកស្លឹក បន្លែយកមើម និងបន្លែយកផ្លែ។ ដំណាំបន្លែជាដំណាំដែលមានទំនាក់ទំនងជាមួយការរស់នៅរបស់មនុស្សយើង ទាំងម្ហូបអាហារក៏ដូចជាផ្នែកសេដ្ឋកិច្ច។

### ក-សារៈសំខាន់នៃផ្នែកម្ហូបអាហារ

បន្លែមានលក្ខណៈពិសេសសំរាប់សុខភាពមនុស្ស។ វាសំបូរដោយប្រូតេអ៊ីន,គ្លុយស៊ីត,ជាតិប្រេងជាពិសេសរូបធាតុខនិជ ព្រមទាំងជីវជាតិ អា, បេ, សេជាដើម។

### ខ-សារៈសំខាន់ផ្នែកសេដ្ឋកិច្ច

ក្រៅពីការដាំដុះសំរាប់គ្រួសារគេយកបន្លែមួយចំនួនទៅលក់នៅទីផ្សារ ដែលផ្តល់ប្រាក់កាសតិច ឬ ច្រើនទៅតាមចំនួនផលិតផល។ កត្តាសំខាន់ដែលទាក់ទងទៅនឹងការដាំដុះបន្លែគឺ ធាតុអាកាស, ទឹក, ដី និងជីព្រមទាំងការចាំបាច់ទៀត ដែលទាក់ទងទៅនឹងចំណេះដឹងខាងបច្ចេកទេសដាំដុះដែរ។



ដោយឡែកនៅរដូវប្រាំងវិញដំណាំបន្លែនៅជួបការលំបាកជាច្រើនដូចជា ខ្វះទឹកស្រោចស្រពដំណាំ(ឆ្ងាយពីប្រភពទឹក ឬ ទឹកមិនគ្រប់គ្រាន់)សីតុណ្ហភាពខ្ពស់ខ្លាំង,ជួបប្រទះសត្វល្អិតចង្រៃច្រើន,ការលូតលាស់អន់ថយជាពិសេសពពួកបន្លែគ្រុយស៊ីហ្វែដូចជាពពួកស្ពៃ, ខាត់ណា......ដែលបានដាំក្នុង ខែមករា, កុម្ភៈ, មិនា តែងតែជួបសត្វល្អិតចង្រៃបំផ្លាញជាច្រើន។

## II-គោលបំណង

១-ចង់អោយប្រជាជនដាំបន្លែមានបច្ចេកទេសយល់ដឹងច្បាស់អំពីដំណាំបន្លែនៅរដូវប្រាំង។

២-ធ្វើលើដីតូច តែបានផលច្រើន។

៣-យល់ពីរដូវកាលដាំ ហើយយកទៅលក់នៅទីផ្សារបានថ្លៃ (កំរៃច្រើន ដូចជាបុណ្យទានខ្មែរ ឬ បុណ្យចិន) សំរាប់សេដ្ឋកិច្ចគ្រួសាររីកចំរើន។

៤-យល់ពីការលំបាកមួយចំនួនដែលជួបប្រទះនៅរដូវប្រាំង (កង្វះទឹក, ធាតុអាកាសក្តៅខ្លាំង និងវិធានការទប់ទល់ដោះស្រាយបាន, ទីតាំងដាំដុះនៅជិតប្រភពទឹក, ដំណាំមានគំរប ឬ ដំបូល)។

៥-យល់ដឹងពីសត្វល្អិតចង្រៃច្រើននៅរដូវប្រាំង, របៀបការពារ និងកំចាត់វាព្រមទាំងដំណាំឆ្លាស់ផ្លាស់មុខដំណាំនៅលើរងបន្លែ ដើម្បីបង្វែងដានសត្វល្អិតចង្រៃ ។
៦-យកចិត្តទុកដាក់ប្រើជី លាមកសត្វ, ជីធម្មជាតិ ដែលមានគុណភាពល្អជាងជីគីមីចេញពីរោងចក្រ ហើយចំណាយប្រាក់កាសច្រើនទៅលើជីគីមី ដែលធ្វើអោយខូចគុណភាពដី ( ដីរឹង ) និងបាត់បង់ថវិកា ។
៧-ទម្លាប់ប្រើថ្នាំពុលផ្សំពីរុក្ខជាតិ( ថ្នាំបុរាណ) ដើម្បីការពារនិងកំចាត់សត្វល្អិត( គ្រាប់ស្តៅ, ថ្នាំជក់, រំដេង, សាប៊ូ..) និងដើម្បីជៀសវាងគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ផង ដូចជាថ្នាំគីមីដែលគេទិញមកពីទីផ្សារ ។

## III- ទម្លាប់ដាំដុះបន្លែរបស់កសិករ

- ទីតាំងដាំដុះបន្លែនៅឆ្ងាយពីប្រភពទឹក ឬទឹកមិនមានគ្រប់គ្រាន់ ។ ការរៀបចំដីសំរាប់ដាំ បន្លែដោយកាប់ដី ឬភ្ជួររាស់ពុំបានម៉ដ្ឋល្អ ឬ អោយដីធូរថែមទាំងមិនបានបំបែកដីឱ្យបានសមស្របនឹងមុខដំណាំ ។
- ចូលចិត្តទិញជីគីមីនៅទីផ្សារ រីឯជីធម្មជាតិប្រើតិចតួច ជីមិនគ្រប់គ្រាន់ ។
- គ្មានបច្ចេកទេសដាំដុះគឺ ដាំទៅតាមទំលាប់មើលឃើញអ្នកជិតខាង ឬ តាមឪពុកម្តាយបង្ហាញប្រាប់ ។
- ជួបការលំបាកច្រើនដូចជាសត្វល្អិតចង្រៃបំផ្លាញដំណាំនិងជម្ងឺជាច្រើនធ្វើអោយខូចដំណាំទទួលទិន្នផលទាប ។
- ប្រើថ្នាំពុលគីមីហួសកំរិតកំណត់, ការប្រើប្រាស់ថ្នាំពុលគីមីគ្មានកំរិតច្បាស់ លាស់ដោយមិនដឹងឥទ្ធិពលកម្លាំងសាបរបស់ថ្នាំអស់ជាតិពុលប៉ុន្មានថ្ងៃ និងរបៀបប្រើថ្នាំនេះដើម្បីជៀសវាងពីគ្រោះថ្នាក់ ។
- ខ្វះការថែទាំ និងកិច្ចការពារសត្វល្អិតចង្រៃ ការសំអាតស្មៅពុំបានទៀងទាត់, មិនសូវយកចិត្តទុកដាក់លើការជ្រុំជ្រួយដាក់ជីបំប៉ន, ការស្រោចស្រពទឹកតិចតួចមិនបានគ្រប់គ្រាន់ដល់ការលូតលាស់របស់ដំណាំ ។ ជារួមមូលហេតុមកពីកត្តាខាងលើនេះហើយដែលកសិករដាំបន្លែនៅលើផ្ទៃដីធំ តែទទួលបានទិន្នផលទាប ទទួលកំរៃតិចតួច ។

## IV- បច្ចេកទេសដាំដំណាំបន្លែនៅរដូវប្រាំង

### ១_ការរៀបចំដី

ដំណាំបន្លែជាដំណាំមានឫសខ្លី ។ ដូច្នេះត្រូវទាមទារការធ្វើដីអោយបានរៀបស្មើ, ដីម៉ដ្ឋ, ដីធូរ ។ នោះវាងាយស្រួលដល់ការរីកលូតលាស់ឆាប់រហ័សផ្នែកប្រព័ន្ធឫសមានខ្យល់ចេញចូល, ដីស្អាតគ្មានស្មៅ, គ្មានសត្វល្អិតចង្រៃ, ដីមានជីជាតិដើម្បីទទួលផលបានខ្ពស់ ។

ការរៀបចំដីភ្ជួររាស់ដោយគោ ក្របី ឬ កាប់បំបែកដីរាស់អោយម៉ដ្ឋជាច្រើនសាទើបល្អ ។ ចំពោះដីជំរាលការភ្ជួររាស់ត្រូវធ្វើកាត់ទទឹងនឹងទិសជំរាល ដើម្បីជៀសវាងទឹកហូរច្រោះធ្វើអោយបាត់បង់ជីជាតិដូចជា ដីនៅមាត់បឹង, ស្ទឹង, ទន្លេ... ។ ការធ្វើរងបន្លែនៅរដូវប្រាំងត្រូវលើកអោយទាប ហើយលើកគែមរងអោយខ្ពស់បន្តិចដើម្បីរក្សាទឹក ។

### ២_ការជ្រើសរើសពូជ

- ពូជជាកត្តាមួយសំខាន់ណាស់ដែរ ។ ជាការល្អយើងត្រូវជ្រើសរើសពូជដោយទុកខ្លួនឯង ។ ពូជបន្លែមាន ២ ប្រភេទគឺ ពូជបង្កាត់ និងពូជមិនបង្កាត់ ។



### យើងគួរជ្រើសរើសពូជ

- ដុះលូតលាស់សមស្របទៅនឹងតំបន់ផលិត ។
- ផ្តល់ទិន្នផលខ្ពស់, ធន់នឹងការរាំងស្ងួត, ធន់នឹងជម្ងឺ, ធន់នឹងសត្វចង្រៃ និងសំបូរដោយសារធាតុចិញ្ចឹម ។
- គ្រាប់ពូជល្អគ្មានសត្វស៊ី, គ្មានជម្ងឺ ។

## ៣_ការដាំដុះ

### ក-ពេលវេលាដាំដុះ

ការកំណត់ពេលវេលាដាំដុះមានសារៈសំខាន់ណាស់ ។ ពេលវេលាអាចកំណត់នូវលទ្ធភាពក្នុងការដាំដុះ និងទិន្នផលនៃដំណាំមួយចំនួនបាន ហើយវាក៏អាចកំណត់បាននូវភាពធូរស្រាល ឬ ភាពធ្ងន់ធ្ងរក្នុងការថែទាំដែរ ។ ក្នុងចំណោមពពួកបន្លែ មានបន្លែដាំបានតែមួយដងក្នុងមួយឆ្នាំ ហើយអោយផលខ្ពស់បើមានការថែទាំល្អ ដូចជាខ្ទឹមបារាំង ស្ពៃផ្កា, ស្ពៃមើម, ដំឡូងជ្វា ។

ដូច្នេះ នៅរដូវប្រាំងការដាំដុះយឺតយ៉ាវអាចអោយដំណាំខ្វះទឹក,ប៉ះពាល់សីតុណ្ហភាពខ្លាំង, សត្វល្អិតចង្រៃច្រើន, ការលូតលាស់ដំណាំអន់ថយ ។ចំពោះពពួកស្ពៃ,សាឡាត់,ខាត់ណាជាដើមតាមការសង្កេតឃើញថានៅតំបន់ទំនាបការដាំដុះបន្លែក្នុងខែ មករា, កុម្ភៈ មិនាធ្វើអោយជួបការលំបាកជាច្រើនជាពិសេសបញ្ហាសត្វល្អិត ដែលមានច្រើនជាងខែណាៗទាំងអស់ ។

### ខ-របៀបដាំ

របៀបដាំមានច្រើន ដូចជា

- ព្រោចពេញដី ។
- ដាំជាជួរ ។
- ដាំជារណ្តៅ ។
- ដាំលើករង ។
- ដាំលើដីរាបធម្មតា ។



បន្លែមានច្រើនប្រភេទ រីឯការដាំដុះក៏មានរបៀបខុសៗគ្នាដែរ ។ គេដាំដំណាំមួយចំនួនដោយផ្ទាល់តែម្តងដូចជាស្ពៃមើមសណ្តែកកួរ ការ៉ុត សណ្តែកបាយ ពោតនិង ជីរ...។ ខ្លះទៀតគេនិយមដាំ ឬ សាបផ្ទាល់ ឬ ដាក់កន្ទោងរួចយកទៅស្ទូងជាក្រោយដូចជា ននោង, ល្ពៅ, ឃ្លោក, ឪឡឹក, បន្លែយកស្លឹក និងបន្លែយកផ្លែជាដើម ។

ចំពោះបន្លែដែលដាំចន្លោះគុម្ពរង្វើល គេនិយមសាបរួចទើបយកទៅស្ទូងដូចជា ស្ពៃក្តោប, ស្ពៃខាត់ណាសាឡាត់ជាដើម ។

### គ-ការសាប

គេនិយមសាបនៅក្នុងថ្នាលឬនៅលើរានជាមុនសិនរួចយកទៅដាំនៅលើផ្ទៃដីរាបស្មើដែលគេបានដាក់ជីធម្មជាតិជាស្រេចចំនួន ២ ទៅ ៣ គ.ក្រ ក្នុងដី ១ ម៉ែត្រការ៉េ រួចគេថែទាំជាប្រចាំដោយស្រោចទឹក ៣ ដងក្នុង ១ ថ្ងៃ ។

ឃ-ការស្ទូង

អាយុកូនបន្លែដែលត្រូវស្ទូងមានខុសៗគ្នាគឺ ផ្លាស់ប្តូរតាមមុខដំណាំ។ រីឯចន្លោះគុម្ព និងជួរដែលត្រូវស្ទូងរបស់ដំណាំនីមួយៗក៏ខុសគ្នាដែរ។



ចំពោះកូនបន្លែដែលត្រូវស្ទូង ត្រូវតែអនុវត្តដូចតទៅៈ

- ស្រោចទឹកថ្នាលអោយបានជោកល្អ មុននឹងគាស់កូនបន្លែយកទៅដាំ។
- ត្រូវគាស់កូនបន្លែអោយជាប់ទាំងដី ដើម្បីកុំអោយដាច់ឬស។
- ស្ទូងពេលល្ងាចមេឃត្រជាក់ ជៀសវាងការស្វិតស្រពោន។
- កូនបន្លែក្នុងកន្ទោងត្រូវបកកន្ទោងចេញមុនយកទៅដាំ។
- លុបដីតាមគល់កូនបន្លែត្រឹមគល់ចាស់របស់វា។

## ៤_ការថែទាំ

ក-ការជំរះស្មៅ, ជ្រុំជ្រួយដី, ពូនគល់ត្រូវជំរះស្មៅអោយស្អាត ដើម្បីជៀសវាងការដណ្តើមជីពីបន្លែ, ស្មៅជាជំរកសត្វល្អិតចង្រៃដែលបណ្តាលអោយទិន្នផលថយចុះ។ ការជ្រុំជ្រួយ និងពូនគល់ធ្វើអោយដីធូរ, មានខ្យល់ចេញចូល, ងាយស្រួលដល់ឬសស្រូបយកជីជាតិ និងលូតលាស់ល្អ។

ខ-ការដាក់ជីបំប៉ន

ជីមានសារៈសំខាន់ណាស់ចំពោះរុក្ខជាតិទាំងការលូតលាស់ទាំងការផ្តល់ផ្លែផ្កាពីព្រោះការដាក់ជីតែមួយដងនៅមុនពេលដាំ ឬ ស្ទូងមិនគ្រប់គ្រាន់ទេ។ ដើម្បីអោយបន្លែផ្តល់ទិន្នផលខ្ពស់ ត្រូវដាក់ជីបន្ថែមទៀតនៅពេលដំណាំកំពុងលូតលាស់។ ដូច្នេះ យើងត្រូវមានរណ្តៅជីដើម្បីសន្សំជីធម្មជាតិ ឬ មួយធ្វើជីកំប៉ុស្តិ៍ពីវត្ថុធាតុផ្សេងៗដូចជា លាមកសត្វ, ទន្រ្ទានខេត្ត, ស្លឹកឈើ, ចំបើង, ស្មៅ, ផេះ និងកាកសំណល់ផ្សេងៗ។

គ-ទឹក

រុក្ខជាតិត្រូវការទឹកចាំបាច់។កង្វះទឹកនៅរដូវប្រាំងសំរាប់ដំណាំបន្លែបណ្តាលអោយការលូតលាស់មិនបានល្អ,ដើមតូចឆ្មារ, គ្មានទម្ងន់ផ្លែផ្កាតិចតួច, លក់នៅទីផ្សារមានតម្លៃថោក។

ឃ-កិច្ចការពារសត្វល្អិតចង្រៃ និងជម្ងឺ

បើយើងនិយាយពីសត្វល្អិតចង្រៃ ក៏យើងនឹកឃើញសត្វមានប្រយោជន៍ (ប្រេដាទ័រ) និងពួកប៉ារ៉ាស៊ីត។ សត្វមានប្រយោជន៍ទាំង ២ ពពួកខាងក្រោយនេះជាសត្រូវធម្មជាតិរបស់សត្វល្អិតចង្រៃ តាមរយៈការចាប់ស៊ី (ប្រេដាទ័រ) ឬ ពងដាក់ក្នុងខ្លួន ឬ ក្នុងពងសត្វល្អិតចង្រៃ (ប៉ារ៉ាស៊ីត)។ ដូច្នេះ មុននឹងការពារ ឬ កំចាតសត្វល្អិតចង្រៃដោយប្រើថ្នាំពុលបាញ់សម្លាប់វា ក៏យើងត្រូវសង្កេតក្រែងមានសត្វមានប្រយោជន៍ទាំងនេះ។

ជម្ងឺនៅលើដំណាំបន្លែមានច្រើនប្រភេទណាស់ដូចជា ជម្ងឺផ្សិត, ជម្ងឺរលួយគល់, ជម្ងឺរលួយដើម,ជម្ងឺបាក់តេរីស្រពោនស្លឹក។

## V-តារាងប្រៀបធៀបលើទិន្នផលបន្លែ(ការវិភាគសេដ្ឋកិច្ច)

| បរិយាយ | ទិន្នផលបន្លែដាំគ្មានបច្ចេកទេស | | ទិន្នផលបន្លែដាំតាមបច្ចេកទេស | |
|---|---|---|---|---|
| | កំរិតបាត់បង់ជាភាគរយ | ក្នុង ១០០ គក្រ នៅសល់ | កំរិតបាត់បង់ជាភាគរយ | ក្នុង ១០០គក្រ នៅសល់ |
| ផ្ទៃដីដាំដុះទំហំ ១៦០០ ម៉ែត្រក្រឡា<br>-ការដាំដុះ<br>-ការបំផ្លាញដោយសត្វល្អិត, ជម្ងឺ<br>-ការថែទាំ | 5<br>10<br>20 | | 5<br>5<br>3 | |
| សរុប | **35** ភាគរយ | **65** ភាគរយ | **10** ភាគរយ | **90** ភាគរយ |

# សួនដំណាំបន្លែតាមគ្រួសារ
# (Home Gardens / Home gardening)

## I- សេចក្តីផ្តើម

បន្ទាប់ពីបានធ្វើស្រែរួច កសិករខ្មែរយើងមួយចំនួនតូចបានដាំដំណាំផ្សេងៗជុំវិញផ្ទះ មានស្លឹកគ្រៃ ជី ល្ហុង សំរាប់យកមកធ្វើជាបន្លែ ឬលក់ដូរខ្លះ សំរាប់ផ្គត់ផ្គង់គ្រួសារ ។ ការដាំដំណាំជាដំណាំចម្រុះគ្នាដែលមានក្រឡាផ្ទៃតូច ។ សួនបន្លែមានប្រយោជន៍ច្រើនយ៉ាងសំរាប់សមាជិក ក្នុងគ្រួសារ ដែលត្រូវយកមកធ្វើម្ហូបអាហារគ្រប់ពេលវេលាដែលយើងត្រូវការ ។

ហេតុអ្វីបានជាសួនបន្លែជាលក្ខណៈគ្រួសារមានសុវត្ថិភាពល្អ?

- ការដាំបន្លែក្នុងក្រឡាផ្ទៃតូចជាលក្ខណៈគ្រួសារ អាចនាំមកនូវលទ្ធផលល្អប្រសើរ ព្រោះនៅជុំវិញផ្ទះមានការថែទាំជិតដល់ ។
- ប្រភពទឹកគ្រប់គ្រាន់សំរាប់ដំណាំផ្សេងៗ ឬ ប្រើទឹកដែលនៅសល់ពីការប្រើប្រាស់ក្នុងគ្រួសារ ។
  ឧទាហរណ៍ : ពេលងូតទឹកអាចបញ្ចូលទឹកហូរបានតាមកន្លែងធម្មតា ។
- ប្រើជីធម្មជាតិ ( កំប៉ុស្តទឹក-កំប៉ុស្តគោក, មមោក ) ។
- កាត់បន្ថយការប្រើថ្នាំសម្លាប់សត្វល្អិតលើរុក្ខជាតិ នាំអោយបន្លែគ្មានបញ្ហាដល់អ្នកទទួលទាន ។

## II- គោលបំណង

- រកបន្លែធ្វើម្ហូបទាន់ពេលវេលា ។
- បន្លែនៅស្រស់ ពណ៌ខៀវល្អ ។
- គ្មានបញ្ហាដល់សុខភាព ។
- គ្មានចំណាយប្រាក់ទិញបន្លែនៅទីផ្សារ ។
- អាចរកប្រាក់ចំណូលបានពីបន្លែ
- មិនខាតពេលវេលាទៅទិញបន្លែនៅទីផ្សារ ។
- មានអារម្មណ៍ល្អ ព្រោះបន្លែមានពណ៌បៃតងជុំវិញផ្ទះ ។

## III- ទម្លាប់របស់កសិករ

- ក្រោយពីច្រូតកាត់រួច កសិករតែងតែនៅទំនេរ ។
- ត្រូវការបន្លែតោងទៅផ្សារ ដើរសុំគេ ទិញគេ ឬបានពីអ្នកជិតខាង ។
- អាចមានបញ្ហាដល់អ្នកជិតខាង នៅពេលទៅសុំបន្លែគេញឹកញាប់ ។

- មិនព្រមអនុវត្តការដាំដុះបន្លែជាលក្ខណៈគ្រួសារនៅជុំវិញផ្ទះ ។
- មិនថែរក្សាដំណាំដាំដុះ មើលបំណាំគ្នាក្នុងគ្រួសារ ។

## IV- បច្ចេកទេសដាំដុះ

### ក_ការជ្រើសរើសទីកន្លែង និងពេលវេលា

- ទីកន្លែងមានទឹកគ្រប់គ្រាន់នារដូវប្រាំង ។
- ដីល្អមានជីជាតិ ។
- បង្ហូរទឹកចេញបាន កុំអោយដីសើមពេកនារដូវភ្លៀង ទីកន្លែងស្រឡះមានខ្យល់ល្អ ។
- ទំហំដីដាំបានស្រួល ៩៦ ឬ ១០០ ម៉ែត្រការ៉េ ឬ ដីមានបណ្តោយ ១៦ ម៉ែត្រ និង ទទឹង ៦ ម៉ែត្រ ។
- ទំហំដីនេះអាចដាំបានស្រួល ។
- ទទួលផលបានល្អសំរាប់ធ្វើម្ហូប បន្លែស្រស់ថ្មីៗក្នុងរង្វង់គ្រួសារដែលមានសមាជិក ៦ នាក់ ។

សរុបរួម ចំពោះដំណាំបន្លែ យើងត្រូវគិតទៅលើកត្តាចំបង:

- បរិយាកាស
- ពេលវេលា
- រដូវកាល
- សីតុណ្ហភាព សំណើម
- ទីកន្លែង
- ប្រភេទដី
- ពូជ

### ខ_ការរៀបចំដី

ដីសំរាប់ដាំបន្លែត្រូវរៀបចំយ៉ាងសិរិតសំរាំងបំផុត ។ ត្រូវកាប់ដី ឬ ភ្ជួរអោយបានច្រើនសា ពី ២ ទៅ ៣ ដង អោយបានជំរៅ ពី ២០ ទៅ ៣០ សង្ទីម៉ែត្រ, កៀរអោយស្មើនិងធ្វើអោយបានម៉ដ្តល្អ,យកស្មៅ ឬរុក្ខជាតិចេញ ។

ផលប្រយោជន៍នៃការធ្វើដីដោយសិរិតសំរាំងនាំអោយ :

- អាចធ្វើអោយធាតុអាកាស និង ទឹកជ្រាបទៅក្នុងដីបានយ៉ាងស្រួល ។
- ឬសបន្លែដុះចាក់បែកខ្នែក ស្រូបយកជីជាតិបានយ៉ាងងាយស្រួល ។
- ធ្វើអោយដីសើមបានយូរ ក្រោយពេលយើងស្រោចទឹក ។

បើដំណាំបន្លែត្រូវការដាំលើរង ត្រូវលើករងអោយបានស្មើគ្នា ខ្ពស់ ឬទាបទៅតាមប្រភេទដំណាំ និងសមស្រប ទៅតាមរដូវកាល ។ រដូវភ្លៀងលើករងអោយបានខ្ពស់ជាងរដូវប្រាំងពី ២០ ទៅ ៣០ សង្ទីម៉ែត្រ ដើម្បីកុំអោយបន្លែលិចជាំទឹក ។ ហាលដីអោយបានយូរថ្ងៃ ដើម្បីសម្លាប់មេរោគ ឬសត្វល្អិតនៅក្នុងដី ។

### គ_របៀបដាំ

ដំណាំបន្លែត្រូវអនុវត្តជាដំណាំចំរុះ ដូច្នេះការដាំដុះក៏មានច្រើនរបៀបខុសៗគ្នាៈ

- បន្លែខ្លះដាំផ្ទាល់ដី ពុំចាំបាច់សាបយកកូនទៅស្ទូង ព្រោះបន្លែនោះក្រចាប់ឫសថ្មីជាងបន្លែដទៃ។

ឧទាហរណ៍ៈ ឆៃថាវ, ការ៉ុត, ប៉ិគក់...។

- បន្លែខ្លះទៀតត្រូវធ្វើថ្នាលសាបកូន ឬបណ្តុះកូនលើកន្ទោងសិន ទើបយកកូនទៅស្ទូងលើរង ឬដាក់ក្នុងរណ្តៅ។

ឧទាហរណ៍ៈ ស្ពៃ, សាឡាត់, ប៉េងប៉ោះ, ត្រប់, ត្រឡាច ...។

### ឃ_របៀបធ្វើថ្នាលសាប ឬព្រោះគ្រាប់

ត្រូវធ្វើថ្នាលអោយបានសមស្របទៅតាមទំហំដីដែលយើងយកកូនទៅស្ទូង។ កំពស់ថ្នាលពី ១០ ទៅ ២០ សម ទៅតាមរដូវកាល។

### ង_របៀបដាក់ជីមុនពេលសាប ឬព្រោះគ្រាប់

កាលណារៀបចំថ្នាលបានត្រឹមត្រូវហើយ ត្រូវយកជីធម្មជាតិ មានកំប៉ុស្តលាមកគោមកដាក់ទ្រាប់បាត រោយអោយស្មើ កាប់ត្រឡប់ទៅក្នុងដី រួចស្រោចទឹកអោយសើមជានិច្ច។ ចំនួនជីដែលត្រូវប្រើគឺ លាមកគោចំនួនពី ៣ ទៅ ៥ គីឡូក្រាម ក្នុង១ ម៉ែត្រក្រឡា។

### ច_របៀបសាប ឬព្រោះពូជបន្លែ

ត្រូវរោយអោយស្មើហើយថ្នមៗដៃ។ គ្រាប់បន្លែល្អិតពេក ត្រូវលាយជាមួយផេះ ឬ ខ្សាច់ម៉ដ្ឋក្នុងកំរិតគ្រាប់ពូជ ១ ភាគត្រូវលាយ ជាមួយដីខ្សាច់ ឬ ផេះ ៤ ភាគ។ ការលាយរបៀបនេះនាំអោយកូនបន្លែដុះស្មើគ្នា មិនក្រាស់ពេក មិនស្តើងពេក។ ក្រោយពីសាបរួច ត្រូវយកដីម៉ដ្ឋរោយពីលើបន្ថែម និងគ្របចំបើងដែលកាត់ជាកំណាត់ខ្លីៗដើម្បីរក្សាសំណើមបានយូរ។ ក្រោយពីសាបរួច ត្រូវបាញ់ថ្នាំការពារ ឬយកផេះទៅរោយជុំវិញថ្នាលដើម្បីការពារស្រមោច មិនអោយចូលស៊ីគ្រាប់ពូជ ឬ កូនបន្លែ។

### ឆ_របៀបដាំ ឬស្ទូងកូនបន្លែ

ត្រូវស្ទូងកូនបន្លែនៅពេលថ្ងៃរសៀល ដែលមានធាតុអាកាសត្រជាក់ ដើម្បីកុំអោយកូនបន្លែស្វិតស្រពោន ឬស្លោកដោយសារកំដៅថ្ងៃ។ ត្រូវជ្រើសរើសយកកូនបន្លែណាដែលមានដើមថ្លោសធំគ្មានជម្ងឺឫសត្វល្អិតបំផ្លាញ។មុនពេលដកកូនបន្លែ ត្រូវស្រោចទឹកលើថ្នាលអោយបានសើមល្អ ដើម្បីស្រួលដកកុំអោយដាច់ឫស។ គេអាចដកកូនបន្លែទៅតាមអាយុកាលនៃប្រភេទបន្លែ។

### បញ្ជាក់ៈ

ត្រូវចំណាំកូនបន្លែដែលមានស្លឹកពី ៤ទៅ ៥ សន្លឹក គេអាចយកទៅស្ទូង ឬដាំតាមចន្លោះជួរ និងចន្លោះគុម្ព។ ចន្លោះជួរ និងចន្លោះគុម្ពអាចកំណត់បានទិន្នផល និងចំនួនគ្រាប់ពូជ។ ការដាំញឹកបណ្តាលអោយដើមស្គម ទិន្នផលទាប ។

ការដាំរធ្វើលពេក នាំអោយខាតផ្ទៃដីដាំដុះ ទិន្នផលទាប ។

ឧទាហរណ៍

- ស្ពៃ : ចន្លោះជួរមួយទៅជួរមួយ ២០ ទៅ ៣០ សង្ទីម៉ែត្រ ។
  ចន្លោះគុម្ពមួយទៅគុម្ពមួយ ១៥ ទៅ ២៥ សង្ទីម៉ែរត ។
- សាឡាត់ : ចន្លោះជួរមួយទៅជួរមួយ ១៥ សង្ទីម៉ែត្រ ។
  ចន្លោះគុម្ពមួយទៅគុម្ពមួយ ២០ សង្ទីម៉ែត្រ ។
- ប៉េងប៉ោះ : ចន្លោះជួរមួយទៅជួរមួយ ៥០ សង្ទីម៉ែត្រ ។
  ចន្លោះគុម្ពមួយទៅគុម្ពមួយ ៨០ សង្ទីម៉ែត្រ ។
- ត្រប់ : ចន្លោះជួរមួយទៅជួរមួយ ៥០ សង្ទីម៉ែត្រ ។
  ចន្លោះគុម្ពមួយទៅគុម្ពមួយ ៨០ សង្ទីម៉ែត្រ ។

## ជ_របៀបដាំបន្លែជុំវិញដីកំប៉ុស្ត

យកដីកំប៉ុស្តដាក់គរមួយកន្លែង ព័ទ្ធឬស្សីជុំវិញ ការពារមិនអោយសត្វចូលមកកកាយ មានកំពស់ពី ២០ ទៅ ៣០ សង្ទីម៉ែត្រ ។ ដាំបន្លែព័ទ្ធជុំវិញដីកំប៉ុស្ត ដូចជាម្ទេស ប៉េងប៉ោះ ត្រប់ ជាដើម ដែលមានចម្ងាយពីដីកំប៉ុស្តពី ៧ ទៅ ៩ សង្ទីម៉ែត្រ ។ក្នុងពេលស្រោចទឹក ចូរស្រោចទៅលើដីកំប៉ុស្ត ដើម្បីអោយទឹកមានជីជាតិល្អ ។ កូនដំណាំធំធាត់ តែមិនត្រូវស្រោចទឹកទៅលើកូនរុក្ខជាតិទេ ។

**បញ្ជាក់:** ជីកំប៉ុស្តត្រូវមានចំបើងគ្របពីលើ ។

## ឈ_របៀបដាំបន្លែ

ក្នុងផ្ទៃដី ១៦ ម x ៦ ម = ៩៦ ម$^{២}$ ត្រូវចែកជាបីចំណែក:

ចំណែកទី១: ដាំទៅលើបន្លែណាដែលអាចប្រមូលផលបានក្នុងរយៈពេលពី ២ ទៅ ៤ ខែ មានត្រសក់ ប៉េងប៉ោះ ស្ពៃ ម្ទេស.....។.

ចំណែកទី២: ដាំទៅលើដំណាំណា ដែលអាចប្រមូលផលចាប់ពី ៥ ឡើងទៅ ប៉ុន្តែទុកពាក់កណ្តាលសំរាប់ដាំនៅពេលក្រោយ ដូចជា ពពួកត្រប់ ម្ទេស .....។

ចំណែកទី៣: ដាំទៅលើដំណាំណា ដែលមានអាយុចាប់ពី ១ ឆ្នាំឡើងទៅ ប៉ុន្តែ អាចដាំដំណាំចម្រុះលាយគ្នាមានពពួកស្ពៃជាដើម ប៉ុន្តែទុកពាក់កណ្តាលសំរាប់ដាំបន្ត ដូចជា ស្ពៃ ម្រុំ.......។

ដំណាំព័ទ្ធជុំវិញផ្ទៃដីដាំបន្លែ: ល្ហុង ត្របែក ចេក ក្រូចឆ្មារ ស្លឹកគ្រៃ ជីគ្រប់មុខ ។

**បញ្ជាក់:** ដីទុកពាក់កណ្តាល ដាំបន្តនៅពេលដំណាំទាំងនោះមានអាយុកាលជិតប្រមូលផល ។

ឧទាហរណ៍ : ដើមចាស់ ចាប់ផ្តើមផ្កា ផ្លែ ។

## V-ការវិភាគសេដ្ឋកិច្ច

ក្រឡាផ្ទៃដំណាំដាំដុះ ១៦ ម x ៦ម = ៩៦ ម² ។

| បរិយាយ | ចំនួនថ្ងៃ | តម្លៃរាយ | តម្លៃសរុប |
|---|---|---|---|
| កាប់ដី រាស់ដី លើករង | ២ថ្ងៃ | ៦ 000 រៀល | ១២ 000 រៀល |
| ជីលាមកគោ | | | ៣ 000 រៀល |
| ដកស្មៅ | | | ២ 000 រៀល |
| គ្រាប់ពូជសាឡាត់ ម្រះ | | | ៥ 000 រៀល |
| ស្ពៃជើងទា | | | សរុប = ២២ 000 រៀល |

មុខបន្លែដាំលើកទី ១ មាន :

- សាឡាត់ ២៧ គីឡូក្រាម = ២៧ 000 រៀល
- ម្រះ ១០ គីឡូក្រាម = ១៤ 000 រៀល
- ស្ពៃជើងទា ២៧ គីឡូក្រាម = ២១ ៦00 រៀល
- សរុប ៦៤ គីឡូក្រាម = ៦២ ៦00 រៀល

**លទ្ធផលទទួលបាន:**

បើសិនជាលក់ដំណាំបន្លែទាំងអស់ គេបានចំណេញ: ៦២ ៦00 រៀល - ២២ 000 រៀល = ៤0៦00រៀល ។ ដំណាំទាំងនេះជាដំណាំសួនបន្លែក្នុងគ្រួសារ ។ ដូច្នេះ យើងអាចលក់បានខ្លះ ទទួលទានបន្លែស្រស់ គ្មានជីគីមី គ្មានថ្នាំគីមី អាចចំណេញបានថវិការ គ្មានចំណាយទៅទិញពីខាងក្រៅ គុណភាពបន្លែល្អ សុខភាពល្អ អាយុយឺនយូរ ។

**បញ្ជាក់:**

នេះគ្រាន់តែបញ្ជាក់ពីតម្លៃសំភារៈនិងការងារដែលបានជួលគេ ។

ក្នុងផ្ទៃដី ៩៦ម² គេដាំតែពាក់កណ្តាល គឺ ៤៨ ម² ពាក់កណ្តាលទៀត ទុកបំរុងដាំបន្ត ។

មុខបន្លែដាំលើកទី ១ មាន :

- សាឡាត់ ២៧ គីឡូក្រាម = ២៧ 000 រៀល
- ម្រះ ១០ គីឡូក្រាម = ១៤ 000 រៀល
- ស្ពៃជើងទា ២៧ គីឡូក្រាម = ២១ ៦00 រៀល
- សរុប ៦៤ គីឡូក្រាម = ៦២ ៦00 រៀល

**លទ្ធផលទទួលបាន:**

បើសិនជាលក់ដំណាំបន្លែទាំងអស់ គេបានចំណេញ: ៦២ ៦00 រៀល - ២២ 000 រៀល = ៤0៦00រៀល ។

ដំណាំទាំងនេះជាដំណាំសួនបន្លែក្នុងគ្រួសារ ។ ដូច្នេះ យើងអាចលក់បានខ្លះ ទទួលទានបន្លែស្រស់ គ្មានជីគីមី គ្មានថ្នាំគីមី អាចចំណេញបានថវិកា គ្មានចំណាយទៅទិញពីខាងក្រៅ គុណភាពបន្លែល្អ សុខភាពល្អ អាយុយឺនយូរ ។

# ដំណាំស្រូវប្រដេញទឹក
# (Irregated & Recession Rice Growing)

## I- ទស្សនៈទូទៅ

ប្រទេសកម្ពុជាមានវិសាលភាពធំធេងក្នុងការអនុវត្តស្រូវប្រដេញទឹក ដែលនឹងផ្តល់នូវទិន្នផលខ្ពស់ ហើយមានរយៈពេលខ្លី ។ ការចំណាយទៅលើការស្រោចស្រព ក៏មានលក្ខណៈងាយស្រួល ហើយមិនចំណាយទុនច្រើន ដូចស្រូវប្រាំងទេ ។

គេប្រទះឃើញការអនុវត្តស្រូវប្រដេញទឹកច្រើននៅតាមដងទន្លេមេគង្គ និងទន្លេបាសាក់ ក្នុងតំបន់វាលទំនាបលិចទឹក ក្បែរបឹង ក្រោយច្រាំងទន្លេ គេប្រទះឃើញផងដែរ នៅក្នុងតំបន់វាលទំនាបនៃបឹងទន្លេសាប ។ នៅក្នុងតំបន់ទាំងពីរនេះ ការអនុវត្តមានភាពប្រហាក់ ប្រហែលគ្នា ដោយការចាត់ចែងធ្វើជាកូនស្រែតូចៗ មានភ្លឺទប់ទឹកនៅក្នុងរដូវសំរកចាប់ពីចុងខែតុលា ឬដើមខែ វិច្ឆិកា ជារៀងរាល់ឆ្នាំ ។

នៅតំបន់វាលរាបដោយស្ថានភាពទឹកភ្លៀងមិនទៀងទាត់ពិសេសនៅដើមរដូវ គេសង្កេតឃើញមានដីទំនេរដែលកសិករយើង ត្រៀមអនុវត្តរបៀបស្រូវប្រដេញទឹកដែរ ប៉ុន្តែការអនុវត្តនេះ ត្រូវបានយកចិត្តទុកដាក់សំខាន់បំផុតលើប្រភពទឹក (ស្ទឹង បឹង ឬ អូរធម្មជាតិ) ដែលអាចផ្គត់ផ្គង់ដល់ការស្រោចស្រពស្រូវក្នុងខែបន្តបន្ទាប់ ។ ការធ្វើស្រែរបៀបនេះ គេអាចថាបានដែរ ជាស្រូវរដូវស្រូវប្រាំង ប៉ុន្តែការប្រមូលផល អាចធ្វើនៅពេលជាមួយគ្នានៃស្រូវប្រដេញទឹក ក្នុងតំបន់វាលទំនាបបត់បែននៃទន្លេដែរ ។

## II- គោលបំណង

១-បង្កើនការយល់ដឹងឱ្យកាន់តែប្រសើរឡើងលើការអនុវត្តផលិតកម្មស្រូវប្រដេញទឹក ។

២-លើកកំពស់សមត្ថភាព ក្នុងផលិតកម្មស្រូវប្រដេញទឹកតាមបច្ចេកទេសដើម្បីទទួលបានទិន្នផលខ្ពស់ និងពង្រីកការដាំដុះ ដោយពង្រីកផ្ទៃដីឱ្យបានច្រើនលើតំបន់ដែលមានលទ្ធភាពអាចធ្វើបាន ។

៣-បង្កើននូវប្រាក់ចំណូលឱ្យបានកាន់តែខ្ពស់ ដែលបានមកពីការធ្វើផែនការបានត្រឹមត្រូវ ក្នុងផលិតកម្មនិងការលក់ដូរផលិតផលស្រូវប្រដេញទឹក ។

## III- ការអនុវត្តន៍របស់កសិករលើផលិតកម្មស្រូវប្រដេញទឹកកន្លងមក

១-ការជ្រើសរើសពូជស្រូវពុំទាន់បានល្អនៅឡើយ ។

២-ការសាបស្រូវនៅពុំទាន់បានសមស្របតាមបច្ចេកទេស ។

៣-អនុវត្តការដកសំណាប ការស្ទូងស្រូវ មិនទាន់បានត្រឹមត្រូវតាមបច្ចេកទេស( សំណាបចាស់ពេក, បាក់ដើមសំណាប និងដាច់ឫស...) ។

៤-ការប្រើប្រាស់ជីមិនទាន់បានត្រឹមត្រូវពឹងផ្អែកទៅលើជីគីមីតែមួយមុខ( ដាក់ជីច្រើនហួស ឬ តិចពេក មិនស្គាល់ជីច្បាស់ ដាក់ជីមិនទាន់ចំពេល ដែលដំណាំត្រូវការ...) ។

៥-ការគ្រប់គ្រងទឹកក្នុងស្រែ ឬក្នុងថ្នាលសំណាប ពុំទាន់បានល្អ ។

៦-ការថែទាំស្រូវ និងការប្រមូលផលស្រូវ មិនទាន់បានត្រឹមត្រូវ នាំឱ្យបាត់ទិន្នផលស្រូវ ។

## IV- ការអនុវត្តន៍បច្ចេកទេសក្នុងផលិតកម្មស្រូវប្រដេញទឹក

ការអនុវត្តផលិតកម្មដំណាំស្រូវ ប្រដេញទឹក មានភាពស្រួចស្រាល់ណាស់ ព្រោះការងារនេះមានរយៈពេលខ្លី តំរូវឱ្យផលិតករ យក ចិត្តទុកដាក់និងមានផែនការជាក់លាក់ ដោយផ្តោតសំខាន់ទៅលើពូជស្រូវនិងការគ្រប់គ្រងទឹកឱ្យបានល្អ ដើម្បីដំណើរការបច្ចេក ទេសបានសមស្រប និងទទួលបានទិន្នផលខ្ពស់ ។

### ១_ការជ្រើសរើសពូជស្រូវ :

- ពូជស្រូវធន់នឹងជំងឺនិងសត្វល្អិត ។
- ពូជស្រូវផ្តល់ទិន្នផលខ្ពស់ ។
- ពូជស្រូវមិនប្រកាន់រដូវ និងមានរយៈពេលខ្លី ។
- ពូជស្រូវមានគុណភាពល្អ - សុទ្ធ - មានដំណុះគ្រាប់ពី ៨៥% ឡើងទៅ ។
- ពូជស្រូវត្រូវមានគុណភាពអង្ករល្អ តំរូវទីផ្សារ ។

### ២_យល់ដឹងពីដំណាក់កាលលូតលាស់របស់ដំណាំស្រូវ :

ការយល់ដឹងពីដំណាក់កាលលូតលាស់របស់ដំណាំស្រូវមានសារៈសំខាន់ណាស់ដើម្បីគ្រប់គ្រងដំណាំស្រូវឱ្យបានត្រឹមត្រូវតាមបច្ចេកទេសនិងជៀសវាងបាននូវការចំណាយច្រើនឥតប្រយោជន៍ ព្រមទាំងធ្វើឱ្យបាត់បង់នូវទិន្នផលស្រូវដោយកត្តាផ្សេងៗ ។

ការលូតលាស់របស់ដំណាំស្រូវ ត្រូវចែកជា ៣ វគ្គសំខាន់ ៖

ក) -វគ្គលូតលាស់ ៖ វគ្គលូតលាស់នេះ មានរយៈពេលខុស១គ្នា អាស្រ័យតាមប្រភេទស្រូវ (ស្រូវប្រកាន់រដូវ ឬមិនប្រកាន់រដូវ ) និងអាយុកាលនៃពូជស្រូវនីមួយ១ ហើយចែកចេញជា ៤ ដំណាក់កាល គឺ ៖

- ដំណាក់កាលដុះពន្លក (ចាប់ពីគ្រាប់ស្រូវដល់ស្រូវដុះពន្លកស្លឹកទី១) ។
- ដំណាក់កាលសំណាប (ចាប់ពីស្រូវដុះស្លឹកទី ១ ដល់ស្រូវចាប់បែកគុម្ព) ។
- ដំណាក់កាលបែកគុម្ព (ចាប់ពីស្រូវបែកគុម្ពដំបូង ដល់ស្រូវបែកគុម្ពពេញទំហឹង) ។
- ដំណាក់កាលពន្លូតដើម (ចាប់ពីស្រូវបែកគុម្ពពេញទំហឹង ដល់ស្រូវចាប់ផ្ដើមពន្លកកកួរ) ។

ខ) -វគ្គបង្កបង្កើតផល ៖ វគ្គបង្កបង្កើតផលមានរយៈពេល ៣៥ ថ្ងៃ និងចែកចេញជា ៣ ដំណាក់កាល គឺ ៖

- ដំណាក់កាលពន្លកកកួរ (ចាប់ពីពន្លកកកួរដល់ស្រូវផើម) ។
- ដំណាក់កាលចេញកួរ (ចាប់ពីស្រូវផើមដល់ស្រូវចេញកួរផុតពីស្លឹកទង់ជ័យ) ។
- ដំណាក់កាលចេញផ្កា (ចាប់ពីស្រូចេញកួរផុតដល់ស្រូវរោយលំអង) ។

គ) -វគ្គទុំ ៖ វគ្គទុំមានរយៈពេល ៣០ ថ្ងៃ និងចែកចេញជា ៣ ដំណាក់កាល គឺ ៖

- ដំណាក់កាលដាក់ទឹកដោះ ។
- ដំណាក់កាលដាក់ម្សៅ ។
- ដំណាក់កាលទុំពេញលេញ ។

## ៣_អំពីថ្នាលសំណាប

- ត្រូវភ្ជួរដាស់ដីទុករយៈពេល ៧ - ១០ថ្ងៃសិន ។
- អនុវត្តថ្នាលសំណាបគោក និងជិតប្រភពទឹក ។
- ថ្នាលសំណាបត្រូវមានដីជាតិល្អ និងរាបស្មើ ។
- ត្រូវភ្ជួរនិងរាស់ឱ្យបានច្រើនសាក្នុងជំរៅ ១៥សម ។
- ត្រូវធ្វើជារងដែលមានទទឹងពី ១ ម៉ែត្រ កន្លះ ទៅ ២ ម៉ែត្រ ដោយមានចង្អូរ (បណ្ដោយមិនកំណត់តាមលទ្ធភាព) ។
- ត្រូវដាក់ជីកំប៉ុស្ត ឬលាមកសត្វពុករលួយល្អ ពី ២-៣ គក្រ ក្នុងដី ១ម២ និងជី ដេ-អា-ប៉េ ១០០ក្រាមក្នុងដី ១ម២ ជាជី ទ្រាប់បាត ។
- ត្រូវធ្វើថ្នាលសំណាបពី ២០០ - ២៥០ម២ សំរាប់ស្ទូងលើផ្ទៃដី ១ ហិកតារ ។
- ថ្នាលសំណាបត្រូវនៅឆ្ងាយពីម្លប់ (មានពន្លឺថ្ងៃពេញលេញ) ។

**សេចក្តីបញ្ជាក់ :** ការភ្ជួររាស់ត្រូវធ្វើឱ្យបានច្រើនសា ដើម្បីធ្វើឱ្យដីធូរ ខ្យល់ចេញចូលបានល្អ សំរួលដល់ការរីកលូតលាស់ផ្នែកប្រព័ន្ធឫស បានច្រើន ព្រមទាំងធ្វើដីឱ្យរាបស្មើល្អ ។

ម្យ៉ាងទៀត ការដាក់ជីទ្រាប់បាតដោយជីកំប៉ុស្ត ឬជីលាមកសត្វពុកផុយល្អ ត្រូវធ្វើនៅពេលភ្ជួររាស់ចុងក្រោយ ដោយភ្ជួររាស់ច្របល់ជីឱ្យបាន សព្វល្អ ។ ថ្នាលត្រូវមានភ្លឺជាទ្រនំលលក ជាការល្អ ។

## ៤_ការត្រៀមពូជស្រូវសំរាប់សាប_ការដកសំណាប

- ជាដំបូង ត្រូវធ្វើការសំអាតគ្រាប់ពូជស្រូវដោយត្រូវរែញកគ្រាប់ពូជមិនគ្រប់លក្ខណៈចេញ : ដាក់ពងមាន់ ឬពងទាទៅក្នុងធុងទឹក រួចដាក់អំបិលមួយចំនួនទៅក្នុងទឹកជាមួយគ្នានោះដែរ ។ កូរឱ្យអំបិលរលាយអស់រង់ចាំស៊ុតអណ្តែតឡើង (បើមិនទាន់ អណ្តែត ត្រូវថែមអំបិល) ។ បន្ទាប់មកត្រូវចាក់ស្រូវទៅក្នុងធុងទឹក ព្រមទាំងកូរឱ្យបានច្រើនដង ។ រង់ចាំនិងស្រង់គ្រាប់ស្រូវ ដែលអណ្តែតចោល ហើយស្រង់គ្រាប់ស្រូវដែលលិចនៅក្នុងធុងទុកមួយកន្លែង ។ ត្រូវធ្វើរបៀបនេះឱ្យ បាន២ ឬ ៣ដង រួចហើយ ត្រូវលាងគ្រាប់ស្រូវនឹងទឹកធម្មតាឱ្យស្អាត (ឱ្យអស់ជាតិអំបិល និងធូលីដី) ។
- បន្ទាប់មក យកគ្រាប់ស្រូវដាក់ក្នុងបាវស្អាតចងមាត់ រួចត្រាំក្នុងទឹកធម្មតារយៈពេល ២៤ ម៉ោង ។ ត្រូវលាងគ្រាប់ពូជត្រាំនេះ ឱ្យស្អាត រួចយកទៅផ្អាប់រយៈពេល ២៤ ម៉ោងនៅក្រោមម្លប់ដោយពង្រាបបាវស្រូវនេះក្នុងកំពស់ ១០-១៥សម និងយកចំបើង គ្របពីលើបាវស្រូវ ដើម្បីបង្កើនកំដៅឱ្យគ្រាប់ពូជដុះបានល្អ ។ ត្រូវធ្វើការត្រឡប់បាវស្រូវផង ដើម្បីសំរួលកំដៅក្នុងរយៈពេល ១២ ម៉ោងហើយត្រូវស្រោចទឹក រក្សាសំណើមឱ្យស្រូវឆាប់ចេញពន្លក ។
- ផ្អាប់ពូជរួចហើយ ស្រូវចាប់ផ្តើមបែកពន្លក ត្រូវយកគ្រាប់ពូជទៅសាបលើថ្នាលក្នុងអត្រា ១០០-១៥០ក្រាមក្នុង ១ម២ ដោយធ្វើការរាយគ្រាប់ឱ្យបានស្មើល្អ (ស្មានប្រហែលមួយទូកដៃ) ។ ធ្វើរបៀបនេះ ជៀសវាងសំណាបក្រាស់ពេក មានលក្ខណៈ ដើមតូចវៀវខ្វះគុណភាព ។

ការសាបស្រូវ ត្រូវអនុវត្តនៅពេលល្ងាច ជៀសវាងការថយចុះកំលាំងគ្រាប់ពូជដោយសារកំដៅថ្ងៃ និងម្យ៉ាងទៀតបើ មេឃបំរុងនឹងភ្លៀង គួរផ្អាកការសាប ជៀសវាងធ្វើឱ្យរមូរគ្រាប់ពូជ ឬហូរគ្រាប់ចូលក្នុងចង្អូរថ្នាលសំណាប ។

- ត្រូវថែទាំសំណាបឱ្យបានល្អ, កុំឱ្យមានសត្វបំផ្លាញ, កំចាត់ស្មៅចង្រៃចេញ, ថែរក្សាទឹកឱ្យសើមជានិច្ចនៅក្នុងថ្នាល យកល្អដាក់ទឹកក្នុងចង្អូរថ្នាលជាប្រចាំ ។
- សំណាបអាចដកយកទៅស្ទូងបានក្នុងរយៈពេល ១៥ ថ្ងៃ ឬលើសបន្តិចបន្តួច (ជាគោលការណ៍សំណាបត្រូវធ្វើការដកទៅស្ទូង នៅក្រោមអាយុ ២០ថ្ងៃ) ដោយអនុវត្ត :

  - ដកថ្នមៗកុំឱ្យបាក់ដើមសំណាប និងដាច់ឫស ។

- ដករួចដាក់ក្នុងបង្គី ឬសំភារៈផ្សេងៗដែលអាចធានាបាននូវភាពល្អនៃដើមសំណាប រួចហើយត្រូវយកទៅស្ទូងជាបន្ទាន់ (ក្នុងថ្ងៃតែមួយ) ។

**ប្រការត្រូវជៀសវាង!**

- មិនត្រូវដកសំណាបបោកឡើយ ។
- មិនត្រូវចងជាកណ្តាប់ទេ ។
- មិនត្រូវផ្អាប់ទុកឆ្លងថ្ងៃឡើយ ។

## ៥_ការរៀបចំដីផ្ទៃស្រែសំរាប់ស្ទូងស្រូវ

ការរៀបចំដីសំរាប់ស្ទូង ជាផ្នែកមួយមានឥទ្ធិពលនិងមានសារៈសំខាន់បំផុតដល់ការអនុវត្តស្រូវប្រដេញទឹកឱ្យបានលឿននិងឆ្លើយ តបតាមបច្ចេកទេស ។ ដូចនេះ ការរៀបចំដី ត្រូវបានអនុវត្តនៅពេលមុនទឹកលិច (ទឹកទន្លេជោរជន់) ។

-ស្រែត្រូវកំណត់ជាដីដែលមានទំហំតូចៗ (៥០០ម២) ឬលើសដោយមានភ្លឺសំរាប់ទប់ទឹក នៅពេលទឹកស្រកវិញ ដើម្បីសំរួលដល់ការរាស់ពង្រាបដីឱ្យបានស្មើល្អ ។

-ត្រូវធ្វើការភ្ជួរឱ្យបានហើយស្រេចមុនទឹកលិច ។ ត្រូវភ្ជួរឱ្យបានល្អ កុំឱ្យមានល្វែងក្នុងជំរៅ ១៥សម ដោយមានអាចម៏ បំណាស់គ្របជាស្រទាប់ៗលុបកំទេចកំទីសារធាតុសរីរាង្គ ឬ កាកសំណល់ក្រោយពីការប្រមូលផលដំណាំមុន ។

-ក្រោយទឹកស្រកផុតពីភ្លឺស្រែ (កុំឱ្យទឹកនៅក្នុងស្រែច្រើនពេក២-៣សម ជាការល្អ) គេអាចភ្ជួរម្តងទៀតរិតតែប្រសើរ បើសិនជាមានលទ្ធភាព ។

-ដាក់ជីកំប៉ុស្ត ឬ ជីលាមកសត្វពុកផុយល្អ ៥-១០ តោន ក្នុង ១ ហិកតារ ។

-ដាក់ជី ដេ-អា-ប៉េ (១៨-៤៦-០) ១០០គក្រ ក្នុង ១ ហិកតារ ។

-ដាក់ជីប៉ូតាស្យូម (០-០-៦០) ៥០គក្រ ក្នុង ១ ហិកតារ សំរាប់ជាជីទ្រាប់បាត ។

ត្រូវអនុវត្តការព្រោចជីទាំងពីរមុខនេះឱ្យបានល្អនៅក្នុងស្រែ រួចធ្វើការរាស់ឱ្យបានច្រើនសា ដើម្បីឱ្យជីទ្រាប់បាតច្របល់កប់ចូលក្នុងដី និងធ្វើឱ្យដីម៉ដ្ឋនិងរាបស្មើល្អ ។

## ៦_ការស្ទូងស្រូវ

សំណាបដែលបានដករួច ត្រូវដឹកជញ្ជូនដោយប្រុងប្រយ័ត្ន យកទៅស្ទូងជាបន្ទាន់នៅក្នុងស្រែ ដែលបានរៀបចំដីជាស្រេច ។

-ត្រូវស្ទូងដោយចាប់ថ្មមៗ ពី ១ -២ ដើម ក្នុង ១ ដំណោត ។

-ត្រូវស្ទូងរាក់ៗ ។

-ត្រូវស្ទូង ដោយជ្រើសរើសរាំងបត់ដើមសំណាប ។

ការស្ទូងស្រូវ គួរអនុវត្តជាជួរតាមខ្សែក្រិត ២០សម ខ ២០សម ឬ ២៥សម ខ ២៥សម ទៅតាមប្រភេទដីដើម្បីសំរួលដល់ការថែទាំបោចស្មៅ និងការរីកលូតលាស់ឆាប់របស់ដំណាំស្រូវ ។

## ៧_ការថែទាំសន្ទូង និងការគ្រប់គ្រងទឹក

- ត្រូវពិនិត្យ និងធ្វើការជួសសន្ទូងជាបន្ទាន់ បើមានបាត់ដំណោត ឬគុម្ពស្រូវ ព្រោះអាចបាត់បង់ទិន្នផល បើយើងខកខានជួសសន្ទូង (បាត់ដោយសារក្តាម ឬរលួយដើមស្រូវ) ។

- ត្រូវខុសប្រាហ៊ីបោចស្មៅ កុំឱ្យស្មៅដុះប្រជែងដំណាំស្រូវ (ស្មៅជាប្រភពអ្នកស្រូបយកជីជាតិ និងរំខានដល់ការលូតលាស់ របស់ដំណាំ និងជាជំរករបស់សត្វល្អិត និងកណ្តុរ) ។

- ត្រូវខុសប្រាហ៊ីត្រួតពិនិត្យភ្លឺស្រែ ក្រែងមានធ្លុះធ្លាយ ដោយសត្វក្តាម ឬ កណ្តុរធ្វើរន្ធ និងត្រូវធ្វើការគ្រប់គ្រងទឹកក្នុងស្រែឱ្យបានល្អ ។ ស្រូវត្រូវការទឹកក្នុងវគ្គបង្កបង្កើតផល និងវគ្គទុំ (២-៣សម ជាការប្រសើរ) ។ ក្នុងវគ្គលូតលាស់ ស្រូវត្រូវការទឹកធម្មតា (ចាប់ពីស្ទូងរហូតដល់វគ្គបង្កបង្កើតផល) ។

## ៨_ការដាក់ជីបំប៉ន

ជាការសំខាន់ ការដាក់ជីបំប៉នស្រូវ ត្រូវធ្វើឱ្យចំពេលដែលដំណាំស្រូវត្រូវការ ។ បើពុំដូចនោះទេ នឹងនាំឱ្យមានការខាតបង់ថវិកា និងទិន្នផលថយចុះ ។

- ពេលវេលាសមស្រប ត្រូវធ្វើនៅពេលស្រូវចាប់ផ្តើមបែកគុម្ពក្នុងគោលបំណងឱ្យស្រូវបែកគុម្ពជាអតិបរមាគ្មានដើមស្ទៀតដែល មិនផ្លែផ្កា ។ ការងារនេះត្រូវធ្វើម្តងទៀតនៅពេលស្រូវចាប់ផ្តើមកំណកំណើតពន្លកកក្កូរ ។

- ជីដែលត្រូវប្រើគឺជី អាសូត (អ៊ុយរ៉េ) ។ លើកទី១ ចំនួនជីអ៊ុយរ៉េ ៥០ គក្រ ក្នុង ១ហិតា បាចឱ្យបានសព្វល្អធ្វើនៅពេលស្លឹកស្រូវស្ងួតសន្សើម និងលើកទី២ ចំនួន ៥០ គក្រ ទៀតក្នុង ១ ហិកតារ ។

- គេអាចប្រើជីកំប៉ុស្ត ឬ លាមកសត្វក៏បានដែរ ប៉ុន្តែជីនេះ ពិបាកក្នុងការដឹកជញ្ជូន និងមានប្រតិកម្មយឺត (ស្រូវត្រូវការបន្ទាន់ ក្នុងដំណាក់កាលទាំងពីរខាងលើ (ពូជស្រូវស្រាលនាំចូល) ។

## ៩_ការប្រមូលផលស្រូវ និងទុកដាក់ផលស្រូវ :

### ក) -ការប្រមូលផលស្រូវ :

ដើម្បីប្រមូលផលស្រូវ តម្រូវឱ្យមានការត្រួតពិនិត្យ និងពិចារណាលើភាពទុំរបស់ស្រូវឱ្យបានត្រឹមត្រូវ ។ពេលវេលាច្រូតកាត់ ដែលសមស្របនោះគឺនៅពេលដែលគ្រាប់ស្រូវ ៨០-៨៥% ផ្នែកចុងកួរមានពណ៌លឿងដូចចំបើង ហើយគ្រាប់ស្រូវនៅគល់កួរស្ថិត នៅក្នុងដំណាក់កាលដាក់ម្សៅខ្ពស់ ។ ការច្រូតកាត់បានទាន់ពេលវេលានេះមានសារៈសំខាន់ :

- គុណភាពអង្ករល្អ តំរូវការទីផ្សារ

- មិនមានបាត់បង់ទិន្នផល ដែលបណ្តាលពីការដួលដើមស្រូវ និងបាក់កក្កួរស្រូវ ជ្រុះគ្រាប់ស្រូវ និងម្យ៉ាងទៀត ធ្វើឱ្យគ្រាប់ស្រូវមិនពេញលេញ (ស្មៀត) បើសិនជាយើងច្រូតមុនពេលទុំ ។

## ខ) -ការទុកដាក់ផលស្រូវ :

គ្រាប់ស្រូវដែលទើបនឹងបោកបែនហើយ អាចមានសំណើមគ្រាប់រហូតដល់២៥% ។ គេមិនអាចយកគ្រាប់ស្រូវដែលមានសំណើមខ្ពស់នេះទៅស្តុកទុកបានទេ - គ្រាប់ស្រូវនោះនឹងត្រូវពុកផុយដោយជំងឺផ្សិត និងពពួកសត្វល្អិតចង្រៃបំផ្លាញ ថែមទៀត ។ ដូចនេះត្រូវហាលស្រូវឱ្យបានស្ងួតល្អ ដែលកំណត់សំណើមត្រឹម ១៤% ។ គេអាចធ្វើតេស្ត ដោយខាំគ្រាប់ស្រូវ ហើយពិនិត្យ មើលផ្នែកគ្រាប់អង្ករមានពណ៌ថ្លានោះ គ្រាប់ស្រូវស្ងួតល្មមហើយ ។ បើសិននៅស្រអាប់ មិនទាន់ថ្លានោះទេ គ្រាប់ស្រូវមិនទាន់ស្ងួតឡើយ ។

ម្យ៉ាងទៀត ចូរកុំហាលស្រូវឱ្យស្ងួតហួសពេក នឹងនាំឱ្យគុណភាពអង្ករបាក់ខ្ទេច មានកញ្ចុំងច្រើន ។ គេអាចទុកដាក់ស្រូវក្នុងជង្រុកដែលមានខ្យល់ចេញចូលបានល្អ ព្រមទាំងការពារបានពីសំណាក់សត្វកណ្តុរនិងចាបផង ។ បាវក៏ជាឧបករណ៍ម្យ៉ាង សំរាប់ស្តុកស្រូវបានល្អដែរ ។ ស្រូវត្រូវទុកដោយឡែកពីគ្នា បើសិនជាមានពូជច្រើន ត្រូវសរសេរផ្លាកដាក់តាមពូជនោះផង ។

# V- ការវិភាគសេដ្ឋកិច្ចក្នុងផលិតកម្មស្រូវប្រដេញទឹក

| បរិយាយ | ឯកតា | ការអនុវត្តរបស់កសិករ | | | អនុវត្តតាមបច្ចេកទេស | | |
|---|---|---|---|---|---|---|---|
| | | ចំនួន | តំលៃឯកតា(រ) | តំលៃសរុប(រ) | ចំនួន | តំលៃឯកតា(រ) | តំលៃសរុប(រ) |
| ការរៀបចំដីសរុប | ហិកតារ | ១ | ១០០ ០០០ | ១០០ ០០០ | ១ | ១២០ ០០០ | ១២០ ០០០ |
| ពូជស្រូវ | គក្រ | ៦០ | ៨០០ | ៤៨ ០០០ | ៣៥ | ២ ០០០ | ៧០ ០០០ |
| ដកស្ទូងសរុប | នាក់ | ២៥ | ៧ ០០០ | ១៧៥ ០០០ | ២៥ | ៧០០០ | ១៧៥ ០០០ |
| ជីគីមី ដេ.អា.ប៉េ | គក្រ | ៥០ | ១ ៨០០ | ៩០ ០០០ | ១០០ | ១ ៨០០ | ១៨០ ០០០ |
| ជីគីមី $K_2O$ | គក្រ | ៥០ | ១ ៦០០ | ៨០ ០០០ | ៥០ | ១ ៨០០ | ៩០ ០០០ |
| ជីគីមីអ៊ុយរ៉េ | គក្រ | ៥០ | ១ ៤០០ | ៧០ ០០០ | ១០០ | ១ ៤០០ | ១៤០ ០០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ជីធម្មជាតិ | តោន | - | - | - | ៧ | ២០ 000 | ១៤០ 000 |
| ថ្នាំសំលាប់សត្វល្អិត | លីត្រ | ២ | ២០ 000 | ៤០ 000 | ២ | ២០ 000 | ៤០ 000 |
| ថ្នាំកំចាត់ស្មៅចង្រៃ | លីត្រ | - | - | - | - | - | - |
| ច្រូតកាត់ | នាក់ | ២០ | ៧ 000 | ១៤០ 000 | ២០ | ៧ 000 | ១៤០ 000 |
| ដឹកជញ្ជូនបោកបែន | គោយន្ត | ៥ | ២០ 000 | ១00 000 | ៧ | ២០ 000 | ១៤០ 000 |
| ទុកដាក់ | បាវ | ៦០ | ១ 000 | ៦០ 000 | ៩០ | ១ 000 | ៩០ 000 |
| សរុបចំណាយ | = | ៩០៣ 000 | | | ១ ៣២៥ 000 | | |
| ទិន្នផល | គក្រ | ២ ៥00 | | | ៤ ៥00 | | |
| ប្រាក់ចំណូល | ៥00 x ២៥00 = ១ ២៥០ 000 | | | | ៥00 x ៤៥00 = ២ ២៥០ 000 | | |
| ប្រាក់ចំណេញ | ៣៤៧ 000 | | | | ៩២៥ 000 | | |

- តំលៃស្រូវ = ៥00៛ ក្នុង ១ គក្រ

# ការពង្រាបដី (ដីស្រែ)
# Land Levelling (Rice field)

## I- សេចក្តីផ្តើម

ប្រជាកសិករខ្មែរយើងមានប្រហែល ៨៥ ភាគរយធ្វើស្រែ ហើយចាត់ទុកថា ជាមុខរបរចំបង ។ ភាគច្រើនក្នុងចំណោមកសិករយើងច្រើនអនុវត្តតាមទំនៀមទំលាប់ពីដូនតា ឪពុកម្តាយ ពុំបានស្វែងយល់ពីបច្ចេកទេសទំនើបៗ សំរាប់ដំណាំស្រូវបង្កើនទិន្នផលឱ្យបានខ្ពស់ ។

កត្តាសំខាន់ៗដែលបណ្តាលអោយដំណាំស្រូវបានផលទាបដូចជាកត្តាទឹកជីជាតិសត្វល្អិតចង្រៃជាដើម ។ដោយឡែក កត្តាចំបងគឺបញ្ហាទឹក និងជីជាតិសំរាប់ប្រជាកសិករដែលមានដីស្រែខ្ពស់ ទាប មិនស្មើ ទទួលទិន្នផលមិនសមស្រប បណ្តាលអោយការទទួលទឹក និងជីជាតិមិនគ្រប់គ្រាន់ពោលគឺទឹក និងជីជាតិគ្រប់គ្រាន់តែកន្លែងទាប ។

ដូច្នេះហើយ កត្តាដីស្រែដែលមានផ្ទៃដីរាបស្មើ ជាកត្តាសំខាន់ណាស់សំរាប់ការលូតលាស់ល្អចំពោះដំណាំស្រូវ ។ ផ្ទុយទៅវិញបើយើងមិនបានចាប់អារម្មណ៏ស្វែងយល់អំពីបញ្ហាទាំងនេះទេ យើងត្រូវខាតបង់ច្រើនណាស់នូវទិន្នផលស្រូវ ។

## II- គោលបំណង

១-យល់ដឹងអំពីដំណាំស្រូវមានក៏រិតទាបនោះ បណ្តាលមកពីការចែកចាយទឹក និងជីជាតិមិនបានសព្វគ្រប់នាំឱ្យដំណាំស្រូវលូតលាស់មិនបានល្អស្មើគ្នា ។

២-កសិករនៅខ្វះបច្ចេកទេសកសិកម្មទំនើបនិងសេចក្តីឧស្សាហ៏ព្យាយាមថែរក្សាដំណាំស្រូវ ដើម្បីអោយគាត់កែប្រែអ្វីដែលនៅខ្វះខាត ។

៣-ជឿជាក់ទៅលើបច្ចេកទេស និងអាចអនុវត្តបានទៅអនាគត ណែនាំទៅដល់កូនចៅ និងផ្សព្វផ្សាយទៅដល់អ្នកដទៃ ។

៤-យល់ច្បាស់ ឃើញច្បាស់នូវការខូចខាត បាត់បង់ប្រាក់កាស បណ្តាលមកពីកត្តាទឹក និងជីជាតិចាំបាច់សំរាប់ដំណាំស្រូវ ។


រៀបចំដោយលោក ជិត សុវណ្ណ និងស្រី ស្រស់ធីតា

## III- ទម្លាប់ធ្វើរបស់កសិករ

- ភ្ជួរស្រែ តែពុំបានចាប់អារម្មណ៍ទៅលើផ្ទៃដីខ្ពស់ ទាបគ្រួសត្រាយកាប់ឆ្ការឡើយ ។ ភាគច្រើនគិតគូរតែពីការលើកភ្លឺស្រែទប់ទឹក ។
-ទម្លាប់ប្រើជីក្នុងស្រែដែរ តែមិនបានសមស្រប ដោយទឹកមិនគ្រប់គ្រាន់ ទឹកមានក្នុងស្រែពុំបានសព្វផ្ទៃដីស្រែខ្ពស់ ទាប ។
- មិនឧស្សាហ៍ព្យាយាមក្នុងការងារស្រែចំការ ។
- មិនពង្រាបផ្ទៃដីស្រែអោយបានស្មើ ផ្ទុយទៅវិញ គាត់ទៅទាក់ទងជាមួយឈ្មួញម្ចាស់រថយន្តដឹកដី អោយគេកាប់ដីស្រទាប់ខាងលើ ដែលមានជីជាតិល្អ ដឹកយកចេញពីស្រែ ដោយពុំបានគិតគូរអំពីជីជាតិល្អឡើយ ។
- ការគ្រប់គ្រងថែរក្សាទឹកមានការលំបាក កន្លែងខ្លះទួល ភាគច្រើនមានស្មៅដុះជាជំរកសំរាប់សត្វល្អិតចង្រៃផង ។

## IV- វិធានការអនុវត្តន៍តាមលក្ខណៈបច្ចេកទេស

ក្រៅពីបច្ចេកទេសដាំដុះ ដំណាំស្រូវត្រូវការចាំបាច់បញ្ហាទឹក រួមផ្សំនិងជីជាតិ ។

- បញ្ហាទឹកក្នុងស្រែ : វាជាកត្តាសំខាន់ណាស់សំរាប់ការលូតលាស់នៃដំណាំស្រូវ ។ នោះក៏អាស្រ័យទៅដោយផ្ទៃដីស្រែរាបស្មើដើម្បីអោយទឹកជ្រាបគ្រប់សព្វលើផ្ទៃធ្វើអោយដំណាំស្រូវលូតលាស់បានល្អ ។ម្យ៉ាងទៀតកន្លែងណាដែលមានទឹក ស្មៅក៏ពុំអាចដុះបានដែរ មិនរំខានដល់ដើមស្រូវ ឬ ដណ្តើមជីពីដើមស្រូវ ។

- បញ្ហាជីជាតិ : ដីស្រែមានទឹកគ្រប់គ្រាន់ងាយស្រួលដល់ជីជាតិរលាយ ។ វាធ្វើអោយដើមស្រូវស្រូបជញ្ជក់លូតលាស់ធំធាត់បានល្អ ។ ជារួម កត្តាទឹកនិងជីជាតិ រួមផ្សំនឹងការភ្ជួររាស់ ការដាំដុះមានដំណើរការល្អ ក៏អាស្រ័យដោយផ្ទៃដីស្រែស្អាត ភ្ជួររាស់បានល្អ ផ្ទៃដីមានសភាពរាបស្មើ មានទឹក មានជីគ្រប់គ្រាន់ ហើយទទួលបានផលល្អ ។ កត្តាទាំងនេះត្រូវដើរទន្ទឹមគ្នា ហើយផ្ទុយមកវិញ បើស្រែជួបការលំបាកដោយធ្វើដីមិនបានរាបស្មើនោះ ក៏យើងមិនបានទទួលជោគជ័យ ទិន្នផលស្រូវមិនបានខ្ពស់ដែរ ។ ដូច្នេះ ផ្ទៃដីស្រែត្រូវតែពង្រាបអោយបានស្មើ ។

### ១_ពង្រាបដីតាមរបៀបចាក់បំពេញ ឬកៀរដី

ក្រៅពីដីទួលខ្ពស់ តាមការសង្កេតឃើញមានថ្លុកតូចៗ ដែលជាថ្លុកក្របីដេកត្រាំ ក្រោយពេលច្រូតកាត់រួច ។ នោះក៏បណ្តាលអោយផ្ទៃស្រែរបស់យើងមិនបានស្មើ ។ គួរអោយយើងចាប់អារម្មណ៍ដែរនូវចំណុចខ្វះខាតបន្តិចបន្តួចនេះ ។យើងត្រូវភ្ជួរលុបកប់ ចាក់ដីបំពេញអោយបានស្មើ ឬរាស់ ហើយកៀរអោយបានស្អាត ដែលជាផលប្រយោជន៍មួយយ៉ាងសំខាន់សំរាប់ផ្លូវទឹកចែកចាយសព្វកន្លែងលើដំណាំស្រូវ និងការបាចជីបង្កើនទិន្នផលស្រូវ ។

## ២_ពង្រាបដីតាមរបៀបភ្ជួរផាត់ចេញ ឬផាត់ចូល

យោងតាមសភាពដីមានផ្ទៃមិនស្មើ ពោលគឺ ជួនកណ្ដាលស្រែមានទួលខ្ពស់ ជួននៅគៀនស្រែមានផ្ទៃខ្ពស់ជាងផ្ទៃកណ្ដាល ។

តាមការសង្កេតនិងការចាប់អារម្មណ៍ពីបញ្ហាទឹកលើដំណាំស្រូវ ពុំមានគ្រប់សព្វគ្រប់ទីកន្លែងទេ ហើយមិនអាចបាចដីបានទេនោះ ជាវិធានការ ។ បើនៅកណ្ដាលស្រែមានដីទួលខ្ពស់ យើងត្រូវភ្ជួរផាត់ចេញ ហើយនៅទីបញ្ចប់នៃការភ្ជួរ ក៏មានចង្អូរនៅកណ្ដាលដែលជាចង្អូរគន្លងនង្គ័ល ។ ចង្អូរនេះ ត្រូវតែភ្ជួរលុបអោយបានរៀបស្មើ ។ បើនៅគៀនស្រែ មានដីទួលខ្ពស់វិញ យើងត្រូវភ្ជួរផាត់ចូល បំពេញដីដែលទាបកណ្ដាលអោយបានរាបស្មើ ។

## ៣_ពង្រាបតាមរបៀបភ្ជួរកែងទិសដី ឬភ្ជួរទទឹងដីទាបខ្ពស់

ការភ្ជួររបៀបនេះគឺគេភ្ជួរនៅលើដីទួលខ្ពស់មួយចំហៀងទម្លាក់មកមួយចំហៀងទៀតដែលជាដីទាប ។ ដីស្រែដែលមានទួលខ្ពស់មួយចំហៀង ធ្វើអោយមានការលំបាកក្នុងការថែរក្សាទឹក ។ ទឹកនោះហូរទៅទីទាបធ្វើអោយទួលខ្ពស់ ខ្សត់ទឹក ខ្សត់ជី ។ ស្រូវលូតលាស់ពុំបានល្អ ទិន្នផលចុះទាប ។ ដើម្បីពង្រាបដីនេះ យើងត្រូវភ្ជួរកែងទិសដី ឬ ភ្ជួរទទឹងផាត់ទៅចំហៀងដីទាបដើម្បីអោយបានផ្ទៃដីស្មើគ្នា ។ យើងមិនត្រូវភ្ជួរបណ្ដោយដីទេ ពោលគឺភ្ជួរដីពីខ្ពស់មកទាប ។

## ៤_ពង្រាបដីតាមរបៀបកាប់ ឬចូកយ៉ាលយកដីទួលខ្ពស់ដាក់រថយន្តដឹកចេញពីស្រែ

ការអនុវត្តរបៀបនេះគឺខុសពីបច្ចេកទេសកសិកម្ម ។ ទង្វើនេះនាំអោយបាត់បង់ដីជាតិ ។ ម្ចាស់ស្រែខ្លះយល់ថាការពង្រាបដីរបៀបនេះ មិនចំណាយប្រាក់កាស ឬចំណាយកំលាំង គឺគ្រាន់តែអោយគេកាប់ដីពីទួលខ្ពស់ដឹកចេញពីស្រែ ។ ផ្ទុយទៅវិញ ដី ដែលនៅស្រទាប់ខាងលើ ជាដីមានជីជាតិល្អ ហើយយើងយកដីទាំងនេះចេញ គឺជាការខាតបង់ជីជាតិ ។ នៅពេលច្រូតកាត់ស្រូវយកផល យើងតែងតែយកជីចេញពីស្រែនៅក្នុងកណ្ដាប់ស្រូវជារៀងរាល់ឆ្នាំ លើកលែងតែជីជាតិប៉ូតាស់ នៅពេលស្រូវទុំ វាចូលទៅក្នុងដីវិញ ។ យើងគួរកែប្រែវិញគឺត្រូវដឹកដីនោះចាក់ក្នុងស្រែនៅកន្លែងណា ដែលទាបទើបល្អ វាមានប្រយោជន៍ធ្វើអោយដីស្រែបានស្មើ និងមិនបាត់ជីជាតិ ។

## ៥_ពង្រាបដីតាមរបៀបរៀងឆែកជាប្លុក ជាកូនស្រែហើយមានភ្លឺត្រឹមត្រូវ

ក្រៅពីនោះ យើងមានវិធានការមួយទៀតក្នុងការពង្រាបដីស្រែ គឺយើងមានមធ្យោបាយបែងចែកដីស្រែ ទៅតាមសភាពឱ្យទៅជាកូនស្រែ ។ យើងអនុវត្តរបៀបនេះ វាងាយស្រួលលើកភ្លឺស្រែ ងាយពង្រាបដី និងងាយស្រួលដល់ការថែរក្សាទឹក ដាក់ជីស្រែទៀតផង ។ ការអនុវត្តរបៀបនេះ មានសារៈសំខាន់ចំពោះស្រូវប្រដេញទឹកនៅក្រោយច្រាំងទន្លេ ឬនៅតំបន់ជុំវិញបឹង ទន្លេសាប ។ ជារួមការពង្រាបដីស្រែធ្វើអោយយើងទទួលផលយ៉ាងច្រើន ដូចជា:

- មានទឹកក្នុងស្រែគ្រប់គ្រាន់ សព្វទីកន្លែង រួមផ្សំជីជាតិចិញ្ចឹមស្រូវ អោយលូតលាស់បានល្អ ទិន្នផលបានខ្ពស់។
- ដំណាំស្រូវចេញកក្ខរវែង ដាក់គ្រាប់ពេញ មានទម្ងន់ គ្មានស្កក។
- ទឹកស្រែពេញស្មើ គ្មានស្មៅដុះ ក្មានជំរកសត្វល្អិតចង្រៃ។

កត្តាទាំងនេះហើយដែលយើងប្រៀបធៀប វិភាគសេដ្ឋកិច្ចពីការបាត់បង់ ខូចខាតភោគផល និងផលចំណូលចំណេញ ដូចខាងក្រោម។

## V- តារាងប្រៀបធៀបក្នុងការវិភាគសេដ្ឋកិច្ច

| បរិយាយ | ផលទទួលបានពីទម្លាប់របស់កសិករ | | ផលទទួលបានពីការអនុវត្តបច្ចេកទេសកសិកម្មពង្រាបដី | |
|---|---|---|---|---|
| | កំរិតបាត់បង់ជាភាគរយ | ផលទទួលបានជាភាគរយ | កំរិតបាត់បង់ជាភាគរយ | ផលទទួលបានជាភាគរយ |
| ផ្ទៃដីទួលខ្ពស់មិនស្មើចំនួន ២០ អារ<br>-ទឹកមិនគ្រប់គ្រាន់<br>-ខ្វះជីជាតិ<br>-ម៉ាស៊ីនកិនជាអង្ករ* | ៨<br>៥<br>១ | | ២<br>១ | |

សរុប = ១៤ភាគរយ : ៨៦ ភាគរយ : ៣ ភាគរយ : ៩៧ភាគរយ

*គ្រាប់ស្រូវមិនស្មើគ្នា ម៉ាស៊ីនលំបាកសំរួលតាមគ្រាប់ស្រូវ ។

# ដំណាំស្រូវវស្សា
# (Lowland Rice Growing)

## I- សេចក្តីផ្តើម

ប្រជាជនខ្មែរយើងប្រកបរបរកសិកម្មប្រមាណ៨០ទៅ៨៥ភាគរយពិសេសលើដំណាំស្រូវ ។ ប៉ុន្តែបច្ចុប្បន្នដោយយោលទៅលើអាកាសធាតុប្រែប្រួល ប្រជាជនយើងច្រើនអនុវត្តលើដំណាំស្រូវស្រាលរយៈពេលខ្លី ដែលបានផ្តល់ទិន្នផលឆាប់រហ័ស ព្រមទាំងបានផលខ្ពស់ជាងស្រូវកណ្តាល និងស្រូវធ្ងន់ទៀតផង ។

ដើម្បីសំរេចគោលបំណងរបស់ខ្លួន ប្រជាកសិករយើងត្រូវស្វែងយល់អំពីដំណាក់កាលនីមួយៗ ដែលមានចាប់ពីដំណាក់កាលចាប់ផ្តើមរហូតដល់ដំណាក់កាលប្រមូលផល ។ គេចែកដំណាក់កាលលូតលាស់ជា ៣ វគ្គគឺ ៈ វគ្គលូតលាស់ វគ្គបង្កបង្កើតផល និង វគ្គទុំ ។

### ក-វគ្គលូតលាស់

វគ្គលូតលាស់មាន៤ដំណាក់កាល គឺកកើតពន្លក, សំណាប, បែកគុម្ព និង ពន្លូតដើម ។ ដំណាក់កាលលូតលាស់មានរយៈពេលខុសគ្នា អាស្រ័យទៅតាមពូជ ។

### ខ-វគ្គបង្កបង្កើតផល

វគ្គបង្កបង្កើតផលនេះមាន ៣ ដំណាក់កាល គឺ កកើតជាកួររហូតដល់ស្រូវផើម, ចេញកួរ និង ចេញផ្កា ។ វគ្គបង្កបង្កើតផលនេះចាប់ផ្តើមពីការកកួរ ហើយចប់នៅពេលចេញផ្កា ។ វគ្គនេះមានរយៈពេល ៣៥ ថ្ងៃ ។

### គ-វគ្គទុំ

វគ្គទុំនេះមាន ៣ ដំណាក់កាល គឺគ្រាប់ស្រូវដាក់ទឹកដោះ, ដាក់ម្សៅ និងទុំ ។ វគ្គទុំមានរយៈពេល ៣០ ថ្ងៃ ចាប់ផ្តើមពីចេញផ្ការហូតដល់ទុំ ។ វគ្គទុំអាចពន្យាស្រូវទុំបាន ដោយសារស្ថិតនៅពេលមានអាកាសធាតុត្រជាក់ ។ ប៉ុន្តែស្រូវអាចឆាប់ទុំនៅពេលមេឃស្រទ្បះ ។

## II- គោលបំណង

-ចង់អោយប្រជាកសិករយល់ច្បាស់អំពីដំណាក់កាលនីមួយៗ សំរាប់ការប្រើជី ។

-ចង់អោយយល់ច្បាស់អំពីពូជសុទ្ធ, ពូជមិនសុទ្ធទៅតាមដំណាក់កាល ។

-ចង់អោយយល់ច្បាស់អំពីបច្ចេកទេសថ្មីនៃការធ្វើស្រែ ។



រៀបចំដោយលោក ជិត សុវណ្ណ និងស្រី ស្រស់ធីតា

- ចង់អោយយល់ច្បាស់អំពីការប្រើជីបំប៉នលើដំណាំស្រូវ ។
- បង្កើនប្រាក់ចំណូលអោយបានកាន់តែខ្ពស់ក្នុងផលិតកម្ម ។

## III- ទម្លាប់ធ្វើរបស់កសិករ

- ក្រោយពីធ្លាក់ភ្លៀងពី ២ ទៅ ៣ ដង កសិករចាប់ផ្តើមភ្ជួរគាស់សា ។
- ភ្ជួររាស់លើកទី ២ ចាប់ផ្តើមស្ទូង ។
- ដកសំណាប រួចទុកក្នុងស្រែចំនួន ៤ ឬ ៥ ថ្ងៃ ។
- ស្ទូងសំណាបចាស់ ។
- ស្រូវទុំ ចាប់ផ្តើមបង្ហូរទឹកចេញ និង ផ្តេកដើមស្រូវចំពោះស្រូវកណ្តាល ។
- ច្រូតស្រូវ ដាក់កណ្តាប់តាមភ្លឺស្រែរយៈពេល ពី ២ ទៅ ៣ ថ្ងៃ ។
- បញ្ជាន់ស្រូវក្នុងលានមិនសូវស្អាត នាំអោយមានលាយដីខ្លះៗ ។
- ស្រូវលាយចំរុះគ្នានៅក្នុងជង្រុក ។

## IV- បច្ចេកទេសដាំដុះ

វិធីសាស្ត្រនៃការដាំដុះស្រូវមាន៤យ៉ាងគឺ : ស្រូវពង្រោះ, ស្រូវសន្ទូង, ស្រូវបុកដាំនិងការព្រោចសំណាប ។ ប៉ុន្តែដោយឡែកការអនុវត្តធ្វើស្រូវសន្ទូងតាមបច្ចេកទេសទំនើបមានសារៈសំខាន់ក្នុងការផ្តល់ទិន្នផលខ្ពស់ស្របទៅនឹងប្រជាកសិករដែលមានផ្ទៃដីតិចតួច ។

### ក-ការជ្រើសរើសពូជដាំដុះ

ដើម្បីអោយបានសមស្របតាមបច្ចេកទេសក្នុងការជ្រើសរើសពូជស្រូវស្រាល កណ្តាល ធ្ងន់ ត្រូវ :
- គ្រាប់ពូជល្អផ្តល់ទិន្នផលខ្ពស់ ។
- គ្រាប់ពូជដែលមានអត្រានៃការដុះលើសពី ៨៥ %ឡើងទៅ ។
- គ្រាប់ពូជធន់ទ្រាំ នឹងជំងឺ សត្វល្អិត ។
- គាប់ពូជបែកគុម្ព ។
- គ្រាប់ពូជសុទ្ធល្អ ។

### ខ-ការរៀបចំដី

ដើម្បីអោយបរិស្ថានដីងាយស្រួលដល់គ្រាប់ពូជដុះពន្លក និងដុះលូតលាស់របស់ដំណាំស្រូវត្រូវធ្វើការភ្ជួរ និងរាស់ជាច្រើនសានៅពេលមានភ្លៀងធ្លាក់ ១ ដង ឬ ២ ដង ក្នុងជំរៅអោយបាន ១៥ សង្ទីម៉ែត្រ ដោយមានអាចម៍បំណះគ្របជាស្រទាប់ៗលុបស្មៅចង្រៃ និងសារធាតុសរីរាង្គ បង្កប់ជី ទៅក្នុងដី និងងាយស្រួលដល់ការស្ទូង ។

## គ-ការរៀបចំធ្វើថ្នាលសំណាប :

មុននឹងស្ទូងត្រូវរៀបចំធ្វើថ្នាលសំណាប ។ ការសាបមាន ៣ យ៉ាងគឺ សាបលើថ្នាលគោក សាបថ្នាលទឹក និង សាបលើថ្នាលដាប៉ុក ។

- សាបលើថ្នាលគោក :

- ភ្ជួររាស់ ៣ដង ដើម្បីឱ្យដីធូរផុល រួចព្រោះគ្រាប់ស្ងួត ។
- ពូជពី ៣០ ទៅ ៥០ គីឡូក្រាម សំរាប់ស្ទូងដី ១ ហិកតារ ។
- ផ្ទៃដីសាប ពី ២៥០ ទៅ ៣៥០ ម៉ែត្រក្រឡា សំរាប់ស្ទូងដី ១ ហិកតារ ។

ការធ្វើរបៀបនេះស្ថិតនៅលើតំបន់គ្មានទឹកគ្រប់គ្រាន់ ។

- សាបលើថ្នាលទឹក :

ប្រជាពលរដ្ឋខ្មែរ សឹងតែពី ៧០ ទៅ ៨០ ភាគរយនិយមសាបលើថ្នាលទឹក ព្រោះគេយល់ថា គេអាចកំចាត់ស្មៅបាន ។

- ពូជ ៣០ ទៅ ៥០ គិឡូក្រាម សំរាប់ដី ១ ហិកតារ ។
- ផ្ទៃក្រឡាសាបពី ២៥០ ទៅ ៣៥០ ម៉ែត្រក្រឡា សំរាប់ដី ១ ហិកតារ ។
- រយៈពេលត្រាំគ្រាប់ពូជ ៤៨ ម៉ោង ។
- អាយុសំណាបដែលនឹងត្រូវយកទៅស្ទូង ១៨ ថ្ងៃ បើពូជស្រូវមានអាយុ ៣ ខែ ទុំ ។
- ផ្អាប់ពូជពី ២៤ ទៅ ៤៨ ម៉ោង ។
- អាយុសំណាបដែលនឹងត្រូវយកទៅស្ទូង ១៨ ថ្ងៃ បើពូជស្រូវមានអាយុ ៣ ខែទុំ ។

- សាបលើថ្នាលដាប៉ុក

គេច្រើនធ្វើថ្នាលដាប៉ុកនៅក្បែរផ្ទះសម្បែង ព្រោះវាត្រូវការកន្លែងតូច ( ចំពោះអ្នកខ្លះដែលខ្វះដីសំរាប់ធ្វើថ្នាល) តែកសិករមិននិយមធ្វើទេ ។

## ឃ-ការស្ទូង

ការស្ទូងមាន ២ បែប គឺស្ទូងជាជួរ និង ស្ទូងធម្មតា ។

- ស្ទូងជាជួរ

ក្នុងការស្ទូងជាជួរ គេត្រូវប្រើឧបករណ៍ច្រើនយ៉ាងមានខ្សែ, ក្តារដាក់ជាក្រិត, ឈើសំរាប់វាយក្រឡា ។ ក្នុងការស្ទូងនេះ គេត្រូវចំណាយថវិកាច្រើនលើកំឡាំងពលកម្ម រយៈពេលស្ទូងយឺតជាងធម្មតា ។

ការស្ទូងនេះមានគុណសម្បត្តិ និង គុណវិបត្តិដូចតទៅនេះ :


រៀបចំដោយលោក ជិត សុវណ្ណ និងស្រី ស្រស់ធីតា

**គុណសម្បត្តិ**

- ងាយស្រួលបាចជី បាញ់ថ្នាំ និង ធ្វើស្មៅ ។
- ចន្លោះគុម្ពត្រឹមត្រូវតាមក្បួនខ្នាត ។ សន្ទូងដុះស្មើល្អ ។

**គុណវិបត្តិ**

- ប្រើកំឡាំងពលកម្មច្រើនពី ១៥០ ទៅ ១៨០ ម៉ោង ក្នុងមនុស្ស ១ នាក់ ក្នុង ១ ហិកតារ ។
- ស្ទូងធម្មតា
- រៀបចំដីស្រែមានទឹក ។
- ប្រើកំលាំងពលកម្មតិច ។
- គ្មានចន្លោះគុម្ពច្បាស់លាស់ ។

របៀបស្ទូងមាន ២ យ៉ាងគឺ ៖

- ពូជទាបស្ទូងអោយញឹក ។
- ពូជខ្ពស់ស្ទូងអោយរង្វើល ។

ចំនួនដើមសំណាបក្នុង ១ គុម្ព ៖

- ទិន្នផលពុំមានខុសគ្នារវាងសំណាប ១ ដើម ឬ ២ ដើមក្នុង ១ គុម្ព  ប្រសិនបើគ្មានដើមណា ១ ស្លាប់ ។

ជំរៅសន្ទូង ៖

- ក្រោយពីស្ទូងរយៈពេលពី ៥ ទៅ ១០ ថ្ងៃ ស្រូវចាប់ផ្ដើមបែកគុម្ព ឬ ដើមបែក ។
- ស្ទូងជ្រៅពេកបណ្ដាលអោយពន្យាបែកគុម្ព ។
- ជំរៅស្ទូងល្អគឺ ពី ២ ទៅ ៣ សង្ទីម៉ែត្រ ។
- ក្រោយស្ទូងរួចពី ២ ទៅ ៥ ថ្ងៃ ឫសថ្មីដុះចេញឡើង ។

## ង-ការប្រើប្រាស់ជី

ជាធម្មតា ជីដែលតំរូវការលើដំណាំស្រូវ មាន ២ ប្រភេទគឺ  ជីធម្មជាតិ និង ជីគីមី ។

- ជីធម្មជាតិមាន លាមកសត្វ, កំប៉ុស្ដ, ជីស្រស់ ។
- ជីគីមីមាន ៣ ប្រភេទគឺ  អាសូត, ផុស្វាត និង ប៉ូតាស់ស្យូម ។

របៀបប្រើជីធម្មជាតិ ( ជីសរីរាង្គ)

- ចំនួនជីសរីរាង្គដែលត្រូវដាក់គឺពី ១០ ទៅ ២០ តោនក្នុង ១ ហិកតារ ។ មុនភ្ជួរលើកទី៣ ត្រូវយកជីធម្មជាតិមករាយពីលើផ្ទៃស្រែ រួចភ្ជួរលុប ។

**របៀបដាក់ជីគីមីក្នុងដី**

ការដាក់ជីគីមីត្រូវចែកជា ៖

- ការដាក់ជីទ្រាប់បាតមុនស្ទូង

  - ដាក់ជី ដេ-អា-ប៉េ (១៨-៤៦-0) ចំនួន ១00 គក្រ ក្នុង ១ ហិកតារ ។

  - ដាក់ជី ប៉ូតាស្យូម (0-0-៦0) ចំនួន ៥0 គក្រ ក្នុងដី ១ ហិកតារ ។

- ដាក់ជីបំប៉ន

ដើម្បីអោយដំណាំស្រូវបានល្អ ការប្រើជីកំប៉ុស្តត្រូវគិតទៅតាមពេលវេលាសមស្រប និងសេចក្តីត្រូវការរបស់ដំណាំ ពេលចាប់ផ្តើមបែកគុម្ព និងចាប់ផ្តើមកំណកួរ ឬ កន្ទុយឆ្លាំង ។

**ជីបំប៉នលើកទី១** បាចជីអ៊ុយរ៉េចំនួន ៥0 គក្រ ក្នុង ១ ហិកតារ នៅក្នុងដំណាក់កាលបែកគុម្ព ក្រោយស្ទូងបាន ១0-១២ ថ្ងៃ ។

**ជីបំប៉នលើកទី២** បាចជីអ៊ុយរ៉េចំនួន ៥0 គក្រ ក្នុង ១ ហិកតារ នៅក្នុងដំណាក់កាលចាប់ផ្តើមកំណកួរ ឬកន្ទុយឆ្លាំង ។

## ច-ការថែទាំ

បច្ចេកទេសដាំដុះល្អ ពូជល្អ ប៉ុន្តែខ្វះការថែទាំ ស្រូវមិនអាចផ្តល់ទិន្នបានខ្ពស់ ។

- ស្រូវត្រូវការទឹក ក្នុងលក្ខណៈ ៤ យ៉ាង ៖

  - សំណាប (ឆាប់ដុះឫស) ។

  - បែកគុម្ព (បែកគុម្ពច្រើន) ។

  - ពេលកកើតកួរ ចេញផ្កា (ផ្លែច្រើន) ។

  - ពេលដាក់ម្សៅ (គ្រាប់ពេញល្អ) ។

ដូច្នេះ ត្រូវថែរក្សា និងការពារគ្រប់បែបយ៉ាងអោយមានទឹកក្នុងស្រែ ។

- ការកំចាត់ស្មៅចង្រៃ និងកំចាត់សត្វល្អិត ត្រូវតែមានវិធានការ ការពារគ្រប់យ៉ាង ដើម្បីអោយស្រូវទទួលទិន្នផលខ្ពស់ ។

**វិធានការការពារ ៖**

- ពូជធន់នឹងជំងឺ សត្វល្អិត ។
- ពូជមានអាយុកាលខ្លី ។
- ភ្ជួរលុបស្មៅ និងកញ្ច្រាំងទៅក្នុងដី ។
- ពន្លិចទឹកក្នុងស្រែ ។
- ប្រើថ្នាំគីមីក្នុងករណីចាំបាច់ ។

### ឆ-ការច្រូតកាត់

នៅពេលគ្រាប់ស្រូវទុំ ៨៥% ឡើងពណ៌ដូចចំបើង។ គ្រាប់ស្រូវមានសំណើម ២០ - ២៤% ក្នុងលក្ខណៈស្រូវច្រូតកាត់ជាបន្ទាន់។

## V- ការវិភាគសេដ្ឋកិច្ចលើផលិតកម្មដំណាំស្រូវវង្សវស្សា (ផ្ទៃដី ១ ហិកតារ)

| បរិយាយ | ឯកតា | ការអនុវត្តរបស់កសិករ | | | អនុវត្តតាមបច្ចេកទេស | | |
|---|---|---|---|---|---|---|---|
| | | ចំនួន | តំលៃឯកតា(រ) | តំលៃសរុប(រ) | ចំនួន | តំលៃឯកតា(រ) | តំលៃសរុប(រ) |
| -ការរៀបចំដីសរុប | ហិកតារ | ១ | ១០០ 000 | ១០០ 000 | ១ | ១២០ 000 | ១២០ 000 |
| -ពូជស្រូវ | គក្រ | ៦០ | ៨00 | ៤៨ 000 | ៣៥ | ២ 000 | ៧0 000 |
| -ការដកស្ទូង | នាក់ | ២៥ | ៧ 000 | ១៧៥ 000 | ២៥ | ៧000 | ១៧៥ 000 |
| -ជីកំប៉ុស្ត | គក្រ | ៥0 | ១ ៨00 | ៩0 000 | ១00 | ១ ៨00 | ១៨0 000 |
| -ជី DAP + $K_2O$ | គក្រ | ៥0 | ១ ៦00 | ៨0 000 | ៥0 | ១ ៨00 | ៩0 000 |
| -ជី អ៊ុយរ៉េ | គក្រ | ៥0 | ១ ៤00 | ៧0 000 | ១00 | ១ ៤00 | ១៤0 000 |
| -ការថែទាំសរុប | តោន | - | - | - | ៧ | ២0 000 | ១៤0 000 |
| -ថ្នាំពុលកសិកម្ម | លីត្រ | ២ | ២0 000 | ៤0 000 | ២ | ២0 000 | ៤0 000 |
| -ថ្នាំកំចាត់ស្មៅ | លីត្រ | - | - | - | - | - | - |
| -ការប្រមូលផល | នាក់ | ២0 | ៧ 000 | ១៤0 000 | ២0 | ៧ 000 | ១៤0 000 |
| **-ចំណាយសរុប** | $ ១៨៥.៥0 | | | | $ ៣៦៩.២៥ | | |
| **-ចំណូលសរុប** | $ 0.១៣ x ២២00 = $ ២៨៦.00 | | | | $ 0.១៣ x ៤២00 = $ ៥៤៦.00 | | |
| **-ចំណេញ** | $ ១00.៥0 | | | | $ ១៧៦.៥0 | | |

***តម្លៃស្រូវ : 40.១៣ក្នុង ១គីឡូក្រាម**

# ដំណាំសណ្តែកបាយ
# (Mungbean)

## I- ទស្សនៈទូទៅ

សណ្តែកបាយ គឺជាដំណាំមួយប្រភេទ ដែលផ្តល់ផលប្រយោជន៍យ៉ាងច្រើន នៅក្នុងជីវភាពប្រចាំថ្ងៃរបស់យើង ក៏ដូចជាវិស័យកសិកម្មឧស្សាហកម្ម ជាដើម ។ គ្រាប់របស់វា យើងអាចយកមកប្រើប្រាស់បានច្រើនយ៉ាងដូចជា : ធ្វើជាសណ្តែកបណ្តុះ, ម្សៅសណ្តែក ឬក៏ម្ហូបអាហារ ជាច្រើនរបៀបទៀត តាមរយៈសិប្បកម្ម និងឧស្សាហកម្ម ។ បច្ចុប្បន្ន ផលិតផលសណ្តែកបាយ ត្រូវបានគេប្រើប្រាស់ពាសពេញពិភពលោក ចំណែកឯកាកសំណល់របស់វាដូចជា ស្លឹក ដើម សំបក ត្រូវបានចូលរួមយ៉ាងសកម្មខាងផ្នែកបង្កើនគុណភាពដី ព្រោះកាកសំណល់ទាំងនោះ វាបានបង្កើតសារធាតុអាសូតដល់ដី ។ មិនតែប៉ុណ្ណោះ ដំណាំសណ្តែកបាយ យើងក៏អាចដាំវាធ្វើជាជីធម្មជាតិបានយ៉ាងប្រសើរទៀតផងដោយគ្រាន់តែសាបគ្រាប់ឱ្យដុះរយៈពេល ៤០ថ្ងៃ រួចយើងភ្ជួរលុបរយៈពេល១៥ថ្ងៃ វានឹងក្លាយទៅជាជីសរីរាង្គយ៉ាងល្អប្រសើ ។ ដូច្នេះ ដំណាំសណ្តែក បាយ ត្រូវបានគេចែកចេញជា ២ ប្រភេទគឺ :

- ប្រភេទគ្រាប់ល្អិត ( ដើមមានរោមច្រើន) ។
- ប្រភេទគ្រាប់ភ្លឺរលោង ( ឬសណ្តែកប្រេង) ។

## II- គោលបំណង

១-ឱ្យកសិករយល់ដឹងអំពីបច្ចេកទេសផលិតកម្មដំណាំសណ្តែកបាយ ។

២-បង្កើនប្រាក់ចំណូលឱ្យបានខ្ពស់តាមរយៈការអនុវត្តបច្ចេកទេសផលិតកម្មដំណាំសណ្តែកបាយ ។

៣-បង្កើនចំណេះដឹងនៃការធ្វើផែនការដាំដុះ ដោយបង្កើនផ្ទៃដីផលិតឱ្យបាន២ ដងយ៉ាងតិចក្នុង ១ ឆ្នាំហើយបានទិន្នផលខ្ពស់ ។

## III- ការអនុវត្តន៍របស់កសិករកន្លងមក

ជាទូទៅ កសិករតែងតែអនុវត្ត ធ្វើការដាំសណ្តែកបាយនេះដោយរបៀបសាមញ្ញ ឬការដាំដុះដោយចេះតៗគ្នាជារបៀបប្រពៃណី ដូចជា :

- ការដាំដោយរបៀបព្រោះគ្រាប់ ។
- ដាំជាលក្ខណៈគ្រួសារតូចៗ ។
- ការដាំដោយគ្មានបច្ចេកទេស ។

- ដាំទៅតាមយថាផល ។
- មិនបានធ្វើការរៀបចំដី ឱ្យបានសមស្រប ។
- មិនបានធ្វើការជ្រើសរើសពូជល្អ ។
- មិនបានធ្វើការជ្រើសរើសទីកន្លែងដាំដុះ ។
- ខ្វះការថែទាំ និងដាក់ជីបំប៉ន ។
- គ្មានវិធានការកំចាត់សត្វល្អិត ។

## IV- បច្ចេកទេសដាំសណ្តែកបាយ

**១_ការជ្រើសរើសដី និង រៀបចំដី :** សណ្តែកយកជាប្រភេទដំណាំដែលអាចដុះលូតលាស់លើដីច្រើនប្រភេទបានតែបើប្រភេទដីអិដ្ឋដែលមានភាពស្អិតខ្លាំងពេក ហើយ ផះ ទាបជាង ៤ ជាហេតុធ្វើឱ្យសណ្តែកបាយលូតលាស់យឺតនិងបង្កើតចំនួនកំពកឫសតិច ហើយទិន្នផលទាប ។ ដូច្នេះ ដីដែលសមស្របសំរាប់ដំណាំនេះគឺប្រភេទដីល្បាប់ល្បាយខ្សាច់ និងដីក្រៃពីភ្នំភ្លើងនៅខ្ពង់រាប ។

ភាគច្រើន ដីធូរជ្រាបទឹករប៉ស់សំបូរទៅដោយសារធាតុចិញ្ចឹមមមោក ។ សារធាតុមមោក តែងបង្កើតនូវសារធាតុចិញ្ចឹម ដូចជា : អាសូត(N), ហ្វូស្វ័រ(P), ប៉ូតាស្យូម(K), កាល់ស្យូម(Ca), មាញ៉េស្យូម(Mg) ។ សណ្តែកបាយ ២ ប្រភេទ ត្រូវការ ផះ ដីខុសគ្នា ។ សណ្តែកផេះ ត្រូវការ(pH) ៤,៤ - ៧,៥ ។ សណ្តែកប្រេងត្រូវការ pH ៥,៥ - ៧ ។

ការរៀបចំដី គឺត្រូវប្រមូលយកកាកសំណល់ផ្សេងៗ ដែលមានមកពីការបំផ្លាញដោយជំងឺ និងសត្វល្អិតពីរដូវមុនយកទៅដុតចោលហើយភ្ជួរនិងរាស់ ជាច្រើនលើក លុបដីឱ្យបានជ្រៅល្អ ដើម្បីឱ្យដីនោះរក្សាសំណើម និងជ្រាបទឹកបានល្អ ងាយស្រួលឱ្យសណ្តែកដុះលូតលាស់ ។ កាលណាដីមិនម៉ដ្ឋហើយខ្វះសំណើម សណ្តែកមិនអាចដុះពន្លកស្មើគ្នាបានល្អឡើយ ។

ក្នុងករណីដាំដោយប្រើប្រព័ន្ធស្រោចស្រព (បញ្ចូលទឹក) ត្រូវលើករងឱ្យបានខ្ពស់ : ២០-៣០សម, ទទឹង=១០០សម, ចន្លោះរង= ២៥-៣០សម ។ ការអនុវត្តរបៀបនេះ ច្រើនធ្វើនៅតំបន់វាលទំនាប ។

### ២_ការជ្រើសរើសពូជ

ជាធម្មតា សណ្តែកបាយគឺជាដំណាំមួយដែលអាចលូតលាស់បានគ្រប់រដូវក្នុងលក្ខខ័ណ្ឌតំបន់ត្រូពិច ហើយមិនប្រកាន់រដូវ ប៉ុន្តែភាគច្រើន មិនធន់ទ្រាំនឹងជំងឺ ដូច្នេះការជ្រើសពូជ ត្រូវផ្អែកទៅតាមលក្ខណៈសម្បត្តិ ដូចតទៅ:

#### ២.១-ពូជលូតលាស់មិនកំណត់

ភាគច្រើនជាពូជក្នុងស្រុក មានដើមខ្ពស់ មែកច្រើន ថ្នាំងវង្វេល ស្លឹកធំ ដើមទន់ អាយុកាលលូតលាស់វែង ភាគច្រើនមិនធន់ទ្រាំទៅនឹងជំងឺផ្សេងៗ ។

### ២.២-ពូជលូតលាស់កំណត់

ពូជនេះមានដើមទាបរឹងមាំ បែកមែកតិច ផ្កាំងញឹក ស្លឹកល្អិត អាយុកាលលូតលាស់ខ្លី មានការធន់ទ្រាំទៅនឹងជំងឺ ។ ដើម្បីឆ្លើយតបទៅនឹងការដាំដុះ ពូជដែលល្អគឺ សណ្តែកផេះ (៤-១០គ្រាប់ ក្នុង ១ កួរ, ១០០គ្រាប់ទំងន់ ៤-១០ក្រាម) ។ គ្រាប់សណ្តែកប្រេង (៦ - ១១ គ្រាប់ក្នុង ១ កួរ, ១០០ គ្រាប់ទំងន់ ៥,៨ - ៨,៨ក្រាម) ធន់ទ្រាំនឹងជំងឺនិងសត្វល្អិត គ្រាប់ធំ ថ្លោសស្មើគ្នា ។ភាគរយនៃដំណុះមាន៩០-៩២% ។ភាពសុទ្ធរបស់ពូជមានកំរិតខ្ពស់ ទុំមិនផ្ទុះ ហើយរយៈពេលស្មើគ្នា ទិន្នផល ខ្ពស់ពេញនិយម ។ ដើម្បីដាំលើផ្ទៃដី ១ ហិកតារ គេត្រូវប្រើពូជ ចំនួន ២០-៣០គក្រ ។ស្ថានីយ៍ក្បាលកោះ បានជំរើសពូជសណ្តែកបាយជាច្រើនដែលមានប្រភពមកពី AVRDC ដូចជា : kk1, KK2, KK3, KK4, KK5, KK6 ។

បច្ចុប្បន្ននេះ ពូជដែលពេញនិយមជាងគេបំផុត ផ្តល់ទិន្នផលខ្ពស់ ហើយការលូតលាស់មានអាយុកាលខ្លីធន់នឹងជំងឺទៀតនោះគឺពូជ KK2, KK3 ។

## ៣_លក្ខណៈធាតុអាកាស

សណ្តែកបាយអាចលូតលាស់បានក្នុងតំបន់ដែលមានសីតុណ្ហភាព ដូចជា :

- ពូជសណ្តែកប្រេង ២៨-៣០ អង្សាសេ, មធ្យម ២៧ អង្សាសេ ។
- ពូជសណ្តែកផេះ ២៥-៣៥ អង្សាសេ ។

- នៅប្រទេសកម្ពុជា គេអាចដាំសណ្តែកបាយស្ទើរពេញ ១ ឆ្នាំ អាស្រ័យដោយកត្តាសំណើម ។
- នៅតំបន់វាលជំរាល និងវាលទំនាប ការដាំដុះច្រើនធ្វើឡើងនៅរដូវទឹកសំរក (តំបន់មាត់ទន្លេ) គឺចាប់ផ្តើមពីខែ វិច្ឆិកា ដល់ខែ មករា ។ រដូវទី២ ចាប់ពីខែ ឧសភា និងប្រមូលផលនៅខែ កក្កដា ។
- ចំណែកឯតំបន់ខ្ពង់រាប និងជួរភ្នំ វិញ រដូវទី១ ចាប់ផ្តើមពីខែ មេសា និងប្រមូលផល ក្នុងខែ កក្កដា និងរដូវទី២ ចាប់ពីខែ កក្កដា ឬ សីហា ហើយប្រមូលផលក្នុងខែ កញ្ញា ឬ តុលា ។ ប៉ុន្តែករណីតំបន់ដែលមានភ្លៀងធ្លាក់ច្រើន គេអាចពន្យាពេលដាំរហូតដល់ខែ សីហា ឬដើមខែ កញ្ញា ។

## ៤_ការដាំដុះសណ្តែកបាយ

-មុនពេលដាំ គ្រាប់ពូជត្រូវយកទៅហាលថ្ងៃឱ្យបានរយៈពេល ១-២ ម៉ោងសិន ។គេអាចដាំបានច្រើនរបៀបទៅតាមការនិយម និងចូលចិត្ត ប៉ុន្តែដើម្បីឱ្យដើមសណ្តែកលូតលាស់ល្អ ហើយទទួលទិន្នផលខ្ពស់ ត្រូវធ្វើការរៀបចំចន្លោះជួរ និងចន្លោះគុម្ពឱ្យត្រឹមត្រូវតាម ក្បួនខ្នាត ។

### ៤.១-របៀបដាំជាជួរ

គឺដាំមិនលើកជារងទេ គេបុកដាំនៅតាមខ្សែបន្ទាត់ដែលមានចន្លោះជួរ ៥០ សង្ទីម៉ែត្រ, ចន្លោះគុម្ព ៣០ សង្ទីម៉ែត្រ និងជម្រៅ ៣-៤ សម ហើយដាក់គ្រាប់ពូជ ៣-៤គ្រាប់ក្នុង១រណ្តៅ ។ យើងក៏អាចដាំតាមចង្អូរនង្គ័លបានដែរគឺ ៣ គន្លងនង្គ័លរាយ ១ជួរក្នុងជម្រៅ ៤-៥សម ។ ត្រូវរាយគ្រាប់ឱ្យបាន ១៨-២០ គ្រាប់ក្នុងប្រវែង ១ម៉ែត្រ ។

### ៤.២-របៀបដាំជារង

ត្រូវលើករងឱ្យបានទទឹង ១០០សម, កំពស់ ២០-៣០សម ហើយដាំតាមគែមរង ដែលមានចន្លោះជួរ ៥០សម, ចន្លោះ គុម្ព ២០សម ដាក់ពូជ ២-៣ គ្រាប់ក្នុង ១រណ្ដៅ ។

### ៤.៣-របៀបដាំដោយព្រោះ

គឺគេព្រោះគ្រាប់សណ្ដែកទៅលើដីដែលរាស់កៀរ រួចហើយបន្ទាប់មករាស់លុបគ្រាប់ ។ គេអាចធ្វើបានលើដីល្បប់មាត់ទន្លេដោយប្រើគ្រាប់ច្រើនចាប់ពី ៣០-៣៣គក្រ ក្នុង១ហិកតារ ។

## ៥_ការស្រោចស្រព

សណ្ដែកបាយជាដំណាំដែលត្រូវការទឹកជាមធ្យម ខុសពីសណ្ដែកទ្រើង ហើយតំរូវការទឹក គេចែកចេញជា ៣វគ្គ ។វគ្គដុះពន្លក និងវគ្គលូតលាស់ដើមស្លឹក វាត្រូវការទឹកជាមធ្យម សំណើមពី ៦០-៧០ ភាគរយ ។ វគ្គចេញផ្កា និងបន្តពូជវាត្រូវការទឹកច្រើនជាងវគ្គនានា ។ ក្រោយពីការដាំរយៈពេល២ថ្ងៃ រហូតដល់សណ្ដែកមានអាយុ ៤០ ថ្ងៃ វាត្រូវការសំណើមដីប្រមាណ ៦៥-៧០ ភាគរយ ។ ក្រោយ ពីការទុំនៃកួរ វាត្រូវការទឹកពី ៦៥-៧០ ភាគរយ ហើយកាន់តែថយចុះបណ្ដើរៗ ។ កាលណាសំណើមដីឡើងខ្ពស់ក្នុងវគ្គទុំ គឺធ្វើឱ្យសណ្ដែកពន្យាពេលនៃការទុំរបស់វា និងបង្កឱ្យកើតជំងឺថែមទៀត ។ គេស្រោចដោយបញ្ចូលតាមចន្លោះជួររយៈពេល ៤-៥ថ្ងៃម្ដង អាស្រ័យទៅ តាមប្រភេទដីនិងសីតុណ្ហភាព ។ ចំពោះការស្រោចស្រព ដោយប្រើរបបទឹកភ្លៀងគឺក្នុងមួយអាយុកាលនៃសណ្ដែក មានកំពស់ ៥០០-៥៣០មីលីម៉ែត្រ ។ ក្នុង ១ ហិកតារ នៃផ្ទៃដី បរិមាណទឹកដែលត្រូវប្រើមានពី ៥០០០-៥៧០០ ម៉ែត្រគីប ។

## ៦_ការជ្រួយដី

ការជ្រួយដីធ្វើឡើងក្នុងគោលបំណងឱ្យដីធូរ មានខ្យល់ចេញចូលបានល្អ រក្សាសំណើមបានយូរ ជ្រាបទឹករហ័សបន្ថយការដុះស្មៅ ធ្វើឱ្យសណ្ដែកចាក់ឫសបានវែង និងបង្កើតកំពកឫសបានច្រើន ជាអត្ថប្រយោជន៍នៃការបង្កើតចំនួនបាក់តេរីដល់ដីជួយឱ្យទិន្នផលនៃសណ្ដែកកើនឡើង ។រយៈពេលនៃការជ្រួយដីឱ្យសមស្របគឺ១៥-២០ ថ្ងៃក្រោយដាំ ហើយពូនលុបគល់សណ្ដែកបន្តិចៗផងដោយចប ។

## ៧_ការប្រើប្រាស់ជី

នៅក្នុងវគ្គលូតលាស់ដំបូង សណ្ដែកត្រូវការសារធាតុអាសូត មុនសារធាតុនានា បន្ទាប់មកទើបត្រូវការសារធាតុហ្វូសស្វ័រ និង ប៉ូតាស្យូម ។ ហ្វូសស្វ័រ និង ប៉ូតាស្យូម វាមានតួនាទីក្នុងការផ្ដល់ឱ្យកួរនិងគ្រាប់សណ្ដែករីកលូតលាស់បានល្អ ។ តាមការស្រាវជ្រាវរបស់ មជ្ឈមណ្ឌលដំណាំបន្លែអាស៊ី និងមហាសន្និបាតលើកទី ២ ថ្នាក់អន្តរជាតិស្ដីពីដំណាំសណ្ដែកបាយ ឆ្នាំ ១៩៨៨ បានបង្ហាញថា : ដើម្បីផលិតសណ្ដែកស្ងួតទំងន់ ១០០០គក្រ លើផ្ទៃដី ១ ហិកតារ វាស្រូបយកសារជាតិជាច្រើនក្នុងដី ដូចជា អាសូត ៤០គក្រ, ហ្វូសស្វ័រ ៤គក្រ, ប៉ូតាស្យូម ១២គក្រ, កាល់ស្យូម ១គក្រ, ស្ពាន់ធ័រ ២ គក្រ, ម៉ាញ៉េស្យូម ២គក្រ,... ។ ដូច្នេះដើម្បីឱ្យការដាំដុះ ទទួលបានទិន្នផលខ្ពស់ ការដាក់ជីត្រូវធ្វើឡើងខុសៗគ្នា ទៅតាមសក្ដានុពលនៃដី ។ ប្រភេទដីមាត់ទន្លេ គេប្រើជី ១៥.១៥.១៥ ចំនួន

១៥០-២០០ គក្រ ក្នុង ១ ហិកតារទៀត បាចរាស់លុបទៅក្នុងដីមុនពេលដាំ ។ ប៉ុន្តែចំពោះដីវាលរាប និងតំបន់ខ្ពង់រាបមួយចំនួន គេអាចបន្ថែមជីអ៊ុយរ៉េ ចំនួន ៥០-៧០ គក្រ ក្នុង ១ ហិកតារ បាចក្នុងពេលសណ្តែកបាយចេញផ្កាដំបូង ធ្វើឱ្យសណ្តែកចេញផ្កាបានច្រើន និងភាគរយនៃការបន្តពូជបានល្អ ។

## ៨_វិធានការកំចាត់សត្វល្អិត និងការពារ

ដើម្បីការពារនិងកំចាត់សត្វល្អិតគេអនុវត្តបានច្រើនវិធីសាស្រ្តដូចជា: ការជ្រើសរើសរដូវ,រៀបចំដីឱ្យបានល្អ, ដាំតាមបច្ចេកទេសកំចាត់ស្មៅ,ជ្រើសរើសពូជធន់ទ្រាំ ព្រមទាំងវិធានការប្រើថ្នាំគីមី ដូចជាថ្នាំប្រភេទ ម៉េទីលការបាម៉ាត(Methyl carbamate) លាយជាមួយ ម៉េទីល ហ្វូសស្វាត (Methyl phosphate dichlorvos) ឬ Atabron បាញ់ពេលពិនិត្យឃើញមានកូនដង្កូវ (Nymph) ។

## ៩_ការប្រមូលផល

នៅពេលសណ្តែកទុំ ១០០ ភាគរយ ត្រូវប្រមូលយកកួរសណ្តែកមកដាក់ហាលថ្ងៃ ឱ្យស្ងួតស្រួយរយ:ពេល ២-៣ថ្ងៃ ។បន្ទាប់មកទើបយើងវាយបំបែកសំរាំងយកគ្រាប់ ព្រមទាំងសំអាតដោយជ្រើសរើសយកចេញនូវគ្រាប់ស្អុយ ឬដង្កូវស៊ី ហើយបន្តការហាល ១ ថ្ងៃថែមទៀត ដើម្បីឱ្យសំណើមគ្រាប់ស្ថិតក្នុងស្តង់ដាជាក់លាក់ ១៣-១៤ ភាគរយ ទើបអាចទុកបាន ។ អាយុកាលនៃការប្រមូលផលទៅតាមប្រភេទពូជ : ពូជស្រាល ៦០-៦៥ថ្ងៃ, ពូជកណ្តាល ៦៥-៧០ថ្ងៃ និងពូជធ្ងន់ ៧០-៨០ថ្ងៃ ក្រោយពីការដុះ។ ការប្រមូលផលត្រូវធ្វើឡើងចំនួន ២-៣ លើក អាស្រ័យទៅតាមការដាំដុះ ។

ចំពោះទិន្នផលមានលក្ខណ:ខុសគ្នារវាង សណ្តែកផេះ និង សណ្តែកខៀវ ។

- សណ្តែកផេះ : ទិន្នផលចន្លោះពី ៥៦០-១៥០០ គក្រ ក្នុង ១ ហិកតារ ជាមធ្យម ៨០០-១០៥០ គក្រ ក្នុង ១ ហិកតារ (សំរាប់ប្រទេសកម្ពុជា)
- សណ្តែកខៀវ : ចន្លោះពី ៥០០-១៤០០ គក្រ ក្នុង ១ ហិកតារ ជាមធ្យម ៨០០-១០០០គក្រ ក្នុង ១ហិកតារ (សំរាប់ប្រទេសកម្ពុជា) ។

## V- វិភាគសេដ្ឋកិច្ចលើដំណាំសណ្តែកបាយ

| ល.រ | មុខចំណាយ | ឯកតា | តាមប្រពៃណី | | | តាមបច្ចេកទេស | | |
|---|---|---|---|---|---|---|---|---|
| | | | ចំនួន | តំលៃរាយ | តំលៃសរុប | ចំនួន | តំលៃរាយ | តំលៃសរុប |
| ១ | ការរៀបចំដី | ដង | ១ | ៨0000៛ | ៨0000៛ | ២ | ៨0000៛ | ១៦0000៛ |
| ២ | ជី ១៥.១៥.១៥ | គក្រ | - | - | - | ១៥0 | ២000៛ | ៣000000៛ |
| ៣ | ការជ្រើសរើសពូជ | គក្រ | ៣0 | ២000៛ | ៦0000៛ | ២0 | ២000៛ | ៤0000៛ |
| ៤ | ដាក់ជីបំប៉ន | គក្រ | ១00 | ១៤00៛ | ១៤0000៛ | ១៥0 | ១៤00៛ | ២១0000៛ |
| ៥ | ការថែទាំ | ដង | - | - | - | ២ | ១៥000៛ | ៣0000៛ |
| ៦ | កំចាត់សត្វល្អិត | ដង | - | - | - | ២ | ២0000 | ៤0000៛ |
| ៧ | ពលកម្ម | នាក់ | ១0 | ៥000៛ | ៥0000៛ | ១0 | ៥000៛ | ៥0000៛ |
| | **ចំណាយសរុប** | ៣៣0 000៛ | | | | ៨៣0 000៛ | | |
| | **ចំណូលសរុប** | ៧00គក្រ x ១៥00៛ = ១ 0៥0 000៛ | | | | ១៥00គក្រ x ១៥00៛ = ២២៥0 000៛ | | |
| | **ចំណេញ** | ៧២0 000៛ | | | | ១ ៤២0 000៛ | | |

- **តាមប្រពៃណី ក្នុង ១ ហិកតារ = ៧00 គក្រ**
- **តាមបច្ចេកទេស ក្នុង ១ ហិកតារ = ១៥00 គក្រ**
- **តម្លៃទីផ្សារជាមធ្យម = ១៥00៛ ក្នុង ១ គក្រ ។**

# ផលិតកម្មផ្សិតចំបើង
# (Mushroom Production)

## I- ទស្សនៈទូទៅ

មនុស្សយើងតែងនិយមទទួលទានផ្សិតចំបើងជាអាហារគ្រប់ៗគ្នា ។ តាមធម្មតា ផ្សិតចំបើង មានដុះដោយធម្មជាតិរបស់វា ក្នុងរដូវវស្សាតែប៉ុណ្ណោះ ។ ដូច្នេះ ការដុះរបស់ផ្សិតចំបើងតាមរបៀបធម្មជាតិនេះ មិនឆ្លើយតបទៅនឹងសេចក្តីត្រូវការឡើយ ។ ហេតុដូច្នេះហើយ ទើបក្នុងការស្រាវជ្រាវ អ្នកវិទ្យាសាស្ត្របានប្រឹងប្រែងរិះរកនូវបច្ចេកទេសវិទ្យា និងបច្ចេកទេស ដើម្បីធ្វើឱ្យផលិតកម្មផ្សិតចំបើងរីកដុះដាល និងតំរូវការទីផ្សារ ដោយធ្វើការពិសោធ និងស្រាវជ្រាវផ្តោតទៅលើវត្ថុធាតុផ្សេងៗ ឬកាកសំណល់ពីផ្នែកកសិកម្មដែលមានជាតិសែលលុយឡូស ។ តាមធម្មតា ផ្សិតចំបើងមានរសជាតិឆ្ងាញ់ ហើយសំបូរទៅដោយសារជាតិផ្សេងៗសំរាប់ជួយទ្រទ្រង់ សរីរាង្គរបស់មនុស្សយើង ដូចជាសារធាតុរ៉ែ អំបិល ខនិក និងវីតាមីនជាដើម ។ កន្លងមកក្នុងផលិតកម្មផ្សិតចំបើង កសិករតែងនិយមអនុវត្តរបៀបផ្សេងៗគ្នាទៅតាមទំលាប់ និងតាមមូលដ្ឋាន ។ ផលិតកម្មផ្សិតចំបើង វាមិនមែនជាការពិបាកអនុវត្តឡើយ ហើយវាក៏អាចផ្តល់កំរៃយ៉ាងខ្ពស់ក្នុងរយៈពេលខ្លីទៀតផង ។ ប៉ុន្តែការអនុវត្តនេះ វាអាស្រ័យទៅលើវត្ថុធាតុដើម ទីកន្លែង និងបច្ចេកទេសនៃការផលិតឱ្យបានត្រឹមត្រូវផងដែរ ។

## II- គោលបំណង

- បង្កើនការយល់ដឹងអំពីបច្ចេកទេសនៃការបណ្តុះផ្សិតចំបើង ។
- បង្កើនសមត្ថភាពក្នុងការផលិតផ្សិតចំបើង ទាំងបរិមាណ និងគុណភាពខ្ពស់ តាមតំរូវការទីផ្សារ ។

## III- ការអនុវត្តរបស់កសិករកន្លងមក

១-បណ្តុះទៅតាមពំនូកចំបើងគោ-ក្របី តាមធម្មជាតិ ។

២-បណ្តុះដោយគ្មានការប្រើមេផ្សិត (ប្រើកញ្ចុងអង្ករ) ។

៣-បណ្តុះដោយគ្មានការគ្រប់គ្រងថែទាំឱ្យបានល្អតាមបច្ចេកទេស ។

៤-ការអនុវត្តបណ្តុះ ច្រើនធ្វើតៗគ្នា ។

៥-ផលិតកម្មផ្សិតរីកស្គុះស្គាយតែរដូវវស្សា ។

## IV- បច្ចេកទេសបណ្តុះផ្សិតចំបើង

បើយើងអនុវត្តទៅតាមក្បួនខ្នាតនិងបច្ចេកទេសនៃការបណ្តុះ យើងអាចធ្វើបានទាំងរដូវប្រាំង និងរដូវវស្សា ហើយទទួលបានទិន្នផលខ្ពស់ទៅតាមតំរូវការដែលយើងបានគ្រោងទុក ។ដូច្នេះផលិតករត្រូវមានការយល់ដឹងអំពីវិធី និងបច្ចេកទេសនៃការ បណ្តុះផ្សិតចំបើង តាមលំដាប់លំដោយដូចខាងក្រោម :

### ១_ការត្រៀមបំរុងទុក :

#### ១.១-ការជ្រើសរើសទីកន្លែង

- យើងចាំបាច់ត្រូវជ្រើសរើសយកទីកន្លែងដែលនៅកណ្តាលវាលដូចជា: ក្នុងចំការ, ក្នុងស្រែដែលមានដី ទួល ហើយរាបស្មើ គ្មានជាំទឹក ។
- ជាកន្លែងដែលមានប្រភពទឹកគ្រប់គ្រាន់ដែលស្ថិតនៅក្បែរខ្លួនរបស់យើងក្នុងរដូវប្រាំងដូចជាព្រែក, បឹង, អូរ, ស្រះជាដើម ។
- ជាកន្លែងដែលមានសុវត្ថិភាព ជៀសផុតពីការបំផ្លាញពីសំណាក់ពពួកសត្វផ្សេងៗ ។

#### ១.២-ការរៀបចំដី

- យើងត្រូវកាប់ដីហាលឱ្យបានរយះពេល ៣ ថ្ងៃសិន ។
- ក្រោយពេលហាលដីបានរយះពេល ៣ ថ្ងៃហើយ យើងត្រូវសំអាតបរិវេណនោះឱ្យស្អាត ព្រមទាំងពង្រាបដីនោះឱ្យរាប ដោយការវាយបំបែកឱ្យស្មើល្អជាការស្រេច ។

#### ១.៣-ការជ្រើសរើសវត្ថុធាតុសំរាប់បណ្តុះផ្សិតចំបើង

- យើងអាចជ្រើសរើសវត្ថុធាតុច្រើនយ៉ាងយកមកបណ្តុះផ្សិតចំបើងបាន ដូចជា ជញ្ជ្រាំង, ចំបើង ,
- វត្ថុដែលយើងជ្រើសយកមកប្រើនេះ ចាំបាច់ត្រូវហាលឱ្យស្ងួតល្អជាមុនសិន ។

#### ១.៤-អាហារបន្ថែម ឬជំនួយ

- ក្នុងការបណ្តុះផ្សិតចំបើង យើងអាចយក ចក, សំបក, សណ្តែកបាយ, លាមកសត្វ, សំបកផ្លែឈូក មកធ្វើជាអាហារបន្ថែម ឬអាហារបំប៉នពីលើ ដែលមានវត្ថុ ដូចដែលយើងបានជ្រើសរើសខាងលើ (១.៣) ។
- អាហារបន្ថែម ឬអាហារបំប៉ននេះ ចាំបាច់ត្រូវហាលទាំងអស់ឱ្យស្ងួតជាមុនសិនដែរ (ជាវត្ថុថ្មីៗ) ។

**លក្ខណៈពិសេស :**

-ក្រៅពីអាហារបន្ថែម ឬជំនួយខាងលើនេះ យើងក៏អាចយកវត្ថុធាតុផ្សេងៗទៀតមកធ្វើជាអាហារបន្ថែមបានដែរ ដោយគ្រាន់តែមានលក្ខណៈបច្ចេកទេសខុសៗគ្នាប៉ុណ្ណោះគឺ :

**របៀបទី១ :**

- យកអង្ករដំណើប ០,៥០គក្រ ត្រាំទឹករយៈពេល ២ ម៉ោង ហើយស្រង់វាមកហាលឱ្យស្ងួត រួចបុកឱ្យម៉ដ្ឋ។

- យកមេដំបែស្រា ១ ខាំ បុកឱ្យម៉ដ្ឋ លាយបញ្ចូលគ្នាជាមួយម្សៅដំណើប លាយជាមួយចុងអង្ករដំណើប ត្រាំទឹកនោះ ច្របល់ឱ្យសព្វល្អ ។ (វត្ថុធាតុនេះ ប្រើលាយជាមួយមេផ្សិតចំបើងចំនួន ៩-១០ កញ្ចប់) ។

**របៀបទី២ :**

-អាចម៍សេះស្ងួត ១០ គក្រ ច្របាច់ឱ្យបែកម៉ដ្ឋ ។

-អាចម៍គោស្ងួត ១០ គក្រ ច្របាច់ឱ្យបែកម៉ដ្ឋ ។

-កំប្លោក ឬ ចកស្ងួត ៥ គក្រ ចិញ្ច្រាំឱ្យល្អិត ។

-សំបកផ្លែឈូកស្ងួត ៥ គក្រ ចិញ្ច្រាំឱ្យល្អិត ។

-ស្នូលគទុំស្ងួត ៥ គក្រ ចិញ្ច្រាំឱ្យល្អិត ។

• សំរាប់វត្ថុធាតុទាំង ៥ ប្រភេទនេះ ចាំបាច់ច្របល់ចូលគ្នាឱ្យសព្វល្អ ហើយស្រោចទឹកឱ្យសើមល្មម ផ្អាបទុករយៈពេល ៧ ថ្ងៃ ទើបប្រើប្រាស់បាន (គ្របដោយផ្លាស្ទិក) ។

### ១.៥-ការជ្រើសមេផ្សិត

• ត្រូវជ្រើសរើសយកមេផ្សិតដែលល្អ (ធ្វើអំពីស្នូលគ ឬ អង្កាម) ដែលមានពណ៌ស្លាទុំ មកប្រើប្រាស់ ។

• ត្រូវយកមេផ្សិតដែលមានអាយុចាប់ពី ១០ ទៅ ១៥ថ្ងៃ ហើយគ្មានផ្សិតចម្រែងនៅក្នុងកញ្ចប់ ឬ ចង់មេផ្សិតឡើយ ។

## ២_ការអនុវត្តបច្ចេកទេសបណ្តុះផ្សិតចំបើង:

ត្រូវត្រៀមសំភារៈសំរាប់ដំណើរការដូចជា : ពូថៅ, ចបកាប់, ខ្សែនីឡុង, បង្គោល, ចានដែកជ័រ, ឡាំងស្រោច ។ល ។

២.១- យកវត្ថុធាតុ (ចំបើង) ដែលត្រៀមទុកទៅត្រាំទឹក ឱ្យបានក្នុងរយៈពេល ១ ទៅ ២ ម៉ោងជាមុនសិន ។

២.២- បោះបង្គោលទាញខ្សែលើករងនៅលើដីដែលត្រៀមទុកតាមខ្នាត ០,៥០ម x ១២,០០ម (បណ្តោយមិនកំណត់)

២.៣-ក្រោយពីរៀបចំរងតាមខ្នាតដូចខាងលើរួចហើយ ត្រូវបាចកំបោរ-ស៣០០ក្រាមឬថ្នាំហ្វូរ៉ាដង់ដើម្បីកែលំអដី ការពារកណ្តៀរ និង ស្រមោច ។

២.៤-យកចំបើងដែលបានត្រាំមកមូរនិងរៀបនៅលើរងក្នុងខ្សែឱ្យបានកំរាស់ពី៨-១០សមរួចស្រោចទឹកឱ្យជោកល្មម ហើយជាន់ឱ្យណែន ។

២.៥- យកអាហារបន្ថែមមករោយចំនួន១-២ជួរនៅលើផ្ទៃរងដែលមានកំរាស់ពី១-២សម ទទឹង១០-២០សម ។

២.៦- យកមេផ្សិតចាក់ចូលក្នុងចានជ័រ រួចច្របាច់ឱ្យបែកតូចៗល្មម យកទៅរោយពីលើអាហារបន្ថែម ។

២.៧- ត្រូវអនុវត្តជាន់ទី២-ទី៣-ទី៤ ឱ្យដូចជាន់ទី១ ដែរ ។

**បញ្ជាក់:** ចំណែកជាន់លើបង្អស់ មិនមានប្រើមេផ្សិត ឬអាហារបន្ថែមឡើយ ។

២.៨- ក្រោយពេលធ្វើរួច ត្រូវទុករងផ្សិតនោះហាលថ្ងៃ រយៈពេល ៣ ថ្ងៃ ។ ក្រោយ ៣ ថ្ងៃ យើងត្រូវយកចំបើងស្ងួតមករោយពីលើស្តើងៗល្មមហើយដុតឱ្យឆេះតិចៗរួចពន្លត់វិញដោយប្រើទឹកស្រោចពីលើឱ្យបានសើមល្មម ។

២.៩- ក្រោយពេលដុតរួច យើងត្រូវទុករងផ្សិតនោះ ហាលថ្ងៃរយៈពេល ៣ ថ្ងៃទៀត ។ បន្ទាប់មកទើបស្រោចទឹកឱ្យជោកល្មម ហើយគ្របឱ្យជិតល្អជាការស្រេច ។

២.១០- សរសៃផ្សិតចាប់ផ្តើមដុះពេញរងក្នុងរយៈពេលពី៦-៨ថ្ងៃហើយចាប់កកើតជាដុំផ្សិតក្នុងរយៈពេលតែ ៩ - ១៣ ថ្ងៃ គេអាចប្រមូលផលបាន ។

## ៣_ការថែទាំរងផ្សិតចំបើង:

- ការថែទាំរងផ្សិតចំបើងមានសារៈសំខាន់ណាស់ ពិសេសទៅលើសំណើមឱ្យសមស្រប ទៅតាមតំរូវការទាំងរដូវប្រាំង និង រដូវវស្សា គឺ :
- ក្រោយពេលគ្របរួចបាន ៣ ថ្ងៃ ត្រូវរក្សាកំដៅចាប់ពី ៣៥ អង្សា ទៅ ៣៨ អង្សាសេ ។
- នៅពេលសង្កេតឃើញដុំផ្សិតចាប់ផ្តើមដុះតូចៗ ត្រូវរក្សាកំដៅចាប់ពី ៣៣ ទៅ ៣៥ អង្សាសេ ។
- នៅពេលផ្សិតល្មមដក ឬបេះផលបានហើយ ត្រូវរក្សាកំដៅចាប់ពី ៣០ ទៅ ៣៣ អង្សាសេ ។
- គប្បីរក្សារងផ្សិតដោយសង្កេតទៅលើសត្វល្អិតផងដែរបើសិនជាមានសត្វល្អិតមកបំផ្លាញផ្សិត ចាំបាច់ត្រូវកំចាត់វាចេញដោយមេកានិក ។

## ៤_ការប្រមូលផលផ្សិតចំបើង:

- ផ្សិតចំបើងគឺជាដំណាំដែលមានរយៈពេលខ្លី ហើយឆាប់រលួយជាទីបំផុត ។ ដូច្នេះ យើងត្រូវធ្វើការប្រុងប្រយ័ត្នក្នុង ការប្រមូលផលរបស់វា គឺយើងត្រូវបេះនៅមុនថ្ងៃរះ ។ ការបេះ ឬកាត់នេះត្រូវធ្វើដោយកូនកាំបិតជៀសវាងការរលួយដល់ផ្សិត ដែលដុះបន្ទាប់ ។ ការប្រមូលផលផ្សិត អាចធ្វើឡើងបានរយៈពេល ៣-៥លើកប៉ុណ្ណោះ ។

**កំណត់សំគាល់ :**

ក្នុងការថែរក្សារងផ្សិតនិងប្រមូលផលផ្សិតចំបើងដូចបានរៀបរាប់ខាងលើនេះ យើងចាំបាច់ត្រូវត្រួតពិនិត្យទៅលើសំណើមឱ្យបានច្បាស់លាស់ ។ បើសិនជារងផ្សិតរបស់យើងមានសំណើមគ្រប់គ្រាន់ហើយ យើងមិនចាំបាច់ស្រោចទឹកបន្ថែមទេ ។ ប៉ុន្តែ បើសិនជារងផ្សិតរបស់យើង មានសភាពស្ងួត ចាំបាច់ត្រូវស្រោចទឹកបន្ថែមដោយ :

-ពេលព្រឹក ស្រោចនៅម៉ោង ៨ ។

-ពេលល្ងាច ស្រោចនៅម៉ោង ៥ ។

(ស្រោចដោយធុងមានក្បាលផ្កាឈូក ហើយដើរលឿន) ។

## V- ការវិភាគសេដ្ឋកិច្ចលើផលិតកម្មផិតចំបើង

( ក្នុងរង = 0,៥0ម ខ ១២,00 = ៦,00ម២ )

| ល.រ | មុខចំណាយ | ឯកតា | តាមប្រពៃណី | | | តាមបច្ចេកទេស | | |
|---|---|---|---|---|---|---|---|---|
| | | | ចំនួន | តំលៃរាយ | តំលៃសរុប | ចំនួន | តំលៃរាយ | តំលៃសរុប |
| ១ | កណ្តាប់, ជញ្ជ្រាំង | កណ្តាប់ | ១៥0 | ៣0រ | ៤៥00រ | ១២0 | ៣0រ | ៣៦00រ |
| ២ | ជញ្ជ្រាំង, គំរប | កណ្តាប់ | ១00 | ៣0រ | ៣000រ | ១00 | ៣0រ | ៣000រ |
| ៣ | ផ្លាស្ទិក | ម | - | - | - | ២ | ១000រ | ២000រ |
| ៤ | មេផ្សិត | កញ្ចប់ | ១0 | ១000រ | ១0000រ | ៩ | ១000រ | ៩000រ |
| ចំណាយសរុប | | | ១៧៥00រ | | | ១៧៦00រ | | |
| ចំណាយសរុប | | | ២១000រ | | | ៦៣000រ | | |
| ចំណាយសរុប | | | ៣៥00រ | | | ៤៥៤00រ | | |

- តាមប្រពៃណី ៖ ក្នុង ១ម$^{២}$ បានផល 0,៥0 គក្រ = 0,៥0 គក្រ x ៦ម = ៣ គក្រ
- តាមបច្ចេកទេស ៖ ក្នុង ១ម$^{២}$ បានផល ១,៥0 គក្រ = ១,៥0 គក្រ x ៦ម = ៩ គក្រ
- តំលៃជាមធ្យម ទីផ្សារ = ៧000រ ក្នុង ១ គក្រ ។

# ការទុកដាក់ផលិតផលស្រូវ និងស្រូវពូជ
# (Paddy/seed storage)

## I- ទស្សនៈទូទៅ

ការទុកដាក់ស្រូវពូជ ឬផលិតផលស្រូវ ជាការងារចុងក្រោយ ហើយដែលជាការងារចំបងក្នុងការប្រមូលផលស្រូវ ដើម្បីរក្សាបាននូវសុវត្ថិភាពគ្រាប់ស្រូវត្រូវប្រើប្រាស់នាពេលអនាគតដ៏ខ្លី ដែលនឹងត្រូវចាប់ផ្តើមការបង្កបង្កើនផលជាថ្មីក្នុងឆ្នាំបន្ត ។ ប៉ុន្តែការទុកដាក់ផលិតផលស្រូវ និងពូជស្រូវ នាពេលនេះ ក៏មានទាក់ទងយ៉ាងជិតស្និតទូទៅនឹងការងារមួយចំនួននៃការប្រមូលផលស្រូវផងដែរគឺ ៖

- ពេលវេលានៃការច្រូតកាត់ ។
- ការរៀបចំទុកដាក់កណ្តាប់ស្រូវក្នុងស្រែ ។
- ការបោកបែនស្រូវ ។
- ការហាលស្រូវ ជាដើម ។

ដូចនេះ ដើម្បីអោយការងារទុកដាក់ផលស្រូវបានល្អ លុះត្រាតែការអនុវត្តនូវដំណាក់កាលខាងលើនេះ បានសមស្រប និងត្រឹមត្រូវតាមបច្ចេកទេសកំណត់ព្រោះថា នៅក្នុងផលិតកម្មកសិកម្ម កសិករឬផលិតករតែងតែនឹកជានិច្ចដល់ផលិតផលដែលនឹងទទួលបានសំរាប់ការផ្គត់ផ្គង់លក់ ឬ ទុកសំរាប់តំរូវការក្នុងគ្រួសារទៅអនាគតបានល្អប្រសើរ ។

## II- គោលបំណង

១-បង្កើនចំណេះដឹងអោយកាន់តែសុក្រឹតលើការងារទុកដាក់ផលិតផលស្រូវ ។

២-បង្កើនសមត្ថភាពអោយកាន់តែខ្ពស់លើរាល់ការងារទុកដាក់ផលិតផលស្រូវ ដោយចេះបែងចែកប្រភេទគុណភាពបានច្បាស់លាស់

៣-ជួយផ្តល់នូវវិធីសាស្រ្តក្នុងការគ្រប់គ្រងថែរក្សាផលិតផលស្រូវអោយបានគង់វង្សជៀសផុតពីការបាត់បង់ ឬខូចខាតដោយប្រការផ្សេងៗ ។

## III- ការអនុវត្តទុកដាក់ផលិតផលស្រូវរបស់កសិករកន្លងមក

- មិនបានគិតពីការបំផ្លាញរបស់សត្វ ។
-ប្រមូលទុកដាក់ផលិតផលស្រូវពុំមានសុវត្ថិភាព ( មិនមានបិទបាំងអោយបានគត់មត់ ផ្តល់ឱកាសអោយសត្វបំផ្លាញ) ។
-ទុកដាក់ឧបករណ៍ ឬសំភារៈមិនមានរបៀប នៅពីលើ ឬញាត់ពាសពេញកន្លែងទុកដាក់ស្រូវ (ឱកាសដល់សត្វកណ្តុរ) ។

-ខ្វះការត្រួតពិនិត្យសំងួតគ្រាប់ស្រូវនាំអោយខូចគុណភាពអង្ករ និងទទួលការបំផ្លាញពីសត្វល្អិត និងជំងឺផ្សិត ។
-ខ្វះការសំអាតគ្រាប់ស្រូវអោយបានស្អាតល្អដែលកត្តាធ្វើជាជំរកដល់សត្វល្អិត ។

# IV- បច្ចេកទេសក្នុងការទុកដាក់ផលិតផលស្រូវ

## ១_អំពីការសំងួតគ្រាប់ស្រូវ

ស្រូវពូជក៏ដូចជាស្រូវហូប ជាផលិតផលដែលត្រូវសំរាំងដោយយកចិត្តទុកដាក់ជាចំបងលើមូលហេតុ ៤ យ៉ាងដែលបណ្ដាលអោយគ្រាប់ស្រូវខូចគុណភាព :

-ហាលសំងួតមិនគ្រប់គ្រាន់ និងមិនត្រឹមត្រូវ ។

-សំអាតមិនបានស្អាតល្អ ។

-ធ្វើអោយគ្រាប់ពូជឡើងកំដៅ និងឡើងសំណើមវិញ ។

-សត្វល្អិត និងផ្សិតយាយីបំផ្លាញ ។

ដូចនេះដើម្បីធានាក្នុងការទុកដាក់ផលិតផលស្រូវ( ស្រូវពូជនិងស្រូវហូប) អោយបានល្អ ត្រូវគិតពីកត្តាទាំងឡាយដែលទាក់ទងនឹងការសំងួតគ្រាប់ស្រូវគឺៈ

### ក-ការសំអាតគ្រាប់ស្រូវ

ត្រូវរោយ អុំ ឬ រែងគ្រាប់ស្រូវដោយយកចេញអោយអស់នូវសំដីស្រូវ និងកំទេចកំទី សំរាមផ្សេងៗចេញពីស្រូវ ។ សំរាមអាចរួមចំណែកអោយស្រូវឡើងកំដៅបាន និងជាជំរកនៃសត្វល្អិត ។

### ខ-ការហាលគ្រាប់ស្រូវ

ត្រូវប្រញាប់ប្រញាល់ បន្ទាប់ពីសំអាតគ្រាប់ស្រូវរួចល្អហើយ យកគ្រាប់ស្រូវនោះទៅហាលជាបន្ទាន់ កុំទុកគរគ្រាប់ស្រូវដែលមានសំណើមយូរពេក ជៀសវាងស្រូវឡើងកំដៅបង្កអោយកកើតផ្សិតលើគ្រាប់ស្រូវ ។ នៅពេលហាល ត្រូវយកកន្ទេលស្អាតទ្រាប់រួចចាក់គ្រាប់ស្រូវពង្រាយអោយស្តើងមានកំរាស់ពី ៣ ទៅ ៥ ស.ម ហើយឧស្សាហ៍រឺស្រូវ ពិសេសនៅពេលមានកំដៅថ្ងៃខ្លាំងដើម្បីឱ្យគ្រាប់ស្រូវស្ងួតសព្វ និងមិនសូវឡើងកំដៅខ្ពស់ ។

### គ-កំណត់សំងួតស្រូវសមស្រប

ការហាលស្រូវត្រូវអនុវត្តអោយបានត្រឹមត្រូវ ជៀសវាងការហាលស្រូវអោយស្ងួតហួសពេកនាំអោយបាក់គ្រាប់អង្ករ ឬខូចគុណភាពគ្រាប់ស្រូវដែលបំរុងទុកពូជ (បន្ថយកំលាំងដុះ) ។ ដូចនេះ ការហាលស្រូវអោយបានល្អត្រូវស្តាប់សំឡេងដែលយើងចាក់ស្រូវទៅលើគំនរស្រូវ បើឮសូរស្រួយ( មិនស្អក់) ឬក៏អាចធ្វើតេស្តដោយយកគ្រាប់ស្រូវមកខាំ មើលគ្រាប់អង្ករមានសម្បុរថ្លា ហើយមានលក្ខណៈស្រួយបញ្ជាក់ថា គ្រាប់ស្រូវស្ងួតហើយ ។ អត្រាសំណើមដែលអាចយកទៅទុកដាក់បានគឺ ១៤ % (ចំពោះស្រូវហូប) និងទាបជាង ១៤ % បន្តិច( សំរាប់ស្រូវទុកពូជ) ។

**សេចក្តីបញ្ជាក់ ៖**

១-ចំពោះស្រូវពូជគេទុកអោយស្រូវទុំតាមធម្មជាតិ (Maturité physiologique) ទើបគេច្រូតកាត់ ហើយបោកបែនដាយសំអាត និងហាលទុកដាក់ជាបន្ទាន់មុនស្រូវហូប ។

២-ចំពោះស្រូវហូបគេមិនទុកស្រូវអោយទុំញោសទេ គឺទុកអោយស្រូវទុំស្លាបសេក (Maturité commerciale) ទើបគុណភាពអង្ករល្អ ។

## ២_អំពីការទុកដាក់ផលិតផលស្រូវ

- **ស្រូវពូជ**

ការទុកដាក់ស្រូវពូជនៅក្នុងធុង ឬក្នុងឧបករណ៍ដែលបិទជិត (មានគំរបត្រឹមត្រូវ) ជាជំរើសដ៏ល្អ ព្រោះវាអាចទប់ស្កាត់សត្វល្អិត សត្វកណ្តុរ ឬការបង្កអោយមានផ្សិតដោយសារធាតុអាកាស។ នៅក្នុងឧបករណ៍ទាំងនោះមានខ្យល់អុកស៊ីហ្សែនតិច ធ្វើអោយសត្វល្អិតពិបាករស់មិនអាចទ្រាំបាន ។ស្រូវពូជស្ងួត ១៤% នឹងអាចមានគុណភាពល្អបានយូរជាងមួយឆ្នាំ ។ បើមានពូជច្រើនត្រូវសរសេរផ្លាកដាក់ចំណាំ ។

- **ស្រូវហូប ឬស្រូវចំណី**

បន្ទាប់ពីច្រូតកាត់រួច និងបោកបែនហើយ ត្រូវតែទុកដាក់ស្រូវអោយមានសុវត្ថិភាព ដើម្បីធានាជាស្បៀងទំរាំដល់ពេលដាំដុះ ប្រមូលផលជាថ្មី ។ មានមូលហេតុច្រើនណាស់ដែលអាចធ្វើអោយបាត់បង់ស្រូវពេលទុកដាក់ ៖

-កណ្តុរធំមួយស៊ីស្រូវអស់ ២៥ ក្រាម និងកណ្តុរតូចៗមួយអាចស៊ីស្រូវអស់ពី ៣ ទៅ ៤ ក្រាមក្នុងមួយថ្ងៃ ។

-វាធ្វើអោយស្រូវយើងកខ្វក់ដោយសារលាមក ទឹកនោម និងសំរាមដែលធ្វើអោយប៉ះពាល់ដល់សុខភាពយើង ។

-វាច្រើនស៊ីផ្នែកដុះពន្លក ១មែបរយៀនច នៃគ្រាប់ស្រូវធ្វើអោយថយចុះនូវជីវជាតិអង្ករ ។

-វាក៏កាត់បំផ្លាញបាវស្រូវ ធុងដាក់ស្រូវ ឬ ប្រដាប់ដាក់ស្រូវផ្សេងៗធ្វើអោយជ្រុះកំពប់បានដែរ ។

ដូចនេះ ឧបករណ៍ផ្សេងៗ ឬជង្រុកស្រូវត្រូវធ្វើយ៉ាងណាដើម្បីជៀសវាងនូវការខូចខាតផលិតផលស្រូវ ។

-គួរកុំសង់ជង្រុកនៅជិតកន្លែងកខ្វក់ មានទឹកដក់ដែលអាចជាប្រភពនៃការរាតត្បាត ។

-ជង្រុកត្រូវតែមានដំបូល និងជញ្ជាំងត្រឹមត្រូវគត់មត់ល្អ ប៉ុន្តែត្រូវអោយមានខ្យល់ចេញចូលល្អ ។

-ជង្រុក ឬកន្លែងទុកស្រូវត្រូវកុំអោយក្តៅខ្លាំងពេក ។

-សំណើមស្រូវអាចកើនឡើងក្នុងរដូវវស្សា បើយើងដាក់ស្រូវក្នុងបាវក្រចៅ ឬ ពាងធ្វើពីដីឥដ្ឋ (ត្រូវមានវិធានការគ្របដោយសំពត់កៅស៊ូអោយបានគត់មត់ល្អ) ។

-ជៀសវាងយកស្រូវថ្មីដាក់ចូល ឬ លាយជាមួយស្រូវចាស់ពីឆ្នាំមុន ។

-បើការទុកដាក់កាន់តែយូរ ស្រូវគួរតែមានសំណើមកាន់តែតិច ឬកាន់តែស្ងួត ។

-ជៀសវាងទុកដាក់ស្រូវដែលមានសំបកស្រូវបែក ឬរលាត់ ព្រោះវាងាយទទួលការបំផ្លាញពីសំណើម ការកើតផ្សិត និងសត្វល្អិត ។

## V- ការវិភាគសេដ្ឋកិច្ចក្នុងការទុកដាក់ស្រូវ

ការបាត់បង់ស្រូវមានជាហូរហែ ចាប់ពីគ្រាប់ស្រូវធ្លាក់ដល់ដី (ការសាប ព្រោះ រហូតដល់ការកិនជាអង្ករ ឬ តពីអង្ករដល់ការហូបបាយ) ។ ការបាត់បង់ទាំងអស់នេះ បើយើងមិនបានយកចិត្តទុកដាក់នោះទេ វាអាចនឹងបាត់បង់យ៉ាងច្រើនឥតគណនា សមដូចពាក្យចាស់លោកពោលថា" ទំរាំដល់ចូលក្នុងមាត់ ១ កូរស្រូវ សល់តែ ១ គ្រាប់ប៉ុណ្ណោះ " ។

តារាងខាងក្រោមនេះបង្ហាញពីការទុកដាក់ស្រូវ ដែលគួរពិចារណាថា ត្រូវអនុវត្តតាម ឬក៏ត្រូវជៀសវាង ។

| រយះពេលទុកដាក់ | សំណើមសមស្រប | បញ្ហាអាចកើតមានបើសំណើមខ្ពស់ជាងនេះ |
|---|---|---|
| ២ ទៅ ៣ អាទិត្យ | ១៤ % ទៅ ១៨ % | ដុះផ្សិត ឬប្រែពណ៌ស្រអាប់លឿង ឬ ខ្មៅ |
| ៨ ទៅ ១២ ខែ | ទាបជាង ឬស្មើ ១៣ % | សត្វល្អិតបំផ្លាញ |
| យូរជាង ១ ឆ្នាំ | ទាបជាង ឬស្មើ ៩ % | គ្រាប់ពូជលែងសូវដុះ |

# ដំណាំសណ្តែកដី
# (Peanuts)

## I- សេចក្តីផ្តើម

សណ្តែកដីស្ថិតនៅក្នុងពួក លេហ្គុមីណឺ ដែលមានផ្កានៅលើដើមមែក ហើយបន្ទាប់ពីកកើតទងផ្លែ និងចាក់ចូលទៅក្នុងដីជាមួយអូវូល កកើតជាគ្រាប់រីកធំរហូតដល់ទុំ។ ដំណាំសណ្តែកដីមានគេធ្វើការដាំដុះនៅក្នុងតំបន់ត្រូពិច និងស៊ុបត្រូពិច ដែលមានផលិតផលបានជាប្រេង សំរាប់សេចក្តីត្រូវការរបស់មនុស្ស។

ដំណាំសណ្តែកដីមានសារៈសំខាន់ បន្ទាប់ពីធ្វើការកិនកៀបយកប្រេង ហើយកាកសំណល់ត្រូវបានគេប្រើប្រាស់សំរាប់ជាចំណីសត្វ។ សណ្តែកដី ត្រូវការដីធូរ មានដីជាតិដែលជាលក្ខណៈងាយស្រួលដល់ការចុះផ្លែទៅក្នុងដី និងរីកធំបានងាយ ព្រមទាំងមានការងាយស្រួលដល់ការប្រមូលផល(ដកដោយដៃផ្ទាល់)។ការដាំដុះអាចធ្វើទាំងសំបក ឬក៏ដាំគ្រាប់ បន្ទាប់ពីបានបកសំបកចេញដោយយោលទៅតាមការនិយម។បន្ទាប់ពីការដាំរួច ការ ជួសរណ្តៅដែលដាច់(មិនដុះ) ឬបាត់រណ្តៅ រួមទាំងការសំអាតស្មៅនិងជ្រុំជ្រួយដីឱ្យបានល្អ ជាការងារសំខាន់បំផុត ក្នុងការថែទាំដំណាំនេះ ហើយក៏ជាកត្តាកំណត់ក្នុងការប្រមូលផលបានល្អប្រសើរ។

## II- គោលបំណង

១) -បង្កើនការយល់ដឹងឱ្យកាន់តែខ្ពស់ពីការដាំដុះដំណាំសណ្តែកដីតាមបច្ចេកទេស។

២) - បង្កើនសមត្ថភាពក្នុងការអនុវត្តបច្ចេកទេសឱ្យបានល្អ។

៣) - បង្កើនប្រាក់ចំណូលឱ្យកាន់តែប្រសើរក្នុងការអនុវត្តបច្ចេកទេសដោយកាត់បន្ថយការចំណាយ។

## III- ការអនុវត្តការដាំដុះរបស់កសិករកន្លងមក

-ការជ្រើសរើសពូជមិនទាន់បានល្អដែលអាចឆ្លើយតបនឹងតំរូវការទីផ្សារ(ពូជខ្វះគុណភាព)។

-អនុវត្តការដាំដុះនៅមិនទាន់សមស្របទៅនឹងបច្ចេកទេស(ការរៀបចំដី, ការថែទាំ, ការប្រើប្រាស់ជី...)។

-មិនទាន់យកចិត្តទុកដាក់ក្នុងការប្រើប្រាស់សំណល់ពីការប្រមូលផល ដើម្បីរក្សានិងបង្កើនគុណភាពដីដាំដុះ។

## IV- បច្ចេកទេសនៃការដាំដំណាំសណ្តែកដី

សណ្តែកដីជាដំណាំដែលត្រូវការដីធូរ មានជីជាតិនិងស្រស់ទឹកល្អ(ដីច្រាំងទន្លេ ឬដីល្បាប់ក្រោយច្រាំង និងដីខ្ពង់រាប)។ ម្យ៉ាងទៀត សណ្តែកដីត្រូវការ ការថែទាំមានការសំអាតស្មៅចង្រៃ និងការជ្រុំជ្រួយដីឱ្យបានស-មស្របតាមពេលវេលា។ ដូចនេះ ការរៀបចំដីបានល្អ ធ្វើឱ្យដីផុសមានខ្យល់ចេញចូលស្រួល ជាគន្លឹះធ្វើឱ្យដំណាំរីកលូតលាស់បានឆាប់ ពិសេសផ្នែកប្រព័ន្ធឫស។

### ១_ការជ្រើសរើសពូជ

ការជ្រើសរើសពូជជាកត្តាកំណត់នូវទិន្នផល បានខ្ពស់ និងឆ្លើយតបតំរូវការទីផ្សារ :

- ពូជធន់ជំងឺ និងសត្វល្អិត។
- ពូជដែលផ្តល់ទិន្នផលខ្ពស់និងតំរូវការទីផ្សារ។
- ពូជមានរយៈពេលខ្លី។
- ពូជដែលរក្សាទុកទាំងសំបកមានគុណភាពដំណុះគ្រាប់ចាប់ពី៩05 ឡើងទៅ។

### ២_ការរៀបចំដីសំរាប់ដាំដុះ

សណ្តែកដីស្ថិតក្នុងពពួក លេហ្គូមីណឺ មិនសូវត្រូវការជីច្រើនប៉ុន្មានទេ ប៉ុន្តែដើម្បីបង្កើនទិន្នផលខ្ពស់ក្នុងផលិកម្មនោះ ការរៀបចំដី ក៏ជាកត្តាកំណត់មួយមានសារៈសំខាន់ក្នុងការអនុវត្តបច្ចេកទេសដាំដុះផងដែរ។

**ការភ្ជួររាស់ដី :**

- ត្រូវធ្វើការភ្ជួររាស់ដីឱ្យបាន ២-៣ ដងក្នុងជំរៅ ១៥សម - ២០សម។
- ការភ្ជួរត្រូវធ្វើឱ្យបានហ្មត់ចត់ (កុំឱ្យឆកល្វែងដី, ភ្ជួរកាត់ទទឹងលើកទី១ និងភ្ជួរកាត់ទទឹងលើកទី២)។
- ភ្ជួរទី១ (ភ្ជួរដាស់ដី) ត្រូវទុកហាលដីឱ្យបាន១០-១៥ថ្ងៃ មុននឹងចាប់ភ្ជួរលើកទី២។
- ភ្ជួរលើកទី២ រួមការរាស់ដីសំអាតកំទេចកំទីនិងស្មៅឱ្យបានស្អាត។
- ភ្ជួរលើកទី៣ រួមការរាស់សំរេច ឱ្យដីហ្មត់ផង់ល្អ និងមានភាពរាបស្មើសំរាប់ធ្វើការដាំដុះ។

### ៣_ការដាក់ជីទ្រាប់បាត

ដំណាំសណ្តែកដីមិនសូវល្មោភជីប៉ុន្មានទេ ប៉ុន្តែការអនុវត្តនៃការដាក់ជីទ្រាប់បាត ជាការចាំបាច់បំផុតក្នុងការដាំដុះដំណាំ គ្រប់ប្រភេទដើម្បីធានានូវសារធាតុបំរុងសំរាប់តំរូវការរបស់ដំណាំនិងការពារការបាត់បង់ជីជាតិក្នុងដីនិងរក្សាបាននូវគុណភាពដីកសិកម្មឱ្យមាននិរន្តរភាព។ នៅលើដីដែលខ្សត់ជីជាតិ គេត្រូវអនុវត្តការដាក់ជីទ្រាប់បាតសំរាប់ដំណាំសណ្តែកដី ដូចជា :

- ជីកំប៉ុស្ត ឬជីលាមកសត្វពុករលួយល្អចំនួន១០-១៥ តោនក្នុង ១ ហិកតារ។

- ជីគីមី ១៥.១៥.១៥ ចំនួន ១៥០គក្រ - ២០០គក្រ ក្នុង ១ ហិកតារ ។

ជីទាំងពីរមុខនេះ ត្រូវបាចរោយសព្វល្អលើដីរួចភ្ជួររាស់ (ភ្ជួររាស់លើកទី៣) ច្របល់ឱ្យបានចូលគ្នាទៅក្នុងដី ។

## ៤_ការរៀបចំគ្រាប់ពូជ

ពូជសណ្តែកដីមាន ៣ ប្រភេទដែលគេនិយមធ្វើការដាំដុះ :

- ពូជគ្រាប់ធំ ។

- ពូជសំបកឆ្នូត ។

- ពូជសំបករលីង ។

- ត្រូវយកផ្លែសណ្តែកដីទាំងសំបកមកបកយកគ្រាប់ឱ្យបានពី ៧-១០ថ្ងៃ មុនពេលដាំ ។
- ត្រូវរើសយកគ្រាប់ស្ទៀត-គ្រាប់តូច-គ្រាប់ស្អុយនិងគ្រាប់ដែលមានរោគចេញឱ្យអស់( ទុកតែគ្រាប់ល្អពេញលក្ខណៈ) ។
- ត្រូវយកគ្រាប់ពូជដែលបានសំរាំងរួច មកប្រឡាក់ថ្នាំបិនឡាត ក្នុងអត្រា២% (ពីរភាគពាន់) ក្នុងពូជ ១គក្រ មុនពេលយកទៅដាំ ការពារសត្វស្រមោចស៊ីពូជក្នុងរណ្តៅ ។

## ៥_ពេលវេលា និងរបៀបដាំ

- គេអាចធ្វើការដាំដុះបាន :

  - នៅដើមរដូវភ្លៀង (ខែ មេសា, ខែ ឧសភា) ។

  - នៅក្នុងរដូវភ្លៀង (ខែ មិថុនា, ខែ កក្កដា) ។

  - នៅចុងរដូវភ្លៀង (ខែ តុលា ) ។

- របៀបដាំមាន ២ យ៉ាង តាមការនិយម :

- ការដាំដោយលើករង : ការដាំរបៀបនេះ គេច្រើនអនុវត្តនៅក្នុងរដូវវស្សា ដោយការលើករងក្រោយពី ការរៀបចំដីដាំដុះរួច (ក្នុងតំបន់វាលរាបមិនលិចទឹក) ។

-ការដាំលាត : គេអនុវត្តនៅរដូវប្រាំង និងរដូវវស្សាផងដែរ (តំបន់ខ្ពង់រាប, វាលរាប, ក្រោយច្រាំងទន្លេ,...) ការដាំនៅដើមរដូវភ្លៀងនិងចុងរដូវភ្លៀង ត្រូវឧស្សាហ៍ត្រួតពិនិត្យនិងគ្រប់គ្រងសំណើមដីឱ្យបានល្អសំរាប់ការលូតលាស់ និងផ្កាផ្លែបានពេញលេញ (៦០-៨០ស) ។

- ដំណាំសណ្តែកដីត្រូវការចន្លោះរង ៥០សម និងចន្លោះជួរ ២០ - ២៥សម ដើម្បីលូតលាស់ល្អ ។ រណ្តៅមានជំរៅ ២ -៤សម ។
- តំរូវការពូជបកស្រេចចំនួន ៨០គក្រ ក្នុង ១ ហិកតារ ឬ ពូជទាំងសំបកចំនួន ១៥០គក្រ ក្នុង ១ ហិកតារ ។ ក្នុង១រណ្តៅដាក់ ១ - ២ គ្រាប់ ។

## ៦_ការថែទាំ

- ការជំរះស្មៅ និងពូនគល់

ការជំរះស្មៅ ឬការសំអាតស្មៅចង្រៃ ជាសកម្មភាពមួយសំខាន់ណាស់ នៅក្នុងផលិតកម្មដំណាំសណ្តែកដី ដើម្បីធ្វើឱ្យដំណើររីកលូតលាស់លឿនទៅតាមសក្តានុពលរបស់វា។ ដូចនេះ ការសំអាតស្មៅចង្រៃ ត្រូវអនុវត្តឱ្យបាន២ដងនិងទាន់ពេលវេលា ធ្វើយ៉ាងណាកុំឱ្យស្មៅដុះប្រជែងជាមួយដំណាំឱ្យសោះ ព្រោះការងារនេះ បើយើងធ្វេសប្រហែសនឹងនាំឱ្យដំណាំបន្ថយការលូតលាស់ ហើយទិន្នផលក៏នឹងថយចុះទៅតាមនោះដែរ (មិនអាចកែបានឡើយ)។

- លើកទី១ :

- ពី១៥-២០ ថ្ងៃ ក្រោយពេលដាំ។ ពេលនេះ សំខាន់គឺបំបាត់ស្មៅចង្រៃ និងរក្សាសំណើមដីឱ្យបានល្អតាមរយៈការជ្រុំជ្រួយដីជាមួយ។

- លើកទី២ :

- ពី៣០-៤០ថ្ងៃ ក្រោយពេលដាំ។ ពេលនេះ ការសំអាតស្មៅចង្រៃរួមទាំងការពូនគល់តិចៗផង។

**បញ្ជាក់ :** បើហួសពី ៦០ថ្ងៃឡើងទៅ ហាមមិនឱ្យពូនគល់ឡើយ។

- ការស្រោចស្រព

ដំណាំសណ្តែកដី ត្រូវការសំណើមដីល្មមពី ៦៥-៧៥5 ដើម្បីធ្វើការលូតលាស់បានល្អ។ ក្នុងមួយវដ្តលូតលាស់របស់វា ត្រូវការទឹកពី ១០០០ - ១៥០០ម៣ ប៉ុណ្ណោះ។ ដូចនេះ ត្រូវពិនិត្យឱ្យបានជាប្រចាំនូវសំណើមដី បើមានការរាំងស្ងួត ត្រូវធ្វើការបូមទឹកស្រោចស្រព ជាបន្ទាន់។

## ៧_សត្វល្អិត និងជំងឺ

ដំណាំសណ្តែកដីមិនសូវមានជួបប្រទះការបំផ្លាញពីសត្វល្អិតនិងជំងឺធ្ងន់ធ្ងរទេ។ ប្រការដែលត្រូវប្រុងប្រយ័ត្ន គឺនៅពេលមុនដាំ ត្រូវការពារសត្វល្អិតបំផ្លាញគ្រាប់ពូជនៅក្នុងរណ្តៅធ្វើឱ្យបាត់រណ្តៅ ដោយប្រើថ្នាំ ហ្វ៊ុយរ៉ាដាន (ធុរាដាន) ក្នុងអត្រា ១ ក្រាម ក្នុង ១ម២ ឬ ១០គក្រ ក្នុង ១ ហិកតារ (រោយព្រោចឱ្យបានសព្វដីមុនដាំ)។ ការប្រើថ្នាំនេះ ក៏អាចការពារការបំផ្លាញពីសត្វល្អិតដល់សណ្តែកដី ដែលកំពុងរីកលូតលាស់នៅក្នុងដីដោយដង្កូវឈ្មោះអាក្រូទីសអ៊ីបស៊ីឡុង(ងៀវតិសហាយផសិល្យន)។ មានដង្កូវរមូរស្លឹកសណ្តែកដីធ្វើឱ្យដំណាំបន្ថយការលូតលាស់។ វិធីកំចាត់ ប្រើថ្នាំ អាហ្សូឌ្រីន (Azodrin) ក្នុងអត្រា ២-៣% ក្នុង ១ លីត្រទឹក។

- ជំងឺអុតស្លឹកពណ៌ខ្មៅ

វិធីការពារមាន :

-កុំដាំញឹកពេកនៅរដូវវស្សា។

-ប្រើពូជធន់នឹងជំងឺនេះ ។

- ជំងឺរលួយគល់

វិធីការពារមាន :

- ត្រូវរក្សាសំណើមដីឱ្យបានល្អ ។
- ត្រូវផ្លាស់ប្តូរមុខដំណាំ ( សណ្តែកដី សណ្តែកបាយ ពោត) ។ល ។

## ៨_ការប្រមូលផល

គេចាប់ប្រមូលផលដំណាំសណ្តែកដី ក្នុងកំឡុង ៣ខែ ទៅ ៣ ខែកន្លះ ក្រោយពីការដុះចេញ គិតទៅតាមពូជដែលបានធ្វើការដាំដុះ ។ ប៉ុន្តែការកំណត់ពេលប្រមូលផលនៅដំណាក់កាលដែលដំណាំសណ្តែកដីមានស្លឹកលឿងទុំច្រើន ( ៦០-៧០5) ។ គេដកដើមសណ្តែកដីដោយទាំងផ្លែពីក្នុងដីរួចគេធ្វើការហាលក្នុងរយៈពេល២-៣ថ្ងៃ រួចគេធ្វើការប្រលេះនិងបកយកគ្រាប់ជាបន្តបន្ទាប់ ។

- ប្រការដែលគួរជៀសវាង
  - កុំទុកឱ្យស្ងួតដោយកំដៅខ្លាំងពេក ។
  - កុំដកដើមផ្លែស្រស់ គរជាគំនរ ។
  - កុំហាលថ្ងៃយូរពេក ក្រោយពេលដកប្រមូលផល ។

## V- វិភាគសេដ្ឋកិច្ចក្នុងផលិតកម្មដំណាំសណ្តែកដី (ក្នុង ១ហិកតារ)

| មុខចំណាយ | ឯកតា | តាមការអនុវត្តរបស់កសិករ | | | ការអនុវត្តតាមបច្ចេកទេស | | |
|---|---|---|---|---|---|---|---|
| | | ចំនួន | តំលៃរាយ($) | តំលៃសរុប($) | ចំនួន | តំលៃរាយ($) | តំលៃសរុប($) |
| ការរៀបចំដីសរុប | ហត | ១ | ២០.០០ | ២០.០០ | ១ | ៤០.០០ | ៤០.០០ |
| គ្រាប់ពូជ | គក្រ | ៨០ | ០.៨០ | ៦៤.០០ | ៨០ | ០.៨០ | ៦៤.០០ |
| ដាំដុះ | ថ្ងៃ/នាក់ | ៧ | ១.៧០ | ១១.៩០ | ៧ | ១.៧០ | ១១.៩០ |
| ថែទាំសរុប | ថ្ងៃ/នាក់ | ២០ | ១.៧០ | ៣៤.០០ | ៣០ | ១.៧០ | ៥១.០០ |
| ជី១៥.១៥.១៥ | គក្រ | ១០០ | ០.៤៥ | ៤៥.០០ | ១៥០ | ០.៤៥ | ៦៧.០០ |
| ជីកំប៉ុស្តលាមកសត្វ | តោន | - | - | - | ១០ | ៥.០០ | ៥០.០០ |
| ថ្នាំ ធុរាដាន | គក្រ | - | - | - | ១០ | ១.២០ | ១២.០០ |
| ថ្នាំ ប៉េវ៉ូដរិន | លីត្រ | - | - | - | ២ | ៥.០០ | ១០.០០ |
| **ប្រមូលផលសរុប** | $ | ២២៥.៩០ | | | ៣៥៧.៤០ | | |
| **ទិន្នផល** | គក្រ | ២,០០០ | | | ៣,៥០០ | | |
| **ចំណូលក្នុងផលិតកម្ម** | $ | ០.២៥ ខ ២,០០០ = ៥០០.០០ | | | ០.២៥ ខ ៣,៥០០= ៨៧៥.០០ | | |
| **ចំណេញសរុប** | $ | ២៧៤.១០ | | | ៥១៧.៦០ | | |

***តំលៃ ០.២៥$ ក្នុង ១គក្រ ទាំងសំបក**

# ដំណាំពោតក្រហម
# (Yellow Maize)

## I- សេចក្តីផ្តើម

ពោតគឺជាដំណាំមួយប្រភេទ ដែលគេបានស្គាល់តាំងពីសតវត្សទី ១៧ មកម្ល៉េះ ហើយគេបានដាំដំណាំនេះនៅលើផ្ទៃដីតូចៗទៅតាមតំបន់នានា ក្នុងប្រទេសកម្ពុជា ហើយគេចាត់ទុកវាដូចជាអាហារសំរាប់បំពេញអាហារដទៃទៀត។ អាហារនេះមានសារៈសំខាន់ឡើងដល់ថ្នាក់ជាតិតាំងពីឆ្នាំ ១៩១០ ដែលបារាំងបានទិញពោតក្នុងចំនួនច្រើនពីប្រទេសក្រៅ ដើម្បីយកទៅធ្វើជាចំណីសត្វ។ ពោតក្រហមលេចចេញមកក្រោយឆ្នាំ ១៩២១ ការបង្កាត់ពូជដោយឯងៗ រវាងពោតចូលពីតុងកឹង និងអាមេរិកខាងត្បូង។ បន្ទាប់មកទៀត ការបង្កាត់ពូជដោយក្រសួងកសិកម្ម រវាងឆ្នាំ ១៩៣០ បង្កើតបានជាពោតក្រហមខ្មែរ ដែលមានដើមខ្ពស់ អាយុកាលខ្លី (៩០ថ្ងៃ) ផ្លែរាងមូលតូចខាងចុង ប្រវែងប្រហែល ២០សម គ្រាប់ ញឹកធំល្មម (៨មម) មូលខាងលើ ពណ៌លឿងក្រមៅ ឬក្រហមស្ទើទាំងអស់ មានស្នាមឆ្នូត និងខ្នងគ្រាប់ពណ៌ស ធ្វើឱ្យវាថយចុះតំលៃ ។ ការប្រឹងប្រែងកែលំអដោយបង្កាត់ពូជ បានអនុវត្តធ្វើនៅទីក្រុងភ្នំពេញ និងខេត្តកំពង់ចាម។ ពោតជាដំណាំមួយសំខាន់ក្នុងចំណោមដំណាំស្បៀងផ្សេងៗទៀត។ យោងតាមល្បឿននៃផលិតកម្មពោត គេអាចសន្និដ្ឋានបានថា ចាប់ពីឆ្នាំ ២០០០ទៅ ដំណាំពោតនឹងក្លាយជាដំណាំទី ១ ក្នុងពិភពលោក។



## II- គោលបំណង

១-បង្កើនការយល់ដឹងដល់កសិករអំពីសារៈសំខាន់នៃដំណាំពោត។

២-ផ្តល់បច្ចេកទេសដាំដុះក្នុងផលិតកម្មដំណាំពោត។

៣-បង្កើនប្រាក់ចំណូលឱ្យបានខ្ពស់តាមការអនុវត្តបច្ចេកទេសក្នុងផលិតកម្មដំណាំពោត។

## III- ការអនុវត្តរបស់កសិករកន្លងមក

- មិនបានធ្វើការជ្រើសរើសដីឱ្យបានត្រឹមត្រូវមុនពេលដាំដុះ។

- ការប្រើប្រាស់ជីមិនសមស្របតាមក្បួនខ្នាត ។
- ការជ្រើសរើសពូជមិនសមស្របតាមបច្ចេកទេស ។
- ការដាំដុះមានលក្ខណៈសាមញ្ញ ខ្វះការថែទាំ ។
- ការរៀបចំដីមិនទាន់សមស្របតាមបច្ចេកទេស ។
- ការដាំដុះពឹងផ្អែកទៅលើទឹកភ្លៀងទាំងស្រុង ។

## IV- បច្ចេកទេសក្នុងការដាំដំណាំពោត

### ១_ការជ្រើសរើសពូជ :

ពោត គឺជារុក្ខជាតិមួយបែបដែលមានអាយុកាលលូតលាស់ខ្លីល្មម ហើយសមស្របនឹងការដាំដុះ ។ ចំពោះពូជពោតនៅប្រទេសកម្ពុជាយើងច្រើនមានអាយុកាល ៨៥ ថ្ងៃ, ៩០ថ្ងៃ និង ១១០ ថ្ងៃ ។ ដូច្នេះ យើងត្រូវធ្វើការជ្រើសរើសពូជឱ្យសមស្របតាមបច្ចេកទេសដូចជា :



- គ្រាប់ពូជល្អផ្តល់ទិន្នផលខ្ពស់
- គ្រាប់ពូជដែលមានអត្រានៃការដុះលើសពី ៨៥ ភាគរយ ឡើងទៅ ។
- គ្រាប់ពូជធន់ទ្រាំនឹងជំងឺ និងសត្វល្អិត ។
- គ្រាប់ពូជថ្មីមិនទុកយូរខែឆ្នាំ ។

### ២_ការរៀបចំដី :

#### ២.១-រដូវប្រាំង



ត្រូវធ្វើការភ្ជួររាស់ដីឱ្យម៉ដ្ឋល្អ ដើម្បីរក្សាសំណើមក្នុងដីបានយូរ ហើយហាលដីឱ្យបាន ៧-១០ថ្ងៃសិន មុនពេលភ្ជួររាស់សំរាប់ធ្វើការដាំដុះចុងក្រោយ ។

#### ២.២-រដូវវស្សា

យើងមិនអាចធ្វើការភ្ជួររាស់ដីឱ្យម៉ដ្ឋពេកទេ ព្រោះបណ្តាលឱ្យដីឆាប់ហាប់ក្រោយពីភ្លៀងធ្លាក់ ។ការភ្ជួរដីហាលក្នុងរដូវវស្សានេះ ត្រូវធ្វើឱ្យបានចាប់ពី១-២ ដង ដើម្បីសំលាប់ស្មៅចង្រៃ, សត្វល្អិត ព្រមទាំងបង្កើនបន្ទុកខ្យល់ក្នុងដីបានល្អ ហើយត្រូវភ្ជួរជួយច្របល់ជីគ្រប់ប្រភេទដែលបានដាក់ទ្រាប់បាត ។ ការភ្ជួររាស់លើកទី ២ ត្រូវភ្ជួរកាត់ទទឹងលើកទី ១ ។

### ៣_រដូវកាលដាំដុះ:

-នៅតំបន់ត្រូពិក ពោតគឺជាដំណាំមួយ មិនរើសរដូវកាលដាំដុះ ។ ដោយឡែកនៅប្រទេសកម្ពុជា គេអាចដាំ

ពោតបានល្អនៅតាមបណ្តាខេត្តមួយចំនួន តាមដងទន្លេ ដូចជា ខេត្តកណ្តាល, ខេត្តព្រៃវែង, ខេត្តកំពង់ចាម, ខេត្តក្រចេះ, ខេត្តកំពង់ឆ្នាំង និងតំបន់ខ្ពង់រាប ។

ចំពោះដីនៅមាត់ទន្លេ គេអាចដាំ ២ ដងក្នុង ១ ឆ្នាំ ដោយសារតំបន់នេះអាចធានាទឹកនិងជីជាតិបានគ្រប់គ្រាន់។

### ៣.១-រដូវវស្សា :

- ចំពោះតំបន់មាត់ទន្លេ គេចាប់ផ្តើមដាំពីចុងខែ មេសា ដល់ពាក់កណ្តាលខែ ឧសភា និងប្រមូលផលនៅចុងខែ សីហា។

- ចំពោះតំបន់ខ្ពង់រាប គេចាប់ផ្តើមដាំនៅខែ ឧសភា ដល់ខែ កក្កដា និងប្រមូលផលនៅចុងខែ កញ្ញា ។

### ៣.២-រដូវប្រាំង :

- គេចាប់ផ្តើមដាំនៅរដូវទឹកសំរក គឺចាប់ពីខែវិច្ឆិកា ហើយត្រូវប្រមូលផលនៅចុងខែមិនា និងដើមខែមេសា។

## ៤_ការប្រើប្រាស់ជី :



- ជីទ្រាប់បាត : ត្រូវដាក់ជីទ្រាប់បាតក្នុងដី ១ ហិកតារ មាន :
  - ជីលាមកសត្វ ឬ ជីកំប៉ុស្ត ២០ - ៣០ តោននៅពេលភ្ជួរលើកទី២
  - ជី ដេ-អា-ប៉េ (១៨.៤៦.0) ១00 គក្រ ក្នុង ១ ហិកតារ
  - ជីប៉ូតាស្យូម (0.0.៦0) ១00 គក្រ ក្នុង ១ ហិកតារ
- ការដាក់ជីបំប៉ន :

ជីអ៊ុយរ៉េ គេដាក់នៅពេលពោតចេញស្លឹក ៦-៨ សន្លឹក កំពស់ ៥ តឹក ឬនៅពេលពូនគល់លើកទី១ ក្នុងបរិមាណ ៥0 គក្រ ក្នុង ១ ហិកតារ ដើម្បីបំប៉នដំណាំ ។ លើកទី ២ គេដាក់នៅពេលពោតចេញផ្កាឈ្មោល ៣0 ភាគរយ ក្នុងបរិមាណ ៥0 គក្រ ក្នុង ១ ហិកតារ ។

## ៥_ការដាំដុះ :

### ៥.១-របៀបប្រើពូជ :

- គេត្រូវប្រើគ្រាប់ពូជចាប់ពី ២៥-៣0 គក្រ ក្នុង ១ ហិកតារ សំរាប់ពូជក្នុងស្រុក ។ មុនពេលដាំ គេត្រូវយកគ្រាប់ពូជទៅហាល ១-២ ម៉ោង ដើម្បីឱ្យគ្រាប់ពូជជប់ទឹកបានរហ័សនៅពេលដាំ ឆាប់ដុះ និងឱ្យដើមពោតរឹងមាំល្អ ។

- គេយកគ្រាប់ពូជដែលហាលស្ងួត នោះទៅត្រាំទឹកឱ្យបានរយៈពេល ៤-៦ ម៉ោងសិនដើម្បីបង្កើនអត្រានៃការដុះឆាប់របស់គ្រាប់ពូជ និងបានស្មើគ្នាល្អ (ចំពោះពូជថ្មី ដេកា-DK ប្រើក្នុង១ហិតា ១៣-១៥គក្រ) ។

### ៥.២-របៀបដាំ :

ការដាំពោតមានច្រើនរបៀបគឺ ដាំជារណ្តៅ, ដោយដៃ និងដោយម៉ាស៊ីន ។

### ៥.៣-របៀបដាក់គ្រាប់ :

- ចំពោះពូជ ដេកា-ឌុគ៨៨៨ យើងត្រូវដាក់ចំនួន ២ គ្រាប់ ក្នុង ១ រណ្តៅ ។
- ចំពោះពូជក្នុងស្រុក យើងត្រូវដាក់ចំនួន ៣-៤ គ្រាប់ ក្នុង ១ រណ្តៅ ។

គេអាចអនុវត្តរបៀបដាំទាំងពីររបៀបនេះ តាមតារាងខាងក្រោម :

| ចន្លោះជួរ | ចន្លោះគុម្ព | ចំនួនដើមក្នុង១គុម្ព | ចំនួនដើមក្នុង ១ ហិកតារ | ផ្សេងៗ |
|---|---|---|---|---|
| ៨០សម | ៤០សម | ២ | ៦២៥០០ | ពូជ ដេកា ៨៨៨ |
| ៨០សម | ២០សម | ១ | ៣១២៥០ | ពូជ ដេកា ៨៨៨ |
| ៧៥សម | ៥០-៦០សម | ២ | ៤៤០០០-៥៣០០០ | ពូជ ក្នុងស្រុក |

ជំរៅគ្រាប់ដែលត្រូវកប់ឬបុកដាំ គឺអាស្រ័យដោយសំណើមដែលមាននៅក្នុងដី ។ ចំពោះដីសើម ឬរដូវវស្សា មានជំរៅប្រមាណ ២ - ៤សម ។ ចំណែកដីស្ងួត ឬរដូវប្រាំងគឺមានជំរៅប្រមាណ ៣-៥សម ។

**បញ្ជាក់ :** គ្រាប់ពូជសើម ត្រូវដាំលើដីសើម គ្រាប់ស្ងួត ត្រូវដាំលើដីស្ងួត រួចធ្វើការស្រោចស្រព ។

### ៥.៤-ការជួសរណ្តៅ :

ក្រោយពេលដាំរយៈពេល ២ - ៣ថ្ងៃ គ្រាប់ពោតចាប់ផ្តើមចេញពន្លក ដូច្នេះបើយើងសង្កេតឃើញបាត់រណ្តៅតិចជាង ១០% គឺយើងមិនចាំបាច់ជួសវាទេ ។ ប៉ុន្តែ បើយើងសង្កេតឃើញមានចំនួនច្រើនជាង ១០% ត្រូវប្រញាប់ដាំជួសថ្មីជាបន្ទាន់ ដើម្បីធានា បាននូវចំនួនដើម និងធានាបានបរិមាណផលច្រើន ។

### ៥.៥-ការដកបំបែកកូន :

ក្រោយពេលកូនពោតដុះបាន ១០-១៥ថ្ងៃ ឬមានស្លឹកចាប់ពី ៣-៤ សន្លឹក មានកំពស់ ១០-១៥សម ត្រូវប្រញាប់ដក បំបែកដើមចេញខ្លះ ទុកតែ ១-២ ដើមក្នុង១គុម្ព ។ ត្រូវដកដើមដែលស្គម រៀវ ឬ មានរោគចេញ ។

### ៥.៦-ការសំអាតស្មៅ - ជ្រួយគល់ និងពូនគល់ដំណាំពោត :

ក្រោយពេលដកកូនពោតចោលខ្លះរួចហើយ ត្រូវចាប់ផ្តើមជំរះស្មៅ ជ្រួយដី ដើម្បីឱ្យដីធូរ ជប់សំណើមបានច្រើនធ្វើឱ្យឬសពោតដុះបានល្អ ខ្យល់ចេញចូលបានស្រួល ។ ពេលពោតមានអាយុ ៤០ ថ្ងៃ ឬឃើញពោតមានស្លឹកចាប់ពី ៦-៨ សន្លឹក ត្រូវធ្វើស្មៅ ដាក់ជីបំប៉ន និងពូនគល់ដាក់ជីជាលើកទី១ ដើម្បីបង្កើនប្រព័ន្ធឬសថ្មីបន្ថែមទៀត និងជំរុញឱ្យដំណាំពោតមានការលូត លាស់បានល្អ ។ ជាទូទៅ យើងអាចជំរះស្មៅ ១-២ ដងក្នុងរដូវវស្សា ។

បើយើងបណ្តោយឱ្យស្មៅដុះច្រើននោះ ទិន្នផលពោតនឹងថយចុះ ស្មៅចង្រៃដណ្តើមយកជីជាតិពីដំណាំពោត ហើយធ្វើឱ្យដំណាំទទួលការលូតលាស់មិនរួច ។

## ៦_ការប្រមូលផល និងការទុកដាក់ផលិតផលពោត ៖

ការប្រមូលផលគឺប្រែប្រួលទៅតាមប្រភេទពូជនីមួយៗ ម្យ៉ាងទៀតយើងអាចសន្និដ្ឋានបានថា ផ្លែពោតទុំ គេសង្កេតឃើញដើមនិងស្លឹកមានពណ៌លឿងទុំ សំបកផ្លែស្ងួត ក្រៀមស្រួយ សក់វាឡើងពណ៌ខ្មៅស្រួយ គ្រាប់ភ្លឺរលោង ហើយរឹង និងមានសំណើមក្នុងគ្រាប់តិចជាង ២៥% ។

## ៧_ការប្រមូលផលពោតជាលក្ខណៈគ្រួសារ ៖



គេអាចប្រមូលផលពោតចងព្យួរទុកដាក់ជាចង្កោមនៅតាមក្រោមដើមឈើក្បែរផ្ទះ និងក្រោមផ្ទះ។ ម្យ៉ាងទៀតគេ អាចទុកដាក់ពោតនៅក្នុងក្រង់ដោយបកសំបកចេញ ហាលថ្ងៃឱ្យស្ងួត។ គេអាចប្រមូលផលប្រឡេះជាគ្រាប់រួចយកទៅហាលឱ្យស្ងួត ១៤% នៃសំណើមគ្រាប់ ។ ការធ្វើក្រង់ដាក់ពោតឱ្យបានកំពស់ពីដី ៥ តឹក, កំពស់ទ្រូង ០,៤០ម ខ ១,៥០ម ខ ៤ម ។

## ៨_សារៈប្រយោជន៍នៃដំណាំពោត ៖

ពោត គឺជាដំណាំមួយប្រភេទយ៉ាងសំខាន់សំរាប់បំរើផលប្រយោជន៍ដល់មនុស្សនិងសត្វ ។ នៅក្នុងគ្រាប់ពោតមានផ្ទុក ទៅដោយសារជាតិផ្សេងៗជាច្រើនដូចជា ៖ ជាតិទឹក ១០.៨% ជាតិប្រូតេអ៊ីន ១០% ជាតិកាបូអ៊ីដ្រាត ៧៣.៤% និង ជាតិរ៉ែ ១.៤% ។

### ៨.១-ពោតជាចំណីអាហាររបស់មនុស្ស ៖

ពោតត្រូវបានគេយកមកធ្វើជាម្ហូបអាហារប្រចាំថ្ងៃសំរាប់ប្រទេសមួយចំនួន ។ ពោតជាអាហារបន្ថែមពីលើអាហារមូលដ្ឋានដែលប្រជាជនតែងតែនិយមចូលចិត្តដូចជា ៖ អាំង,ស្ងោរ,ដុត និងកែច្នៃធ្វើជាអង្ករពោត ម្សៅពោត និងនំពោត ។



### ៨.២-ពោតជាវត្ថុធាតុដើមសំរាប់រោងចក្រ ៖

- ដើម និងស្នូលធ្វើជាក្រដាស់ ខ្សែ ឬសំរាប់ដុត ។
- គ្រាប់ពោតក្រហមកិនធ្វើជាចំណីសត្វ ។
- ចំរាញ់យកជាតិប្រូតេអ៊ីន និងអាមីដុង ធ្វើជាឱសថ ។
- កែច្នៃធ្វើជានំប៉័ង ប្រេងឆា ទឹកស៊ីរ៉ូ ។ល ។
- ដោយឡែកសំរាប់គ្រាប់ពោតដំណើប គេកិនធ្វើជាការ គ្រឿងតំបាញ និងសាប៊ូ ។

## V- ការវិភាគសេដ្ឋកិច្ចលើដំណាំពោតក្នុង ១ ហិកតារ

| ល.រ | មុខចំណាយ | ឯកតា | តាមប្រពៃណី | | | តាមបច្ចេកទេស | | |
|---|---|---|---|---|---|---|---|---|
| | | | ចំនួន | តំលៃរាយ | តំលៃសរុប | ចំនួន | តំលៃរាយ | តំលៃសរុប |
| ១ | ការរៀបចំដី | ដង | ២ | ៨០០០០៛ | ១៦០០០០៛ | ២ | ៨០០០០៛ | ១៦០០០០៛ |
| ២ | ការប្រើប្រាស់ពូជថ្មីដេកា | គក្រ | - | - | - | ១៥ | ១៦០០០៛ | ២៤០០០០៛ |
| ៣ | ពូជក្នុងស្រុក | គក្រ | ៣០ | ២០០០៛ | ៦០០០០៛ | - | - | - |
| ៤ | ការដាក់ជីបំប៉នអ៊ុយរ៉េ | គក្រ | ៥០ | ១៧០០៛ | ៨៥០០០៛ | ១០០ | ១៧០០៛ | ១៧០០០០៛ |
| ៥ | ការដាក់ជីកំប៉ុស្ត | តោន | - | - | - | ៧ | ២០០០០៛ | ១៤០០០០៛ |
| ៦ | ការដាក់ជី ដេ-អា-ប៉េ | គក្រ | - | - | - | ១០០ | ១៧០០៛ | ១៧០០០០៛ |
| ៧ | ជីប៉ូតាស្យូម | គក្រ | - | - | - | ៥០ | ១៩០០៛ | ៩៥០០០៛ |
| ៨ | ជំរះស្មៅពូនគល់ | នាក់ | ២០ | ៧០០០៛ | ១៤០០០០៛ | ២០ | ៧០០០៛ | ១៤០០០០៛ |
| ៩ | ការប្រមូលផល | នាក់ | ២០ | ៧០០០៛ | ១៤០០០០៛ | ២០ | ៧០០០៛ | ១៤០០០០៛ |
| ចំណាយសរុប | | ៥៨៥ ០០០៛ | | | | ១២ ៩៥០ ០០០៛ | | |
| ចំណូលសរុប | | ១ ០៥០ ០០០៛ | | | | ២ ៤០០ ០០០៛ | | |
| ចំណេញ | | ៤៦៥ ០០០៛ | | | | ១១ ៤៥៥ ០០០៛ | | |

-តាមប្រពៃណី : ក្នុង ១ ហកិតារ បានផល ៣៥០០គក្រ

-តាមបច្ចេកទេស : ក្នុង ១ ហិកតា របានផល ៨០០០គក្រ

-តំលៃជាមធ្យម នៅទីផ្សារ = ១គក្រ = ៣០០៛

# ការបោកបែន និងការហាលស្រូវ
# (Threshing and Drying)

## I- ទស្សនៈទូទៅ



ការប្រមូលផលស្រូវ ជាការងារពិបាកជាងការការងារប្រមូលផលដំណាំផ្សេងៗដែលគេបានធ្វើការដាំដុះ ព្រោះការងារនេះ ត្រូវធ្វើការឆ្លងកាត់ការត្រួតពិនិត្យអោយបានត្រឹមត្រូវតាមដំណាក់កាលនីមួយៗតាំងពីការច្រូតកាត់ ដឹកជញ្ជូន បោកបែន និងការហាលស្រូវ ។ ដំណាក់កាលទាំងនេះបើយើងមិនយកចិត្តទុកដាក់ទេនោះ អាចបណ្តាលអោយបាត់បង់ទិន្នផលស្រូវ ឬខូចគុណភាពស្រូវ និងអង្ករនៅពេលយើងកិនវា ។ ការបោកបែន និងហាលស្រូវជាសកម្មភាពមួយ អាចថាបានជាការងារចុងក្រោយក្នុងការប្រមូលផលស្រូវ ហើយវាមានសារៈសំខាន់ណាស់ ដើម្បីជៀសវាងអោយបាននូវការបាត់បង់នេះ ។

កន្លងមកកសិករច្រើនដឹកកណ្តាប់មកគរទុកជាពំនូកនៅលើលានដែលបានរៀបចំរួចជាស្រេច ទើបធ្វើការបោកបែនជាក្រោយ ។ រយៈពេលគរទុកនេះមានរហូតដល់ ១ ខែ ក៏មាន ។ ការបោកស្រូវតាមវិធីនេះគេច្រើនតែអនុវត្តដោយកំលាំងមនុស្ស (បែននឹងជើង ឬបោកនឹងក្តារ) គេរៀបតាំងបញ្ជាន់ដោយគោ ឬក្របី ។ បច្ចុប្បន្នជាទូទៅ ការបោកបែន គេធ្វើដោយម៉ាស៊ីនបោកស្រូវនៅនឹងកន្លែងតែម្តង ។ ឯតំលៃបោកស្រូវគឺ ១០% លើផលិតផលស្រូវ ដែលបានបោករួច (ស្អាតជាស្រេច) ។

## II- គោលបំណង

១-បង្កើនការយល់ដឹងអោយកាន់តែខ្ពស់លើការអនុវត្តនូវសកម្មភាព ២ ចុងក្រោយក្នុងការប្រមូលផលស្រូវ ។
២-ធ្វើអោយផលិតករដឹងពីការបាត់បង់ និង ខូចខាតពីការប្រមូលផលស្រូវ ។
៣-បង្កើនសមត្ថភាពក្នុងការធ្វើផែនការលំអិត និងផ្ចិតផ្ចង់បំផុតលើការប្រមូលផល និងទុកដាក់ផលស្រូវ ។
៤-បង្កើនចំណូលអោយកាន់តែប្រសើរសំរាប់ផលិតករ ។

# III- ការអនុវត្តបោកបែន និងហាលស្រូវរបស់កសិករកន្លងមក

-ការបោកបែនស្រូវដោយម៉ាស៊ីនបោកនៅតាមវាលស្រែផ្ទាល់ ។

-ការបោកបែន និងហាលស្រូវក្រោយការដឹកជញ្ជូនស្តុកទុកនៅតាមកន្លែងដែលបានគ្រោងទុក និងការអនុវត្តការហាលស្រូវ ។

-ហាលស្រូវផ្ទាល់នឹងដីដែលបានរៀបចំរួច (លើលានបោក) ។

-ហាលស្រូវនៅលើកន្ទេលក្បែរផ្ទះ ។

# IV- បច្ចេកទេសក្នុងការអនុវត្តការបោកបែនស្រូវ និងការហាលស្រូវ

## ១_ការបោកបែនស្រូវ

ការបោកបែនស្រូវ គឺជាដំណើរការនៃការប្រព្រឹត្តផ្តាច់ ឬប្រឡេះគ្រាប់ស្រូវអោយចេញពីកួរ ។

### ១-១-ការបោកបែនមាន ៣ យ៉ាងគឺ :

-ការបោកដោយកំលាំងមនុស្សគឺជាវិធីល្អមួយ ប៉ុន្តែចំណាយកំលាំងពលកម្មច្រើន ខាតពេលវេលា ។

-ការបញ្ជាន់ដោយសត្វ ឬត្រាក់ទ័រ វិធីនេះធ្វើអោយគ្រាប់ស្រូវបាក់បែកជាច្រើនកំណាត់ប៉ុន្តែប្រើកំលាំងពលកម្មតិច ។

-ការបោកបែនដោយម៉ាស៊ីនជាវិធីល្អ លឿន បើសិនអ្នកបោកនោះប្រសប់ក្នុងការបញ្ជាគ្រឿងចក្រចំណេញពេលវេលា ។

ការប្រើប្រាស់ដោយម៉ាស៊ីននេះ វាមានករណីដែលត្រូវអនុវត្តដូចខាងក្រោម :

- យើងពិនិត្យមើលគ្រាប់ស្រូវមានអត្រាសំណើមចាប់ពី ២០ ទៅ ២៥ % កាលណាស្រូវសើមជាងនេះធ្វើអោយពិបាកបោកប្រឡេះគ្រាប់ចេញពីចំបើងមិនអស់ តែបើស្ងួតជាងនេះធ្វើអោយស្រូវងាយប្រេះស្រាំ ។
- បញ្ជាត្បាល់ម៉ាស៊ីនកុំអោយវិលលឿនពេក (ជាង ៦០០ជុំក្នុង ១ នាទី) ។
- បើកាលណាវាវិលយឺតពេកធ្វើអោយការបោករបស់ម៉ាស៊ីនយឺត ឬប្រឡេះគ្រាប់ស្រូវមិនអស់ពីចំបើង តែបើវាវិលលឿនពេក ធ្វើអោយគ្រាប់ស្រូវរងការវាយផ្ទប់ខ្លាំង ងាយបែក រលាត់សំបក និងប្រេះស្រាំអង្ករនៅពេលកិន ។

### ១-២-ដើមស្រូវដែលច្រូតកាត់គឺអោយបានសមស្របទៅតាមវិធីសាស្ត្រនៃការបោកបែន

-បោក ឬបែនស្រូវត្រូវកាត់ដើមស្រូវអោយបានប្រវែង ៣០ ទៅ ៥០ សង្ទីម៉ែត្រ ឬកាត់ត្រឹមកួរ ។

-បើបញ្ជាន់ដោយសត្វ ឬត្រាក់ទ័រត្រូវកាត់ដើមស្រូវអោយបានប្រវែង ៦០ ទៅ ៨០ សង្ទីម៉ែត្រ ឬ ត្រឹមគល់ ។

-បើប្រើម៉ាស៊ីនបោក ត្រូវកាត់ដើមស្រូវអោយបានប្រវែង ៤០ ទៅ ៥០ សង្ទីម៉ែត្រ ។

## ១-៣-ការបោកស្រូវសំរាប់ទុកពូជ និងហាលគ្រាប់ពូជ

-តាមលក្ខណៈបច្ចេកទេស ស្រូវអាចច្រូតកាត់បានលុះត្រាតែអត្រាស្រូវទុំក្នុងស្រែ មាន៨០ទៅ៨៥% និងសំណើមប្រមាណ២០ទៅ២៤%។ ចំណែកស្រូវសំរាំងធ្វើពូជក៏មិនខុសពីស្រូវធម្មតាប៉ុន្មានទេ តែដើម្បីជៀសវាងការថយចុះគុណភាព និងលាយឡំពូជគ្នា យើងត្រូវធ្វើការច្រូតកាត់កន្លែងស្រូវសំរាប់ធ្វើពូជនោះ អោយបានមុនពេលច្រូតកាត់កន្លែងផ្សេងទៀត ។

-ចំណែកឯការបោកបែនវិញយើងត្រូវទុកដាក់ពូជស្រូវដោយឡែកពីគ្នា ។ត្រូវរៀបចំប្រដាប់បោកស្រូវ និងកន្លែងហាលកុំអោយលាយឡំគ្នាជាមួយពូជស្រូវផ្សេងទៀត ដែលនាំឱ្យមានការថយគុណភាព ។ ហាលពូជស្រូវអោយបានស្ងួតល្អ និងរក្សាទុកដាក់អោយដាច់ពីគ្នា ។



-បន្ទាប់ពីបោកបែនរួចតើត្រូវហាលសំងួតគ្រាប់ពូជយ៉ាងដូចម្តេច ?

គ្រាប់ពូជគួរហាលនៅក្រោមកំដៅថ្ងៃលើកន្ទេល ឬលើលានដែលមានចាក់បេតុងស្អាតល្អ ។ ការហាលនេះគួរធ្វើបន្តរហូតសំណើមស្រូវនោះមានប្រមាណ ១៤ %។ ការងារនេះយើងអាចប្រព្រឹត្តទៅចាប់ពី ៣ ទៅ ៥ថ្ងៃ ក្រោមពន្លឺថ្ងៃ ។

-តើត្រូវរក្សាពូជសុទ្ធយ៉ាងដូចម្តេច ?

-គ្រាប់ស្រូវគួររក្សាទុកនៅកន្លែងដែលមានខ្យល់ចេញចូលបានល្អដោយប្រើបាវក្រចៅ ឬឧបករណ៍ផ្សេងទៀតលាយជាមួយថ្នាំកំចាត់សត្វល្អិត ដើម្បីកុំឱ្យសត្វល្អិតបំផ្លាញគ្រាប់ពូជ ។

-តើយើងចងផ្លាកសញ្ញាលើពូជស្រូវយ៉ាងដូចម្តេច ?

-ផ្លាកសញ្ញាត្រូវសរសេរឈ្មោះ ពូជ ខែ ថ្ងៃច្រូតកាត់ និងប្រភេទពូជ ។ ផ្លាកសញ្ញាត្រូវប្រើយ៉ាងតិចចំនួន ២ ដាក់ក្នុងបាវ ១ និងនៅក្រៅបាវ ១ ដោយចងភ្ជាប់ទៅនឹងសំបកបាវ ។

## ២_ការហាលគ្រាប់ស្រូវ



-គ្រាប់ស្រូវដែលបោកបែនរួច វាអាចមានសំណើមចាប់ពី ១៨ ទៅ ២៥ % ហើយមិនត្រូវយកគ្រាប់ស្រូវដែលមានសំណើមខ្ពស់បែបនេះទៅទុកដាក់ទេព្រោះអាចធ្វើអោយពុកផុយដុះផ្សិត និងមានសត្វល្អិតបំផ្លាញច្រើន។

-យើងហាលគ្រាប់ស្រូវ ដើម្បីបន្ថយសំណើមរហូតដល់ ១៤%ទោះបីការទុកដាក់ស្រូវនោះមានរយៈពេលខ្លី ឬទំនើបយ៉ាងណាក៏ដោយ។ ដើម្បីអោយស្រូវឆាប់ស្ងួត យើងត្រូវហាលនឹងកំដៅថ្ងៃរយៈពេល ២ ទៅ ៣ ថ្ងៃ ក្នុងកំរាស់ស្តើងល្មមចាប់ពី ៣ សង្ទីម៉ែត្រ ទៅ ៥ សង្ទីម៉ែត្រ ឧស្សាហ៍រីត្រឡប់វា ។

-នៅថ្ងៃត្រង់ពេញកំដៅ គ្រាប់ស្រូវអាចកើនកំដៅខ្ពស់រហូតដល់ ៥០ ដឺក្រេសេ ទៅ ៦០ ដឺក្រេសេ ដូច្នេះត្រូវរីត្រឡប់វាអោយបានញឹកញាប់ ។

-យើងអាចហាលទាំងកណ្តាប់បានដោយមិនថយចុះគុណភាពអង្ករ ព្រោះគ្រាប់ស្រូវជាប់នឹងកណ្តាប់មិនងាយឡើងកំដៅ និងមិនស្ងួតលឿនប៉ុន្មានទេ។ ប៉ុន្តែបើស្ងួតជ្រុលធ្វើអោយជ្រុះគ្រាប់ស្រូវនៅពេលយើងប្រមូលកណ្តាប់និងដឹកជញ្ជូន ។

## ២-១-របៀបមើលគ្រាប់ស្រូវស្ងួត

យើងអាចដឹងពីភាពស្ងួតរបស់គ្រាប់ស្រូវបាន ដោយសារការខាំគ្រាប់ស្រូវជាពីរកំណាត់ ហើយពិនិត្យមើលបើផ្នែកខាងក្នុងគ្រាប់ស្រូវមានពណ៌ថ្លាល្អនោះបញ្ជាក់ថា គ្រាប់ស្រូវស្ងួតល្អហើយ។ តែបើមិនមានពណ៌ថ្លានោះទេគ្រាប់ស្រូវមិនទាន់ស្ងួតល្អទេ ។

## ២-២-ការហាលស្រូវមាន ២ បែប :

-ការហាលស្រូវក្រោមកំដៅថ្ងៃ ។

-ការហាលស្រូវដោយម៉ាស៊ីនសម្ងួតដោយខ្យល់ ។

## ២-៣-បញ្ជាក់ពីការហាលគ្រាប់ស្រូវ

-មិនត្រូវធ្វើអោយគ្រាប់ស្រូវដែលត្រូវទុកធ្វើពូជមានកំដៅខ្លាំងលើសពី ៤0 ដឺក្រេសេទេ ព្រោះវាអន់ ឬងាប់ហើយលែងដុះ ។

-ត្រូវសា ឬគ្របស្រូវនៅពេលមានភ្លៀង ឬសន្សើមធ្លាក់ ព្រោះគ្រាប់ស្រូវនៅពេលស្ងួត វាឆាប់ស្រូបយកសំណើមណាស់ បណ្តាលអោយប្រេះស្រាំ និងបាក់នៅពេលកិនជាអង្ករ ។

-ការពារស្រូវកុំអោយលាយឡំគ្នាជាមួយស្រូវកខ្វក់ ឬស្រូវដែលមានគ្រួសឬថ្មកុំអោយសត្វផ្សេងៗចូលក្បែរ។

-បើរយៈពេលទុកដាក់យូរ សំណើមស្រូវកាន់តែតិច ។

# V- ការវិភាគសំណើមស្រូវនៅពេលទុកដាក់

| រយៈពេលទុក | សំណើមសមស្រប | បញ្ហាកើតឡើងនៅពេលមានសំណើមខ្ពស់ |
|---|---|---|
| ២ ទៅ ៣ អាទិត្យ | ១៤ % ទៅ ១៨ % | ដុះផ្សិត ឬប្រែពណ៌ស្រអាប់លឿង ឬ ខ្មៅ |
| ៨ ទៅ ១២ ខែ | ទាបជាង ឬស្មើ ១៣ % | សត្វល្អិតបំផ្លាញ |
| យូរជាង ១ ឆ្នាំ | ទាបជាង ឬស្មើ ៩ % | គ្រាប់ពូជលែងសូវដុះ |

# ដំណាំសណ្តែកសៀង
# (Soybean )

## I- សេចក្តីផ្តើម

សណ្តែកសៀងជាប្រភេទដំណាំ ដែលគេរាប់បញ្ចូលជាប្រភេទដំណាំឧស្សាហកម្ម ហើយជាដំណាំដែលអាចកែច្នៃនៅក្នុងរោងចក្រ ឬធ្វើសិប្បកម្មអ្វីផ្សេងៗបានជាច្រើនមុខ ដូចជាការផលិតជាសៀង, ធ្វើតៅហ៊ូ, ពពុះសណ្តែក, ទឹកស៊ីអ៊ីវ, ទឹកសណ្តែក ។ល។ មួយផ្នែកទៀត គេអាចយកទៅធ្វើចំណីសត្វជ្រូក មាន់ ទា ត្រី ។ល។



តាមការពិនិត្យរបស់អ្នកវិទ្យាសាស្ត្រ បានឱ្យដឹងថា សណ្តែកសៀងជាប្រភេទដំណាំម្យ៉ាង សំបូរទៅដោយសារធាតុប្រូតេអ៊ីន ដែលមនុស្ស និងសត្វត្រូវការចាំបាច់សំរាប់ថែបំប៉នសុខភាពផ្នែកការលូតលាស់ធំធាត់ បានយ៉ាងឆាប់រហ័ស ។ រីឯកាកសំណល់របស់វាដូចជា ស្លឹក ដើមគេអាចភ្ជួរលុបចោលនៅនឹងកន្លែងដើម្បីធ្វើដីឱ្យមានជីជាតិល្អ និងសំបូរទៅដោយជាតិមមោក ដូចជាធ្វើឱ្យដីធូរ ដីមិនហាប់ណែន ក្នុងដីមានខ្យល់អុកស៊ីហ្សែនល្អ។

## II- គោលបំណង

១-ធ្វើឱ្យប្រជាកសិករស្គាល់ពីអត្ថប្រយោជន៍របស់សណ្តែកសៀង។

២- ផ្តល់បច្ចេកទេសដាំដុះសណ្តែកសៀង ជូនដល់កសិករ ។

៣- បំរើតំរូវការទីផ្សារ ។

៤- បង្កើនជីវភាពខ្វះខាតរបស់កសិករ ។

## III- ទំលាប់ធ្វើរបស់កសិករ

-ការរៀបចំដីមិនបានត្រឹមត្រូវតាមក្បួនខ្នាត ។

-ការដាំជាលក្ខណៈប្រពៃណី ។

-គ្មានការថែទាំ ឱ្យបានសមស្របតាមបច្ចេកទេស ។

-មិនប្រើប្រាស់កាកសំណល់សំរាប់ធ្វើជីធម្មជាតិ ។

## IV- បច្ចេកទេសនៃការដាំដំណាំសណ្តែកសៀង

### ១_ការជ្រើសរើសទីតាំងសំរាប់ដាំសណ្តែកសៀង:



ដីត្រូវមានលក្ខណល្អ :

-ដីមានជីជាតិ ។

-ដីខ្ពស់មិនលិចទឹក ។

-ដីធូរ និងរាបស្មើល្អ ។

### ២_ការជ្រើសរើសពូជសណ្តែកសៀង



ការជ្រើសរើសពូជសណ្តែកសៀង មានច្រើនប្រភេទមានពូជក្នុងស្រុក ពូជក្រៅស្រុក តាមតំរូវការទីផ្សារ ។

#### ក-ពូជនៅក្នុងស្រុក :

-ពូជសំបកផ្លែពណ៌ស មានរយៈពេល ៩៨ ថ្ងៃ ។

- ពូជសំបកផ្លែពណ៌ខ្មៅ មានរយៈពេល ៩២ ថ្ងៃ ។

#### ខ-ពូជក្រៅស្រុក :

- ពូជស្រមូវ រយៈពេល ៩៥ ថ្ងៃ ។

- ពូជស្កា រយៈពេល ៩៥ ថ្ងៃ ។

- ពូជស្រោល រយៈពេល ៨១ ថ្ងៃ ។

ក្នុងចំណោមពូជទាំងអស់ខាងលើនេះ មានតែពូជស្រោល ៨១ ថ្ងៃ ដែលប្រជាកសិករនិយមចូលចិត្តដាំភាគច្រើនជាងគេ បានផលច្រើន និងមានរយៈពេលខ្លី ។

### ៣_ការរៀបចំដីសំរាប់ដាំសណ្តែកសៀង

-ត្រូវភ្ជួរឱ្យបានជំរៅពី ០.១៥ម ទៅ ០.២៥ម ចំនួន ២ ដង រួចហើយរាស់បំបែកដីឱ្យបានបែកល្អិតល្មម ។

-ភ្ជួរលើកទី១ ត្រូវទុកហាលដីពី ៧ - ១០ ថ្ងៃ ឧស្សាហ៍ព្យាយាមរើសយកស្មៅ និងសំរាមផ្សេងៗចេញពីចំការឱ្យបានស្អាតល្អ ដើម្បីសំរួលដល់ការដាំដុះ ព្រោះសណ្តែកសៀងត្រូវការដីធូរ, មានជីជាតិល្អ, មិនបៀម មិនជាំទឹក ប៉ុន្តែដំណាំសណ្តែកសៀង ត្រូវការសំណើមទឹករហូតដល់ពេលប្រមូលផល ។

## ៤_ការដាក់ជីទ្រាប់បាត

-ជីកំប៉ុស្ត (ជីធម្មជាតិ) ត្រូវប្រើពី ១០ ទៅ ២០ តោន ក្នុង ១ ហិកតារ

-ជី ដេ- អា-ប៉េ ត្រូវប្រើ ១០០ គ.ក្រ ក្នុង ១ ហិកតារ

-ជី ប៉ូតាស្យូម ត្រូវប្រើ ១០០ គ.ក្រ ក្នុង ១ ហិកតារ

ជីទាំងអស់នេះ ត្រូវដាក់នៅពេលភ្ជួររាស់មុនដាំ និងត្រូវភ្ជួរច្របល់រាស់ឱ្យសព្វទៅក្នុងដី ។

## ៥_ពេលវេលាដាំដុះ



នៅតាមតំបន់នានាក្នុងប្រទេសកម្ពុជាយើង សណ្តែកសៀងត្រូវបានគេកំណត់ការដាំដុះគឺនៅ ដើមខែកក្កដារហូតដល់ចុង ខែកក្កដា យ៉ាងយូរបំផុត ព្រោះរយៈពេលក្នុង ខែកក្កដានេះ មានសន្សើមចុះពេលយប់ គ្រាប់សណ្តែកអាចរីកដុះបានក្រោយពេលដាំ និងស្រោចទឹកបន្តិចបន្តួច ហើយរយៈពេល ៤-៥ ថ្ងៃក្រោយមក ពន្លកសណ្តែកចាប់ផ្តើមដុះចេញជាពន្លកត្រួយ ។

## ៦_បច្ចេកទេសដាំសណ្តែកសៀង

ត្រូវយកគ្រាប់ពូជទៅហាលថ្ងៃចំនួន ១ - ២ ម៉ោង។ ធ្វើដូចនេះ អាចឱ្យគ្រាប់សណ្តែកឆាប់ដុះបានលឿនពេលដាក់គ្រាប់ទៅក្នុងដី ។



-តាមក្បួនខ្នាតគេដាំពីជួរមួយ ទៅជួរមួយ 0.៤0ម ទៅ0.៤៥ម។

-ពីគុម្ពមួយ ទៅគុម្ពមួយ 0.២0ម ទៅ 0.៣0ម។

-រណ្តៅនីមួយៗ យើងដាក់គ្រាប់ ២ - ៣ គ្រាប់ និងមានជំរៅ ៣ - ៤សម. រួចយកដីម៉ដ្ឋ ឬដីលាយជីកំប៉ុស្តលុបឱ្យជិតពីលើគ្រាប់សណ្តែក រួចយកដៃទះបន្ថែមស្រាលៗ ដើម្បីធ្វើឱ្យគ្រាប់សណ្តែកស្រូបយកសំណើមបានល្អ ។

## ៧_ការថែទាំ និងដករំលស់ដំណាំ

-ត្រូវដករំលស់កូនសណ្តែកចេញខ្លះៗក្នុងរយៈពេល ១០-១៥ ថ្ងៃ ក្រោយពេលដំណាំដុះ ។

-ក្នុងមួយរណ្តៅ ឬ មួយគុម្ព មានចំនួន ២ ដើម។

-ក្រោយពេលដាំចំនួន ១២ - ១៧ ថ្ងៃ ជំរះស្មៅលើកទី ១។

-១០- ១៥ ថ្ងៃ ក្រោយជំរះលើកទី១ ត្រូវសំអាតស្មៅលើកទី២ ។

## ៨_ការដាក់ជីបំប៉នលើដំណាំសណ្តែកសៀង

-យើងត្រូវប្រើជីបំប៉នបន្ថែមក្រោយពេលដាំ ២០-២៥ ថ្ងៃ។

-ត្រូវប្រើជីអ៊ុយរ៉េលើកទីមួយ ៥០ - ៧០ គ.ក្រ ក្នុង ១ ហិកតារ

-បន្ទាប់ពីបាចឬដាក់ជីរួច យើងត្រូវពូនគល់សណ្តែក ដោយយកដីតាមចន្លោះរងធ្វើឱ្យបានខ្ពស់ ដើម្បីបង្កើតជាប្រឡាយសំរាប់បង្ហូរទឹកចូល ។ រយៈពេលក្រោយការដាំ ៣០ ថ្ងៃ សណ្តែកចាប់ផ្តើមចេញ ផ្កាផ្លែមួយៗ ហើយយើងត្រូវឧស្សាហ៍ដើរមើល តើមានអ្វីដែលកើតនៅលាយឡំជាមួយដំណាំ យើងត្រូវដកវាចេញឱ្យអស់ ដើម្បីឱ្យសណ្តែកលូតលាស់ល្អ ។

-ពិនិត្យមើលសត្វល្អិតផ្សេងៗដែលមកស៊ីបំផ្លាញ ។យើងគួរប្រើថ្នាំ អាហ្សូឌ្រីន( ម៉ុណូក្រូតូហ្វុស) ក្នុងកំរិតពី ២០-៣០ សេសេ លាយទឹកចំនួន ១០លីត្រ ឬ ២ - ៣ សេសេ លាយទឹក ១ លីត្រ។

## ៩_ការប្រមូលផលសណ្តែកសៀង

-ក្រោយពេលសណ្តែកមានផ្លែចំណាស់ (ផ្លែស្រគៀល) ស្លឹកសណ្តែកវាចាប់ផ្តើមជ្រុះចេញពីដើមម្តងមួយៗ រហូតអស់ពីដើម (៧០-៩០ភាគរយ) ទើបយើងអាចប្រមូលផលបាន ។

-កាត់ដើមសណ្តែកដាក់ជាជួរ ឬយើងអាចពូនជាគំនរ ធ្វើនៅពេលព្រឹកព្រលឹម ។

-ជៀសវាងការប្រមូលផលនៅពេលថ្ងៃ វាអាចធ្វើឱ្យសណ្តែក បែកសំបកគ្រាប់ នាំឱ្យទិន្នផលថយចុះ ។

-ប្រមូលផលទាំងដើម ទាំងផ្លែ មកដាក់លើរាន ឬកន្លែងដែលយើងបានត្រៀមទុកសំរាប់ហាល ។

-ក្រោយពេលប្រមូលផលសណ្តែករួចហើយ យើងត្រូវយកដើមសណ្តែកទៅទុកលើដី ដើម្បីធ្វើជាជីធម្មជាតិ (ធ្វើជីកំប៉ុស្ត, ជីសរីរាង្គ) ។

-យកគ្រាប់សណ្តែកហាលឱ្យស្ងួត រួចច្រកទុកក្នុងការុង ឱ្យបានល្អត្រឹមត្រូវ ។

-បើយើងទុកពូជសំរាប់ឆ្នាំក្រោយយើងត្រូវហាលថ្ងៃឱ្យស្ងួតល្អទ្វេដង ឧស្សាហ៍មើលក្រែងសត្វស៊ីសណ្តែក។



រៀបចំដោយលោក ជិត សុវណ្ណ និងស្រី ស្រស់ធីតា

# V-វិភាគសេដ្ឋកិច្ចផលិតកម្ម ដំណាំសណ្តែកសៀង

( ផ្ទៃដី ១ ហត)

| បរិយាយ | ឯកតា | តាមប្រពៃណី | | | តាមបច្ចេកទេស | | |
|---|---|---|---|---|---|---|---|
| | | ចំនួន | តំលៃរាយ $ | តំលៃសរុប $ | ចំនួន | តំលៃឯកតា $ | តំលៃសរុប $ |
| ការរៀបចំដីសរុប | ហត | ១ | - | ៣០.០០ | ១ | - | ៣០.០០ |
| ជីគីមី( DAP - K2O ) | គក្រ | ៥០ | ០.៤៥ | ២២.៥ | ២០០ | ០.៤៥ | ៩០.០០ |
| ជីអ៊ុយរ៉េ | គក្រ | - | - | - | ៥០ | ០.៣៥ | ១៧.៥០ |
| ជីកុំប៉ុស្ត និងលាមកសត្វ | តោន | - | - | - | ១០ | ៥.០០ | ៥០.០០ |
| ពូជ | គក្រ | ៦៥ | ០.៤៥ | ២៩.២៥ | ៦៥ | ០.៤៥ | ២៩.២៥ |
| ការដាំដុះ | ថ្ងៃ/នាក់ | ១០ | ១.៧៥ | ១៧.៥ | ១០ | ១៧.៥ | ១៧.៥០ |
| ការថែទាំសរុប | ថ្ងៃ/នាក់ | ២០ | ១.៧៥ | ៣៥.០០ | ២០ | ១.៧៥ | ៣៥.០០ |
| ថ្នាំគីមីពុលកសិកម្ម | លីត្រ | - | - | - | ២ | ៥.០០ | ១០.០០ |
| ការប្រមូលផល | ថ្ងៃ/នាក់ | ១៥ | ១.៧៥ | ២៦.២៥ | ១៥ | ១.៧៥ | ២៦.២៥ |
| ដឹកជញ្ជូន | ត្រាក់ទ័រ | - | - | ១០.០០ | - | - | ១០.០០ |
| **ចំណាយសរុប** | ១៧០.៥០ $ | | | | ៣១៥.៥០ $ | | |
| **ចំណូលសរុប** | $០.៤០ x ១២០០ = $៤៨០.០០ | | | | $០.៤០ x ២១០០ = $៨៤០.០០ | | |
| **ចំណេញ** | $៣០៩.៥០ | | | | $៥២៤.៥០ | | |

| | | | | | | |
|---|---|---|---|---|---|---|
| តំលៃលក់សណ្តែកសៀង | $ ០.៤០, ក,គ្រ | | | | | |
| តាមប្រពៃណី :<br>ទិន្នផល : | ១២០០ គក្រ/ហត | | | | | |
| តាមបច្ចេកទេស :<br>ទិន្នផល : | ២១០០ គក្រ ហត | | | | | |

អាគ្រីខែម \ AGRI-CAM

WFP United Nations World Food Programme

# ការធ្វើកសិកម្មតាមបែបផែនបច្ចេកទេស ទទួលបានផលច្រើន និងជួយរក្សាគុណភាពដី

USAID FROM THE AMERICAN PEOPLE

World Health Organization

JICA

unicef